IX 9Marks

# តើ ដំណឹងល្អ? នៃព្រះយេស៊ូវគ្រីស្ទជាអ្វី

What Is the Gos•pel? ដោយ Greg Gilbert

បុព្វកថាដោយ D. A. Carson

9Marks Online PDF

“លោកគ្រូ Greg Gilbert គឺជាបុរសស្មោះត្រង់ និងមានការយល់ដឹងជាច្រើនក្នុងចំណោមបុរសនានា ដែលព្រះអង្គបានត្រាស់ហៅឲ្យបម្រើក្រុមជំនុំរបស់ទ្រង់នៅសព្វថ្ងៃនេះ។ នៅក្នុងសៀវភៅនេះ គាត់បានផ្ដល់មកយើងនូវការយល់ដឹងអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ក្នុងអត្ថន័យតាមព្រះគម្ពីរទាំងស្រុង មានភាពស្មោះត្រង់ ដែលមានការយល់ដឹងយ៉ាងសព្វគ្រប់។ គ្មានតម្រូវការណាធំជាងការយល់ដឹងអំពីដំណឹងល្អដ៏ពិតនោះទេ គឺដើម្បីឲ្យយើងអាចកត់សម្គាល់លើដំណឹងល្អក្លែងក្លាយបាន និងនាំឲ្យមានគ្រីស្ទបរិស័ទជំនាន់ថ្មី ដែលយកដំណឹងល្អជាគោល។ សៀវភៅដ៏សំខាន់មួយនេះបានចេញបោះពុម្ព នៅក្នុងពេលវេលាដ៏ត្រឹមត្រូវ”។

—R. Albert Mohler Jr., President,
The Southern Baptist Theological Seminary

“មានចំណុចពិតពីរដែលធ្វើឲ្យសៀវភៅនេះសំខាន់ខ្លាំង៖ ចំណុចស្នូលនៃដំណឹងល្អក្នុងគ្រប់ជំនាន់ និងភាពច្របូកច្របល់អំពីដំណឹងល្អនៅក្នុងជំនាន់យើង។ សៀវភៅ “តើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទជាអ្វី?” ផ្ដល់ឲ្យយើងនូវការពន្យល់អំពីដំណឹងល្អយ៉ាងស្មោះត្រង់ដោយយោងលើព្រះគម្ពីរ ហើយក៏បានជួយប្រដាប់គ្រីស្ទបរិស័ទឲ្យចេះវែកញែកការបង្រៀនខុសពីព្រះរាជសារដ៏រុងរឿងនោះ។ ខ្ញុំប្រាថ្នាចង់ឲ្យគ្រូគង្វាល និងសមាជិកក្រុមជំនុំគ្រប់រូបមានសៀវភៅនេះ”។

—C. J. Mahaney, Sovereign Grace Ministries

““តើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទជាអ្វី?” នេះជាសៀវភៅដ៏ខ្លីមួយ ប៉ុន្តែមានឥទ្ធិពលដោយឆ្លើយនូវសំណួរនេះដោយមានបទបង្ហាញខ្លី និងច្បាស់លាស់។ វាគឺជាការពិភាក្សាដ៏ល្អប្រសើរអំពីដំណឹងល្អ។ សូមអាន ហើយចែករំលែកដល់អ្នកដទៃចុះ”។

—Daniel L. Akin, President,
Southeastern Baptist Theological Seminary

9Marks Online PDF

«សៀវភៅនេះគឺជាការរៀបរាបឡើងវិញអំពីដំណើររឿងពីបុរាណមួយ នៅក្នុងការប្រើប្រាសពាក្យពេចន៍ថ្មីៗ—ហើយក៏ថែមទាំងមានការព្រមានយ៉ាងត្រឹមត្រូវ ដែលទាសប្រឆាំងនឹងការតំណាងដែលមានល្បិចកល ហើយមិនត្រឹមត្រូវ។ ដូចបទចម្រៀងចាសៗអំពីដំណឹងល្អ នោះសៀវភៅដ៏ល្អមួយនេះរបស់លោកគ្រូ Greg Gilbert ក៏ពិតដូចគ្នាដែរ ដូច្នេះអស់អ្នកដែលពិតជាបានស្គាល់ដំណើររឿងពីបុរាណក៏នឹងកាន់តែស្រេកឃ្លាន ចង់ឮដំណើររឿងនេះដូចអ្នកដទៃផងដែរ»។

—Bryan Chapell, President,
Covenant Theological Seminary

«លោកគ្រូ Greg Gilbert គឺជាបុគ្គលម្នាក់ដែលខ្ញុំមានកិត្តិយស និងអភ័យឯកសិទ្ធិក្នុងការបង្រៀន ហើយឥឡូវនេះគាត់គឺជាអ្នកដែលកំពុងតែបង្រៀនខ្ញុំវិញ។ សៀវភៅដ៏ខ្លីអំពីដំណឹងល្អនេះគឺជាសៀវភៅដ៏ច្បាស់លាស់ និងសំខាន់បំផុតមួយដែលខ្ញុំធ្លាប់បានអានថ្មីៗនេះ»។

—Mark Dever, Senior Pastor,
Capitol Hill Baptist Church, Washington DC

«លោកគ្រូ Greg Gilbert មានចិត្តគំនិតមោះមុត និងមានដួងចិត្តជាគ្រូគង្វាល បានសរសេរសៀវភៅមួយក្បាលនេះដែលនឹងជាជំនួយសម្រាប់អ្នកស្វែងយល់ មិនថាជាអ្នកជឿថ្មោងថ្មី ឬក៏ជាបុគ្គលណាក៏ដោយដែលចង់យល់អំពីដំណឹងល្អឲ្យកាន់តែច្បាស់ជាងមុន។ ខ្ញុំបានរង់ចាំទទួលសៀវភៅបែបនេះ! ក្នុងនាមជាអ្នកដឹកនាំម្នាក់ដែលមានជំហរប្រកាន់ជាប្រាក់ប្រជាចំពោះប្រធានបទដែលមានការច្របូកច្របល់ដែលគួរឲ្យភ្ញាក់ផ្អើល សៀវភៅនេះនាំឲ្យមានភាពច្បាស់លាស់អំពីការគិតមិនត្រឹមត្រូវ ទាក់ទងនឹងដំណឹងល្អ នគរព្រះ និងអត្ថន័យអំពីឈើឆ្កាង»។

—Kevin DeYoung, Senior Pastor,
University Reformed Church, East Lansing, Michigan

លោកគ្រូ Greg Gilbert បានអំពាវនាវក្រុមជំនុំឲ្យត្រឡប់មកកាន់ប្រភពដើមនៃការបើកសម្ដែងរបស់ព្រះមកកាន់ខ្លួនវិញ។ ក្នុងរបៀបដ៏សាមញ្ញ និងស្មោះត្រង់មួយ គាត់បានបង្ហាញយ៉ាងច្បាស់អំពីអ្វីដែលព្រះគម្ពីរបានបង្ហាញអំពីអត្ថន័យនៃដំណឹងល្អ»។

—ARCHBISHOP PETER J. AKINOLA,
Primate of the Church of Nigeria, Anglican Communion

«ក្នុងយុគសម័យនៃការមានមន្ទិលសង្ស័យ និងគំនិតខ្ពស់និយម នោះមិនមានការអ្វីលំបាកខ្លាំងជាងការពន្យល់ដំណឹងល្អដ៏រុងរឿងឲ្យកាន់តែច្បាស់លាស់នោះឡើយ។ នេះគឺជាតម្រូវការដ៏ធំបំផុតសម្រាប់គ្រីស្ទបរិស័ទដែលពេញវ័យ ក៏ដូចជាសម្រាប់អ្នកដែលចេះតែមានការសង្ស័យផងដែរ។ ក្នុងសៀវភៅដែលមានពេញទៅដោយការសញ្ជឹងគិត ប៉ុន្តែងាយទទួលយកបាននេះ លោកគ្រូ Greg Gilbert បានឆ្លើយយ៉ាងច្បាស់លើសំណួរដ៏សំខាន់បំផុតដែលធ្លាប់មានការសួរនាំ»។

—DARRIN PATRICK, Vice President,
The Acts29 Church Planting Network

«លោកគ្រូ Greg Gilbert បានកាត់ចោលនូវការភាន់ច្រឡំដោយស្វែងរកបទគម្ពីរ ដើម្បីឆ្លើយនូវសំណួរដ៏សំខាន់បំផុតដែលបុគ្គលណាម្នាក់អាចសួរបាន។ ទោះបើលោកអ្នកគិតថា ខ្លួនបានស្គាល់អំពីដំណឹងល្អនៃអ្វីដែលព្រះជាម្ចាស់បានសម្រេចក្នុងព្រះគ្រីស្ទក៏ដោយ ក៏លោកគ្រូ Gilbert នឹងសំលៀងការផ្ដោតរបស់លោកអ្នកលើដំណឹងល្អដ៏ពោរពេញទៅដោយសិរីរុងរឿងនេះមួយនេះ»។

—COLLIN HANSEN, *Christianity Today* editor at large

9Marks Online PDF

“ក្នុងចំណោមប្រពៃណីគ្រីស្ទបរិស័ទបច្ចុប្បន្នដែលមានការភាន់ច្រឡំគ្រប់ទីកន្លែង ទាក់ទងនឹងចំណុចស្នូលនៃគោលជំនឿរបស់យើង លោកគ្រូ Greg Gilbert បានផ្តល់មកយើងនូវការពណ៌នាអំពីដំណឹងល្អដែលច្បាស់សម្រាប់អស់អ្នកដែលបានជឿហើយ ក៏ដូចជាមានការជំរុញសម្រាប់អស់អ្នកដែលមិនទាន់បានជឿផងដែរ។ សៀវភៅ “តើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទជាអ្វី?” គឺជាសៀវភៅដែលផ្តោតទៅលើព្រះបន្ទូល យកឈើឆ្កាងជាចំណុចកណ្តាល និងការលើកតម្កើងព្រះជាម្ចាស់។ សៀវភៅ “តើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទជាអ្វី?” នឹងទាក់ទាញចំណាប់អារម្មណ៍នៃគំនិតរបស់លោកអ្នក ក៏ដូចជាបញ្ឆេះភាពឆេះឆួលនៃដួងចិត្តរបស់លោកអ្នកសម្រាប់ព្រះដែលបានសង្គ្រោះយើងតាមរយៈព្រះគុណដោយដំណឹងល្អរបស់ទ្រង់សម្រាប់សិរីល្អរបស់ទ្រង់»។

—David Platt, Senior Pastor,
The Church at Brook Hills, Birmingham, Alabama

“ការយល់លើដំណឹងល្អយ៉ាងច្បាស់លាស់នាំមកនូវទាំងទំនុកចិត្តក្នុងដំណឹងល្អ និងជំនឿស៊ប់ទាក់ទងនឹងខ្លឹមសារនៃសេចក្តីពិតនៃដំណឹងល្អ។ សៀវភៅដ៏ល្អមួយក្បាលនេះមានភាពច្បាស់លាស់ដែលធ្វើឲ្យមានការភ្ញាក់ផ្អើល ហើយក៏មានភាពស្មោះត្រង់ជាមួយនឹងព្រះគម្ពីរ ហើយក៏នឹងផ្តល់រង្វាន់ចំពោះការអានដោយមានការផ្តោតលើដំណឹងល្អជាថ្មីម្តងទៀតផងដែរ»។

—William Taylor, Rector,
St. Helen Bishopsgate, London

“ភាពសាមញ្ញនៃសៀវភៅនេះគឺជាអ្វីដែលធ្វើឲ្យសៀវភៅនេះមានភាពម៉តចត។ ទំនងគ្រោះថ្នាក់ដ៏ធំបំផុតក្នុងជំនឿគ្រីស្ទបរិស័ទគឺការសន្មតអំពីដំណឹងល្អដោយមិនស្តាប់តាមអ្វីដែលជាដំណឹងល្អដ៏ច្បាស់លាស់ស្របតាមអត្ថន័យព្រះគម្ពីរ។ វាមិនមែនជាការលើកឡើងដោយបំផ្លើសក្នុងការនិយាយនោះទេថា នេះទំនងជាសៀវភៅដ៏សំខាន់ជាងគេបំផុតដែលលោកអ្នកនឹងអានអំពីជំនឿគ្រីស្ទបរិស័ទ”។

—Rick Holland, Executive Pastor,
Grace Community Church, Sun Valley, California

“នៅពេលដែលខ្ញុំគិតអំពីចំណុចកណ្តាលនៃព្រះគម្ពីររបស់ខ្ញុំ ភ្លាមនោះដួងចិត្តរបស់ខ្ញុំក៏ឱបក្រសោបដំណឹងល្អ។ ខ្ញុំស្គាល់មនុស្សជាច្រើននាក់ដែលស្រឡាញ់ដំណឹងល្អ ប៉ុន្តែខ្ញុំក៏តែងតែមានចិត្តបើកចំហក្នុងការស្រឡាញ់ដំណឹងល្អនោះជាងមុន និងឲ្យបានយល់ល្អប្រសើរជាងមុនផងដែរ។ លោកគ្រូ Greg Gilbert បានសរសេរសៀវភៅនេះ ដើម្បីជួយឲ្យយើងកាន់តែដឹង និងស្រឡាញ់ដំណឹងល្អបន្ថែមទៀត”។

—Johnny Hunt, President,
the Southern Baptist Convention,
Pastor, First Baptist Church, Woodstock, Georgia

9Marks Online PDF

# តើដំណឹងល្អ
# នៃព្រះយេស៊ូវគ្រីស្ទជាអ្វី?

Greg Gilbert

Forward by D. A. Carson

9Marks Online PDF

*What Is the Gospel?*
Copyright © 2010 by Gregory D  Gilbert
Published by Crossway
1300 Crescent Street
Wheaton, Illinois 60187

*តើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទជាអ្វី?*
រក្សាសិទ្ធិគ្រប់បែបយ៉ាង ដោយអ្នកនិពន្ធដើម៖ Gregory D. Gilbert
Copyright © 2010 by Gregory D. Gilbert
ផលិតដោយ៖ Published by Crossway
ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org

រក្សាសិទ្ធិគ្រប់បែបយ៉ាង។ យើងមិនអនុញ្ញាតឲ្យសៀវភៅនេះមានការបោះពុម្ពផ្សាយឡើងវិញ, ថតទុកក្នុងប្រព័ន្ធម៉ាស៊ីនកុំព្យូទ័រ, ឬចែកចាយបន្តរួមបញ្ចូលទាំង ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក, បច្ចេកទេសថតចម្លង, ការថតទុកជាឯកសារសំឡេង។ល។ ដោយគ្មានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិដើម។

បកប្រែដោយ៖ លោក ឈាង បូរា
កែសម្រួលដោយ៖ លោក ខែម បូឡុង និងលោក ទេព រូ
ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោកស្រី ឡុញ ស្រីរដ្ឋ, លោក ឯក សត្យា, លោក ហុង សម្កស, លោក បុន ដេត,  លោកស្រី ថាវ បុនរី លោក ឡង់ គីមឡុង និងលោក សូ ទិត្យ
អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វ៉េល ណាថាន និង លោក ខែម បូឡុង
Cover design: Dual Identity Design

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ ព្រះគម្ពីរកែសម្រួល រក្សាសិទ្ធិ©ឆ្នាំ២០១៤, ២០១៦ (គកស), ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ©ឆ្នាំ២០០៥ (គខប), ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ©ឆ្នាំ២០១៤ (គគខ) ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្ដេចសង្ឃរាជ ជួន ណាត។

For ordering information please visit: www.plovpit.com
ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖ www.plovpit.com បោះពុម្ពលើកទី១ ចំនួន៣០០០ក្បាល គ.ស. ២០២៤ ព្រះរាជាណាចក្រកម្ពុជា

9Marks ISBN: 979-8-89218-140-2

9Marks Online PDF

*ជូនចំពោះអូន ម៉ូរីយ៉ា*

*បងស្រឡាញ់អូនខ្លាំងណាស់*

*លើសពាក្យពណ៌នា!*

9Marks Online PDF

# មាតិកា


បុព្វកថាសេរី ........ ១៣

បុព្វកថា ........ ១៧

សេចក្តីផ្តើម ........ ២១

១ ការស្វែងរកដំណឹងល្អក្នុងព្រះគម្ពីរ ........ ៣៧

២ ព្រះអាទិករដ៏សុចរិត ........ ៦៣

៣ មនុស្សមានបាប ........ ៧៩

៤ ព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះ ........ ៩៩

៥ ការឆ្លើយតប—ជំនឿ និងការកែប្រែចិត្ត ........ ១២១

៦ នគរព្រះ ........ ១៤៥

៧ ការដាក់ឈើឆ្កាងជាចំណុចកណ្តាល ........ ១៧៣


9Marks Online PDF

៨ អំណាចនៃដំណឹងល្អ.......................................................... ១៩៣

សេចក្តីថ្លែងអំណរគុណដ៏ពិសេស.......................................... ២០៩

9Marks Online PDF

# បុព្វកថាស៊េរី

កម្រងសៀវភៅក្រុម 9Marks ជាសៀវភៅដែលរៀបរាប់លើគំនិតសំខាន់ពីរយ៉ាង។ ទីមួយ ពួកជំនុំតាមតំបន់មានសារៈសំខាន់ចំពោះជីវិតគ្រីស្ទបរិស័ទលើសពីអ្វីដែលគ្រីស្ទបរិស័ទជាច្រើននៅបច្ចុប្បន្ននេះអាចនឹងគិតដល់ទៅទៀត។ យើងជឿថា គ្រីស្ទបរិស័ទដែលមានសុខភាពល្អគឺជាសមាជិកពួកជំនុំដែលមានសុខភាពល្អ។ យើងជឿថា គ្រីស្ទបរិស័ទដែលមានសុខភាពល្អ ក៏ជាសមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់ដែរ។

ទីពីរ ពួកជំនុំនៅតាមតំបន់ចម្រើនឡើងនៅក្នុងជីវិត ហើយនិងចម្រើនឡើងខាងឯកម្លាំង នៅពេលដែលពួកគាត់យកព្រះបន្ទូលរបស់ព្រះជាគោល។ ព្រះជាម្ចាស់មានព្រះបន្ទូល ហើយពួកជំនុំគួរតែស្តាប់ ហើយធ្វើតាម។ វាសាមញ្ញដូចហ្នឹង។ នៅពេលដែលពួកជំនុំស្តាប់ ហើយធ្វើតាម ពួកជំនុំនោះនឹងចាប់ផ្តើមមានលក្ខណៈដូចនឹងព្រះមួយអង្គដែលពួកជំនុំកំពុងតែដើរតាមជាមិនខាន។ ពួកជំនុំនោះនឹងឆ្លុះបញ្ចាំងអំពីសេចក្តីស្រឡាញ់ និងសេចក្តីបរិសុទ្ធរបស់ទ្រង់ព្រមទាំងបង្ហាញអំពីសិរីល្អរបស់ទ្រង់ផងដែរ។ ពួកជំនុំមួយនោះនឹងមានលក្ខណៈដូចទ្រង់ នៅពេលដែលពួកជំនុំនោះស្តាប់ទ្រង់។

ដោយសេចក្តីនេះ មិត្តអ្នកអានអាចនឹងកត់សម្គាល់ឃើញថា

“សញ្ញាសម្គាល់ទាំង៩” គឺជាការដកស្រង់ចេញពីសៀវភៅរបស់លោកគ្រូ ម៉ាក ដិវើរ នៅឆ្នាំ២០០១ ដែលមានចំណងជើងថា *សញ្ញាសម្គាល់ទាំង៩នៃពួកជំនុំដែលមានសុខភាពល្អ* (Nine Marks of a Healthy Church, Crossway Books) មានការចាប់ផ្ដើមជាមួយនឹងព្រះគម្ពីរ។

- សេចក្ដីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ
- ទេវវិទ្យាតាមព្រះគម្ពីរ
- ការយល់ដឹងអំពីដំណឹងល្អតាមព្រះគម្ពីរ
- ការយល់ពីការក្លាយជាគ្រីស្ទបរិស័ទតាមព្រះគម្ពីរ
- ការយល់ពីការផ្សាយដំណឹងល្អតាមព្រះគម្ពីរ
- ការយល់ដ៏ត្រឹមត្រូវពីសមាជិកភាពនៃពួកជំនុំតាមព្រះគម្ពីរ
- ការយល់ពីដាក់វិន័យពួកជំនុំតាមព្រះគម្ពីរ
- ការយល់ពីការបង្កើតសិស្ស និងការលូតលាស់តាមព្រះគម្ពីរ
- ការយល់ពីការដឹកនាំពួកជំនុំតាមព្រះគម្ពីរ

នៅមានចំណុចជាច្រើនទៀតដែលយើងអាចលើកឡើងអំពីអ្វីដែលពួកជំនុំគួរធ្វើ ដើម្បីឲ្យបានសុខភាពល្អ ដូចជាការអធិស្ឋានជាដើម។ ប៉ុន្តែ ការអនុវត្តទាំង៩នេះគឺជាការអនុវត្តដែលយើងជឿថា ត្រូវបានគេមើលរំលងជាញឹកញាប់ជាងគេបំផុត (មិនដូចជាសេចក្ដីអធិស្ឋានទេ)។ ដូច្នេះ គំនិតជាមូលដ្ឋានរបស់យើងដែលយើងចង់លើកឡើងទៅកាន់ពួកជំនុំគឺថា កុំឲ្យមើលទៅកាន់ការអនុវត្តបែបជំនួញដ៏ល្អបំផុត ឬក៏របៀបសម័យថ្មីឡើយ តែចូរសម្លឹងមើលទៅឯព្រះជាម្ចាស់វិញ។ សូម

ចាប់ផ្ដើមដោយស្ដាប់ព្រះបន្ទូលរបស់ព្រះជាថ្មីម្ដងទៀតវិញ។

ដោយព្រោះការនេះ ទើបសៀវភៅភាគ 9Marks ចាប់ផ្ដើមមានឡើង។ គោលបំណងនៃភាគទាំងអស់នេះគឺ ដើម្បីពិនិត្យមើលសញ្ញាសម្គាល់ទាំង៩ឲ្យកាន់តែច្បាស់ ហើយពីជ្រុងផ្សេងៗ។ ជ្រុងខ្លះផ្ដោតទៅលើគ្រូគង្វាល ហើយជ្រុងខ្លះទៀតផ្ដោតទៅលើសមាជិកពួកជំនុំ។ យើងសង្ឃឹមថា គ្រប់ជ្រុងទាំងអស់នឹងរួមបញ្ចូលគ្នានូវការពិនិត្យដោយប្រុងប្រយ័ត្នតាមព្រះគម្ពីរ ការឆ្លុះបញ្ចាំងអំពីទេវវិទ្យា ការពិចារណាខាងវប្បធម៌ ការប្រើប្រាស់ជាប្រយោជន៍ជារួម ហើយសូម្បីទាំងផ្នែកតូចៗមួយចំនួននៃការលើកទឹកចិត្តសម្រាប់បុគ្គលម្នាក់ៗ។ សៀវភៅគ្រីស្ទបរិស័ទដែលល្អបំផុត គឺតែងតែមានទាក់ទងទៅនឹងការសិក្សាអំពីទេវវិទ្យា និងការអនុវត្ត។

យើងអធិស្ឋានសូមឲ្យព្រះជាម្ចាស់ប្រើប្រាស់សៀវភៅនេះ ហើយនិងសៀវភៅដទៃទៀតក្នុងភាគ ដើម្បីជួយរៀបចំក្រុមជំនុំ ដែលជាកូនក្រមុំរបស់ទ្រង់ ឲ្យមានភាពស្រស់បំព្រង និងមានសិរីល្អសម្រាប់ថ្ងៃដែលទ្រង់នឹងយាងមកវិញ។

9Marks Online PDF

# បុព្វកថា

តាមរយៈការបង្រៀនសិស្សខាងផ្នែកទេវវិទ្យាជាង៣០ឆ្នាំនេះ ខ្ញុំឃើញថា សំណួរបដិសេធការពិតជាងគេដែលគេធ្លាប់សួរមានភាពខុសៗគ្នាពីមួយជំនាន់ទៅមួយជំនាន់—ហើយក៏ជាការពិតក្នុងចំណោមគ្រីស្ទបរិស័ទជាច្រើនទៀតដែរ។ ពីមុន លោកអ្នកក៏អាចធានាឲ្យមានការវែកញែកដ៏ក្ដៅគគុកបាន ដោយសួរនូវសំណួរដូចនេះ៖ «តើលោកអ្នកគិតយ៉ាងដូចម្ដេចអំពីចលនានៃនិកាយការីស្មាទិក (charismatic movement)?» ឬក៏ «តើយើងគួរការពារភាពមិនចេះខុសនៃព្រះគម្ពីរដែរឬទេ?» ឬក៏ថា «តើលោកអ្នកគិតយ៉ាងដូចម្ដេចអំពីក្រុមជំនុំនៃអ្នកស្វះស្វែងរកដែលមានការយោគយល់ចិត្ត (seeker-sensitive churches)?» សព្វថ្ងៃនេះ វាគឺជាការងាយស្រួលណាស់ក្នុងការរកមនុស្សដែលមានចិត្តចង់វែកញែកនូវសំណួរទាំងនេះ ប៉ុន្តែជាទូទៅមានកម្ដៅនៅសល់តិចណាស់ក្នុងរឿងនោះ ហើយក៏នៅសល់ពន្លឺខ្លះដែរ។ សព្វថ្ងៃនេះ សំណួរដែលទំនងជាបញ្ឆេះការវែកញែកគឺ—ដូចដែលអ្នកនិពន្ធម្នាក់នេះបានលើកឡើង—តើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទជាអ្វី?»។ ហើយក៏ទំនងជាអាចមានសំណួរស្រដៀងគ្នាមួយទៀតដែរ៖ តើការផ្សាយដំណឹងល្អជាអ្វី?

ត្រង់ចំណុចដែលថា សំណួរទាំងនេះបញ្ច្រាបនូវចម្លើយសម្រិត

សម្រាំងទៅវិញទៅមក ដែលជាទូទៅមានការការពារខាងផ្នែកទេវវិទ្យា ដោយមានការឆ្លុះបញ្ចាំងលើព្រះគម្ពីរតែបន្តិចបន្តួចគឺពិតជាគួរឲ្យភ្ញាក់ផ្អើលមែន ពីព្រោះចំណុចទាំងនោះគឺជាចំណុចនៃមូលដ្ឋានគ្រឹះនៃជំនឿគ្រីស្ទបរិស័ទ។ នៅពេលដែល «ក្រុមជំនុំដំណឹងល្អ» មានមតិយោបល់ខុសៗគ្នាយ៉ាងស្រទ្បះអំពីដំណឹងល្អ នោះយើងត្រូវតែសន្មតថាទំនងជា៖ ១) អ្នកដំណឹងល្អនិយមនោះគឺជាចលនានៃបាតុភូតខុសៗគ្នា ដោយមិនមានការឯកភាពគ្នាលើដំណឹងល្អទេ ហើយក៏មិនមានទំនួលខុសត្រូវ «ដើម្បីការពារសេចក្ដីជំនឿ» ដែលព្រះអម្ចាស់ «បានប្រគល់…មួយដងជាសម្រេច» មកកាន់យើង ដែលជារាស្ត្ររបស់ទ្រង់ដែរ (យូដាស ១:៣) ឬក៏ ២) មនុស្សជាច្រើនដែលហៅខ្លួនឯងថាជា «ក្រុមជំនុំដំណឹងល្អ» មិនមានហេតុផលត្រឹមត្រូវក្នុងការហៅខ្លួនឯងបែបនោះទេ ពីព្រោះពួកគាត់បានទុកដំណឹងល្អចោលហើយ។

ឥឡូវមានលោកគ្រូ ហ្គ្រេក ជីលបឺត (Greg Gilbert)។ សៀវភៅនេះមិនបានអះអាងថាបានរកឃើញចំណុចថ្មីៗទេ ប៉ុន្តែគ្រាន់តែជាការពិនិត្យជាថ្មីលើចំណុចចាស់ៗ ដែលយើងមិនគួរអើពើ ឬក៏បោះបង់ចោលនោះទេ។ ភាពច្បាស់លាស់នៃគំនិត និងការលើកឡើងរបស់លោកគ្រូ ហ្គ្រេក គឺពិតជាស័ក្ដិសមគួរឲ្យគេសរសើរមែន។ សៀវភៅនេះនឹងមិនគ្រាន់តែសំលៀងការគិតរបស់គ្រីស្ទបរិស័ទពេញវ័យប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ជាងនោះទៅទៀត នេះគឺជាសៀវភៅដែលយើងត្រូវតែចែកចាយទៅកាន់អ្នកដឹកនាំក្រុមជំនុំ អ្នកជឿថ្មីថ្មោង ហើយសូម្បីតែអស់

9Marks Online PDF

អ្នកដែលមិនទាន់បានទទួលជឿលើព្រះគ្រីស្ទ ដែលចង់ទទួលបានការពន្យល់ឲ្យច្បាស់ថា “តើដំណឹងល្អជាអ្វី?”។ សូមអានសៀវភៅនេះ ហើយបន្ទាប់មកសូមទិញមួយកេសសម្រាប់ចែកចាយដោយចិត្តសប្បុរសដល់អ្នកដទៃចុះ។

—លោកគ្រូ D. A. Carson

9Marks Online PDF

# សេចក្តីផ្តើម

តើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទជាអ្វី?

លោកអ្នកទំនងជាគិតថា នេះគឺជាសំណួរដែលស្រួលឆ្លើយណាស់ ជាពិសេសសម្រាប់គ្រីស្ទបរិស័ទ។ តាមពិតទៅ លោកអ្នកទំនងជា គិតថា ការនិពន្ធសៀវភៅដូចនេះ—សៀវភៅដែលសួរឲ្យគ្រីស្ទបរិស័ទ គិតដោយយកចិត្តទុកដាក់លើសំណួរ "តើដំណឹងល្អនៃព្រះយេស៊ូវជា អ្វី?"—មិនមែនជាការចាំបាច់ទាល់តែសោះ។ វាប្រៀបដូចជាការសួរ ជាងឈើឲ្យអង្គុយចុះ ហើយគិតលើសំណួរថា "តើញញួរជាអ្វី?"។

ដ្បិតដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទស្ថិតនៅក្នុងចំណុចកណ្តាលនៃ ជំនឿគ្រីស្ទបរិស័ទ ហើយយើងដែលជាគ្រីស្ទបរិស័ទក៏បានអះអាង ថា យើងឲ្យតម្លៃលើដំណឹងល្អលើសគ្រប់អ្វីៗទាំងអស់។ នេះគឺជាអ្វី ដែលយើងមានចិត្តថា ឲ្យជីវិតរបស់យើងឈរនៅលើគោលជំហរនោះ ហើយសង់ក្រុមជំនុំរបស់យើងនៅពីលើនោះដែរ។ នេះគឺជាអ្វីដែល យើងនិយាយទៅកាន់អ្នកដទៃ ហើយក៏ជាអ្វីដែលយើងអធិស្ឋានសូម ឲ្យពួកគាត់ឮ ហើយទទួលជឿផងដែរ។

ទាក់ទងនឹងចំណុចទាំងនោះ តើលោកអ្នកគិតថា គ្រីស្ទបរិស័ទទូទៅ មានការយល់ដឹងយ៉ាងរឹងមាំដល់កម្រិតណាទាក់ទងនឹងប្រធានបទនៃ ដំណឹងល្អ? តើលោកអ្នកនឹងឆ្លើយតបដោយរបៀបណា ប្រសិនបើមាន

9Marks Online PDF

បុគ្គលណាម្នាក់មកសួរលោកអ្នក៖ «តើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនេះជាអ្វីទៅ ដែលលោកអ្នកដែលជាគ្រីស្ទបរិស័ទលើកមកនិយាយឥតឈប់ឈរ? ហើយ តើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនេះល្អយ៉ាងដូចម្ដេច?

តាមការវិនិច្ឆ័យរបស់ខ្ញុំ៖ មានគ្រីស្ទបរិស័ទជាច្រើនណាស់ ដែលនឹងឆ្លើយមិនដល់អ្វីដែលព្រះគម្ពីរបានអះអាងថាជា «ដំណឹងល្អពីព្រះយេស៊ូវគ្រីស្ទ»។ ទំនងពួកគាត់នឹងឆ្លើយថា «ដំណឹងល្អគឺថា ព្រះជាម្ចាស់នឹងអត់ទោសអំពើបាបរបស់លោកអ្នក ប្រសិនបើលោកអ្នកទទួលជឿលើព្រះអង្គ» ឬក៏ថា ពួកគាត់នឹងលើកឡើងដូចតទៅ៖ «ដំណឹងល្អគឺថា ព្រះជាម្ចាស់ស្រឡាញ់លោកអ្នក ហើយក៏មានផែនការល្អសម្រាប់ជីវិតលោកអ្នកផងដែរ»។ «ដំណឹងល្អគឺថា លោកអ្នកគឺជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ ហើយព្រះអង្គសព្វព្រះហឫទ័យឲ្យបុត្រាបុត្រីរបស់ទ្រង់មានភាពជោគជ័យយ៉ាងខ្លាំងក្នុងគ្រប់ចំណាច»។ មានមនុស្សមួយចំនួនដឹងថា គួរលើកឡើងខ្លះៗអំពីការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង និងការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ប៉ុន្តែបន្ទាប់មក ជាថ្មីម្ដងទៀត តើទាំងអស់នោះមានភាពស៊ីគ្នាយ៉ាងដូចម្ដេច?

ចំណាចពិតគឺថា ក្នុងការឲ្យគ្រីស្ទបរិស័ទឯកភាពគ្នាលើចម្លើយចំពោះសំណួរថា «តើដំណឹងល្អជាអ្វី?» គឺវាមិនមែនសាមញ្ញ ដូចនោះទេ។ ខ្ញុំធ្វើការជាមួយនឹងព័ន្ធកិច្ចមួយឈ្មោះក្រុម 9Marks ដែលជាអង្គការ

9Marks Online PDF

មួយសហការជាមួយនឹងក្រុមជំនុំ Capitol Hill Baptist នៅឯរដ្ឋវ៉ាស៊ីនតោន ឌីស៊ី នៅប្រទេសអាមេរិក។ ភាគច្រើន អស់អ្នកដែលអាន ក៏ដូចជាបញ្ចេញមតិយោបល់លើធនធានរបស់យើងគឺជាគ្រីស្ទបរិស័ទក្នុងចំណោមគ្រីស្ទបរិស័ទដំណឹងល្អមានភាគរយតិចណាស់។ ពួកគាត់ជឿថា ព្រះគម្ពីរពិត ហើយក៏មិនមានចំណុចខុសឆ្គង។ ពួកគាត់ជឿថា ព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង ហើយក៏បានមានព្រះជន្មរស់ឡើងវិញពីការសុគត ខាងឯសាច់ឈាម។ ពួកគាត់ជឿថា មនុស្សយើងគឺជាអ្នកមានបាប ដែលត្រូវការសេចក្ដីសង្គ្រោះ។ ហើយពួកគាត់ក៏មានបំណងចិត្តក្នុងការយកដំណឹងល្អជាចំណុចស្នូល ហើយក៏ជាមនុស្សដែលជ្រាបទៅដោយដំណឹងល្អផងដែរ។

ប៉ុន្តែ តើលោកអ្នកនឹងទាយថា ប្រធានបទមួយណាបង្កើតឲ្យមានការបញ្ចេញមតិយោបល់ច្រើនជាងគេ ហើយក៏ជាការចំណាយកម្លាំងច្រើនជាងគេក្នុងការឆ្លើយតបទាក់ទងនឹងអ្វីដែលយើងសរសេរ? ត្រូវហើយ គឺដំណឹងល្អ។ យើងអាចនិពន្ធ និងនិយាយអស់ជាច្រើនខែអំពីការអធិប្បាយ ការបង្កើតសិស្ស ការផ្ដល់ប្រឹក្សាក្នុងក្រុមជំនុំ ថែមទាំងចម្រៀងក្នុងក្រុមជំនុំ ហើយការឆ្លើយតបពីអ្នកអានរបស់យើងក៏ពិតជាគួរឲ្យចាប់អារម្មណ៍មែនដែរ ប៉ុន្តែមិនគួរឲ្យភ្ញាក់ផ្អើលនោះទេ។ តែប្រសិនបើយើងបង្ហោះឯកសារណាមួយដោយព្យាយាមពន្យល់ឲ្យបានច្បាស់ពីអ្វីដែលព្រះគម្ពីរបង្រៀនអំពីដំណឹងល្អនៃជំនឿគ្រីស្ទបរិស័ទ នោះការឆ្លើយតបគឺពិតជាគួរឲ្យភ្ញាក់ផ្អើលមែន។

មិនយូរប៉ុន្មានមុននេះ មិត្តភក្តិម្នាក់របស់ខ្ញុំបានបង្ហោះឯកសារដ៏ខ្លីមួយលើគេហទំព័ររបស់យើងអំពីតន្រ្តីករដែលជាគ្រីស្ទបរិស័ទដែលមានភាពល្បីល្បាញម្នាក់ដែលត្រូវបានគេសួរក្នុងការសម្ភាសមួយឲ្យពន្យល់អត្ថន័យលើដំណឹងល្អនៃជំនឿគ្រីស្ទបរិស័ទ។ ខាងក្រោមនេះគឺជាអ្វីដែលតន្រ្តីករបានលើកឡើង៖

> នេះពិតជាសំណួរដ៏ល្អមួយមែន។ ខ្ញុំគិតថា ខ្ញុំនឹងទំនងជា... សភាវគតិរបស់ខ្ញុំគឺថា វាជាការដែលព្រះយេស៊ូវបានយាងមក បានមានព្រះជន្មរស់នៅ បានសុគត ហើយក៏បានមានព្រះជន្មរស់ឡើងវិញ ហើយការដែលទ្រង់បានតាំងនូវអ្វីដែលបានសម្រេចឡើង ប៉ុន្តែមិនទាន់បានមកដល់នៅឡើយនៃរាល់គ្រប់អ្វីៗទាំងអស់ក៏កំពុងតែត្រូវទទួលបានការស្តារឡើងវិញទៅកាន់ទ្រង់...ហើយការនោះក៏កំពុងតែកើតឡើងតាមរយៈទ្រង់...ការធ្វើឲ្យគ្រប់អ្វីៗទាំងអស់បានត្រឹមត្រូវឡើងវិញ...ដំណើរការនោះក៏កំពុងតែចាប់ផ្តើម ហើយក៏ជាចំណុចពិតនៅក្នុងជីវិត និងដួងចិត្តរបស់អ្នកជឿ ប៉ុន្តែនឹងមានថ្ងៃណាមួយមកដល់ ដែលការទាំងអស់នេះនឹងទទួលបានការសម្រេចជាស្រេចយ៉ាងពេញលេញ។ ប៉ុន្តែ ការនិយាយអំពីដំណឹងល្អ គឺថា ខ្ញុំគិតថាគឺជាដំណឹងដែលនគររបស់ទ្រង់មកដល់ ការតាំងនគររបស់ទ្រង់ដែលនឹងមកដល់...នេះគឺជាសភាវគតិរបស់ខ្ញុំ។

មានអ្នកខ្លះក្នុងចំណោមយើងបានឆ្លើយតបដោយសួរសំណួរដូច

9Marks Online PDF

ជា "ប្រសិនបើយើងកំពុងតែរៀបរាប់អំពីដំណឹងល្អគ្រីស្ទបរិស័ទ តើយើងមិនគួរបញ្ចូលនូវ*ការពន្យល់*ខ្លះៗអំពីការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវមែនឬ?" ឬថា "តើយើងមិនគួរលើកឡើងខ្លះៗអំពីអំពើបាប និងតម្រូវការសម្រាប់សេចក្ដីសង្គ្រោះពីសេចក្ដីក្រោធរបស់ព្រះជាម្ចាស់ដែលប្រឆាំងនឹងវាមែនឬ?"

ការឆ្លើយតបជាបន្តបន្ទាប់លើការបង្ហោះនោះគឺពិតជាអស្ចារ្យមែន។ អស់ជាច្រើនខែ យើងក៏បានទទួលសារជាច្រើនអំពីវាដែរ។ មនុស្សមួយចំនួនដែលបានសរសេរមកកាន់យើងបានឲ្យតម្លៃលើសំណួរដែលយើងបានលើកឡើង  ហើយមនុស្សមួយចំនួនទៀតមានការងឿងឆ្ងល់ថា តើមានអ្វីខុសឆ្គងក្នុងការលើកឡើងអំពីដំណឹងល្អដូចនោះ ដោយសារព្រះយេស៊ូវក៏បានអធិប្បាយអំពីការមកដល់នៃនគរព្រះផងដែរ។ ហើយក៏មានមនុស្សមួយចំនួនទៀតក៏បានទទួលការលើកទឹកចិត្ត ដោយសារឮអំពីការដែលគ្រីស្ទបរិស័ទខំគិតយ៉ាងខ្លាំងអំពីរបៀបនិយាយឲ្យច្បាស់លាស់អំពីដំណឹងល្អជាចំណុចដំបូង។

ក្នុងចំណោចខ្លះ ខ្ញុំពិតជាសប្បាយចិត្តមែនក្នុងការឃើញគ្រីស្ទបរិស័ទមានការឆេះឆួល នៅពេលដែលការពិភាក្សាអំពីដំណឹងល្អចាប់ផ្ដើម។ វាមានន័យថា ពួកគាត់កំពុងតែយកចិត្តទុកដាក់មែនទែន ហើយថាពួកគាត់ក៏បានប្រកាន់ខ្ជាប់នូវគំនិតដ៏ជ្រាលជ្រៅអំពីអ្វីដែលពួកគាត់គិតថាជាដំណឹងល្អដែរ។ វានឹងមិនមែនជាអ្វីដែលល្អនោះទេ ប្រសិនបើគ្រីស្ទបរិស័ទមិនយកចិត្តទុកដាក់លើរបៀបដែលយើងផ្ដល់អត្ថន័យ

9Marks Online PDF

និងយល់អំពីដំណឹងល្អ។ មួយទៀតសោត ខ្ញុំគិតថាកម្លាំងដែលកើតឡើងតាមរយៈការពិភាក្សាអំពីដំណឹងល្អបានចង្អុលបង្ហាញទៅកាន់ភាពស្រអាប់ទូទៅមួយនៃការភាន់ច្រឡំដែលកំពុងតែវិលវល់នៅជុំវិញយើងសព្វថ្ងៃនេះ។ នៅចុងបញ្ចប់ គ្រីស្ទបរិស័ទមិនមានការឯកភាពគ្នាថា ដំណឹងល្អជាអ្វីទេ—សូម្បីតែគ្រីស្ទបរិស័ទដែលហៅខ្លួនឯងថាគ្រីស្ទបរិស័ទដំណឹងល្អក៏ដោយ។

បើលោកអ្នកគ្រាន់តែសួរអ្នកដែលរាប់ខ្លួនថាជាគ្រីស្ទបរិស័ទដំណឹងល្អ ប្រមាណជា១០០នាក់ ថាតើអ្វីទៅជាដំណឹងល្អនៃព្រះយេស៊ូវ នោះលោកអ្នកនឹងទំនងជាទទួលបានចម្លើយខុសៗគ្នាប្រមាណជា៦០ ចម្លើយជាមិនខាន។ ប្រសិនបើលោកអ្នកស្តាប់ការអធិប្បាយដំណឹងល្អ អានសៀវភៅដំណឹងល្អ ចូលមើលគេហទំព័រដំណឹងល្អ នោះលោកអ្នកនឹងឃើញការពណ៌នាពីមួយទៅមួយខុសៗគ្នាអំពីដំណឹងល្អ ដែលជាច្រើនមានភាពសម្រិតសម្រាំងគ្នាទៅវិញទៅមក។ ខាងក្រោមនេះគឺជាការពណ៌នាមួយចំនួនដែលខ្ញុំបានរកឃើញ៖

> ដំណឹងល្អគឺថា ព្រះជាម្ចាស់សព្វព្រះហឫទ័យក្នុងការបង្ហាញនូវគុណប្រយោជន៍ដ៏អស្ចារ្យរបស់ទ្រង់ទៅកាន់លោកអ្នក។ ព្រះអង្គសព្វព្រះហឫទ័យបំពេញជីវិតរបស់លោកអ្នកជាមួយនឹង «ស្រាថ្មី» ប៉ុន្តែ តើលោកអ្នកស្ម័គ្រចិត្តចោលថង់ស្បែកស្រាចាស់របស់លោកអ្នកដែរឬទេ? តើលោកអ្នកនឹងចាប់ផ្តើមគិតធំជាងមុនដែរឬទេ? តើលោកអ្នកនឹងពង្រីកនិមិត្តរបស់លោក

អ្នក ហើយបោះការគិតអវិជ្ជមានចាស់ៗចោល ដែលកំពុងរារាំងលោកអ្នកដែរឬទេ?

នេះគឺជាដំណឹងល្អក្នុងមួយឃ្លា។ ដោយសារព្រះគ្រីស្ទបានសុគតសម្រាប់យើង នោះអស់អ្នកដែលទុកចិត្តលើព្រះអង្គនឹងដឹងថា ពិរុទ្ធភាពរបស់ខ្លួនត្រូវបានអត់ទោសម្ដងជាស្រេច។ តើយើងនឹងត្រូវនិយាយអ្វីនៅមុខកន្លែងកាត់ទោសរបស់ព្រះជាម្ចាស់? និយាយតែមួយឃ្លាប៉ុណ្ណោះ។ ព្រះគ្រីស្ទបានសុគតជំនួសខ្ញុំ។ នោះឯងគឺជាដំណឹងល្អ។

យើងអាចទំនងជាហៅសារអំពីព្រះយេស៊ូវថា ជាសារនៃការបដិវត្តន៍ខ្លាំងជាងគេបំផុតនៅគ្រប់សម័យទាំងអស់៖ «ការបដិវត្តន៍ដ៏ធំនៃអាណាចក្ររបស់ព្រះជាម្ចាស់បានមកដល់ ហើយក៏កំពុងតែចម្រើនចលនាទៅមុខតាមរយៈការផ្សះផ្សា និងសន្តិភាព ពង្រីកតាមរយៈជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់—ចាប់ផ្ដើមជាមួយអ្នកក្របំផុត អ្នកខ្សោយបំផុត អ្នកស្លូតបំផុត និងអ្នកទាបជាងគេបំផុត។ ដល់ពេលក្នុងការផ្លាស់ប្ដូរគំនិតរបស់លោកអ្នកហើយ។ គ្រប់អ្វីៗទាំងអស់ហៀបនឹងផ្លាស់ប្ដូរហើយ។ ពេលនៃការរស់នៅក្នុងជីវិតបែបថ្មីបានមកដល់ហើយ។ ចូរជឿខ្ញុំចុះ។ ចូរតាមខ្ញុំចុះ។ ចូរជឿលើដំណឹងល្អនេះ ដើម្បីឲ្យលោកអ្នកអាចចាប់ផ្ដើមរៀនរស់នៅតាមរយៈវាបាន ហើយមានចំណែកក្នុងការបដិវត្តន៍នេះ»។

ដំណឹងល្អគឺថា ព្រះភក្ត្ររបស់ព្រះជាម្ចាស់នឹងតែងតែមើលទៅកាន់លោកអ្នក មិនថាលោកអ្នកបានប្រព្រឹត្តអ្វី បានទៅកាន់កន្លែងណា ឬក៏ថាលោកអ្នកបានធ្វើខុសប៉ុន្មានដងក៏ដោយ ក៏ព្រះអង្គនៅតែស្រឡាញ់លោកអ្នក ហើយក៏បែរមកកាន់របស់លោកអ្នក ហើយស្វែងរកលោកអ្នកដែរ។

ដំណឹងល្អផ្ទាល់និយាយសំដៅទៅលើការអះអាងដែលថា ព្រះយេស៊ូវដែលជាអង្គត្រូវបានគេឆ្កាង ហើយក៏បានមានព្រះជន្មរស់ឡើងវិញក្នុងនាមជាព្រះមេស្ស៊ី គឺជាព្រះអម្ចាស់នៃផែនដីតែមួយគត់ដ៏ពិតនេះ។ ដំណឹងល្អ! ព្រះបានក្លាយជាស្តេច ហើយព្រះអង្គកំពុងតែធ្វើការងារនោះតាមរយៈព្រះយេស៊ូវ! ហេតុដូច្នេះ *យើងមិនគួរបារម្ភទេ!* យុត្តិធម៌របស់ព្រះជាម្ចាស់ សន្តិភាពរបស់ព្រះជាម្ចាស់ និងផែនដីរបស់ព្រះជាម្ចាស់នឹងត្រូវបានបង្កើតជាថ្មីវិញ។ ហើយពិតណាស់ នៅក្នុងកណ្តាលនោះគឺដំណឹងល្អសម្រាប់យើង។ ប៉ុន្តែ នោះគឺជាផល ឬក៏ជាលទ្ធផលនៃដំណឹងល្អ ដែលជាសារអំពីព្រះយេស៊ូវ ដែលមានឥទ្ធិពលទ្វេ ដណ្តប់លើយើង។ ប៉ុន្តែ ដំណឹងល្អផ្ទាល់គឺមិនមែនអំពីចំណាចដែលថា *លោកអ្នកគឺជាមនុស្សប្រភេទនេះ ហើយការនេះអាចកើតឡើងចំពោះលោកអ្នក* នោះទេ។ នោះគឺជាលទ្ធផលនៃដំណឹងល្អ ជាជាងដំណឹងល្អផ្ទាល់....សេចក្តីសង្គ្រោះគឺជា*លទ្ធផល*នៃដំណឹងល្អ មិនមែនជាចំណាចស្នូលនៃដំណឹងល្អផ្ទាល់នោះទេ។

ដំណឹងល្អគឺជាការប្រកាសអំពីព្រះយេស៊ូវក្នុងអត្ថន័យ [ពីរ] យ៉ាង។ វាគឺជា*ការប្រកាស*ដែលព្រះយេស៊ូវ*ប្រកាស*—ការមកដល់នៃរាជាណាចក្រនៃសក្តានុភាពរបស់ព្រះ («នគរ» របស់ព្រះអង្គ) ក្នុងចំណោមរចនាសម្ពន្ធនៃសក្តានុភាពរបស់មនុស្ស។ ប៉ុន្តែ វាក៏ជាការប្រកាសអំពីព្រះយេស៊ូវផងដែរ—ដំណឹងល្អដែលថា ក្នុងការសុគត និងការរស់ឡើងវិញ នោះព្រះយេស៊ូវបានធ្វើឲ្យយើងអាចទទួលបាននគរដែលទ្រង់បានប្រកាស។

ក្នុងនាមជាគ្រីស្ទបរិស័ទម្នាក់ ខ្ញុំកំពុងតែព្យាយាមយ៉ាងសាមញ្ញក្នុងការណែនាំខ្លួនឲ្យរស់ក្នុងរបៀបណាមួយ គឺក្នុងរបៀបដែលព្រះយេស៊ូវបានបង្រៀនថាអាចទៅរួចបាន។ ហើយខ្ញុំគិតថារបៀបរបស់ព្រះយេស៊ូវគឺជារបៀបដ៏ល្អបំផុតដែលអាចរស់នៅ.... ពេលដែលលោកអ្នកកាន់តែព្យាយាមរស់នៅដោយចេតនាតាមរបៀបរបស់ព្រះយេស៊ូវ នោះលោកអ្នកនឹងចាប់ផ្តើមសម្គាល់ឃើញនូវអ្វីមួយដែលជ្រៅជាងនោះ ដែលកំពុងតែកើនឡើងៗជាមិនខាន។ លោកអ្នកនឹងចាប់ផ្តើមឃើញថា មូលហេតុដែលថានេះគឺជារបៀបដ៏ល្អបំផុតក្នុងការរស់នៅគឺដោយសារវាមានឫសគល់ក្នុងសេចក្តីពិតដ៏ជ្រាលជ្រៅអំពីរបៀបនៃលោកីយ៍នេះ។ លោកអ្នកនឹងឃើញថា ខ្លួនកំពុងកាន់តែរស់នៅ ដោយមានភាពស៊ីគ្នាជាមួយនឹងមូលដ្ឋាននៅទីបញ្ចប់។ លោកអ្នកក៏នឹងកាន់តែមានភាពស៊ីគ្នាជាមួយនឹងចក្រវាឡនេះ ក្នុងកម្រិតដ៏

> ជ្រាលជ្រៅរបស់វា។...គ្រីស្ទបរិស័ទដំបូងបានប្រកាសអំពីព្រះយេស៊ូវរបៀបនេះថាជា «ដំណឹងល្អ»។
>
> ការយល់ដឹងរបស់ខ្ញុំអំពីសាររបស់ព្រះយេស៊ូវគឺថា ព្រះអង្គបានបង្រៀនឲ្យយើងរស់នៅក្នុងភាពពិតរបស់ព្រះជាម្ចាស់ឥឡូវនេះ—នៅត្រង់នេះ និងនៅថ្ងៃនេះ។ វាហាក់ដូចជាថាព្រះយេស៊ូវគ្រាន់តែនៅបន្តលើកឡើងដូចតទៅ «ចូរផ្លាស់ប្តូរជីវិតរបស់លោកអ្នក។ ហើយចូររស់នៅក្នុងរបៀបនេះវិញ»។

ឥឡូវនេះ លោកអ្នកយល់អំពីអ្វីដែលខ្ញុំបាននិយាយហើយ ពេលដែលខ្ញុំលើកឡើងថា ដំណឹងល្អពោរពេញទៅដោយភាពស្រអាប់នៃការភាន់ច្រឡំ! ប្រសិនបើលោកអ្នកមិនដែលឮអំពីជំនឿគ្រីស្ទបរិស័ទ តើលោកអ្នកនឹងគិតយ៉ាងដូចម្តេច បន្ទាប់ពីបានអានសម្រង់សម្តីទាំងប៉ុន្មានខាងលើនោះ? ច្បាស់ណាស់ លោកអ្នកនឹងដឹងថាគ្រីស្ទបរិស័ទកំពុងតែព្យាយាមបង្ហាញឲ្យលោកអ្នកដឹងនូវសារណាមួយដែលល្អ។ ប៉ុន្តែ លើសពីនោះទៅទៀត វាគ្រាន់តែជាភាពច្របូកច្របល់គ្នាតែប៉ុណ្ណោះ។ តើដំណឹងល្អគ្រាន់តែជាចំណុចដ៏សាមញ្ញដែលថា ព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ ហើយខ្ញុំគ្រាន់តែចាំបាច់ត្រូវចាប់ផ្តើមគិតក្នុងរបៀបវិជ្ជមានមែនឬ? តើវាគ្រាន់តែជាចំណុចដែលថា ព្រះយេស៊ូវពិតជាគំរូដ៏ល្អមួយមែន ដែលអាចបង្រៀនឲ្យខ្ញុំរស់នៅក្នុងរបៀបដែលពោរពេញទៅដោយសេចក្តីស្រឡាញ់ និងមានភាពអាណិតអាសូរក្នុង

9Marks Online PDF

ជីវិតមែនឬ? វាអាចមានការពាក់ព័ន្ធជាមួយនឹងអំពើបាប និងការអត់ទោស។ តាមការសង្កេតមើលទៅ គ្រីស្ទបរិស័ទមួយចំនួនក៏គិតថា ដំណឹងល្អនេះក៏មានការពាក់ព័ន្ធជាមួយនឹងការសុគតរបស់ព្រះយេស៊ូវផងដែរ។ ហើយអ្នកខ្លះទៀតក៏ហាក់បីដូចជាមិនគិតបែបនោះទេ។

គោលបំណងរបស់ខ្ញុំគឺមិនមែនសម្រេចឥឡូវនេះ និងនៅពេលនេះថា សម្រង់សម្តីមួយណាល្អ ឬក៏អាក្រក់ជាងមួយណានោះទេ (ទោះបើខ្ញុំសង្ឃឹមថា បន្ទាប់ពីលោកអ្នកបានអានសៀវភៅមួយនេះ នោះលោកអ្នកនឹងមានសមត្ថភាពក្នុងការសម្រេចក៏ដោយ)។ គោលបំណងគឺគ្រាន់តែចង់ចង្អុលបង្ហាញថា មានចំណាចខុសៗគ្នាជាច្រើនដែលបានផុសឡើងនៅក្នុងគំនិតរបស់មនុស្ស នៅពេលដែលមានគេសួរថា “តើដំណឹងល្អជាអ្វី?”។

ក្នុងសៀវភៅនេះ ខ្ញុំចង់ព្យាយាមផ្តល់ជូននូវចម្លើយដ៏ច្បាស់លាស់លើសំណួរ ចម្លើយដែលមានមូលដ្ឋានលើអ្វីដែលព្រះគម្ពីរបង្រៀនអំពីដំណឹងល្អ។ ក្នុងដំណើរការនេះ ខ្ញុំក៏សង្ឃឹម និងអធិស្ឋានសម្រាប់ចំណុចមួយចំនួនផងដែរ។

*ទី១* ប្រសិនបើលោកអ្នកជាគ្រីស្ទបរិស័ទ ខ្ញុំសូមអធិស្ឋានឲ្យសៀវភៅដ៏តូចមួយក្បាលនេះ—ហើយសំខាន់ជាងនេះទៅទៀត គឺសេចក្តីពិតដ៏រុងរឿងដែលសៀវភៅនេះព្យាយាមពណ៌នា—នឹងបណ្តាលឲ្យដួងចិត្តរបស់លោកអ្នកនឹងប៉ោងឡើងទៅដោយអំណរ និងការសរសើរព្រះយេស៊ូវគ្រីស្ទ សម្រាប់អ្វីដែលព្រះអង្គបានសម្រេច

9Marks Online PDF

សម្រាប់លោកអ្នក។ ដំណឹងល្អដែលតូចតាចនឹងនាំឲ្យមានការថ្វាយបង្គំដែលតូចតាចដែរ។ វាបន្ទាបភ្នែករបស់យើងពីព្រះជាម្ចាស់មកកាន់ខ្លួនឯង ហើយបន្ថោកនូវអ្វីដែលព្រះជាម្ចាស់បានសម្រេចសម្រាប់យើងក្នុងព្រះគ្រីស្ទ។ ផ្ទុយទៅវិញ ដំណឹងល្អយោងតាមព្រះគម្ពីរគឺប្រៀបដូចជាសាំងនៅក្នុងឡភ្លើងនៃការថ្វាយបង្គំ។ ខណៈពេលដែលលោកអ្នកកាន់តែយល់អំពីវា ជឿជាក់លើវា ហើយរំពឹងលើវា នោះលោកអ្នកក៏នឹងកាន់តែស្រឡាញ់ព្រះជាម្ចាស់ទាក់ទងនឹងលក្ខណសម្បត្តិរបស់ទ្រង់ និងអ្វីដែលព្រះអង្គបានសម្រេចសម្រាប់យើងនៅក្នុងព្រះគ្រីស្ទជាមិនខាន។ សាវ័ក ប៉ុល បានស្រែកយំថា «អើហ្ន៎ប្រាជ្ញា និងចំណេះដ៏បរិបូររបស់ព្រះជ្រៅណាស់តើ ឯព្រះតម្រិះរបស់ទ្រង់» (រ៉ូម ១១:៣៣)។ ហើយវាក៏ដូច្នោះ គឺពីព្រោះដួងចិត្តរបស់គាត់មានពេញទៅដោយដំណឹងល្អ។

*ទី២* ខ្ញុំសង្ឃឹមថា តាមរយៈការអានសៀវភៅមួយនេះ នោះលោកអ្នកនឹងកាន់តែមានទំនុកចិត្តខណៈពេលដែលលោកអ្នកនិយាយជាមួយអ្នកដទៃអំពីដំណឹងល្អរបស់ព្រះយេស៊ូវ។ ខ្ញុំបានជួបគ្រីស្ទបរិស័ទជាច្រើននាក់ដែលមានការស្ទាក់ស្ទើរក្នុងការចែកចាយដំណឹងល្អជាមួយនឹងមិត្តភក្តិ គ្រួសារ និងអ្នកស្គាល់គ្នាដោយសារគាត់ខ្លាចថាមិនមានចម្លើយសម្រាប់សំណួរទាំងអស់របស់ពួកគេ។ តាមពិតទៅ មិនថាលោកអ្នកជានរណាក៏ដោយ វាទំនងជាពិតមែនដែលថា លោកអ្នកនឹងមិនអាចមានសមត្ថភាពក្នុងការឆ្លើយលើសំណួរ*ទាំងអស់*នោះទេ! ប៉ុន្តែ

9Marks Online PDF

លោកអ្នកក៏នៅ*អាច*ឆ្លើយបានខ្លះៗដែរ ហើយខ្ញុំសង្ឃឹមថា សៀវភៅមួយនេះនឹងជួយឲ្យលោកអ្នកអាចឆ្លើយបាន*ច្រើនជាង*នោះទៅទៀត។

*ទី៣* ខ្ញុំសូមអធិស្ឋានថា លោកអ្នកនឹងឃើញអំពីចំណុចសំខាន់នៃដំណឹងល្អមួយនេះសម្រាប់ជីវិតក្នុងក្រុមជំនុំ ហើយថាជាលទ្ធផលនោះលោកអ្នកនឹងព្យាយាមប្រាកដថាខ្លួននឹងអធិប្បាយ ច្រៀង អធិស្ឋានបង្រៀន ប្រកាស និងធ្វើឲ្យដំណឹងល្អនេះទទួលបានការព្រួនៅក្នុងគ្រប់ចំណុចនៃជីវិតក្នុងក្រុមជំនុំរបស់លោកអ្នកដែរ។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា គឺតាមរយៈក្រុមជំនុំហើយដែលចក្រវាឡនេះនឹងស្គាល់ប្រាជ្ញាជាច្រើនរបស់ព្រះជាម្ចាស់។ ហើយថា តើការនេះកើតឡើងដោយរបៀបណា? គឺតាមរយៈការប្រកាសដំណឹងល្អ ដែលនឹងបំភ្លឺដល់ «គ្រប់មនុស្សទាំងអស់» អំពីផែនការដ៏នៅអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ក្នុងការសង្គ្រោះមនុស្សលោក (អេភេសូរ ៣:៧-១២)។

*ទី៤* ខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងជួយទ្រទ្រង់ចំណុចពិបាកៗនៃដំណឹងល្អក្នុងគំនិត និងដួងចិត្តរបស់លោកអ្នក។ ដំណឹងល្អគឺជាសារដ៏សោះកក្រោះ ហើយវាយលុកចូលគំនិត និងអាទិភាពរបស់លោកីយ៍ជាមួយនឹងសេចក្ដីពិតដ៏មុត និងពេញទៅដោយកម្លាំង។ ជាការគួរឲ្យសោកស្ដាយណាស់ តែងតែមាននិន្នាការក្នុងចំណោមគ្រីស្ទបរិស័ទ—សូម្បីតែក្នុងចំណោមគ្រីស្ទបរិស័ទដំណឹងល្អ—ក្នុងការបន្ទន់ចំណុចពិបាកមួយចំនួននោះ ដើម្បីឲ្យលោកីយ៍នេះងាយស្រួលនឹងទទួលដំណឹងល្អ។ សេចក្ដីអធិស្ឋានមួយរបស់ខ្ញុំគឺថា សៀវភៅ

9Marks Online PDF

នេះនឹងរក្សាចំណុចពិបាកទាំងនោះ និងបង្ការភាពចម្រោះសេចក្តីពិតចោល (ត្រង់ថា ទោះបើលោកីយ៍នេះពិបាកនឹងទទួលយក) ដ៏សំខាន់ចំពោះដំណឹងល្អពីព្រះយេស៊ូវ។ យើងទាំងអស់គ្នាសុទ្ធតែទទួលការល្បួង ក្នុងការព្យាយាមធ្វើជាទីបន្ទាល់ដែលទាក់ទាញចិត្តគេ ដើម្បីប្រកាសអំពីដំណឹងល្អក្នុងរបៀបដ៏គួរឲ្យទាក់ទាញចំណាប់អារម្មណ៍បានយ៉ាងខ្លាំងបំផុត។ ក្នុងរបៀបមួយចំនួន នោះមិនអីទេ—ដ្បិតវាគឺជា "ដំណឹង*ល្អ*" មែន—ប៉ុន្តែ ដាច់ខាតយើងត្រូវតែមានការប្រុងប្រយ័ត្នក្នុងការមិនធ្វើឲ្យចំណុចមុតមួយចំនួននៃដំណឹងល្អលែងមុតវិញ។ ដាច់ខាត! យើងត្រូវតែរក្សាចំណុចពិបាកៗ ហើយខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងជួយយើងធ្វើការនោះ។

ជាចុងក្រោយ ប្រសិនបើលោកអ្នកមិនមែនជាគ្រីស្ទបរិស័ទទេ ខ្ញុំសូមអធិស្ឋានឲ្យលោកអ្នកថា តាមរយៈការអានសៀវភៅនេះ នោះលោកអ្នកនឹងទទួលការលើកទឹកចិត្តឲ្យគិតយ៉ាងខ្លាំងអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ នេះគឺជាសារដែលយើងជាគ្រីស្ទបរិស័ទបានពឹងផ្អែកជីវិតទាំងមូលរបស់យើងលើ ហើយវាក៏ជាសារមួយដែលយើងជឿជាក់ថាទាមទារឲ្យមានការឆ្លើយតបពីលោកអ្នកផងដែរ។ ប្រសិនបើមានអ្វីមួយនៅលើលោកនេះ ដែលលោកអ្នកមិនអាចមិនអើពើជាមួយនឹងបាន នោះគឺជាសំឡេងរបស់ព្រះជាម្ចាស់ដែលកំពុងតែមានបន្ទូលថា "មានដំណឹងល្អ! នេះគឺជារបៀបដែលឯងអាចទទួលបានការសង្គ្រោះចេញពីការថ្កោលទោសរបស់យើងបាន!" នោះគឺជាការ

ប្រកាសដែលទាមទារឲ្យមានចំណាប់អារម្មណ៍។

ជំពូកទី១

# ការស្វែងរកដំណឹងល្អក្នុងព្រះគម្ពីរ

តើបងប្អូនដឹងទេថា ប្រព័ន្ធរុករក GPS កំពុងតែបង្កបញ្ហានៅគ្រប់ទីកន្លែងនៅប្រទេសអាមេរិក? ជាពិសេស នៅក្នុងតំបន់ដែលមានផ្លូវតូចៗ។ ចំពោះអ្នកដែលរស់នៅក្នុងទីក្រុងធំៗ ប្រព័ន្ធដ៏តូចនេះគឺពិតជាជំនួយដ៏ខ្លាំងមែន។ គ្រាន់តែវាយអាសយដ្ឋានចូល GPS នោះលោកអ្នកនឹងទៅដល់ទីកន្លែងដែលលោកអ្នកចង់ទៅយ៉ាងងាយស្រួល។ មិនមានការជិះហួសផ្លូវ ឬក៏បត់ខុសផ្លូវទៀតទេ—គឺមានតែលោកអ្នក ឡានរបស់លោកអ្នក GPS របស់លោកអ្នក និងសំឡេងពាទ៍! «កំពុងតែដល់ទីកន្លែង»។

ថ្មីៗនេះ ខ្ញុំទើបតែទទួលបានប្រព័ន្ធ GPS ដំបូងរបស់ខ្ញុំ ដែលតាមពិតទៅជាទង្វើនៃការបំពាន-ប្រឆាំងនឹងបុគ្គលដែលមានទំនួលខុសត្រូវសម្រាប់ប្រព័ន្ធផ្លូវ ដែលស្ទើរតែអសមត្ថភាព ក្នុងវ៉ាស៊ីនតោន ឌី.ស៊ី. (Washington D.C.)។ ប៉ុន្តែ បទពិសោធន៍ដំបូងរបស់ខ្ញុំគឺមិនមែននៅក្នុងទីក្រុងវ៉ាស៊ីនតោននោះទេ។ គឺនៅស្រុកលីនដិន រដ្ឋតិចសាស់ (Linden Texas) ដែលជាស្រុកកំណើតរបស់ខ្ញុំ តំបន់នោះជាតំបន់

9Marks Online PDF

ជនបទដ៏តូច ហើយឆ្ងាយពីទីក្រុងណាស់។

ប្រព័ន្ធ GPS របស់ខ្ញុំមិនមានបញ្ហាក្នុងការស្វែងទិសផ្លូវដែលប្រទាក់គ្នាខ្វាត់ខ្វែង បត់ទៅនេះបត់ទៅនោះ នៅក្នុងទីក្រុងវ៉ាស៊ីនតោននោះទេ។ តែចម្លែកណាស់ វាបែរជាមានបញ្ហានេះនៅស្រុកលីនដិនទៅវិញ។ ផ្លូវដែលប្រព័ន្ធ GPS ប្រាកដច្បាស់ថាមាន បែរជាមិនមានទៅវិញ។ ផ្លូវបត់ដែលវាទទូចថាមាន បែរជាមិនមាន។ អាសយដ្ឋានដែលវាជឿជាក់យ៉ាងខ្លាំងថាពិតជាមានកន្លែងមែន បែរជានៅឆ្ងាយជាងគោលដៅរាប់រយម៉ែត្រពីផ្លូវ—ឬក៏ថាមិនទាំងមានផង។

តាមមើលទៅ ការដែលប្រព័ន្ធ GPS មិនស្គាល់តំបន់ជនបទដ៏តូចណាមួយគឺជាបញ្ហាដែលកំពុងតែផ្ទុះឡើង។ ប្រព័ន្ធបញ្ជូនព័ត៌មានបានលើកឡើងអំពីផ្លូវជិតខាង ដែលបានក្លាយជាមហាវិថី ដោយសារប្រព័ន្ធ GPS បានបញ្ជូនចរាចរណ៍ទៅទីនោះ ជាជាងបញ្ជូនទៅផ្លូវជាតិ។ ហើយក៏នៅមានបញ្ហាផ្សេងៗទៀតដែរ។ មានបុរសដែលគួរឲ្យអាណិតម្នាក់បានតវ៉ាថា គាត់គ្រាន់តែធ្វើតាមការណែនាំរបស់ប្រព័ន្ធ GPS ប៉ុណ្ណោះនៅពេលដែលគាត់បត់ស្ដាំចូលផ្លូវតូចមួយ ហើយឃើញថាខ្លួនជាប់លើផ្លូវរទេះភ្លើង ដោយភាំងនឹងពន្លឺរទេះភ្លើងដែលកំពុងតែបើកបរមករកគាត់! គាត់នៅរស់ទេ។ ប៉ុន្តែ ឡានជួលរបស់គាត់ និងប្រព័ន្ធ GPS ដែលគួរឲ្យអន់ចិត្តជាមួយនោះ មិននៅសល់ទៀតទេ។

អ្នកតំណាងឲ្យក្រុមហ៊ុនបើកបរម្នាក់ (សមាគមរថយន្តអាមេរិក “American Automobile Association”) មានចិត្តអាណិតអាសូរ

9Marks Online PDF

—បន្តិច។ គាត់បានលើកឡើងដូចតទៅ “ច្បាស់ណាស់! ប្រព័ន្ធ GPS បានបរាជ័យក្នុងអត្ថន័យដែលថា វាមិនគួរបានប្រាប់គាត់ឲ្យបត់ស្តាំចូលផ្លូវរទេះភ្លើងនោះទេ។ ប៉ុន្តែ បើគ្រាន់តែថាដោយសារម៉ាស៊ីនប្រាប់លោកឲ្យធ្វើអ្វីមួយ ដែលមើលទៅហាក់បីដូចជាមានគ្រោះថ្នាក់ នោះមិនមែនមានន័យថា លោកអ្នកត្រូវតែស្តាប់តាមវានោះទេ”។ ពិតណាស់!

ដូច្នេះ តើមានអ្វីកំពុងតែកើតឡើង? អ្នកផលិតប្រព័ន្ធ GPS បានលើកឡើងថាបញ្ហាគឺមិនមែនដោយសារឧបករណ៍នោះទេ។ តាមពិតទៅ វាកំពុងតែធ្វើនូវអ្វីដែលវាត្រូវធ្វើហើយ។ ផ្ទុយទៅវិញ បញ្ហាគឺដោយសារផែនទីដែលពួកគេកំពុងប្រើប្រាស់។ គេបានរកឃើញថាជាពិសេសទាក់ទងនឹងភូមិតូចៗ ជាទូទៅផែនទីដែលប្រព័ន្ធ GPS ទទួលបានគឺជាផែនទីចាស់ បួនដប់ឆ្នាំ ឬក៏ចាស់ជាងនោះទៅទៀតក៏ថាបាន។ ពេលខ្លះ ផែនទីគឺគ្រាន់តែជាគម្រោងផែនទីប៉ុណ្ណោះ—អ្វីដែលអ្នករៀបចំផែនការសម្រាប់ទីក្រុង*ចង់ធ្វើ* ប្រសិនបើភូមិរបស់ពួកគាត់រីកចម្រើន។ លទ្ធផល? ពេលខ្លះ អាសយដ្ឋានដែលមាននៅកន្លែងណាមួយ ក្នុងគម្រោងផែនទី បែរជាទៅនៅកន្លែងមួយផ្សេងទៀតនៅពេលដែលគេបានសាងសង់។ ពេលខ្លះ ផ្លូវដែលអ្នករៀបចំគម្រោងទីក្រុងចង់សាងសង់បែរជាមិនបានសាងសង់ទាល់តែសោះ—ហើយពេលខ្លះ គេក៏បែរជាសាងសង់វាជាផ្លូវរទេះភ្លើង ជាជាងផ្លូវបើកបរទៅវិញ!

ក្នុងពិភពប្រព័ន្ធ GPS ដូចនៅក្នុងជីវិតផ្ទាល់ វាជារឿងសំខាន់ណាស់ ដែលលោកអ្នកទទួលបានព័ត៌មានពីប្រភពដែលអាចទុកចិត្តបាន!

## តើយើងអាងលើអំណាចអ្វី?

ចំណុចនេះក៏ពិត នៅពេលដែលយើងសួរសំណួរថា «តើដំណឹងល្អជាអ្វី?»។ ចាប់តាំងពីដើម យើងត្រូវតែធ្វើការសម្រេចចិត្តណាមួយអំពីប្រភពនៃព័ត៌មានដែលយើងនឹងប្រើប្រាស់ ដើម្បីឆ្លើយសំណួរ។ សម្រាប់អ្នកដំណឹងល្អ ជាទូទៅចម្លើយផុសឡើងក្នុងរបៀបដ៏ងាយស្រួលៈ យើងរកចម្លើយក្នុងព្រះគម្ពីរ។

នោះគឺជាចំណាចពិត ប៉ុន្តែក៏ជាការប្រសើរដែរ ក្នុងការដឹងពីដំបូងថាមិនមែនគ្រប់គ្នាឯកភាពទាំងស្រុងជាមួយនឹងចម្លើយនោះទេ។ ទំនៀមទម្លាប់របស់ «គ្រីស្ទបរិស័ទ» ខុសៗគ្នា បានផ្តល់ជូននូវចម្លើយខុសៗគ្នាជាច្រើនប្រភេទសម្រាប់សំណួរអំពីប្រភពនៃអំណាច។ ឧទាហរណ៍ៈ អ្នកខ្លះបានវែកញែកថា យើងមិនគួរពឹងទាំងស្រុង ឬក៏ជាចម្បងលើព្រះបន្ទូលក្នុងព្រះគម្ពីរ ទាក់ទងទៅនឹងចំណេះដឹងរបស់យើងសម្រាប់ដំណឹងល្អនោះទេ ប៉ុន្តែពឹងលើទំនៀមទម្លាប់គ្រីស្ទបរិស័ទវិញ។ ពួកគាត់បានវែកញែកថា ប្រសិនបើក្រុមជំនុំបានជឿលើអ្វីមួយអស់ច្រើនឆ្នាំហើយ នោះយើងគួរទទួលស្គាល់ថាវាគឺជាការពិត។ អ្នកខ្លះទៀតបានលើកឡើងថា យើងស្គាល់សេចក្តីពិតបាន តាមរយៈការប្រើប្រាស់ហេតុផល។ ការសាងសង់ចំណេះដឹងរបស់យើង ពីក្រោមឡើងលើ—«ក»

9Marks Online PDF

នាំទៅ “ខ” ទៅ “គ” ទៅ “ឃ”—នឹងនាំឲ្យយើងយល់អំពីខ្លួនឯង ពីពិភពលោកនេះ និងពីព្រះជាម្ចាស់បានយ៉ាងពិតប្រាកដ។ ហើយក៏នៅមានអ្នកដទៃទៀតថា យើងគួរតែស្វែងរកសេចក្តីពិតនៃដំណឹងល្អក្នុងបទពិសោធន៍របស់យើងផ្ទាល់ដែរ។ អ្នកខ្លះជឿថា អ្វីដែលយើងឮខ្ទរខ្លាំងជាងគេបំផុតនៅក្នុងចិត្តរបស់យើងគឺជាអ្វីដែលយើងយល់ជាចុងក្រោយថាជាសេចក្តីពិតអំពីខ្លួនឯង និងអំពីព្រះជាម្ចាស់។

ប្រសិនបើលោកអ្នកចំណាយពេលល្មមគ្រប់គ្រាន់ក្នុងការគិតអំពីវានោះលោកអ្នកនឹងឃើញថា នៅទីបំផុតចំណុចនីមួយៗនៃសក្តានុពលនៃប្រភពអំណាចទាំងបីនោះនឹងបរាជ័យក្នុងការផ្តល់ឲ្យនូវអ្វីដែលវាសន្យាថាឲ្យជាមិនខាន។ ទំនៀមទម្លាប់នឹងមិនបន្សល់ឲ្យយើងនូវអ្វីក្រៅពីមតិយោបល់របស់មនុស្សតែប៉ុណ្ណោះ។ ចំណែកឯ “ហេតុផល” វិញ ទស្សនវិទូឆ្នាំទី១នៅមហាវិទ្យាល័យនឹងប្រាប់លោកអ្នកថា វានឹងមិនបន្សល់អ្វីដល់យើង ក្រៅពីការធ្លាក់ចុះក្នុងការមានមន្ទិលសង្ស័យនោះទេ។ (ឧទាហរណ៍៖ សូមព្យាយាមផ្តល់ជា*ភស្តុតាង*ថា លោកអ្នកមិនមែនជាអ្វី ក្រៅពីអ្វីដែលអ្នកដទៃបានស្រមើស្រមៃនោះទេ ឬក៏ថាលោកអ្នកអាចទុកចិត្តបានលើញាណទាំងប្រាំរបស់ខ្លួន)។ ហើយបទពិសោធន៍នឹងនាំឲ្យយើងមានការទុកចិត្តលើដួងចិត្តដែលផ្លាស់ប្តូររបស់យើងប៉ុណ្ណោះ ដើម្បីបោកបញ្ឆោតយើងនូវអ្វីដែលពិត—ទស្សនីយភាពនៃមនុស្សដែលស្មោះត្រង់ភាគច្រើននឹងឃើញថាជាស្មារតីបាននឹងនរខ្លាំងជាងគេ។

9Marks Online PDF

ដូច្នេះ តើយើងគួរធ្វើអ្វីទៅ? តើយើងគួរទៅកន្លែងណា ដើម្បីឲ្យដឹងថាអ្វីទៅជាការពិតដែលការនោះនឹងនាំឲ្យយើងស្គាល់ថា តើអ្វីទៅពិតជាដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទមែន? ក្នុងនាមជាគ្រីស្ទបរិស័ទ យើងជឿថា ព្រះជាម្ចាស់បានមានព្រះបន្ទូលមកកាន់យើងតាមរយៈព្រះបន្ទូលរបស់ទ្រង់ គឺព្រះគម្ពីរ។ លើសពីនោះទៅទៀត យើងក៏ជឿជាក់ផងដែរថា អ្វីដែលព្រះជាម្ចាស់បានមានព្រះបន្ទូលមកកាន់យើងក្នុងព្រះគម្ពីរក៏ឥតមានកំហុស និងពិតដែរ។ ហេតុដូច្នេះហើយបានជាព្រះគម្ពីរនឹងមិននាំយើងឲ្យមានមន្ទិលសង្ស័យ អស់សង្ឃឹម ឬក៏មិនមានភាពប្រាកដប្រជានោះឡើយ ប៉ុន្តែនាំឲ្យយើងមានទំនុកចិត្តទៅវិញ។ «គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងទេ» (២ធីម៉ូថេ ៣:១៦)។ ស្តេច ដាវីឌ បានសរសេរថា៖

> «ឯព្រះ ផ្លូវនៃទ្រង់គ្រប់លក្ខណ៍ ព្រះបន្ទូលនៃព្រះយេហូវ៉ាបានសាកមើលហើយ» (ទំនុកតម្កើង ១៨:៣០)។

ហេតុដូច្នេះ យើងសម្លឹងមើលក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីរកនូវអ្វីដែលទ្រង់បានមានព្រះបន្ទូលមកកាន់យើងអំពីព្រះយេស៊ូវ ដែលជាព្រះរាជបុត្រារបស់ទ្រង់ និងអំពីដំណឹងល្អ។

## តើយើងមើលក្នុងកណ្ឌគម្ពីរមួយណា?

ប៉ុន្តែ តើយើងទៅមើលក្នុងកណ្ឌគម្ពីរណា ដើម្បីស្វែងរកចំណាចនោះ? ខ្ញុំគិតថា មានរបៀបបីបួនយ៉ាងដែលយើងអាចធ្វើបាន។ របៀបមួយគឺ

មើលគ្រប់ទីកន្លែងដែលពាក្យ*ដំណឹងល្អ*មាននៅក្នុងព្រះគម្ពីរសញ្ញាថ្មី ហើយព្យាយាមធ្វើសេចក្ដីសន្និដ្ឋានណាមួយអំពីអ្វីដែលអ្នកនិពន្ធមានន័យនៅពេលដែលពួកគាត់បានប្រើប្រាស់ពាក្យនោះ។ ពិតណាស់! មានពីរបីកន្លែងដែលអ្នកនិពន្ធបានមានការប្រុងប្រយ័ត្នក្នុងការផ្ដល់អត្ថន័យ។

ក្នុងរបៀបនេះ យើងអាចរៀនបានចំណុចសំខាន់ៗ ប៉ុន្តែក៏អាចមានបញ្ហាខ្លះៗដែរ។ បញ្ហាមួយគឺថា ជាទូទៅនៅក្នុងព្រះគម្ពីរសញ្ញាថ្មី យើងឃើញយ៉ាងច្បាស់ថា អ្នកនិពន្ធព្យាយាមផ្ដល់ជូននូវការសង្ខេបអំពីដំណឹងល្អរបស់គ្រីស្ទបរិស័ទ ប៉ុន្តែគាត់មិនបានប្រើប្រាស់ពាក្យ*ដំណឹងល្អ*ទាល់តែសោះ។ ឧទាហរណ៍៖ នៅក្នុងសេចក្ដីអធិប្បាយរបស់សាវ័ក ពេត្រុស ក្នុងកណ្ឌគម្ពីរ កិច្ចការ ២ នៅថ្ងៃបុណ្យទី៥០។ ប្រសិនបើពិតជាមានការប្រកាសអំពីដំណឹងល្អរបស់គ្រីស្ទបរិស័ទមែនពិតណាស់គឺនៅទីនេះហើយ—ទោះជាយ៉ាងណាក៏ដោយក៏សាវ័ក ពេត្រុស មិនបានប្រើប្រាស់ពាក្យ*ដំណឹងល្អ*ឡើយ។ សាវ័ក យ៉ូហាន គឺជាឧទាហរណ៍មួយទៀត ដែលគាត់បានប្រើប្រាស់ពាក្យ*ដំណឹងល្អ*តែមួយដងក្នុងការនិពន្ធរបស់គាត់ក្នុងព្រះគម្ពីរសញ្ញាថ្មី (វិវរណៈ ១៤:៦)!

សម្រាប់ឥឡូវនេះ សូមអនុញ្ញាតឲ្យខ្ញុំលើកជាសំណើថា យើងដោះស្រាយការផ្ដល់អត្ថន័យចម្បងលើដំណឹងល្អនៃគ្រីស្ទបរិស័ទ គឺមិនមែនតាមរយៈការសិក្សាពាក្យពេចន៍ទេ ប៉ុន្តែគឺតាមរយៈការមើលអ្វីដែលគ្រីស្ទបរិស័ទនៅសម័យដំបូងបានលើកឡើងអំពីព្រះយេស៊ូវ

និងអំពីចំណុចសំខាន់នៃព្រះជន្ម ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់។ ប្រសិនបើយើងមើលការនិពន្ធរបស់ពួកសាវ័ក និងការអធិប្បាយរបស់ពួកគាត់នៅក្នុងព្រះគម្ពីរ នោះយើងនឹងឃើញការពន្យល់របស់ពួកគាត់អំពីអ្វីដែលពួកគាត់បានរៀនពីព្រះយេស៊ូវទាក់ទងនឹងដំណឹងល្អ ពេលខ្លះពួកគាត់បានពន្យល់ ទោះបើថាត្រួសៗហើយពេលខ្លះទៀតយ៉ាងក្បោះក្បាយក៏ដោយ។ យើងទំនងអាចវែកញែកនូវសំណួរសាមញ្ញមួយចំនួន និងគម្រោងនៃសេចក្ដីពិតដូចគ្នាក្នុងអ្វីដែលពួកសាវ័ក និងគ្រីស្ទបរិស័ទសម័យដំបូងបានរៀបរៀងឡើងក្នុងការធ្វើបទបង្ហាញអំពីដំណឹងល្អរបស់ព្រះយេស៊ូវ។

**ដំណឹងល្អនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១-៤**

កន្លែងដ៏ល្អបំផុតមួយក្នុងការចាប់ផ្ដើមស្វែងយល់អំពីការពន្យល់បែបមូលដ្ឋាន លើដំណឹងល្អគឺក្នុងសំបុត្ររបស់សាវ័ក ប៉ុល ទៅកាន់ក្រុមជំនុំរ៉ូម។ ទំនងជាច្បាស់ជាងកណ្ឌគម្ពីរណាផ្សេងទៀតនៅក្នុងព្រះគម្ពីរ គឺថា កណ្ឌគម្ពីរ រ៉ូម មានការពន្យល់យ៉ាងយកចិត្តទុកដាក់ពីមួយជំហានទៅមួយជំហានទៀតអំពីការយល់ឃើញរបស់សាវ័ក ប៉ុល ទាក់ទងទៅនឹងដំណឹងល្អ។

តាមពិតទៅ កណ្ឌគម្ពីរ រ៉ូម មិនសូវមានលក្ខណៈដូច*សៀវភៅ*ប៉ុន្មានទេ យ៉ាងហោចណាស់ក្នុងរបៀបដែលយើងគិតជាទូទៅលើកណ្ឌគម្ពីរនានា។ វាគឺជាសំបុត្រ ជារបៀបមួយដែលសាវ័ក ប៉ុល បានណែនាំខ្លួនគាត់ និងសាររបស់គាត់ទៅកាន់គ្រីស្ទបរិស័ទមួយក្រុម ដែលគាត់

មិនដែលធ្លាប់បានជួប។ ហេតុដូច្នេះហើយបានជាយើងមានអារម្មណ៍ថាកណ្ឌគម្ពីរនេះមានលំដាប់លំដោយពីជំហានមួយទៅជំហានមួយទៀត។ សាវ័ក ប៉ុល ចង់ឲ្យគ្រីស្ទបរិស័ទទាំងនោះស្គាល់គាត់ ស្គាល់ព័ន្ធកិច្ចរបស់គាត់ ហើយជាពិសេសនោះគឺជាសាររបស់គាត់។ សាវ័ក ប៉ុល ចង់ឲ្យពួកគាត់ដឹងថា ដំណឹងល្អដែលគាត់ប្រកាសក៏ដូចជាដំណឹងល្អដែលពួកគាត់បានទទួលជឿផងដែរ។

«ដ្បិតខ្ញុំគ្មានសេចក្ដីខ្មាស ចំពោះដំណឹងល្អនៃព្រះគ្រីស្ទទេ» គាត់បានចាប់ផ្ដើម «ពីព្រោះជាព្រះចេស្ដានៃព្រះ សម្រាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ» (រ៉ូម ១:១៦)។ ចាប់ពីទីនោះ ជាពិសេសក្នុងបួនជំពូកដំបូងសាវ័ក ប៉ុល បានពន្យល់អំពីដំណឹងល្អរបស់ព្រះយេស៊ូវក្នុងរបៀបដ៏លម្អិត។ ខណៈពេលដែលយើងមើលជំពូកទាំងនេះ នោះយើងនឹងឃើញថាសាវ័ក ប៉ុល បានគ្រោងបទបង្ហាញរបស់គាត់អំពីដំណឹងល្អ នៅជុំវិញសេចក្ដីពិតដ៏សំខាន់មួយចំនួន គឺសេចក្ដីពិតដែលបានលើកឡើងម្ដងហើយម្ដងទៀតនៅក្នុងការអធិប្បាយរបស់ពួកសាវ័កអំពីដំណឹងល្អ។ តោះ! ចូរមើលដំណើរការនៃផ្នត់គំនិតរបស់សាវ័ក ប៉ុល ក្នុងកណ្ឌគម្ពីរ រ៉ូម ១-៤។

*ជាដំបូង សាវ័ក ប៉ុល បានប្រាប់មិត្តអ្នកអានរបស់គាត់ថា ពួកគាត់ត្រូវតែឆ្លើយតបចំពោះព្រះជាម្ចាស់។* បន្ទាប់ពីគាត់បានណែនាំខ្លួននៅក្នុងកណ្ឌគម្ពីរ រ៉ូម ១:១-៧ នោះសាវ័ក ប៉ុល ក៏ចាប់ផ្ដើមបើកបទបង្ហាញរបស់គាត់នៃការពន្យល់លើដំណឹងល្អតាមរយៈការប្រកាសថា «សេចក្ដី

9Marks Online PDF

ក្រោធរបស់ព្រះ បានសម្តែងមកពីស្ថានសួគ៌» (ខ១៨)។ តាមរយៈពាក្យពេចន៍ដំបូងរបស់គាត់ សាវ័ក ប៉ុល ទទូចថាមនុស្សយើងមិនមែនជាម្ចាស់របស់ខ្លួនឯងនោះទេ។ យើងមិនបានបង្កើតខ្លួនឯង ហើយយើងក៏មិនពឹងពាក់ទៅលើខ្លួនឯង ឬក៏មានទំនួលខុសត្រូវចំពោះខ្លួនឯងនោះឡើយ។ មិនដូច្នោះទេ! ព្រះជាម្ចាស់គឺជាអង្គដែលបានបង្កើតផែនដី និងគ្រប់អ្វីៗទាំងអស់ រួមទាំងយើងផងដែរ។ ដោយសារព្រះអង្គជាអង្គដែលបានបង្កើតយើង នោះព្រះអង្គមានសិទ្ធិទាមទារឲ្យយើងថ្វាយបង្គំទ្រង់។ សូមមើលអំពីអ្វីដែលសាវ័ក ប៉ុល លើកឡើងនៅក្នុង ខ២១ «ព្រោះកាលគេបានស្គាល់ព្រះ នោះគេមិនបានតម្កើងទ្រង់ ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់ដែរ គេកើតមានគំនិតឥតប្រយោជន៍វិញ ហើយចិត្តគេ ដែលឥតយោបល់ ក៏បានត្រឡប់ជាងងឹតទៅ»។

ហេតុដូច្នេះហើយបានជាសាវ័ក ប៉ុល ចោទប្រកាន់មនុស្សលោកថា៖ ពួកគេបានប្រព្រឹត្តអំពើបាបដោយសារពួកគេមិនបានថ្វាយព្រះកិត្តិយស និងអរព្រះគុណដល់ព្រះជាម្ចាស់។ វាគឺជាកាតព្វកិច្ចរបស់យើង ក្នុងនាមជាមនុស្សដែលព្រះជាម្ចាស់បានបង្កើតមក ហើយក៏ជាកម្មសិទ្ធិរបស់ទ្រង់ ក្នុងការថ្វាយព្រះកិត្តិយស និងសិរីល្អដែលទ្រង់ស័ក្តិសមនឹងទទួល ក្នុងការរស់នៅ និយាយស្តី ប្រព្រឹត្តទង្វើ និងគិតក្នុងរបៀបដែលមើលឃើញ និងទទួលស្គាល់ព្រះចេស្តារបស់ទ្រង់លើយើង។ ព្រះអង្គគឺជាអង្គដែលបានបង្កើតយើង ហើយយើងជាកម្មសិទ្ធិរបស់ទ្រង់ ត្រូវពឹងលើទ្រង់ ដែលនេះបណ្តាលឲ្យយើងត្រូវឆ្លើយតបទៅ

9Marks Online PDF

កាន់ទ្រង់។ នោះគឺជាចំណុចដំបូងដែលសាវ័ក ប៉ុល ព្យាយាមលើកឡើង ខណៈពេលដែលគាត់ពន្យល់អំពីដំណឹងល្អរបស់គ្រីស្ទបរិស័ទ។

*ទី២ សាវ័ក ប៉ុល បានប្រាប់មិត្តអ្នកអានរបស់គាត់ថា បញ្ហារបស់ពួកគេគឺថាពួកគេបានបះបោរទាស់ប្រឆាំងនឹងព្រះជាម្ចាស់។* ពួកគេ—ព្រមទាំងមនុស្សគ្រប់ៗគ្នា—មិនបានថ្វាយព្រះកិត្តិយសដល់ព្រះជាម្ចាស់ ហើយក៏មិនបានអរព្រះគុណទ្រង់ ក្នុងលក្ខណៈដែលពួកគេគួរធ្វើទេ។ ចិត្តដ៏ភ្លីភ្លើរបស់ពួកគេបានធ្លាក់ក្នុងសេចក្តីងងឹត ហើយពួកគេក៏បាន «បំផ្លាស់សិរីល្អនៃព្រះដែលមិនចេះខូច ឲ្យទៅជារូប មើលទៅដូចជាមនុស្ស ដែលតែងតែខូចវិញ ហើយដូចជាសត្វស្លាប សត្វជើង៤ និងសត្វលូនវារដែរ» (ខ២៣)។ នោះពិតជាការពណ៌នាដ៏គួរឲ្យស្អប់ខ្ពើមណាស់មែនទេ? ក្នុងការដែលមនុស្សលោករាប់ព្រះអាទិកររបស់ខ្លួន ដោយសម្រេចថារូបចម្លាក់ដែលធ្វើមកពីឈើ មកពីដែកទៅជាសត្វកង្កែប ឬក៏សត្វចាប ក៏ដូចជាពី*ខ្លួនឯង*ថា មានសិរីល្អលើសទ្រង់ អាចផ្តល់នូវការស្កប់ស្កល់លើសទ្រង់ ហើយក៏មានតម្លៃលើសទ្រង់ នោះគឺជាចំណុចដ៏ខ្ពស់បំផុតនៃការប្រមាថ និងការបះបោរទាស់ប្រឆាំងនឹងព្រះជាម្ចាស់ហើយ។ វាគឺជាឫសគល់ និងចំណុចស្នូលនៃអំពើបាប លទ្ធផលរបស់វាគ្មានអ្វីក្រៅពីរឿងដ៏សែនអាក្រក់នោះទេ។

ស្ទើរតែគ្រប់ចំណុចនៃបីជំពូកបន្ទាប់ សាវ័ក ប៉ុល ច្របាច់ចំណុចនេះ ដោយចោទប្រកាន់ថាមនុស្សគ្រប់គ្នាគឺជាអ្នកមានបាបទាស់ប្រឆាំងនឹងព្រះជាម្ចាស់។ ក្នុងជំពូកមួយ គាត់បានផ្តោតលើសាសន៍ដទៃ

ហើយបន្ទាប់មកក្នុងជំពូកពីរ គាត់បានបង្វែរទៅកាន់សាសន៍យូដាយ៉ាងខ្លាំង។ វាហាក់បីដូចជាថាសាវ័ក ប៉ុល ដឹងថាសាសន៍យូដាដែលចាត់ទុកខ្លួនឯងថាសុចរិតបានទះដៃយ៉ាងឮៗលើការស្ដីបន្ទោសរបស់គាត់ទៅលើសាសន៍ដទៃ ដូច្នេះគាត់ក៏បានវិលជុំលើការកាត់ស្រាយក្នុង ២:១ ហើយចង្អុលម្រាមដៃដែលកំពុងចោទប្រកាន់របស់គាត់ទៅឯអ្នកទះដៃនោះថា៖ «ដូច្នេះ ឱ*មនុស្ស*អើយ អស់អ្នកណាដែលថ្កោលទោសគេ នោះគ្មានសេចក្ដីដោះសាចំពោះខ្លួនឡើយ!» គាត់បានមានប្រសាសន៍ថា ដូចទៅនឹងសាសន៍ដទៃ នោះសាសន៍យូដាក៏បានប្រព្រឹត្តល្មើសប្រឆាំងនឹងក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ ហើយក៏ស្ថិតក្រោមការថ្កោលទោសរបស់ព្រះផងដែរ។

ពេលដល់ពាក់កណ្ដាលនៃជំពូកបី សាវ័ក ប៉ុល ក៏បានចោទប្រកាន់មនុស្សគ្រប់គ្នាក្នុងពិភពលោកនេះ ដែលបានបះបោរទាស់ប្រឆាំងនឹងព្រះជាម្ចាស់។ «យើងខ្ញុំបានចោទប្រកាន់រួចហើយថា ទោះទាំងសាសន៍យូដា និងសាសន៍ក្រេកផង សុទ្ធតែនៅក្រោមអំពើបាប» (ខ៩)។ ហើយសេចក្ដីសន្និដ្ឋានដែលគួរឲ្យម៉ឺងម៉ាត់របស់គាត់គឺថា នៅពេលដែលយើងឈរនៅមុខព្រះភក្ត្ររបស់ព្រះជាម្ចាស់ដែលជាអង្គជំនុំជម្រះ នោះគ្រប់បបូរមាត់នឹងនៅស្ងៀមជាមិនខាន។ គ្មានអ្នកណានឹងតវ៉ាទេ។ ហើយក៏នឹងមិនមានការលេចចេញឡើងនូវលេសណាមួយដែរ។ ផែនដីទាំងមូល—សាសន៍យូដា សាសន៍ដទៃ និងយើងគ្រប់គ្នាទាំងអស់—នឹងត្រូវឆ្លើយរៀបរាប់ប្រាប់ទាំងស្រុងទៅកាន់

9Marks Online PDF

ព្រះជាម្ចាស់ (ខ១៩)។

តាមពិតទៅ បើនិយាយឲ្យតឹងតែង ចំណុចពីរដំបូងមិនមែនជាដំណឹងល្អទាល់តែសោះ។ តាមពិត វាជាដំណឹងដ៏*អាក្រក់*វិញ។ ត្រង់ថា ខ្ញុំបានបះបោរទាស់ប្រឆាំងនឹងព្រះអាទិករដ៏បរិសុទ្ធ ហើយក៏ជាព្រះដែលនឹងជំនុំជម្រះ នោះមិនមែនជាគំនិតដែលធ្វើឲ្យខ្ញុំសប្បាយចិត្តនោះទេ។ ប៉ុន្តែ វាគឺជាចំណុចដ៏សំខាន់មួយ ពីព្រោះវារៀបចំផ្លូវសម្រាប់ដំណឹងល្អ។ ប្រសិនបើលោកអ្នកគិតអំពីវា នោះវាសមហេតុផលណាស់។ ក្នុងការមានបុគ្គលណាម្នាក់និយាយមកកាន់លោកអ្នកថា «ខ្ញុំកំពុងតែមក ដើម្បីសង្គ្រោះអ្នក!» គឺតាមពិតទៅមិនមែនជាដំណឹងល្អនោះទេ លុះត្រាតែលោកអ្នកជឿថា ខ្លួនក៏ពិតជាត្រូវការមានអ្នកមកជួយសង្គ្រោះមែនដែរ។

*ទី៣ សាវ័ក ប៉ុល មានប្រសាសន៍ថា ដំណោះស្រាយរបស់ព្រះជាម្ចាស់ចំពោះអំពើបាបរបស់មនុស្សលោកគឺ យញ្ញបូជានៃការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ។* បន្ទាប់ពីគាត់បានលើកឡើងអំពីដំណឹងអាក្រក់នៃស្ថានភាពដ៏ពិបាក ដែលយើងកំពុងតែប្រឈមមុខ ក្នុងនាមជាមនុស្សមានបាប ចំពោះព្រះជាម្ចាស់ដ៏សុចរិតរបស់យើង នោះសាវ័ក ប៉ុល ក៏បែរទៅកាន់ដំណឹងល្អ គឺដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។

«ប៉ុន្តែ ឥឡូវនេះ» សាវ័ក ប៉ុល បានលើកឡើង ទោះបើយើងមានអំពើបាបក៏ដោយ «ក្រៅពីក្រឹត្យវិន័យ សេចក្ដីសុចរិតផងព្រះ...បានលេច

9Marks Online PDF

ចេញមកហើយ» (៣:២១)។ បើនិយាយម្យ៉ាងវិញទៀតទៅ មានផ្លូវសម្រាប់មនុស្សក្នុងការឲ្យពួកគាត់ទទួលបានការរាប់ជាសុចរិតនៅចំពោះព្រះជាម្ចាស់ជាជាងទុច្ចរិត ក្នុងការប្រកាសថាពួកគាត់គ្មានទោសជាជាងមានទោស និងក្នុងការរាប់ជាសុចរិតជាជាងទទួលការថ្កោលទោស។ ហើយវាក៏មិនមានអ្វីទាក់ទងទៅនឹងការមានអាកប្បកិរិយាល្អប្រសើរ ឬក៏ការរស់នៅដែលសុចរិតជាងមុនដែរ។ វាកើតឡើង «ក្រៅពីក្រឹត្យវិន័យ»។

ដូច្នេះ តើការនោះកើតឡើងដោយរបៀបណា? សាវ័ក ប៉ុល បានលើកឡើងយ៉ាងសាមញ្ញក្នុងកណ្ឌគម្ពីរ រ៉ូម ៣:២៤។ ទោះបីយើងបានបះបោរទាស់ប្រឆាំងនឹងព្រះជាម្ចាស់ ហើយស្ថិតនៅក្នុងកាលៈទេសៈដែលគ្មានសង្ឃឹមក៏ដោយ ក៏យើងនៅអាចទទួលបានការ «រាប់ជាសុចរិតទទេ ដោយសារសេចក្ដីប្រោសលោះ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ» (រ៉ូម ៣:២៤)។ តាមរយៈយញ្ញបូជានៃការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ—ដោយសារព្រះលោហិត និងព្រះជន្មរបស់ទ្រង់—នោះមនុស្សមានបាបអាចទទួលបានសេចក្តីសង្គ្រោះរួចផុតពីការថ្កោលទោសនៃអំពើបាបដែលយើងស័ក្តិសមនឹងទទួល។

ប៉ុន្តែ ក៏នៅមានសំណួរមួយទៀតដែលសាវ័ក ប៉ុល បានឆ្លើយផងដែរ។ តើការនោះជាដំណឹងល្អសម្រាប់ខ្ញុំដោយរបៀបណាទៅ? តើខ្ញុំធ្វើដូចម្តេច ដើម្បីឲ្យទទួលបានការរាប់បញ្ចូលក្នុងសេចក្តីសង្គ្រោះនេះដែលបានសន្យាឡើង?

9Marks Online PDF

*នៅចុងបញ្ចប់ សាវ័ក ប៉ុល ក៏បានប្រាប់មិត្តអ្នកអានរបស់គាត់អំពីរបៀបដែលពួកគាត់អាចទទួលបានការរាប់បញ្ចូលក្នុងសេចក្តីសង្គ្រោះមួយនេះ។* នោះគឺជាអ្វីដែលគាត់បានសរសេរនៅចុងបញ្ចប់នៃជំពូកទី៣ ហើយឆ្លងចូលជំពូកទី៤។ សេចក្ដីសង្គ្រោះដែលព្រះជាម្ចាស់បានប្រទានឲ្យកើតឡើងបាន «ដោយសារជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទ» ហើយការនោះគឺ «សម្រាប់គ្រប់អស់អ្នកណាដែលជឿ» (៣:២២)។ ដូច្នេះ តើសេចក្ដីសង្គ្រោះនេះក្លាយជាដំណឹងល្អសម្រាប់ខ្ញុំ មិនមែនគ្រាន់តែសម្រាប់អ្នកដទៃ ដោយរបៀបណា? តើខ្ញុំគួរធ្វើដូចម្ដេច ដើម្បីឲ្យទទួលបានការរាប់បញ្ចូលក្នុងវាបាន? គឺតាមរយៈការជឿដល់ព្រះយេស៊ូវគ្រីស្ទ។ តាមរយៈការជឿទុកចិត្តលើព្រះអង្គ មិនមែនលើអ្នកណាផ្សេងទៀតក្នុងការសង្គ្រោះខ្ញុំ។ «តែចំណែកអ្នកដែលមិនធ្វើការសោះ គឺគ្រាន់តែជឿដល់ព្រះអង្គ ដែលទ្រង់ប្រោសឲ្យមនុស្សទមិលល្មើសបានសុចរិត» សាវ័ក ប៉ុល បានពន្យល់ថា «ជំនឿរបស់អ្នកនោះបានរាប់ទុកជាសេចក្ដីសុចរិតវិញ» (៤:៥)។

**សំណួរដ៏សំខាន់៤យ៉ាង**

មកដល់ពេលនេះ បន្ទាប់ពីបានមើលការវែកញែករបស់សាវ័ក ប៉ុល នៅក្នុងកណ្ឌគម្ពីរ រ៉ូម ១-៤ យើងអាចឃើញថា ក្នុងចំណុចស្នូលនៃការអះអាងរបស់គាត់អំពីដំណឹងល្អ គឺគាត់បានផ្ដល់ជូននូវចម្លើយ៤យ៉ាង ទាក់ទងនឹងសំណួរដ៏សំខាន់ៗ៖

១. តើអ្នកណាជាអ្នកបង្កើតយើង ហើយតើយើងឆ្លើយតបទៅកាន់

អ្នកណាសម្រាប់ទង្វើរបស់យើងនៅក្នុងជីវិតនេះ?

២. តើអ្វីទៅជាបញ្ហារបស់យើង? និយាយម្យ៉ាងវិញទៀតទៅ តើយើងកំពុងតែមានកំហុសអ្វី ហើយហេតុអ្វី?

៣. តើអ្វីទៅជាដំណោះស្រាយរបស់ព្រះជាម្ចាស់សម្រាប់បញ្ហានោះ? តើទ្រង់បានធ្វើអ្វី ដើម្បីសង្គ្រោះយើងចេញពីបញ្ហានោះ?

៤. តើខ្ញុំ—ផ្ទាល់ ឥឡូវនេះ និងនៅពេលនេះ—អាចទទួលបានការរាប់បញ្ចូលក្នុងសេចក្ដីសង្គ្រោះនោះដោយរបៀបណា? តើសេចក្ដីសង្គ្រោះនេះក្លាយជាដំណឹងល្អសម្រាប់ខ្ញុំ មិនមែនគ្រាន់តែសម្រាប់អ្នកដទៃ ដោយរបៀបណា?

យើងអាចសង្ខេបចំណុចចម្បងៗទាំងបួននោះដូចនេះ៖ ព្រះជាម្ចាស់ មនុស្ស ព្រះគ្រីស្ទ និងការឆ្លើយតប។

ពិតណាស់! សាវ័ក ប៉ុល បានបន្ដលាតត្រដាងនូវសេចក្ដីសន្យាជាច្រើនទៀត ដែលព្រះជាម្ចាស់បានប្រទានមកអស់អ្នកដែលទទួលបានសេចក្ដីសង្គ្រោះក្នុងព្រះគ្រីស្ទ ហើយវាក៏ស័ក្ដិសមផងដែរថា សេចក្ដីសន្យាជាច្រើននោះក៏យើងអាចរាប់វាជាផ្នែកខ្លះៗនៃដំណឹងល្អរបស់គ្រីស្ទបរិស័ទដែរ—ពោលគឺដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ ប៉ុន្ដែ វាសំខាន់ណាស់ដែលយើងត្រូវយល់ ចាប់តាំងពីដំបូងថា សេចក្ដីសន្យាដ៏ល្អប្រសើរទាំងនោះគឺអាស្រ័យទៅលើ ហើយក៏កើតចេញពីចំណុចដើម និងប្រភពនៃដំណឹងល្អរបស់គ្រីស្ទបរិស័ទ។ សេចក្ដីសន្យាទាំងនោះកើតឡើងតែចំពោះអស់អ្នកដែលទទួលបានការអត់ទោសចេញពីអំពើបាប តាមរយៈជំនឿលើការឆ្កាង និងការមានព្រះជន្មរស់ឡើង

9Marks Online PDF

វិញរបស់ព្រះគ្រីស្ទប៉ុណ្ណោះ។ នោះឯងជាមូលហេតុដែលសាវ័ក ប៉ុល ចាប់ផ្តើមនៅទីនោះ នៅពេលដែលគាត់បានបង្ហាញអំពីចំណុចស្នូល នៃដំណឹងល្អ—សេចក្តីពិតដ៏សំខាន់៤យ៉ាងនេះ។

## ដំណឹងល្អនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដោយទៀកពីកណ្ឌគម្ពីររ៉ូម

មិនមែនតែសាវ័ក ប៉ុល ទេដែលបានធ្វើបែបនោះ។ ខណៈពេលដែលខ្ញុំអានការនិពន្ធរបស់ពួកសាវ័ក ពាសពេញព្រះគម្ពីរសញ្ញាថ្មី សំណួរទាំងបួននោះគឺជាអ្វីដែលខ្ញុំឃើញពួកគាត់ឆ្លើយម្តងហើយម្តងទៀត។ មិនថាពួកគាត់បានលើកឡើងអ្វីផ្សេងទៀតក៏ដោយ ក៏ទាំងនេះគឺជាចំណុចស្នូលនៃបទបង្ហាញរបស់ពួកគាត់អំពីដំណឹងល្អដែរ។ បរិបទមានការប្រែប្រួល ជ្រុងជ្រោយមានការផ្លាស់ប្រែ ពាក្យពេចន៍មានការផ្លាស់ប្តូរ ហើយរបៀបក៏មានការប្រួលប្រែ ប៉ុន្តែមិនថាក្នុងរបៀបណា ឬក៏ផ្លូវណាក៏ដោយក៏គ្រីស្ទបរិស័ទជំនាន់ដំបូងតែងតែបានលើកឡើងអំពីចំណោចទាំង៤នេះ៖ យើងត្រូវឆ្លើយតបទៅកាន់ព្រះជាម្ចាស់ ដែលបានបង្កើតយើងមក សម្រាប់ទង្វើរបស់យើងនៅក្នុងជីវិតនេះ។ យើងបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះអង្គនេះ ហើយក៏នឹងត្រូវទទួលការជំនុំជម្រះដែរ។ *ប៉ុន្តែ* ព្រះជាម្ចាស់បានអន្តរាគមន៍ក្នុងព្រះយេស៊ូវគ្រីស្ទ ដើម្បីសង្គ្រោះយើង ហើយយើងទទួលយកសេចក្តីសង្គ្រោះតាមរយៈការកែប្រែចិត្តចេញពីអំពើបាប និងការមានជំនឿលើព្រះយេស៊ូវ។

ព្រះជាម្ចាស់។ មនុស្ស។ ព្រះគ្រីស្ទ។ ការឆ្លើយតប។

តោះ! ចូរយើងនាំគ្នាមើលខគម្ពីរផ្សេងៗទៀតក្នុងព្រះគម្ពីរសញ្ញាថ្មី

9Marks Online PDF

ដែលបានលើកឡើងជាសង្ខេបអំពីដំណឹងល្អរបស់ព្រះយេស៊ូវ។ ចូរយើងចាប់ដើមដោយមើលពាក្យពេចន៍ដ៏ល្បីល្បាញរបស់សាវ័ក ប៉ុល នៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១៥៖

> “បងប្អូនអើយ! ខ្ញុំចង់ប្រាប់ឲ្យអ្នករាល់គ្នាដឹងពីដំណឹងល្អ ដែលខ្ញុំបានផ្សាយរួចមកហើយ ជាដំណឹងដែលអ្នករាល់គ្នា បានទទួល ក៏ឈរជាប់ក្នុងនោះផង អ្នករាល់គ្នាកំពុងតែបាន សង្គ្រោះ ដោយសារដំណឹងល្អនោះផង គឺបើសិនជាកាន់ខ្ជាប់ តាមព្រះបន្ទូល ដែលខ្ញុំបានថ្លែងប្រាប់មក លើកតែអ្នករាល់គ្នា បានជឿ ដោយឥតបើគិត ដ្បិតមុនដំបូង ខ្ញុំបានប្រាប់មកអ្នក រាល់គ្នា តាមសេចក្ដីដែលខ្ញុំបានទទួលដែរ គឺថាព្រះគ្រីស្ទបាន សុគត ដោយព្រោះបាបរបស់យើងរាល់គ្នា តាមបទគម្ពីរ ហើយ ថា ទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ រួចដល់ថ្ងៃទី៣ នោះទ្រង់មានព្រះជន្ម រស់ឡើងវិញ ក៏តាមបទគម្ពីរ ហើយថា ទ្រង់បានលេចមកឲ្យកេផាសឃើញ រួចដល់ពួក១២នាក់ដែរ” (១ ៥)។

តើលោកអ្នកឃើញរចនាសម្ពន្ធដ៏សំខាន់នៅទីនេះដែរឬទេ? សាវ័ក ប៉ុល មិនបានលើកឡើងយ៉ាងក្បោះក្បាយដូចដែលគាត់បានធ្វើនៅក្នុងកណ្ឌគម្ពីរ រ៉ូម ជំពូក១-៤ ប៉ុន្តែគម្រោងទម្រង់ចម្បងនៅច្បាស់លាស់ដដែល។ មនុស្សលោកកំពុងតែមានបញ្ហា បានធ្លាក់ក្នុង “បាបរបស់យើងរាល់គ្នា” ហើយស្ថិតក្នុងតម្រូវការនៃការ “កំពុងតែបានសង្គ្រោះ” (ច្បាស់ណាស់ ទោះបើមិនបានលើកឡើងយ៉ាងចំៗ៖ ពីការជំនុំជម្រះ

របស់ព្រះជាម្ចាស់)។ ប៉ុន្តែ សេចក្តីសង្គ្រោះកើតឡើងក្នុងការនេះ៖ «ព្រះគ្រីស្ទបានសុគត ដោយព្រោះបាបរបស់យើងរាល់គ្នា...ទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ...ទ្រង់មានព្រះជន្មរស់ឡើងវិញ»។ ហើយទាំងអស់នេះកើតឡើងបានតាមរយៈការ «កាន់ខ្ជាប់តាមព្រះបន្ទូល ដែលខ្ញុំបានថ្លែងប្រាប់មក» តាមរយៈការជឿដ៏ពិត មិនមែនដោយឥតបើគិត។ ដូច្នេះ នេះគឺជាចំណុច៖ ព្រះជាម្ចាស់ មនុស្ស ព្រះគ្រីស្ទ ការឆ្លើយតប។

សូម្បីតែនៅក្នុងសេចក្តីអត្ថាធិប្បាយ ដែលបានសរសេរចុះនៅក្នុងកណ្ឌគម្ពីរកិច្ចការ ក៏យើងឃើញរចនាសម្ពន្ធដ៏សំខាន់នៃដំណឹងល្អនេះយ៉ាងច្បាស់លាស់ដែរ។ នៅពេលដែលសាវ័ក ពេត្រុស ប្រាប់មនុស្សម្នានៅថ្ងៃបុណ្យទី៥០ អំពីអ្វីដែលពួកគាត់គួរធ្វើក្នុងការឆ្លើយតបចំពោះការប្រកាសរបស់គាត់អំពីការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ គាត់បានលើកឡើងថា «ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ប្រយោជន៍ឲ្យបានរួចពីបាប» (កិច្ចការ ២:៣៨)។ ជាថ្មីម្តងទៀត ការអំពាវនាវរបស់សាវ័ក ពេត្រុស ក៏មិនមានការពន្យល់យ៉ាងក្បោះក្បាយផងដែរ ហើយយើងក៏ឃើញម្តងទៀតថា ការកាត់ក្តីរបស់ព្រះជាម្ចាស់ក៏មិនសូវជាច្បាស់លាស់ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏នៅតែមានផងដែរ។ បញ្ហា៖ លោកអ្នកត្រូវការព្រះជាម្ចាស់អត់ទោសអំពើបាបរបស់ខ្លួន។ ដំណោះស្រាយ៖ ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ដែលសាវ័ក ពេត្រុស បានលើកឡើងយ៉ាង

9Marks Online PDF

ក្បោះក្បាយរួចហើយនៅក្នុងសេចក្ដីអធិប្បាយរបស់គាត់។ ការឆ្លើយតបដ៏ត្រឹមត្រូវ៖ ការកែប្រែចិត្ត និងជំនឿ ដែលបង្ហាញជាភស្តុតាងតាមរយៈទង្វើនៃការធ្វើពិធីជ្រមុជទឹក។

ក្នុងសេចក្ដីអធិប្បាយមួយផ្សេងទៀតរបស់សាវ័ក ពេត្រុស នៅក្នុងគម្ពីរ កិច្ចការ ៣:១៨-១៩ យើងក៏បានឃើញនូវសេចក្ដីពិតដ៏សំខាន់ទាំងបួនយ៉ាងនោះយ៉ាងច្បាស់ម្ដងទៀត៖

> ប៉ុន្តែ សេចក្ដីដែលព្រះបានប្រកាសប្រាប់ជាមុន ដោយសារមាត់នៃអស់ទាំងហោរារបស់ទ្រង់ ពីដំណើរព្រះគ្រីស្ទថា ទ្រង់ត្រូវរងទុក្ខលំបាក នោះព្រះទ្រង់ក៏បានសម្រេចតាមយ៉ាងដូច្នោះឯង ដូច្នេះ ចូរប្រែចិត្ត ហើយវិលមកចុះ ដើម្បីឲ្យបាបរបស់អ្នករាល់គ្នាបានលុបចេញ ប្រយោជន៍ឲ្យមានពេលលំហើយ មកពីចំពោះព្រះអម្ចាស់»។

បញ្ហា៖ លោកអ្នកត្រូវការឲ្យមានអ្នកសម្អាតអំពើបាបរបស់លោកអ្នកចោល ដើម្បីមិនឲ្យទទួលការជំនុំជម្រះពីព្រះជាម្ចាស់។ ដំណោះស្រាយ៖ ព្រះយេស៊ូវបានរងទុក្ខ។ ការឆ្លើយតប៖ ចូរកែប្រែចិត្ត ហើយបែរទៅរកព្រះជាម្ចាស់តាមរយៈជំនឿចុះ។

ឬក៏ពិចារណាលើការអធិប្បាយរបស់សាវ័ក ពេត្រុស អំពីដំណឹងល្អទៅកាន់លោក កូនេលាស និងគ្រួសាររបស់គាត់៖

9Marks Online PDF

> “ឯយើងរាល់គ្នា ជាទីបន្ទាល់ពីអស់ទាំងការដែលទ្រង់ធ្វើ នៅក្នុងស្រុករបស់ពួកសាសន៍យូដា ហើយនៅក្រុងយេរូសាឡឹម គេបានធ្វើគុតទ្រង់ ដោយព្យួរនៅលើឈើ តែព្រះបានប្រោសឲ្យទ្រង់រស់ឡើងវិញនៅថ្ងៃទី៣...ពួកហោរាសុទ្ធតែធ្វើបន្ទាល់ពីទ្រង់ថា “អស់អ្នកណាដែលជឿដល់ទ្រង់ នោះបានរួចពីបាប ដោយសារព្រះនាមទ្រង់”» (កិច្ចការ ១០:៣៩ ៤២)។

ការអត់ទោសអំពើបាប តាមរយៈព្រះនាមនៃអង្គដែលត្រូវបានគេឆ្កាង ហើយក៏បានមានព្រះជន្មរស់ឡើងវិញ សម្រាប់អស់អ្នកណាដែលទទួលជឿ។

សាវ័ក ប៉ុល ក៏បានប្រកាសដំណឹងល្អដូចនោះនៅក្នុងកណ្ឌគម្ពីរកិច្ចការ ១៣៖

> “ដូច្នេះ អ្នករាល់គ្នា ជាបងប្អូនអើយសូមជ្រាបថា ដែលមានសេចក្តីប្រោសឲ្យរួចពីបាប បានប្រកាសប្រាប់ដល់អ្នករាល់គ្នានោះគឺដោយសារព្រះអង្គនោះឯង។ មួយទៀត ដោយសារទ្រង់អស់អ្នកណាដែលជឿ បានរាប់ជាសុចរិត រួចពីគ្រប់ការទាំងអស់ដែលពុំអាចនឹងបានរាប់ជាសុចរិត ដោយសារក្រឹត្យវិន័យលោកម៉ូសេបានឡើយ” (៣៨ ៣៩)។

ជាថ្មីម្តងទៀត រចនាសម្ពន្ធដែលយើងឃើញយ៉ាងច្បាស់លាស់គឺ៖ ព្រះជាម្ចាស់ មនុស្ស ព្រះគ្រីស្ទ និងការឆ្លើយតប។ លោកអ្នកត្រូវការឲ្យព្រះ

ជាម្ចាស់ប្រទាន «សេចក្តីប្រោសឲ្យរួចពីបាប»។ ការនោះកើតឡើង «ដោយសារ [ព្រះយេស៊ូវ]» ហើយក៏កើតឡើងចំពោះ «អស់អ្នកណាដែលជឿ» ដែរ។

## ការពន្យល់ចំណុចស្នូលនៃសេចក្តីពិតក្នុងរបៀបខុសៗគ្នា

ពិតណាស់! រចនាសម្ពន្ធនៃ ព្រះជាម្ចាស់ មនុស្ស ព្រះគ្រីស្ទ និងការឆ្លើយតប គឺមិនមែនជារូបមន្តនៃការដែលចំលងតាមគ្នាទាំងស្រុងទេ។ ពួកសាវ័កមិនចាំបាច់គូសសញ្ញាគ្រីសដូចជាបញ្ជីត្រួតពិនិត្យនៅពេលដែលពួកគាត់ប្រកាសដំណឹងល្អឡើយ។ អាស្រ័យទៅលើបរិបទ ពេលវេលាដែលពួកគាត់មានក្នុងការប្រកាស ហើយថាអ្នកណាជាអ្នកស្តាប់ពួកគាត់ ពួកគាត់ពន្យល់លើចំណុចទាំងបួននោះក្នុងពេលវេលាខុសៗគ្នា។ ពេលខ្លះ ពួកគាត់ទុកមួយឬពីរចំណុចជាលក្ខណៈបញ្ជិតបញ្ជៀងជាជាងនិយាយយ៉ាងច្បាស់លាស់—ជាពិសេសគឺថាយើងមានទំនួលខុសត្រូវចំពោះព្រះជាម្ចាស់ ហើយគឺពីព្រះអង្គដែលយើងត្រូវការអំណោយទាននៃការអត់ទោស។ ប៉ុន្តែ ជាថ្មីម្តងទៀត នេះគឺជាចំណុចដែលពួកសាសន៍យូដាមានការយល់ដឹងយ៉ាងជ្រាលជ្រៅក្នុងគំនិតរបស់ពួកគាត់រួចស្រេចទៅហើយ ដែលជារឿយៗពួកគាត់គឺជាអ្នកដែលពួកសាវ័កបានប្រកាសទៅកាន់។

មួយវិញសោត នៅពេលដែលសាវ័ក ប៉ុល មានប្រសាសន៍ទៅកាន់ក្រុមទស្សនវិទូដែលមិនជឿព្រះមួយក្រុមនៅឯទីផ្សារ គាត់បានចាប់ផ្តើមតាំងពីដើម ជាមួយនឹងព្រះជាម្ចាស់ផ្ទាល់។ ជារឿយៗ គេតែងលើក

9Marks Online PDF

ឡើងអំពីសេចក្តីអធិប្បាយរបស់សាវ័ក ប៉ុល នៅក្នុងកណ្ឌគម្ពីរ កិច្ចការ ជំពូក១៧ ថាជាគំរូក្នុងការប្រកាសដំណឹងល្អទៅកាន់ប្រពៃណីដែលមិនជឿលើព្រះ។ ប៉ុន្តែ មានចំណុចដែលគួរឲ្យចាប់អារម្មណ៍ ហើយក៏ប្លែកអំពីការអធិប្បាយនេះ។ ប្រសិនបើលោកអ្នកមើលដោយយកចិត្តទុកដាក់ នោះលោកអ្នកនឹងចាប់ផ្តើមឃើញថា សាវ័ក ប៉ុល ពិតជាមិនបានប្រកាសដំណឹងល្អអំពីព្រះគ្រីស្ទទាល់តែសោះ គឺគ្រាន់តែដំណឹងអាក្រក់ប៉ុណ្ណោះ!

គាត់បានចាប់ផ្តើមដូចនេះថា «ខ្ញុំនឹងប្រាប់ដល់អ្នករាល់គ្នាពីព្រះដែលអ្នករាល់គ្នាគោរពបូជា ដោយឥតស្គាល់នោះឯង»។ បន្ទាប់មកគាត់បានពន្យល់ទៅកាន់ពួកគាត់នៅក្នុងខ ២៤-២៨ ថាមានព្រះ ហើយព្រះនេះបានបង្កើតពិភពលោក ហើយថាព្រះអង្គបានត្រាស់ហៅឲ្យយើងថ្វាយបង្គំទ្រង់។ បន្ទាប់ពីគាត់បានបង្កើតមូលដ្ឋាននោះ គាត់ក៏បែរទៅកាន់ខ២៩ ដើម្បីពន្យល់អំពីផ្នត់គំនិតនៃអំពើបាប និងឫសគល់របស់វាក្នុងការថ្វាយបង្គំនូវអ្វីៗដែលព្រះជាម្ចាស់បានបង្កើតមក ជាជាងថ្វាយបង្គំព្រះអង្គផ្ទាល់ ហើយគាត់បានអះអាងថាព្រះជាម្ចាស់នឹងកាត់ទោសអ្នកស្តាប់គាត់តាមរយៈ «មនុស្សម្នាក់ ដែលទ្រង់បានតម្រូវរួចហើយ» គឺជាបុរសដែលព្រះជាម្ចាស់បានប្រោសឲ្យរស់ពីសុគតឡើងវិញ (ខ៣១)។

ហើយបន្ទាប់មក គាត់ក៏បានឈប់! សូមពិនិត្យមើលឲ្យបានប្រុងប្រយ័ត្ន។ មិនមានការលើកឡើងអំពីការអត់ទោស មិនមានការលើក

ឡើងអំពីឈើឆ្កាង ហើយក៏មិនមានការលើកឡើងអំពីសេចក្តីសន្យានៃការសង្គ្រោះ—គឺគ្រាន់តែមានការប្រកាសនៃការទាមទាររបស់ព្រះជាម្ចាស់ និងការប្រកាសអំពីការមានព្រះជន្មរស់ឡើងវិញ ទុកជាវត្តុតាងនៃការជំនុំជម្រះរបស់ទ្រង់ដែលនឹងមកដល់! សាវ័ក ប៉ុល មិនបានលើកឡើងអំពីព្រះនាមរបស់ព្រះយេស៊ូវនៅក្នុងបរិបទនេះផងទេ!

ដូច្នេះ តើមានអ្វីកំពុងកើតឡើងនៅត្រង់នេះ? តើសាវ័ក ប៉ុល *មិន*បានប្រកាសដំណឹងល្អនៅត្រង់នេះមែនឬ? តាមពិតទៅ ទេ គឺមិនមែននៅពេលនោះឡើយ។ មិនមានដំណឹងល្អទេនៅក្នុងការអធិប្បាយជាសាធារណៈរបស់គាត់នៅពេលនោះ។ ដំណឹងដែលសាវ័ក ប៉ុល ប្រកាស គឺជាដំណឹងអាក្រក់នៅពេលនោះ។ ប៉ុន្តែ សូមមើលនៅក្នុង ខ ៣២-៣៤ ដែលព្រះគម្ពីរបានលើកឡើងថា ពួកគាត់ចង់ស្តាប់សាវ័ក ប៉ុល ម្តងទៀត ហើយត្រង់ថានៅទីបំផុតមានអ្នកខ្លះបានទទួលជឿ។ តាមជាក់ស្តែងសាវ័ក ប៉ុល បានប្រកាសដំណឹង*ល្អ*—ត្រង់ថា មនុស្សមានបាបអាចទទួលបានការសង្គ្រោះចេញពីការជំនុំជម្រះដែលនឹងមកដល់—នៅពេលក្រោយទៀតទំនងជាសាធារណៈ ឬក៏ស្ងៀមស្ងាត់។

ដូចពួកសាវ័កផ្សេងៗទៀត សាវ័ក ប៉ុល ក៏បានប្រកាសអំពីចំណុចស្នូលនៃដំណឹងល្អយ៉ាងល្អឥតខ្ចោះក្នុងរបៀបខុសៗគ្នាដែរ។ ប៉ុន្តែចំណុចសំខាន់ដែលយើងគួរយល់គឺថា *មាន*ចំណុចស្នូលខ្លះៗអំពីដំណឹងល្អ ហើយតាមរយៈសេចក្តីអធិប្បាយ និងសំបុត្រផ្សេងទៀតដែលមានបន្សល់ទុកសម្រាប់យើងពិត នោះយើងមានចំណុចយ៉ាង

ច្បាស់លាស់អំពីចំណុចស្នូលទាំងនោះ។ នៅក្នុងកណ្ឌគម្ពីរ រ៉ូម នៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ក្នុងសេចក្តីអធិប្បាយនានាក្នុងកណ្ឌគម្ពីរកិច្ចការ និងពាសពេញព្រះគម្ពីរសញ្ញាថ្មី គ្រីស្ទបរិស័ទសម័យដំបូងបានរៀបចំការរចនានៃការប្រកាសដំណឹងល្អជុំវិញសេចក្តីពិតដ៏សំខាន់ៗមួយចំនួន។

ជាដំបូង ដំណឹងអាក្រក់៖ ព្រះជាម្ចាស់គឺជាអង្គកាត់ក្តីរបស់លោកអ្នក ហើយលោកអ្នកក៏បានប្រព្រឹត្តអំពើបាបទាស់ប្រឆាំងនឹងទ្រង់។ ហើយបន្ទាប់មកដំណឹងល្អ៖ ប៉ុន្តែព្រះយេស៊ូវបានសុគត ដើម្បីឲ្យមនុស្សមានបាបអាចទទួលបានការអត់ទោសរួចពីអំពើបាបរបស់ខ្លួនប្រសិនបើពួកគាត់កែប្រែចិត្ត ហើយទទួលជឿលើទ្រង់។

9Marks Online PDF

ជំពូកទី២

# ព្រះអាទិករដ៏សុចរិត

សូមអនុញ្ញាតឲ្យខ្ញុំណែនាំលោកអ្នកទៅកាន់ព្រះមួយអង្គ (សូមកត់សម្គាល់លើពាក្យ «មួយ»)

លោកអ្នកទំនងជាចង់ទម្លាក់សំឡេងរបស់ខ្លួនបន្តិចមុនយើងបន្តទៅមុខ។ ព្រះនោះទំនងជាកំពុងតែធំ។ លោកអ្នកដឹងហើយថា ព្រះនោះចាស់ហើយ ហើយព្រះនោះក៏មិនសូវយល់ ឬក៏ចូលចិត្ត «បែបថ្មី» នៃសម័យនេះ។ ថ្ងៃមាសរបស់ព្រះនោះ—គ្រាដែលព្រះនោះរៀបរាប់អំពីនៅពេលដែលលោកអ្នកពិតជាអាចនាំឲ្យព្រះនោះធ្វើអ្វីបាន—គឺជាពេលវេលាយូរណាស់ហើយ ស្ទើរតែមុនពេលយើងរាល់គ្នាកើតមកផង។ កាលនោះគឺជាពេលវេលាដែលមនុស្សលោកបានយកចិត្តទុកដាក់លើអ្វីដែលព្រះនោះគិត ហើយរាប់ព្រះនោះថាពិតជាសំខាន់ណាស់ក្នុងជីវិតរបស់ខ្លួន។

ពិតណាស់! ឥឡូវគ្រប់ទាំងអស់បានផ្លាស់ប្តូរ ហើយព្រះនោះ—បុគ្គលដែលគួរឲ្យអាណិត—ពិតជាមិនបានបត់បែនទាល់តែសោះ។ ជីវិតក៏បានបន្តទៅមុខ ហើយក៏បានហួសគាត់។ សព្វថ្ងៃនេះ គាត់ចំណាយពេលច្រើនលេងនៅសួនខាងក្រោយ។ ពេលខ្លះ ខ្ញុំទៅលេងគាត់នៅទីនោះ ហើយនៅទីនោះយើងអែនអន ដើរនិងនិយាយគ្នា

9Marks Online PDF

ខ្សឹបៗយ៉ាងស្រទន់នៅក្បែរគុម្ពផ្កាកុលាប. . . .

ទោះជាយ៉ាងណាក៏ដោយក៏នៅមានមនុស្សជាច្រើនចូលចិត្តគាត់ពេលមើលទៅ—ឬយ៉ាងហោចណាស់ក៏គាត់នៅអាចគ្រប់គ្រងលើប្រជាប្រិយភាពរបស់គាត់យ៉ាងខ្ពស់បានល្អដែរ។ ហើយលោកអ្នកក៏នឹងមានការភ្ញាក់ផ្អើលផងដែរ ទាក់ទងនឹងចំនួនមនុស្សដែលមកលេងនិងទូលសូមអ្វីពីគាត់ម្ដងម្កាល។ ប៉ុន្តែ ពិតណាស់ នោះមិនជាបញ្ហាអ្វីទេចំពោះគាត់។ គាត់នៅដើម្បីជួយ។

ពិតជាល្អមែន ការឆាប់ខឹងទាំងអស់ដែលលោកអ្នកអានពេលខ្លះនៅក្នុងព្រះគម្ពីររបស់ព្រះនោះ—ដែលលោកអ្នកដឹង ដូចជាឲ្យលេបមនុស្ស ទម្លាក់ភ្លើងមកលើទីក្រុងនានា រឿងពាក់ព័ន្ធដូចៗនោះ—ទាំងអស់ហាក់បីដូចជាលិចបាត់សន្សឹមៗក្នុងវ័យចំណាស់របស់ព្រះនោះ។ មកដល់ពេលនេះ ព្រះនោះគ្រាន់តែជាមិត្តភក្តិដែលមានចិត្តល្អម្នាក់មិនចាំបាច់មានការថែទាំខ្លាំងប៉ុន្មាន ហើយក៏ងាយនិយាយជាមួយផងដែរ—ជាពិសេសគឺដោយសារព្រះនោះស្ទើរតែមិននិយាយរកវិញ ហើយនៅពេលដែលព្រះនោះនិយាយរក ជារឿយៗគឺដើម្បីប្រាប់ខ្ញុំតាមរយៈចំណុច «សម្គាល់» ប្លែកបន្តិចថា អ្វីដែលខ្ញុំចង់ធ្វើដោយចាត់ថាសំខាន់ មិនអីទេចំពោះព្រះនោះ។ នេះពិតជាប្រភេទនៃមិត្តភក្តិដ៏ល្អមែន ពិតអត់?

តើលោកអ្នកដឹងទេថា អ្វីទៅជាចំណុចដ៏ល្អអំពីព្រះនោះ? ព្រះនោះមិនថ្កោលទោសខ្ញុំទេ។ មិនថាអ្វីទាល់តែសោះក៏ដោយ។ ពិតណាស់

9Marks Online PDF

ខ្ញុំដឹងថា នៅក្នុងជម្រៅចិត្តរបស់ព្រះនោះ ព្រះនោះក៏ចង់ឲ្យខ្ញុំល្អប្រសើរជាងមុនដែរ—ស្រឡាញ់ឲ្យច្រើន មិនសូវអាត្មានិយម និងចំណោចដូចនោះ—ប៉ុន្តែ គេប្រាកដនិយមព្រះនោះ។ ព្រះនោះដឹងថាខ្ញុំជាមនុស្ស ហើយមិនមានអ្នកណាល្អឥតខ្ចោះទេ។ ហើយខ្ញុំដឹងយ៉ាងប្រាកដថា ព្រះនោះមិនមានបញ្ហាទេជាមួយនឹងចំណោចនោះ។ ម្យ៉ាងទៀតការអត់ទោសឲ្យមនុស្សគឺជាការងាររបស់ព្រះនោះ។ នោះគឺជាអ្វីដែលព្រះនោះធ្វើ។ សរុបទៅ ព្រះនោះគឺជាសេចក្តីស្រឡាញ់ ត្រូវអត់? ហើយខ្ញុំចូលចិត្តគិតអំពីសេចក្តីស្រឡាញ់ថា «ការមិនចេះថ្កោលទោស ហើយចេះតែអត់ទោស»។ នេះគឺជាព្រះដែលខ្ញុំស្គាល់។ ហើយខ្ញុំក៏មិនចង់ឲ្យព្រះនោះមានលក្ខណៈផ្សេងទៀត ក្រៅពីនេះទេ។

ចាំមួយភ្លែតសិន ឥឡូវយើងអាចទៅបាន។ កុំបារម្ភអី យើងមិនចាំបាច់នៅយូរប៉ុន្មានទេ។ មែនហើយ។ សម្រាប់ពេលវេលាប៉ុន្មានដែលព្រះនោះទទួលបាន ព្រះនោះដឹងគុណគេ។

## ការប៉ាន់ស្មានអំពីព្រះជាម្ចាស់

បាន បាន។ ឧទាហរណ៍នៃប្រជាប្រិយភាពបន្តិចនោះហាក់បីដូចជាគួរឲ្យអស់សំណើចណាស់។ ប៉ុន្តែ ខ្ញុំឆ្ងល់ថា ប្រសិនបើវាពិតជាឆ្ងាយមែនពីអ្វីដែលមនុស្សជាច្រើននាក់ សូម្បីតែអស់អ្នកដែលរាប់ខ្លួនថាជាគ្រីស្ទបរិស័ទគិតអំពីព្រះជាម្ចាស់។ ពួកគេគិតថា ទាក់ទងនឹងចំណោចជាច្រើន ព្រះអង្គសប្បុរស សុភាពរាបសា ភាំងស្មារតី និងមានតម្រូវការបន្តិច ប៉ុន្តែគឺជាជីតាម្នាក់ដែលគួរឲ្យស្រឡាញ់ ដែលមានសេចក្តី

ប្រាថ្នា ប៉ុន្តែមិនមានការទាមទារ ហើយលោកអ្នកក៏អាចមិនអើពើអំពីទ្រង់បានដោយមានសុវត្ថិភាព ប្រសិនបើលោកអ្នកមិនមានពេលវេលាសម្រាប់ទ្រង់ ហើយក៏មានការយល់ដឹងយ៉ាងខ្លាំងត្រង់ថា មនុស្សអាចប្រព្រឹត្តខុសបាន—គឺពិតជាមានការយល់ដឹងខ្លាំងជាងយើងទាំងអស់គ្នាមែន។

នៅប្រទេសអាមេរិក ធ្លាប់មានពេលពីមុនដែរ សូម្បីតែអ្នកដែលមិនរាប់ខ្លួនថាជាគ្រីស្ទបរិស័ទក៏នៅមានការយល់ដឹងអំពីសេចក្តីបង្រៀននៃព្រះគម្ពីរអំពីព្រះជាម្ចាស់ និងលក្ខណសម្បត្តិរបស់ទ្រង់ដែរ។ វាជាចំណែកមួយនៃបរិយាកាសដែលមនុស្សបានដកដង្ហើម—គឺស្រដៀងគ្នាយ៉ាងខ្លាំងជាមួយនឹងពួកសាវ័ក និងពួកសាសន៍យូដារបស់ខ្លួន—លោកអ្នកធ្លាប់អាចធ្វើសេចក្តីប៉ាន់ស្មានមួយចំនួនបានអំពីអ្វីដែលមនុស្សម្នាបានដឹង នៅពេលដែលលោកអ្នកចែកចាយដំណឹងល្អទៅកាន់ពួកគាត់។

នោះលែងពិតទៀតហើយ យ៉ាងហោចណាស់នៅក្នុងភាគច្រើននៃផែនដីនេះ។ ខ្ញុំបានធំធាត់ឡើងនៅក្នុងភូមិដ៏តូចមួយ នៅឯរដ្ឋតិចសាស់ខាងកើត ហើយភាគច្រើនក្នុងការប្រាប់បុគ្គលណាម្នាក់អំពីដំណឹងល្អគឺស្មើនឹងការរៀបរាប់នូវសារមួយដែលពួកគាត់ធ្លាប់បានឮរាប់ពាន់ដងហើយ។ ទោះជាយ៉ាងណាក៏ដោយក៏វាជាពិភពលោកខុសគ្នាទាំងស្រុងតែម្តង នៅពេលដែលខ្ញុំបានចាប់ផ្តើមរៀននៅមហាវិទ្យាល័យនៅឯក្រុងញូវ ហេវិន រដ្ឋខូននិកទិកាត់ (New

Haven, Connecticut)។ ស្រាប់តែភ្លាមៗនោះ ខ្ញុំក៏ចាប់ផ្ដើមរស់នៅក្បែរអស់អ្នកដែលមិនបានធំធាត់ឡើងដោយឮអំពីព្រះជាម្ចាស់ ហើយពួកគាត់ក៏ចាប់ផ្ដើមប្រកែកគ្នាជាមួយខ្ញុំទាក់ទងនឹងផ្នត់គំនិតនោះភ្លាមតែម្ដង។ ខ្ញុំចាំអំពីពេលវេលាដំបូងដែលខ្ញុំបានជួបបុគ្គលម្នាក់ដែលបានឆ្លើយតបនឹងការលើកឡើងរបស់ខ្ញុំអំពីព្រះជាម្ចាស់ថា «ឯងនិយាយលេងជាមួយខ្ញុំមែនឬ ឯងពិតជាជឿលើព្រះនោះមែន?» ហើយបន្ទាប់មកគាត់ក៏បានសើច។

ព្រឹត្តិការណ៍ដូចនោះបានកើតឡើងបួនដប់ដងថែមទៀតក្នុងអំឡុងប៉ុន្មានឆ្នាំទៅមុខ ហើយមិនយូរមិនឆាប់ខ្ញុំក៏គ្រាន់តែរៀននិយាយថា «បាទ មែនហើយ»។ ប៉ុន្តែ ខ្ញុំក៏បានរៀនយ៉ាងឆាប់រហ័សផងដែរថា ខ្ញុំក៏មិនអាចធ្វើសេចក្ដីប៉ាន់ស្មានអំពីអ្វីដែលមនុស្សដឹងអំពីព្រះជាម្ចាស់បានឡើយ។ បច្ចុប្បន្នកាលនេះ ប្រសិនបើខ្ញុំនឹងប្រកាសដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទ គឺខ្ញុំត្រូវចាប់ផ្ដើមពីដើមដំបូងតែម្ដង—គឺនៅឯព្រះជាម្ចាស់។

ពិតណាស់! លោកអ្នកអាច (ហើយក៏គួរ!) ចំណាយពេលពេញមួយជីវិតក្នុងការសិក្សាអំពីអ្វីដែលព្រះជាម្ចាស់បានបើកសម្ដែងមកកាន់យើងអំពីទ្រង់ផ្ទាល់ ហើយលោកអ្នកក៏មិនចាំបាច់រៀបរាប់គ្រប់ចំណុចដែលលោកអ្នកដឹងអំពីព្រះជាម្ចាស់ ដើម្បីប្រកាសដំណឹងល្អឲ្យបានត្រឹមត្រូវដែរ។ ប៉ុន្តែ មានសេចក្ដីពិតមូលដ្ឋានមួយចំនួនអំពីព្រះជាម្ចាស់ដែលបុគ្គលម្នាក់ត្រូវតែដឹង ដើម្បីឲ្យអាចយល់បានអំពីអ្វី

ដែលកំពុងកើតឡើងក្នុងដំណឹងល្អរបស់គ្រីស្ទបរិស័ទ។ សូមគិតអំពីវាហាក់បីដូចជាថាដំណឹងដ៏ល្អនៅក្រោយដំណឹងដ៏អាក្រក់ ដែលនៅពីក្រោយដំណឹងល្អ! មានចំណុចសម្នូលដំបូងពីរយ៉ាងដែលយើងត្រូវតែរៀបរាប់ឲ្យបានច្បាស់លាស់ចាប់តាំងពីដើម—គឺថាព្រះជាម្ចាស់គឺជាព្រះអាទិករ ហើយព្រះអង្គបរិសុទ្ធ និងសុចរិត។

## ព្រះអាទិករ

ចំណុចផ្ដើមនៃសាររបស់គ្រីស្ទបរិស័ទ—ពិតណាស់ គឺចំណុចផ្ដើមនៃព្រះគម្ពីររបស់គ្រីស្ទបរិស័ទ—គឺថា «ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី»។ គ្រប់ទាំងអស់ចាប់ផ្ដើមពីចំណុចនោះ ហើយដូចនឹងគ្រាប់ព្រួញភ្លើងមួយដែលគេបាញ់ចេញពីធ្នូដែលមានការតម្រង់មិនល្អ ប្រសិនបើលោកអ្នកយល់ខុសអំពីចំណុចនោះ  នោះគ្រប់អ្វីៗទាំងអស់ដែលកើតឡើងជាបន្តបន្ទាប់ក៏នឹងខុសដែរ។

កណ្ឌគម្ពីរលោកុប្បត្តិបានចាប់ផ្ដើមដោយរៀបរាប់អំពីដំណើររឿងនៃការដែលព្រះជាម្ចាស់បង្កើតពិភពលោក៖ ភ្នំនិងជ្រលងភ្នំ សត្វនិងត្រី បក្សាបក្សីនិងសត្វលូនវារ និងគ្រប់អ្វីៗទាំងអស់។ ព្រះជាម្ចាស់ក៏បានបង្កើតចក្រវាឡទាំងមូលដែរ៖ ផ្កាយនិងព្រះច័ន្ទ ភពនិងកញ្ចុំផ្កាយនានា។ ទាំងអស់នោះបានកើតឡើងតាមរយៈព្រះបន្ទូលដែលទ្រង់បានមានបន្ទូល ហើយគ្រប់ទាំងអស់ក៏បានកើតឡើងចេញពីភាពសូន្យឈឹងផងដែរ។ ព្រះជាម្ចាស់មិនបានយកសម្ភារៈណាមួយដែលមានតាំងពីយូរណាស់មកហើយ ហើយវាហាក់បីដូចជាដីឥដ្ឋឲ្យក្លាយ

9Marks Online PDF

ទៅជារបស់ផ្សេងៗ ដែលយើងឃើញនៅលើពិភពលោកនេះនោះទេ។ ទេ! កណ្ឌគម្ពីរលោកុប្បត្តិប្រាប់យើងថា ព្រះអង្គមានព្រះបន្ទូល ហើយវាក៏បានកើតឡើង។ “ចូរឲ្យមានពន្លឺឡើង!” ព្រះអង្គបានមានបន្ទូល។ ហើយពន្លឺក៏មានឡើង។

មានខគម្ពីរជាច្រើនប្រាប់យើងអំពីរបៀបដែលអ្វីៗ ដែលព្រះអង្គបានបង្កើតមក ធ្វើជាស្មរបន្ទាល់ទៅកាន់សិរីល្អ និងអំណាចព្រះចេស្ដារបស់ទ្រង់។ កណ្ឌគម្ពីរ ទំនុកតម្កើង ១៩:១ បានលើកឡើង “ផ្ទៃមេឃសម្ដែងពីសិរីល្អនៃព្រះ ហើយលំហអាកាសក៏បង្ហាញការ ដែលព្រះហស្តទ្រង់ធ្វើ”។ សាវ័ក ប៉ុល បានមានប្រសាសន៍នៅក្នុងកណ្ឌគម្ពីររ៉ូម ១:២០ ថា “ដ្បិតអ្វីៗ របស់ទ្រង់ ដែលរកមើលមិនឃើញ តាំងពីកំណើតលោកីយ៍មក ទោះទាំងព្រះចេស្ដាដ៏នៅអស់កល្បជានិច្ច និងនិស្ស័យជាព្រះរបស់ទ្រង់ នោះឃើញច្បាស់វិញ ដោយពិចារណាយល់របស់ទាំងប៉ុន្មាន ដែលទ្រង់បានបង្កើតមក”។ លោកអ្នកនឹងយល់អត្ថន័យនេះ ប្រសិនបើលោកអ្នកធ្លាប់ឈរនៅមាត់ជ្រោះភ្នំ ហើយឃើញចាបហើរឆាបក្រោមលោកអ្នក និងពពកលាតត្រដាងពីលើក្បាលលោកអ្នក ឬក៏ថាប្រសិនបើលោកអ្នកធ្លាប់ឈរនៅទីវាល ហើយមានអារម្មណ៍ភ័យខ្លាចខណៈពេលដែលលោកអ្នកឃើញព្យុះហៀបនឹងកើតឡើងនៅចុងមេឃ។ មានចំណុចអំពីភាពអស្ចារ្យនៃអ្វីដែលព្រះជាម្ចាស់បានបង្កើតមកស្រែកដាក់ដួងចិត្តមនុស្សយើងថា “មិនមានតែឯងនោះទេ!”

ដំណើររឿងនៃការបង្កើតក្នុងកណ្ឌគម្ពីរលោកុប្បត្តិលាតសន្ធឹងទាំងក្នុងទិដ្ឋភាព និងភាពសំខាន់ពីមួយថ្ងៃទៅមួយថ្ងៃ។ ដំបូងគឺការបង្កើតពន្លឺ បន្ទាប់មកគឺដី បន្ទាប់មកទៀតព្រះច័ន្ទ និងព្រះអាទិត្យ ហើយបក្សាបក្សី ត្រី និងសត្វ ហើយជាចុងក្រោយនៅចំណុចកំពូលលម្អបំផុតនៃការបង្កើតរបស់ព្រះជាម្ចាស់—បុរស និងស្ត្រី។

> “ទ្រង់ក៏មានព្រះបន្ទូលថា “ចូរយើងធ្វើមនុស្សឲ្យដូចជារូបយើងឲ្យមានភាពដូចយើង ហើយឲ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងសត្វជើង៤ដែលនៅលើផែនដីទាំងមូលព្រមទាំងសត្វលូនវារដែលវារនៅលើផែនដីផង”»។ ដូច្នេះ ព្រះអង្គបានបង្កើតមនុស្សក្នុងរូបអង្គទ្រង់ក្នុងភាពដូចទ្រង់ នោះព្រះអង្គក៏បានបង្កើតមនុស្ស ព្រះអង្គបានបង្កើតមនុស្សប្រុសនិងមនុស្សស្រី» (លោកុប្បត្តិ ១:២៦ ២៧)។

មិនថាលោកអ្នកគិតអ្វីផ្សេងទៀតអំពីដំណើររឿងនៃការបង្កើតលទ្ធផលនៃអំណះអំណាងនេះ—ថាព្រះជាម្ចាស់បង្កើតពិភពលោកនេះ ហើយជាពិសេសនោះគឺថាព្រះអង្គបង្កើតលោកអ្នក—គឺធំសម្បើមណាស់។ ត្រង់ថាពិភពលោកនេះគឺមិនមែនជាចំណាចដ៏មហិមានោះទេប៉ុន្តែថាវាកើតចេញពីព្រះមត្តលុង្គ១ ព្រះបន្ទូល និងព្រះហស្តរបស់ព្រះអង្គគឺជាគំនិតបដិវត្តមួយ ជាពិសេសនៅបច្ចុប្បន្នកាល។ ផ្ទុយពីភាពសូន្យឈឹងដែលគ្រប់គ្រងលើការគិតជាច្រើនរបស់មនុស្សលោក នេះ

មានន័យថាគ្រប់អ្វីៗទាំងអស់ក្នុងចក្រវាឡមានគោលបំណង—ដែលមានរួមទាំងមនុស្សលោក។ យើងមិនមែនជាលទ្ធផលនៃភាពចៃដន្យ និងបន្លាស់ប្តូរដែលទាក់ទងនឹងហ្សែន ជាហ្សែនដែលមានការលាយឡំគ្នា និងព្រឹត្តិការណ៍ចៃដន្យផ្នែកក្រូម៉ូសូម។ ព្រះអង្គបានបង្កើតយើងមក! យើងគ្រប់គ្នាគឺជាលទ្ធផលនៃព្រះតម្រិះ ផែនការ និងព្រឹត្តិការណ៍របស់ព្រះជាម្ចាស់ផ្ទាល់។ ហើយនេះនាំមកនូវទាំងអត្ថន័យ និងទំនួលខុសត្រូវចំពោះជីវិតមនុស្សលោក (លោកុប្បត្តិ ១:២៦-២៨)។

គ្មានអ្នកណាឯករាជ្យទេក្នុងចំណោមយើង ហើយការយល់សេចក្តីពិតនេះគឺជាគន្លឹះនៃការយល់ដំណឹងល្អ។ ទោះបើយើងនិយាយគ្រប់ពេលអំពីសិទ្ធិ និងសេរីភាព តាមពិតទៅយើងមិនមានសេរីភាពដូចដែលយើងចូលចិត្តគិតនោះទេ។ ព្រះអង្គបានបង្កើតយើងមក។ ព្រះអង្គបានតាក់តែងយើង។ ហេតុដូច្នេះហើយបានជាយើងជាកម្មសិទ្ធិរបស់ព្រះអង្គ។

ដោយសារព្រះអង្គបានបង្កើតយើង ដូច្នេះទ្រង់មានសិទ្ធិក្នុងការប្រាប់យើងអំពីរបៀបរស់នៅ។ ដូច្នេះ នៅឯសួនច្បារអេដែន ព្រះអង្គបានប្រាប់លោក អ័ដាម និងនាង អេវ៉ា ថាពួកគាត់អាចបរិភោគពីដើមឈើណាបាន និងថាផ្លែរបស់ដើមឈើមួយណាដែលពួកគាត់មិនអាចបរិភោគបាន (លោកុប្បត្តិ ២:១៦-១៧)។ វាមិនមែនជាការថា ព្រះជាម្ចាស់កំពុងតែមានអាកប្បកិរិយាដូចជាក្មេងម្នាក់ ដោយចង់ក្តាប់យកអំណាច បញ្ជាប្អូនប្រុសទ្រង់ឲ្យធ្វើនេះធ្វើនោះ និងបង្កើតច្បាប់

ឲ្យធ្វើតាមអំពើព្រះហឫទ័យ១ ដើម្បីឲ្យគ្រាន់តែឃើញថានឹងមានអ្វីកើតឡើងៗ ទេ ព្រះគម្ពីរប្រាប់យើងថា ព្រះជាម្ចាស់ល្អ។ ព្រះអង្គជ្រាបអំពីអ្វីដែលល្អបំផុតសម្រាប់រាស្ត្ររបស់ទ្រង់ ហើយព្រះអង្គបានប្រទានក្រឹត្យវិន័យទៅកាន់ពួកគាត់ដែលថែរក្សា និងចម្រើនអំណរ និងសុខភាពរបស់ពួកគាត់។

ការមានការយល់ដឹងខ្លះៗលើចំណុចនេះគឺពិតជាសំខាន់ខ្លាំងណាស់ ប្រសិនបើបុគ្គលណាម្នាក់ចង់យល់អំពីដំណឹងល្អរបស់គ្រីស្ទបរិស័ទ។ ដំណឹងល្អគឺជាការឆ្លើយតបរបស់ព្រះជាម្ចាស់ទៅកាន់ដំណឹងអាក្រក់នៃអំពើបាប ហើយអំពើបាបគឺជាការបដិសេធរបស់បុគ្គលណាម្នាក់ ទាក់ទងនឹងកម្មសិទ្ធិរបស់ព្រះជាម្ចាស់ ក្នុងនាមជាព្រះអាទិករលើជីវិតរបស់គាត់។ ហេតុដូច្នេះ មូលដ្ឋានគ្រឹះនៃសេចក្តីពិតនៃជីវិតរបស់មនុស្សលោក ដែលចេញពីនោះរាល់គ្រប់ចំណុចទាំងអស់ហូរមក គេថាព្រះជាម្ចាស់បានបង្កើតយើង ហេតុដូច្នេះហើយបានជាយើងជាកម្មសិទ្ធិរបស់ទ្រង់។

## ព្រះដ៏បរិសុទ្ធ និងសុចរិត

ប្រសិនបើលោកអ្នកត្រូវពណ៌នាអំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ដោយប្រើប្រាស់ពាក្យពេចន៍តែមួយចំនួន តើអ្នកនឹងនិយាយដូចម្តេច? ថាព្រះអង្គស្រឡាញ់ និងសប្បុរស? តើព្រះអង្គពេញដោយសេចក្តីមេត្តាករុណា និងការអត់ទោស? ទាំងអស់ពិត។ នៅពេលដែលលោកម៉ូសេ ទូលសូមឲ្យព្រះជាម្ចាស់បង្ហាញសិរីល្អរបស់ទ្រង់ដល់គាត់ ហើយ

9Marks Online PDF

ប្រាប់ព្រះនាមរបស់ទ្រង់មកកាន់គាត់ នេះគឺជាអ្វីដែលព្រះជាម្ចាស់បានមានបន្ទូល៖

> «យេហូវ៉ា គឺយេហូវ៉ាដ៏ជាព្រះទ្រង់មានព្រះហឫទ័យមេត្តាករុណា ហើយទន់សន្តោស ទ្រង់យឺតនឹងខ្ញាល់ ហើយមានសេចក្តីសប្បុរស និងសេចក្តីទៀងត្រង់ ជាបរិបូរ ទ្រង់មានសេចក្តីមេត្តាករុណាដល់មនុស្សទាំងពាន់ ក៏អត់ទោសចំពោះសេចក្តីទុច្ចរិត សេចក្តីរំលង នឹងអំពើបាប» (និក្ខមនំ ៣៤:៦ ៧)។

នេះពិតជាអស្ចារ្យមែន! នៅពេលដែលព្រះជាម្ចាស់សព្វព្រះហឫទ័យប្រាប់យើងអំពីព្រះនាមរបស់ទ្រង់ និងបង្ហាញសិរីល្អរបស់ទ្រង់ដល់យើង—ដែលតាមពិតទៅ គឺជាការបង្ហាញព្រះហឫទ័យរបស់ទ្រង់មកកាន់យើង—តើព្រះអង្គបានមានបន្ទូលយ៉ាងដូចម្តេច? គឺថាទ្រង់មានព្រះហឫទ័យមេត្តាករុណា ហើយទន់សន្តោស ទ្រង់យឺតនឹងខ្ញាល់ ហើយមានសេចក្តីសប្បុរស។

ប៉ុន្តែ នៅមានចំណុចផ្សេងទៀតក្នុងខគម្ពីរនេះ ដែលជារឿយៗមិនមានការលើកឡើង ហើយវាក៏មិនសូវជាផ្តល់ការកំសាន្តចិត្តប៉ុន្មានដែរ។ តើអ្នកដឹងទេថា ព្រះជាម្ចាស់បានមានបន្ទូលយ៉ាងដូចម្តេចទៅកាន់លោក ម៉ូសេ បន្ទាប់ពីព្រះអង្គបានមានបន្ទូល ថាទ្រង់មានពេញទៅដោយសេចក្តីមេត្តាករុណា និងសេចក្តីស្រឡាញ់?

9Marks Online PDF

"ប៉ុន្តែ ទ្រង់មិនរាប់មនុស្សមានទោសទុកជាឥតទោសឡើយ" (ខ៧)។

សូមមើលចំណុចនោះម្តងទៀត ពីព្រោះវាធ្វើឲ្យផ្ទុះ ៩០% នៃអ្វីដែលមនុស្សសព្វថ្ងៃនេះ*គិតថា* ខ្លួនដឹងអំពីព្រះជាម្ចាស់។ ព្រះជាម្ចាស់ដែលពេញដោយសេចក្តីមេត្តាករុណា និងសេចក្តីស្រឡាញ់*នឹងមិនរាប់មនុស្សមានទោសទុកថាជាឥតទោសទេ។*

ទស្សនៈដ៏សាមញ្ញមួយអំពីព្រះជាម្ចាស់គឺថាទ្រង់មិនខុសគ្នាប៉ុន្មានពីអ្នកបោសសម្អាតដ៏ម៉ត់ចត់មិនស្អាតមួយទេ។ ជាជាងពិតជារកដំណោះស្រាយសម្រាប់អំពើបាបនៃពិភពលោកនេះ—អំពើបាប អំពើអាក្រក់ និងភាពកំណាចរបស់វា—ព្រះអង្គគ្រាន់តែបោះវាចូលក្រោមក្រណាត់ជូតជើង មិនអើពើនឹងវា ហើយសង្ឃឹមថានឹងមិនមានអ្នកណាកត់សម្គាល់ឃើញ។ តាមពិតទៅ មានមនុស្សជាច្រើននាក់ដែលមិនអាចគិតដល់បាន អំពីព្រះជាម្ចាស់ ដែលនឹងធ្វើអ្វីមួយផ្សេងទៀតឡើយ។ ពួកគេសួរថា "ព្រះជាម្ចាស់កាត់ទោសអំពើបាប? ដាក់ទារុណកម្មលើខ្ញុំសម្រាប់អំពើអាក្រក់ដែលខ្ញុំប្រព្រឹត្ត? ប្រាកដណាស់ព្រះអង្គនឹងមិនធ្វើដូច្នេះទេ។ ពីព្រោះនោះមិនមែនជាការស្រឡាញ់ទេ"។

នៅពេលក្រោយទៀត យើងនឹងឃើញអំពីរបៀបដែលមើលទៅហាក់បីដូចជាប្រឆាំងគ្នា ក្នុងលក្ខណៈដែលមិនអាចយល់បាននៅក្នុងកណ្ឌគម្ពីរ និក្ខមនំ ៣៤:៦-៧—ព្រះដែល "អត់ទោសចំពោះសេចក្តីទុច្ចរិត សេចក្តីរំលង និងអំពើបាប" ក៏នៅ "មិនរាប់មនុស្សមានទោសទុកជា

ឥតទោសទេឡើយ» បានប្ដេជ្ញាចិត្តតាមរយៈការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង។ ប៉ុន្ដែ មុនយើងអាចគិតដល់ចំណុចនោះបាន ដាច់ខាតយើងត្រូវតែចូលខាងក្នុងថា ទោះជាមានការជំទាស់ផ្ទុយពីនោះ ក៏សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់មិនលុបចោលភាពយុត្តិធម៌ និងភាពសុចរិតរបស់ទ្រង់ដែរ។

ព្រះបន្ទូលបានប្រកាសម្ដងហើយម្ដងទៀតថា ព្រះជាម្ចាស់នៃយើងគឺជាព្រះដ៏យុត្តិធម៌ឥតខ្ចោះ និងសុចរិតដែលពុំអាចឈ្លានពានបាន។ កណ្ឌគម្ពីរ ទំនុកតម្កើង ១១:៧ មានចែងថា៖

> «ដ្បិតព្រះយេហូវ៉ាទ្រង់សុចរិត ទ្រង់ក៏ស្រឡាញ់សេចក្ដីសុចរិតដែរ»។

កណ្ឌគម្ពីរ ទំនុកតម្កើង ៣៣:៥ បានប្រកាសថា «ទ្រង់ស្រឡាញ់សេចក្ដីសុចរិត និងសេចក្ដីយុត្តិធម៌»។ ហើយកណ្ឌគម្ពីរ ទំនុកតម្កើងហ៊ានប្រកាសថា «សេចក្ដីសុចរិត និងសេចក្ដីយុត្តិធម៌ ជាជើងថ្កល់នៃបល្ល័ង្កទ្រង់» (ទំនុកតម្កើង ៨៩:១៤; ៩៧:២)! តើអ្នកឃើញថា ខគម្ពីរទាំងនេះកំពុងតែលើកឡើងអំពីអ្វីខ្លះ? ការគ្រប់គ្រងលើចក្រវាឡអធិបតេយ្យភាពនៃភាពជាអង្គម្ចាស់របស់ទ្រង់លើការបង្កើតមានមូលដ្ឋានលើសេចក្ដីសុចរិត និងយុត្តិធម៌ដ៏ល្អឥតខ្ចោះជារៀងមករបស់ទ្រង់។

ហេតុដូច្នេះហើយបានជាគំនិតដែលថា ព្រះជាម្ចាស់ជាអ្នកបោស

សម្អាតដ៏ម៉ត់ចត់មិនស្អាតម្នាក់ គឺនៅចុងបំផុតជាគំនិតដែលមិនស្កប់ចិត្តសោះ។ វាចោទថា ព្រះអង្គជាព្រះដែលមិនយុត្តិធម៌ និងមិនសុចរិត។ វាធ្វើឲ្យទ្រង់ក្លាយជាព្រះដែលគ្រាន់តែលាក់អំពើបាប—ឬក៏ថែមទាំងពួនពីអំពើបាបផង—ជាជាងប្រឆាំងនឹងវា និងបំផ្លាញវាចោល។ វាធ្វើឲ្យទ្រង់ក្លាយជាបុគ្គលកំសាកផ្នែកសីលធម៌។

ហើយតើអ្នកណាចង់បានព្រះដូចនោះ? វាតែងតែជារឿងគួរឲ្យចាប់អារម្មណ៍ក្នុងការមើលអ្វីដែលកើតឡើងចំពោះអ្នកដែលអះអាងថា ព្រះជាម្ចាស់នឹងមិនថ្កោលទោសពួកគាត់ប្រឈមមុខទល់នឹងមុខជាមួយនឹងអំពើអាក្រក់ដែលមិនអាចបដិសេធបាន។ នៅពេលដែលពួកគាត់ប្រឈមមុខនឹងអំពើអាក្រក់ដ៏ព្រៃផ្សៃពិតមែន នោះពួកគាត់ចង់បានព្រះជាម្ចាស់ដែលមានភាពយុត្តិធម៌—ហើយពួកគាត់ក៏ចង់បានទ្រង់ភ្លាមៗនោះ។ ពួកគាត់ចង់ឲ្យព្រះ ជាម្ចាស់មើលរំលងអំពើបាបរបស់ខ្លួនប៉ុន្តែមិនមើលរំលងអំពើបាបរបស់ពួកភេរវជនទេ។ “សូមអត់ទោសឲ្យ ទូលបង្គំ” ពួកគាត់លើកឡើង “ប៉ុន្តែសូមកុំហ៊ានអត់ទោសគាត់ឡើយ!”។ ឃើញទេ គ្មានអ្នកណាចង់បានព្រះដែលបដិសេធការដោះស្រាយអំពើអាក្រក់ទេ។ ពួកគាត់គ្រាន់តែចង់បានព្រះដែលបដិសេធដោះស្រាយអំពើអាក្រក់របស់ខ្លួនតែប៉ុណ្ណោះ។

ទោះជាយ៉ាងណាក៏ដោយក៏ព្រះបន្ទូលបានប្រាប់យើងថា ដោយសារព្រះអង្គយុត្តិធម៌ និងសុចរិតយ៉ាងល្អឥតខ្ចោះ នោះព្រះអង្គនឹងធ្វើអន្តរាគមន៍យ៉ាងម៉ឺងម៉ាត់ជាមួយនឹងអំពើអាក្រក់។ កណ្ឌគម្ពីរ

ហាបាគុក ១:១៣ ចែងថា៖

> «ទ្រង់មានព្រះនេត្របរិសុទ្ធក្រៃលែង នឹងទតមើលការអាក្រក់មិនបាន ក៏នឹងពិនិត្យមើលការទុច្ចរិតមិនបានដែរ»។

ក្នុងការធ្វើបាបនោះគឺស្មើនឹងការបោះបង់មូលដ្ឋានគ្រឹះបល្ល័ង្ករបស់ទ្រង់ចោល។ ហើយលើសពីនោះទៅទៀតគឺស្មើនឹងការបដិសេធរូបអង្គទ្រង់ផ្ទាល់តែម្តង ហើយនោះព្រះអង្គនឹងមិនធ្វើឡើយ។

មនុស្សជាច្រើនមិនមានបញ្ហាទេ ក្នុងការគិតអំពីព្រះជាម្ចាស់ថាជាព្រះដែលស្រឡាញ់ និងពេញដោយសេចក្តីមេត្តាករុណា។ យើងដែលជាគ្រីស្ទបរិស័ទបានបង្កចលាចលយ៉ាងខ្លាំងនៅក្នុងពិភពលោកក្នុងការបញ្ចុះបញ្ចូលថាព្រះជាម្ចាស់ស្រឡាញ់ពួកគាត់។ ប៉ុន្តែ ប្រសិនបើយើងចង់យល់អំពីសិរីល្អ និងចំណុចដែលប្រទានជីវិតចេញពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងត្រូវតែយល់ថាព្រះដែលពេញទៅដោយសេចក្តីស្រឡាញ់ និងសេចក្តីមេត្តាករុណានេះក៏ជាព្រះដែលបរិសុទ្ធ និងសុចរិត ហើយថាទ្រង់ក៏បានប្តេជ្ញាថានឹងមិនមើលរំលង មិនអើពើ ឬក៏អត់ទ្រាំនឹងអំពើបាបដែរ។

មានរួមទាំងរបស់យើងផ្ទាល់ ដែលនេះនាំយើងមកកាន់ដំណឹងអាក្រក់។

9Marks Online PDF

ជំពូកទី៣

# មនុស្សមានបាប

នៅប្រទេសអាមេរិក ប្រសិនបើអ្នកបើកបរចតឡានហួសពេលកំណត់ នោះពួកគាត់នឹងទទួលសំបុត្រពិន័យចតឡាន។ នេះជាបទពិសោធន៍របស់អ្នកនិពន្ធ៖ ខ្ញុំទើបតែបង់សំបុត្រពិន័យចតឡាននៅថ្ងៃមុន។ វាងាយស្រួលណាស់។ ខ្ញុំអានការចោទមកកាន់ខ្ញុំ ត្រឡប់សំបុត្រទៅម្ខាងទៀត គូសសញ្ញាគ្រីសក្នុងប្រអប់ដែលថា "ខ្ញុំសូមសារភាពកំហុសចំពោះការចោទប្រកាន់នេះ" ហើយក៏ទៅផ្ញើរលុយ ៣៥ ដុល្លារទៅប៉ុស្តិ៍ប៉ូលីសចរាចរណ៍។

ខ្ញុំជាអ្នកមានទោសហើយ។

ទោះជាយ៉ាងណាក៏ដោយក៏ខ្ញុំនៅមានមូលហេតុខ្លះដែលថា ទោះបើខ្ញុំបានគូសសញ្ញាគ្រីសក្នុងប្រអប់ "មានទោស" ក៏ខ្ញុំនៅមិនសូវមានអារម្មណ៍ថាខ្លួនជាប់ពិរុទ្ធភាពខ្លាំងប៉ុណ្ណាដែរ។ ខ្ញុំនឹងមិនឈប់គេងដោយសារខ្ញុំបានដើរលើផ្លូវខុសនៃច្បាប់នោះឡើយ។ ហើយខ្ញុំក៏មិនមានអារម្មណ៍ថា ខ្ញុំត្រូវទៅសូមការអត់ទោសពីអ្នកណាម្នាក់ដែរ ហើយឥឡូវនេះដោយសារខ្ញុំបានគិតអំពីវា ខ្ញុំរៀងអន់ចិត្តបន្តិចដែលសំបុត្រផាកពិន័យ ១០ ដុល្លារថ្លៃជាងសំបុត្រមុនដែលខ្ញុំទទួលបាន។

ហេតុអ្វីបានជាខ្ញុំមិនមានអារម្មណ៍អាក្រក់នៅពេលដែលខ្ញុំប្រព្រឹត្ត

9Marks Online PDF

ល្មើសនឹងច្បាប់? នៅពេលដែលយើងពិតជាព្យាយាមយល់ពីវាមែន ខ្ញុំគិតថាគឺដោយសារការប្រព្រឹត្តល្មើសនឹងច្បាប់ចត វាសំខាន់ប៉ុន្មានទេ—ឬក៏អាក្រក់ទាល់តែសោះ។ ពិតណាស់ ពេលក្រោយខ្ញុំនឹងបង់លុយបន្ថែមលើសចំនួន សម្រាប់ការចតដែលខ្ញុំគិតថាខ្ញុំត្រូវការ ប៉ុន្តែសតិសម្បជញ្ញៈរបស់ខ្ញុំមិនមានការបាក់បែកលើរឿងទាំងមូលនេះទេ។

ចំណុចមួយដែលខ្ញុំកត់សម្គាល់ឃើញប៉ុន្មានឆ្នាំកន្លងនេះ គឺថាមនុស្សជាច្រើននាក់តែងតែគិតអំពីអំពើបាប ជាពិសេសអំពើបាបរបស់ខ្លួនថា មិនសូវលើសជាងការប្រព្រឹត្តល្មើសនឹងច្បាប់ចរាចរណ៍ទេ។ «ប្រាកដណាស់» យើងគិតថា «តាមបច្ចេកទេស អំពើបាបគឺជាការប្រព្រឹត្តរំលងនឹងក្រឹត្យវិន័យ ដែលព្រះដ៏ឧត្តុង្គឧត្តមបានប្រទានមកឲ្យយើង និងចំណុចផ្សេងៗទៀត ប៉ុន្តែព្រះអង្គពិតជាជ្រាបយ៉ាងប្រាកដថាក៏មានជនឧក្រិដ្ឋផ្សេងៗទៀត ដែលប្រព្រឹត្តអំពើអាក្រក់ខ្លាំងជាងខ្ញុំដែរ។ លើសពីនោះទៅទៀត មិនមានអ្នកណារងគ្រោះទេ ហើយខ្ញុំក៏ស្ម័គ្រចិត្តបង់ថ្លៃដែរ។ ហើយបើនិយាយឲ្យចំទៅ—ខ្ញុំមិនចាំបាច់ចាក់រុកខ្លាំងពេក រហូតដល់ព្រលឹងវិញ្ញាណលើរឿងដូចនេះឡើយ។ ពិតអត់?»

បើអញ្ចឹងមែន ខ្ញុំគិតថាវាមិនដូច្នោះទេ យ៉ាងហោចណាស់ក្នុងរបៀបដែលលោកអ្នកគិតអំពីអំពើបាបក្នុងរបៀបដ៏សោះកក្រោះដូចនោះ។ ប៉ុន្តែ យោងតាមព្រះគម្ពីរ អំពើបាបគឺលើសពីការគ្រាន់តែប្រព្រឹត្តល្មើសនឹងច្បាប់ចរាចរណ៍នៃស្ថានសួគ៌ បែបអបុគ្គល ទាំងតាមអំពើចិត្តរបស់មនុស្សម្នាក់ទៅទៀត។ តាមពិត អំពើបាបជាការបែកបាក់ផ្នែកទំនាក់

9Marks Online PDF

ទំនង ហើយលើសពីនេះទៀត វាគឺជាការបដិសេធព្រះជាម្ចាស់ផ្ទាល់តែម្ដង—ការបោះបង់ក្រឹត្យវិន័យ ការយកចិត្តទុកដាក់ អំណាចរបស់ព្រះជាម្ចាស់ចោល និងសិទ្ធិរបស់ព្រះអង្គក្នុងការបញ្ជាអស់អ្នកដែលទ្រង់បានប្រទានជីវិត។ បើនិយាយឲ្យខ្លីទៅ វាជាការបះបោរនៃអ្វីៗដែលព្រះជាម្ចាស់បានបង្កើតមកប្រឆាំងនឹងព្រះអាទិករ។

## មានអ្វីអាក្រក់បានកើតឡើង

នៅពេលដែលព្រះជាម្ចាស់បង្កើតមនុស្សលោក ព្រះអង្គសព្វព្រះហឫទ័យឲ្យពួកគាត់រស់នៅក្រោមការគ្រប់គ្រងដ៏យុត្តិធម៌របស់ទ្រង់ក្នុងអំណរដ៏ល្អឥតខ្ចោះ ដោយថ្វាយបង្គំព្រះអង្គ ស្ដាប់បង្គាប់ទ្រង់ ហើយតាមរយៈការនោះគឺរស់នៅក្នុងការប្រកបគ្នាជាមួយនឹងព្រះអង្គដោយគ្មានការបាក់បែក។ ដូចដែលយើងបានឃើញនៅក្នុងជំពូកមុន ព្រះអង្គបានបង្កើតមនុស្សប្រុស និងមនុស្សស្រីដូចរូបអង្គទ្រង់ ដែលនេះមានន័យថាព្រះអង្គសព្វព្រះហឫទ័យឲ្យពួកគាត់មានលក្ខណៈដូចទ្រង់ មានទំនាក់ទំនងជាមួយនឹងព្រះអង្គ និងដើម្បីប្រកាសសិរីល្អរបស់ទ្រង់ទៅកាន់លោកីយ៍។ លើសពីនោះទៅទៀត ព្រះជាម្ចាស់ក៏មានការងារមួយសម្រាប់ឲ្យមនុស្សលោកធ្វើដែរ។ ពួកគាត់មានតួនាទីជាជំនួយការរបស់ទ្រង់ ដោយគ្រប់គ្រងលើផែនដីដែលទ្រង់បានបង្កើតក្រោមទ្រង់។ «ចូរបង្កើតកូនឲ្យចម្រើនជាច្រើនឡើង» ព្រះជាម្ចាស់បានបញ្ជាពួកគាត់ «ឲ្យមានពេញពាសលើផែនដីចុះ ត្រូវបង្ក្រាបផែនដី ហើយមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស នឹងជីវិតផងទាំង

ឡាយដែលកំពើកនៅផែនដីផង» (លោកុប្បត្តិ ១:២៨)។

ទោះជាយ៉ាងណាក៏ដោយក៏ការដែលមនុស្សប្រុស និងមនុស្សស្រី គ្រប់គ្រងលើរបស់សព្វសារពើក៏មិនមែនជាចំណុចកំពូលបំផុតដែរ។ អំណាចរបស់ពួកគាត់គឺមិនមែនជារបស់ខ្លួនទេ ព្រះជាម្ចាស់គឺជាអង្គ ដែលបានប្រទានដល់ពួកគាត់។ ដូច្នេះ ខណៈពេលដែលលោក អ័ដាម និងនាង អេវ៉ា ប្រើប្រាស់អំណាចគ្រប់គ្រងលើផែនដី គឺពួកគាត់ត្រូវតែ ចងចាំថាជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ និងស្ថិតក្រោមការគ្រប់គ្រង របស់ទ្រង់។ ព្រះអង្គបានបង្កើតពួកគាត់ ហេតុដូច្នេះហើយបានជាទ្រង់ មានសិទ្ធិបញ្ជាពីលើពួកគាត់។

ដើមដឹងខុសត្រូវ ដែលព្រះជាម្ចាស់បានដាំនៅក្នុងកណ្តាលសួន ច្បារ គឺជាការរម្លឹកយ៉ាងសោះកក្រោះនៃចំណុចនោះ (លោកុប្បត្តិ ៣:១៧)។ នៅពេលដែលលោក អ័ដាម និងនាង អេវ៉ា មើលដើមនោះ ហើយឃើញផ្លែរបស់វា នោះពួកគាត់ចងចាំថាអំណាចរបស់ខ្លួនមាន ព្រំដែន ថាខ្លួនជាអ្វីមួយដែលព្រះបានបង្កើត ហើយថាពួកគាត់មាន ការរំពឹងលើព្រះជាម្ចាស់សម្រាប់ជីវិតរបស់ខ្លួន។ ពួកគាត់គ្រាន់តែជា អ្នកត្រួតត្រាប៉ុណ្ណោះ។ ព្រះជាម្ចាស់គឺជាស្តេច។

ដូច្នេះ ពេលដែលលោក អ័ដាម និងនាង អេវ៉ា ខាំផ្លែឈើនោះ គឺពួក គាត់មិនគ្រាន់តែប្រព្រឹត្តល្មើសនឹងក្រឹត្យវិន័យក្នុងការ «ហាមបរិភោគ ផ្លែឈើ» តាមអំពើចិត្តនោះទេ។ គឺពួកគាត់កំពុងតែប្រព្រឹត្តនូវអ្វីដែល អាក្រក់ និងធ្ងន់ធ្ងរជាងនោះទៅទៀត។ ពួកគាត់កំពុងតែបដិសេធ

9Marks Online PDF

អំណាចដែលព្រះទ្រង់មានមកលើពួកគេ ហើយក៏កំពុងប្រកាសឯករាជ្យរបស់ខ្លួនចេញពីទ្រង់ដែរ។ លោក អ័ដាម និងនាង អេវ៉ា ចង់បាននូវអ្វីដែលសត្វពស់សន្យាដល់ពួកគាត់ថានឹងក្លាយ «ដូចជាព្រះ» ដូច្នេះពួកគាត់ទាំងពីរនាក់ក៏ឆក់ (នូវអ្វីដែលខ្លួនគិតថាគឺជា) ឱកាសក្នុងការចាកចេញពីតួនាទីនៃការធ្វើជាជំនួយការរបស់ព្រះជាម្ចាស់ ហើយយកមកុដសម្រាប់ខ្លួនផ្ទាល់។ ក្នុងចក្រវាឡទាំងមូល មានអ្វីតែមួយគត់ដែលព្រះជាម្ចាស់មិនបានដាក់ក្រោមបាតជើងរបស់លោក អ័ដាម—គឺព្រះជាម្ចាស់ផ្ទាល់។ ទោះជាយ៉ាងណាក៏ដោយក៏លោក អ័ដាម បានសម្រេចចិត្តថា ការរៀបចំរឿងបែបនោះមិនល្អល្មមសម្រាប់គាត់ ហេតុដូច្នេះបានជាគាត់បះបោរ។

ថ្វីបើដូច្នោះមែន ចំណុចដ៏អាក្រក់បំផុតគឺថាតាមរយៈការមិនស្ដាប់បញ្ញត្តិរបស់ព្រះជាម្ចាស់ គឺលោក អ័ដាម និងនាង អេវ៉ា បានសម្រេចចិត្ត (ដោយដឹងខ្លួន) ក្នុងការបដិសេធព្រះជាម្ចាស់ថាជាស្ដេចរបស់ខ្លួន។ ពួកគាត់បានដឹងហើយអំពីផលកម្មដែលពួកគេនឹងទទួលបានប្រសិនបើពួកគាត់មិនស្ដាប់បង្គាប់ទ្រង់។ ព្រះជាម្ចាស់បានប្រាប់ពួកគាត់ ក្នុងពាក្យពេចន៍ដែលច្បាស់លាស់យ៉ាងខ្លាំងថា ប្រសិនបើពួកគាត់បរិភោគផ្លែឈើនោះពួកគាត់ «នឹងត្រូវស្លាប់ជាមិនខាន» ដែលមានន័យថានៅចុងបញ្ចប់ នោះព្រះអង្គនឹងបោះបង់ពួកគាត់ចោលចេញពីព្រះវត្តមានរបស់ទ្រង់ ហើយពួកគាត់នឹងក្លាយជាខ្មាំងសត្រូវរបស់ទ្រង់ ជាជាងមិត្តភក្ដិរបស់ព្រះអង្គ និងរាស្ត្រដែលមានពរ (លោកុប្បត្តិ

9Marks Online PDF

២:១៧)។ ប៉ុន្តែ ពួកគាត់មិនខ្វល់។ លោក អ័ដាម និងនាង អេវ៉ា បានប្តូរភាពសំណព្វចិត្តរបស់ព្រះអង្គលើពួកគាត់ជំនួសការសង្វាតដេញតាមការសប្បាយ និងភាពរុងរឿងរបស់ខ្លួន។

ព្រះគម្ពីរហៅការមិនស្តាប់បង្គាប់តាមបញ្ញត្តិនេះរបស់ព្រះជាម្ចាស់ថាជា «អំពើបាប»—មិនថាតាមរយៈពាក្យពេចន៍ គំនិត ឬក៏ទង្វើក៏ដោយ។ តាមន័យចំៗ ពាក្យនេះមានន័យថា «មិនត្រូវគោលដៅ» ប៉ុន្តែយោងតាមព្រះគម្ពីរ អត្ថន័យលើពាក្យអំពើបាបគឺជ្រៅជាងនោះ។ វាមិនមែនហាក់បីដូចជាថា ប្រសិនបើលោក អ័ដាម និងនាង អេវ៉ា បានព្យាយាមគ្រាប់តាមបញ្ញត្តិរបស់ព្រះជាម្ចាស់យ៉ាងខ្លាំង ហើយគ្រាន់តែមិនត្រូវគោលដៅតែប៉ុន្មានដឹក្រែនោះឡើយ។ ទេ! សេចក្តីពិតគឺថា ពួកគាត់កំពុងតែបាញ់តម្រង់ទៅទិសផ្ទុយ។ ពួកគាត់មានគោលបំណង និងសេចក្តីប្រាថ្នាដែលប្រភេទនៃការប្រឆាំងជាមួយនឹងអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យសម្រាប់គាត់ ហេតុដូច្នេះហើយបានជាពួកគាត់បានប្រព្រឹត្តអំពើបាប។ ពួកគាត់បានប្រព្រឹត្តល្មើសនឹងបញ្ញត្តិរបស់ព្រះជាម្ចាស់ដោយចេតនា បំបែកបំបាក់ទំនាក់ទំនងរបស់ខ្លួនជាមួយនឹងទ្រង់ ហើយក៏បានបដិសេធថាជាព្រះអម្ចាស់ ដែលមានសិទ្ធិលើពួកគាត់។

ផលកម្មនៃអំពើបាបរបស់លោក អ័ដាម និងនាងអេវ៉ាក៏បានបង្កមហន្តរាយដល់ពួកគាត់ កូនចៅរបស់ខ្លួន និងរបស់សព្វសារពើទាំងអស់។ ព្រះអង្គក៏បានបណ្តេញពួកគាត់ចេញពីសួនច្បារអេដែន ដែល

ជាកន្លែងសុខស្រួល។ ផែនដីក៏លែងឲ្យផល និងទ្រព្យដោយស្ម័គ្រចិត្ត និងពេញដោយអំណរសម្រាប់ពួកគាត់ដែរ។ ពួកគាត់ត្រូវខិតខំធ្វើការយ៉ាងនឿយហត់ និងពិបាកដើម្បីទទួលបានផលផ្លែ។ ហើយអាក្រក់ជាងនោះទៀត ព្រះជាម្ចាស់ក៏បានសម្រេចការសន្យា ទាក់ទងទៅនឹងសេចក្តីស្លាប់លើពួកគាត់ដែរ។ ពិតណាស់ គាត់ក៏មិនបានស្លាប់ខាងឯសាច់ឈាមភ្លាមៗដែរ។ រូបកាយរបស់ពួកគាត់បន្តរស់នៅ សួតនៅបន្តដកដង្ហើម បេះដូងនៅបន្តលោត ហើយដៃជើងនៅបន្តមានចលនា។ ប៉ុន្តែ ជីវិតខាងឯវិញ្ញាណរបស់ពួកគាត់ ជាអ្វីដែលសំខាន់ជាងគេបំផុត បានស្លាប់ភ្លាមៗតែម្តង។ ការប្រកបគ្នារបស់ពួកគាត់ជាមួយនឹងព្រះជាម្ចាស់ក៏បានបាក់បែក ហេតុដូច្នេះហើយបានជាចិត្តរបស់ពួកគាត់បានរួញស្វិត ហើយខួរក្បាលរបស់ពួកគាត់ក៏បានពេញឡើងដោយគំនិតអាត្មានិយម ភ្នែករបស់ពួកគាត់ក៏ងងឹតចំពោះភាពសង្ហាររបស់ព្រះជាម្ចាស់ ហើយព្រលឹងរបស់ពួកគាត់ក៏ស្រពោន និងរាំងស្ងួត ដល់ថ្នាក់ថាលែងមានជីវិតខាងឯព្រលឹងវិញ្ញាណ ដែលព្រះជាម្ចាស់បានប្រទានទៅកាន់ពួកគាត់តាំងពីដំបូងមក ដែលកាលនោះរាល់គ្រប់អ្វីៗទាំងអស់ល្អ។

## មិនមែនតែពួកគាត់ទេ ប៉ុន្តែពួកយើងដែរ

ព្រះគម្ពីរបានប្រាប់យើងថា មិនមែនគ្រាន់តែលោក អ័ដាម និងនាងអេវ៉ា ទេដែលមានពិរុទ្ធភាពដោយសារអំពើបាប។ គឺយើងគ្រប់គ្នា។ សាវ័ក ប៉ុល បានមានប្រសាសន៍នៅក្នុងកណ្ឌគម្ពីរ រ៉ូម ៣:២៣ "គ្រប់

គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ»។ ហើយប្រមាណជាពីរបីកថាខណ្ឌហ្នឹង គាត់បានលើកឡើងថា «គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង» (រ៉ូម ៣:១០)។

ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទមានពេញទៅដោយថ្មជំពប់ ហើយនេះគឺជាថ្មជំពប់ដ៏ធំមួយដែរ។ ចំពោះចិត្តមនុស្សដែលចចេសក្នុងការគិតថា ជាគោលខ្លួនល្អ ហើយអាចបំពេញខ្លួនឯងបាន គំនិតដែលថាជាមូលដ្ឋានមនុស្សទាំងអស់មានអំពើបាប ហើយទាស់ប្រឆាំង គឺមិនគ្រាន់តែគួរឲ្យស្អប់ខ្ពើមប៉ុណ្ណោះទេ ប៉ុន្តែគឺពិតជាគួរឲ្យស្អប់ខ្ពើមមែន។

នេះហើយជាមូលហេតុដែលសំខាន់ខ្លាំងណាស់ ដែលយើងត្រូវយល់អំពីលក្ខណៈ និងភាពអាក្រក់នៃអំពើបាបរបស់យើង។ ប្រសិនបើយើងមើលទៅកាន់ដំណឹងល្អដោយគិតថាអំពើបាបគឺជាអ្វីផ្សេងទៀត ឬក៏ជាអ្វីដែលតូចជាងនោះ ជាជាងធាតុពិតរបស់វា នោះយើងនឹងយល់ខុសទាំងស្រុងអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ សូមអនុញ្ញាតឲ្យខ្ញុំផ្តល់ជូននូវឧទាហរណ៍មួយចំនួនអំពីរបៀបដែលគ្រីស្ទបរិស័ទបានយល់ច្រឡំជាញឹកញាប់អំពីអំពើបាប។

## ការយល់ច្រឡំអំពីអំពើបាបជាមួយនឹងលទ្ធផលនៃអំពើបាប

ថ្មីៗនេះ គេនិយមប្រកាសដំណឹងល្អដោយលើកឡើងថា ព្រះយេស៊ូវបានយាងមក ដើម្បីសង្គ្រោះមនុស្សលោកចេញពីការមានអារម្មណ៍ពិរុទ្ធភាពពីកំណើត ការគ្មានន័យ ការគ្មានគោលដៅ ឬក៏ភាពទទេ។ ពិតណាស់ ឥឡូវនេះ ទាំងនោះគឺពិតជាបញ្ហាមែន ហើយ

9Marks Online PDF

មនុស្សជាច្រើនក៏ប្រឈមមុខនឹងវាយ៉ាងជ្រៅដែរ។ ប៉ុន្តែ ព្រះគម្ពីរបង្រៀនថា មូលដ្ឋានគ្រឹះនៃបញ្ហារបស់មនុស្សលោក—អ្វីដែលយើងត្រូវទទួលការសង្គ្រោះចេញពី—គឺមិនថាគ្មានន័យ ឬក៏ការបែកបាក់ក្នុងជីវិតរបស់យើង ឬក៏សូម្បីតែអារម្មណ៍នៃពិការភាពខាងឯពិរុទ្ធភាព។ ទាំងនោះគឺគ្រាន់តែជារោគសញ្ញានានានៃបញ្ហាដែលជ្រាលជ្រៅជាងនោះ៖ អំពើបាបរបស់យើង។ ដាច់ខាត! អ្វីដែលយើងត្រូវយល់គឺថា ស្ថានភាពពិបាកដែលយើងកំពុងតែស្ថិតនៅគឺជាស្ថានភាពពិបាកដែលយើងបានបង្កើតឡើងដោយខ្លួនឯង។ *យើង*មិនបានស្តាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ *យើង*មិនបានអើពើនឹងបញ្ញត្តិរបស់ទ្រង់។ *យើង*បានប្រព្រឹត្តអំពើបាបទាស់ប្រឆាំងនឹងទ្រង់។

ការនិយាយអំពីសេចក្តីសង្គ្រោះកើតចេញពីភាពគ្មានន័យ ឬក៏ការគ្មានគោលដៅ ដោយមិនជីករកឫសគល់របស់វាក្នុងអំពើបាបទំនងធ្វើឲ្យការលេបថ្នាំមានភាពងាយស្រួល ប៉ុន្តែវាគឺជាថ្នាំខុស។ វាអនុញ្ញាតឲ្យបុគ្គលណាម្នាក់បន្តគិតអំពីខ្លួនឯងថាជាជនរងគ្រោះ ហើយក៏មិនដែលពិតជាបានប្រឈមនឹងសេចក្តីពិតដែលថា គាត់ផ្ទាល់គឺជាជនឧក្រិដ្ឋ មិនសុចរិត ហើយក៏ស័ក្តិសមក្នុងការទទួលការជំនុំជម្រះ។

**ការបន្ថយអំពើបាបទៅជាទំនាក់ទំនងបែកបាក់**

ទំនាក់ទំនងគឺជាចំណាត់ថ្នាក់ដ៏សំខាន់មួយក្នុងព្រះគម្ពីរ ។ ព្រះអង្គ*បានបង្កើត*មនុស្សលោកមក ដើម្បីឲ្យរស់នៅក្នុងការប្រកបគ្នាជាមួយនឹងទ្រង់។ ទោះជាយ៉ាងណាក៏ដោយក៏អ្វីដែលយើងត្រូវតែចងចាំគឺថា

វាគឺជា*ប្រភេទ*នៃទំនាក់ទំនងដ៏ជាក់លាក់មួយដែលពួកគាត់ត្រូវតែរស់នៅក្នុង—មិនមែនជាទំនាក់ទំនងរវាងបុគ្គលពីរស្មើគ្នាទេ ដែលមានទស្សនៈនៃច្បាប់ការកាត់ក្តី និងការដាក់ទោស ប៉ុន្តែជាទំនាក់ទំនងរវាងស្តេច និងរាជ្យរបស់ទ្រង់វិញ។

មានគ្រីស្ទបរិស័ទជាច្រើននិយាយអំពីអំពើបាប ហាក់បីដូចជាថា វាគ្រាន់តែជាជម្លោះទំនាក់ទំនងតូចតាចមួយរវាងព្រះជាម្ចាស់ និងមនុស្សលោក ហើយអ្វីដែលយើងត្រូវធ្វើនោះគឺគ្រាន់តែសុំទោស ហើយទទួលយកការអត់ទោសរបស់ព្រះជាម្ចាស់បានហើយ។ ការគិតអំពីអំពើបាបបែបនោះថាវាជាជម្លោះរវាងពីរនាក់ដែលស្រឡាញ់គ្នានោះបង្ខូចទ្រង់ទ្រាយទំនាក់ទំនងដែលយើងមាននៅចំពោះព្រះជាម្ចាស់។ វាបង្ហាញថាមិនមានការប្រព្រឹត្តល្មើសនឹងច្បាប់ មិនមានការបំពានលើភាពយុត្តិធម៌ មិនមានសេចក្តីក្រោធដែលសុចរិត មិនមានការជំនុំជម្រះដែលបរិសុទ្ធ—ដែលហេតុដូច្នេះឯងបានជានៅទីបញ្ចប់ នោះក៏មិនចាំបាច់មានអ្នកណាម្នាក់មកជំនួសក្នុងការទទួលការជំនុំជម្រះដែរ។

ប្រាកដណាស់ ព្រះគម្ពីរបានបង្រៀនថា អំពើបាបគឺជាការបែកបាក់ទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់ ប៉ុន្តែទំនាក់ទំនងបែកបាក់នោះមានរួមទាំងការបដិសេធតួនាទីជាស្តេចដ៏ឧត្តុង្គឧត្តមរបស់ទ្រង់។ វាមិនមែន*គ្រាន់តែ*ជាការកំផិត (ទោះបើវាជាយ៉ាងនោះ) ក៏វាជាការបះបោរដែរ។ មិនមែន*គ្រាន់តែ*ជាការក្បត់ ប៉ុន្តែក៏ជាការក្បត់ជាតិដែរ។

ប្រសិនបើយើងគ្រាន់តែបន្ថយអំពើបាបចុះទៅថា វាគ្រាន់តែជាការបែកបាក់នៃទំនាក់ទំនងជាជាងការយល់លើវាថាជាការបោះបង់ដែលជាការក្បត់ជាតិពីប្រជារាស្ត្រដែលទ្រង់ស្រឡាញ់ ដោយប្រឆាំងនឹងស្តេចដ៏ល្អ និងសុចរិត នោះយើងក៏នឹងមិនអាចយល់អំពីមូលហេតុនៃការសុគតដែលត្រូវមានព្រះរាជបុត្រារបស់ព្រះជាម្ចាស់បានយាងមកដោះស្រាយវាដែរ។

## ការយល់ច្រឡំលើអំពើបាបទៅនឹងការគិតអវិជ្ជមាន

ការយល់ដឹងមិនត្រឹមត្រូវមួយទៀតអំពីអំពើបាបគឺការនិយាយថា វាគ្រាន់តែជាចំណុចនៃការគិតអវិជ្ជមានតែប៉ុណ្ណោះ។ យើងបានឃើញខ្លះហើយក្នុងសម្រង់សម្តីក្នុងសេចក្តីផ្តើមនៃសៀវភៅនេះ។ ពួកគេថា “ចូរបោះចោលថង់ស្រាចាស់! សូមគិតឲ្យធំជាងនេះ! ព្រះជាម្ចាស់សព្វព្រះទ័យក្នុងការបង្ហាញមកកាន់លោកអ្នកនូវការពេញព្រះទ័យដ៏ធំធេងរបស់ទ្រង់ បើលោកអ្នកគ្រាន់តែបោះបង់ចោលនូវការគិតបែបអវិជ្ជមានទាំងនោះដែលលោកអ្នកកំពុងតែមាន!”។

នោះគឺជាសារដែលជំរុញចំពោះអស់អ្នកដែលទុកចិត្តលើខ្លួនឯងដែលចង់ជឿថាខ្លួនអាចរកដំណោះស្រាយសម្រាប់អំពើរបស់ខ្លួនដោយខ្លួនឯងផ្ទាល់បាន។ នោះទំនងជាមូលហេតុដែលពេលគេប្រកាសសារបែបនោះអាចមានសមាជិកក្នុងក្រុមជំនុំដ៏ធំមួយនៅជុំវិញពិភពលោកបាន។ តាមពិតទៅ រូបមន្តគឺពិតជាស្រួលណាស់។ គឺគ្រាន់តែប្រាប់អ្នកស្តាប់ថា អំពើបាបរបស់ពួកគេមិនមែនជាបញ្ហាធំជាង

ការគិតបែបវិជ្ជមាន ហើយថាវាគឺជាអ្វីដែលកំពុងតែបង្ខាំងពួកគេពីការមានសុខភាពល្អ ការមានទ្រព្យសម្បត្តិ និងភាពអរសប្បាយ។ ហើយបន្ទាប់មក ប្រាប់ពួកគេថាបើពួកគេគ្រាន់តែគិតបែបវិជ្ជមានអំពីខ្លួនឯង (ដោយមានជំនួយពីព្រះជាម្ចាស់) នោះពួកគេនឹងអាចដកអំពើបាបរបស់ខ្លួនចេញ ហើយអាចក្លាយជាអ្នកមាន និងមានជំហររឹងមាំបាន។ ហើយភ្លាមនោះ ក៏នឹងមានក្រុមជំនុំដ៏ធំជាមិនខាន!

ពេលខ្លះ គោលដៅដែលគេយកមកសន្យាគឺលុយ សុខភាព ហើយពេលខ្លះទៀតគឺអ្វីផ្សេងទៀតទាំងស្រុងតែម្តង។ ប៉ុន្តែ មិនថាលោកអ្នកបំប្លែងវាយ៉ាងណាក៏ដោយ ក្នុងការលើកឡើងថាព្រះយេស៊ូវគ្រីស្ទបានសុគត ដើម្បីសង្គ្រោះយើងចេញពីការមានគំនិតអវិជ្ជមានអំពីខ្លួនឯងគឺពិតជាគួរឲ្យទទួលការថ្កោលទោសមែន ដោយសារមិនមាននៅក្នុងព្រះគម្ពីរ។ តាមពិតទៅ ព្រះគម្ពីរបង្រៀនថា ផ្នែកដ៏ធំមួយនៃបញ្ហារបស់យើងគឺថាយើងគិត*ខ្ពស់ពេក*អំពីខ្លួនឯង មិនមែនគិតទាបពេកនោះទេ។ សូមបង្អង់សិន ហើយគិតបន្តិចអំពីវា។ តើសត្វពស់បានមកល្បួងលោក អ័ដាម និងនាង អេវ៉ា ដោយរបៀបណា? វាបានប្រាប់ពួកគាត់ថា ពួកគាត់កំពុងតែគិតអវិជ្ជមានពេកអំពីខ្លួនឯង។ វាបានប្រាប់ពួកគាត់ថា ពួកគាត់ត្រូវតែគិតឲ្យកាន់តែវិជ្ជមាន ហើយកាន់តែលាតសន្ធឹងការឈោងចាប់របស់ខ្លួន ហើយឈោងទៅកាន់ការមានសក្តានុពលពេញរបស់ខ្លួន គឺអាចឲ្យក្លាយដូចជាព្រះបាន! បើនិយាយឲ្យខ្លីទៅ គឺវាកំពុងតែប្រាប់ឲ្យពួកគាត់គិតធំ។

9Marks Online PDF

ហើយតើការនោះបាននាំឲ្យមានអ្វីកើតឡើងសម្រាប់ពួកគាត់?

**ការយល់ច្រឡំលើអំពើបាប ជាមួយនឹងការធ្វើអំពើបាបខ្លះ**

មានចំណុចខុសគ្នាខ្លាំងណាស់រវាងការយល់អំពីខ្លួនឯងថាមានពិរុទ្ធភាពនៃការប្រព្រឹត្តអំពើបាបខ្លះៗ និងការដឹងខ្លួនឯងថាមានពិរុទ្ធភាពនៃ*អំពើបាប*។ មានមនុស្សជាច្រើនមិនមានបញ្ហាទេក្នុងការទទួលស្គាល់ថា ខ្លួនបានប្រព្រឹត្តអំពើបាបមួយចំនួន (ពហុវចនៈ) យ៉ាងហោចណាស់ក្នុងរបៀបដែលថា ដរាបណាពួកគាត់នៅអាចគិតអំពីអំពើបាបទាំងនោះដោយឡែកពីការប្រព្រឹត្តខុសតូចតាច ក្នុងរបៀបថាក្រៅពីនោះគឺជីវិតដែលល្អ—ការផាកពិន័យចតឡានខុសកន្លែងពេលខ្លះ ក្នុងរបៀបថាក្រៅពីនោះគាត់មានប្រវត្តិល្អ។

ការប្រព្រឹត្តអំពើបាប*មួយចំនួន*មិនធ្វើឲ្យយើងមានភាពតក់ស្លុតប៉ុន្មានទេ។ យើងដឹងថាវាមាន យើងឃើញថាវាមាននៅក្នុងខ្លួនឯងនិងអ្នកដទៃជារៀងរាល់ថ្ងៃ ហើយយើងក៏មានភាពសាំគ្នាខ្លាំងដែរហើយជាមួយនឹងវា។ អ្វីដែលធ្វើឲ្យយើងមានភាពតក់ស្លុតគឺនៅពេលដែលព្រះជាម្ចាស់បង្ហាញ*អំពើបាប* ដែលយើងមានយ៉ាងជ្រាលជ្រៅនៅក្នុងចិត្ត ភាពក្រខ្វក់ និងភាពពុករលួយដែលយើងបានសន្សំទុកជាច្រើនដែលយើងមិនទាំងដឹងផងដែរថាមាននៅក្នុងយើង ហើយថាយើងផ្ទាល់ក៏មិនអាចលុបវាចេញបានផងដែរ។ នោះគឺជារបៀបដែលព្រះគម្ពីរបានរៀបរាប់អំពីជម្រៅ និងភាពងងឹតនៃអំពើបាបរបស់យើង—វាមាននៅ*ក្នុង*យើង និងជា*របស់*យើង មិនមែនគ្រាន់តែនៅ*លើ*យើង

ប៉ុណ្ណោះទេ។

នៅជាន់ទី២នៃសារមន្ទីរជាតិប្រវត្តិសាស្ត្រនៅឯរដ្ឋវ៉ាស៊ីនតោននៅសហរដ្ឋអាមេរិក (National Museum of Natural History in Washington in America) មានគុជថ្មដ៏ធំបំផុតមួយដែលគេថាស្អាតឥតខ្ចោះ (flawless quartz sphere) នៅលើលោកនេះទាំងមូល។ គុជនោះមានទំហំធំជាងបាល់បោះតែបន្តិចប៉ុណ្ណោះ ហើយក៏មិនមានរលាត់ សូម្បីតែមួយដែលយើងអាចមើលឃើញផង មិនមានសម្លាកអុត ឬក៏ការផ្លាស់ពណ៌ទាល់តែសោះ។ វាស្អាតឥតខ្ចោះ។ ជាទូទៅ មនុស្សយើងគិតថា លក្ខណសម្បត្តិរបស់មនុស្សគឺប្រៀបដូចជាគុជថ្មនោះ។ នេះមិនមែនជាការពិតទេ ម្តងម្កាលយើងក៏ធ្វើឲ្យវាប្រឡាក់ដី និងភក់ ប៉ុន្តែក្រោមភាពក្រខ្វក់នៅមានភាពស្រស់ស្អាតដូចដើម ហើយអ្វីដែលយើងគ្រាន់តែចាំបាច់ត្រូវធ្វើនោះគឺជូតវាឲ្យស្អាត ដើម្បីត្រឡប់ទៅភាពភ្លឺរលោងដូចដើមវិញ។

ទោះជាយ៉ាងណាក៏ដោយក៏សេចក្តីបង្រៀននៅក្នុងព្រះគម្ពីរទាក់ទងទៅនឹងលក្ខណៈរបស់មនុស្សលោកគឺមិនស្អាតដូចនោះទេ។ យោងតាមព្រះគម្ពីរ ស្នូលនៃលក្ខណសម្បត្តិរបស់មនុស្សគឺមិនស្អាតទាល់តែសោះ ហើយភក់ក៏មិនគ្រាន់តែប្រឡាក់តែពីខាងក្រៅប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ គឺយើងមានពេញទៅដោយអំពើបាបទាំងស្រុងតែម្តង។ ស្នាមស្រាំ ភក់ ភាពក្រខ្វក់ និងភាពពុករលួយមានរហូតដល់ចំណុចកណ្តាល។ ដូចដែលសាវ័ក ប៉ុល បានមានប្រសាសន៍ “តាមកំណើត

9Marks Online PDF

យើង នោះយើងជាមនុស្សជាប់ក្នុងសេចក្ដីខ្ញាល់» (អេភេសូរ ២:៣)។ យើងក៏មានការរាប់បញ្ចូលក្នុងពិរុទ្ធភាពនិងភាពពុករលួយរបស់លោកអ័ដាម (រ៉ូម ៥)។ ព្រះយេស៊ូវក៏បានបង្រៀនអំពីចំណុចនេះផងដែរថា «ដ្បិតគឺពីក្នុងចិត្តនោះឯងដែលចេញអស់ទាំងគំនិតអាក្រក់ គឺការកាប់សំឡាប់គេ ផិតក្បត់ សហាយស្មន់ លួចប្លន់ ធ្វើបន្ទាល់ក្លែងក្លាយ ហើយនិងជេរប្រមាថ» (ម៉ាថាយ ១៥:១៩)។ ពាក្យអាក្រក់ៗដែលលោកអ្នកនិយាយ និងទង្វើអាក្រក់ៗដែលអ្នកប្រព្រឹត្តគឺមិនមែនកើតឡើងតែឯង។ គឺវាកើតចេញពីបេះដូងដែលអាក្រក់របស់លោកអ្នក។

អំពើបាបសោយរាជ្យលើគ្រប់ផ្នែកនៃជីវិតរបស់មនុស្សយើង។ ការយល់ដឹង បុគ្គលិកភាព អារម្មណ៍ និងមនោសញ្ចេតនារបស់យើង ហើយសូម្បីតែឆន្ទៈរបស់យើង ទាំងអស់ក៏ស្ថិតក្នុងភាពជាទាសករនៃអំពើបាបដែរ។ ហេតុដូច្នេះហើយបានជាសាវ័ក ប៉ុល បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ រ៉ូម ៨:៧៖ «ព្រោះគំនិតខាងសាច់ឈាម នោះរមែងទាស់ទទឹងនឹងព្រះ ដ្បិតមិនចុះចូលនឹងក្រិត្យវិន័យរបស់ព្រះទេ ក៏ពុំអាចនឹងចុះចូលបានផង»។ នេះគឺជាប្រយោគដែលគួរឲ្យភ្ញាក់ផ្អើល និងភ័យខ្លាច! អំពើបាបគ្រប់គ្រងលើជីវិតរបស់យើងយ៉ាងពេញលេញ—គំនិត ការយល់ដឹង និងឆន្ទៈរបស់យើង—ទោះបើយើងឃើញសិរីល្អ និងសេចក្ដីសប្បុរសរបស់ព្រះជាម្ចាស់ ក៏យើង*មិនអាចជៀសបាន*ក្នុងការបែរចេញពីវា ដោយមានការស្អប់ខ្ពើម។

វាមិនល្មមគ្រប់គ្រាន់ទេក្នុងការនិយាយថា ព្រះយេស៊ូវបានយាង

មក ដើម្បីសង្គ្រោះយើងចេញពីអំពើបាប ប្រសិនបើអ្វីដែលយើងមានន័យតាមរយៈឃ្លានោះគឺថា ទ្រង់បានយាងមក ដើម្បីសង្គ្រោះយើងចេញពីកំហុសខុសឆ្គងដាច់ដោយឡែកៗពីគ្នារបស់យើង។ មានតែនៅពេលដែលយើងទទួលស្គាល់ថា លក្ខណៈដើមរបស់យើងផ្ទាល់មានពេញទៅដោយអំពើបាប—គឺថាយើងពិតជាបាន «ស្លាប់ក្នុងការរំលងហើយក្នុងអំពើបាបដែរ» ដូចដែលសាវ័ក ប៉ុល បានមានប្រសាសន៍ (អេភេសូរ ២:១-៥)—គឺថាយើងឃើញដំណឹងដ៏ល្អនេះ ទ្រង់ថាមានរបៀបក្នុងការសង្គ្រោះយើង។

**ភាពសកម្មរបស់ព្រះជាម្ចាស់ក្នុងការជំនុំជម្រះទាស់ប្រឆាំងនឹងអំពើបាប**

ប្រយោគដែលគួរឲ្យខ្លាចខ្លាំងជាងគេបំផុតបង្អស់នៅក្នុងព្រះគម្ពីរទាំងមូលគឺនៅក្នុងកណ្ឌគម្ពីរ រ៉ូម ៣:១៩។ ខគម្ពីរនោះមាននៅក្នុងចុងបញ្ចប់នៃការចោទរបស់សាវ័ក ប៉ុល លើមនុស្សជាតិ—ដំបូងគឺសាសន៍ដទៃ បន្ទាប់មកសាសន៍យូដា—ក្នុងលក្ខណៈនៃការស្ថិតក្រោមអំពើបាប ហើយក៏មិនសុចរិតទាំងស្រុងនៅចំពោះព្រះជាម្ចាស់។ នេះគឺជាអ្វីដែលសាវ័ក ប៉ុល បានមានប្រសាសន៍ ដែលជាមោទនភាពនៃសេចក្តីសន្និដ្ឋានលើចំណុចនេះ៖ «គ្រប់ទាំងមាត់ត្រូវបិទ ហើយឲ្យលោកីយ៍ទាំងមូលជាប់មានទោសនៅចំពោះព្រះ»។

តើលោកអ្នកអាចចាប់ផ្តើមស្រមៃថានេះមានន័យយ៉ាងដូចម្តេចបានដែរឬទេ? ក្នុងការឈរនៅចំពោះព្រះជាម្ចាស់ដោយមិនមានការពន្យល់ ការទទូចអង្វរ លេស និងអំណះអំណាង? ហើយតើឃ្លាថា

យើង «ជាប់មានទោសនៅចំពោះព្រះ» មានន័យដូចម្ដេច? ដូចដែលយើងបានឃើញនៅក្នុងជំពូកមុន ព្រះគម្ពីរបានលើកឡើងយ៉ាងច្បាស់លាស់ថា ព្រះជាម្ចាស់សុចរិត និងបរិសុទ្ធ ដែលនោះមានន័យថាព្រះអង្គនឹងមិនមើលរំលងអំពើបាបឡើយ។ ប៉ុន្តែ តើនេះមានន័យយ៉ាងដូចម្ដេចត្រង់ថាព្រះជាម្ចាស់នឹងដាក់ទោសអំពើបាប ដោយជំនុំជម្រះ និងដាក់ទណ្ឌកម្មលើវា?

កណ្ឌគម្ពីរ រ៉ូម ៦:២៣ បានចែងថា «ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្ដីស្លាប់»។ បើនិយាយម្យ៉ាងវិញទៀតទៅ ការស្លាប់គឺជាកម្រៃនៃឈ្នួលដែលយើងទទួលបានសម្រាប់អំពើបាបរបស់យើង។ ហើយនេះក៏មិនមែនគ្រាន់តែផ្ដោតទៅលើការស្លាប់ខាងឯសាច់ឈាមនោះទេ។ វាគឺជាការស្លាប់ខាងឯវិញ្ញាណ គឺជាការបង្ហំនៃការបែកចេញពីអំពើបាបរបស់យើង ជាសេចក្ដីវេទនារបស់យើងក្នុងការបែកចេញពីព្រះវត្តមានរបស់ព្រះជាម្ចាស់ដែលសុចរិត និងបរិសុទ្ធ។ ហោរា អេសាយបានពណ៌នាវាដូចនេះ៖

> «គឺជាអំពើទុច្ចរិតរបស់ឯងរាល់គ្នា ដែលបានខណ្ឌជាកណ្ដាលឯង ហើយនឹងព្រះនៃឯងទេតើ ហើយអំពើបាបរបស់ឯងរាល់គ្នាបានបាំងព្រះភក្ត្រទ្រង់មិនឲ្យឯងឃើញដល់ម្ល៉េះបានជាទ្រង់មិនព្រមស្ដាប់ទេ» (អេសាយ ៥៩:២)។

ពេលខ្លះ គេនិយាយអំពីការនេះហាក់បីដូចជាថា វាគ្រាន់តែជា

អសកម្ម និងអវត្តមានយ៉ាងស្ងៀមស្ងាត់របស់ព្រះជាម្ចាស់។ ប៉ុន្តែ វាលើសពីនោះទៅទៀត។ វាគឺជាភាពសកម្មរបស់ព្រះជាម្ចាស់ក្នុងការជំនុំជម្រះទាស់ប្រឆាំងនឹងអំពើបាប ហើយព្រះគម្ពីរក៏បានចែងដែរថាវាក៏ជារឿងសកម្មភាពគួរឲ្យភ័យខ្លាច។ សូមមើលអំពីរបៀបដែលកណ្ឌគម្ពីរវិវរណៈបានពណ៌នាអំពីលក្ខណៈនៃអ្វីដែលនឹងកើតឡើងនៅថ្ងៃនៃជំនុំជំរះដ៏សុចរិត និងល្អរបស់ព្រះជាម្ចាស់។ ទេវតាទាំងប្រាំពីរនឹង «ចាក់សេចក្ដីឃោរឃៅរបស់ព្រះ ទៅលើផែនដីទៅ...» ហើយ «រួចគ្រប់ទាំងពូជមនុស្សនៅផែនដីនឹងយំសោក ដោយព្រោះទ្រង់» (វិវរណៈ ១៦:១; ១:៧)។ គេនឹងអង្វរទៅកាន់ភ្នំ និងថ្មថា «ធ្លាក់មកលើយើងដើម្បីបំបាំងយើងពីព្រះភក្ត្រព្រះអង្គ ដែលគង់លើបល្ល័ង្ក នឹងពីសេចក្ដីក្រោធរបស់កូនចៀមចេញ ដ្បិតថ្ងៃធំនៃសេចក្ដីក្រោធរបស់ទ្រង់បានមកដល់ហើយ តើអ្នកណាអាចនឹងឈរនៅបាន» (វិវរណៈ ៦:១៦-១៧)។ ពួកគេនឹងឃើញព្រះយេស៊ូវដែលជាស្ដេចលើអស់ទាំងស្ដេច និងជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់ ហើយពួកគេក៏នឹងធ្វើក្រញៀនៗ ដ្បិត «ទ្រង់ក៏ជាន់ក្នុងធុងឃ្នាបនៃស្រាទំពាំងបាយជូរ ជាសេចក្ដីឃោរឃៅរបស់សេចក្ដីខ្ញាល់នៃព្រះដ៏មានព្រះចេស្ដាបំផុត» (វិវរណៈ ១៩:១៥)។

ព្រះគម្ពីរបានបង្រៀនថា វាសនាចុងក្រោយនៃអស់អ្នកដែលមិនកែប្រែចិត្ត និងមនុស្សមានបាបដែលមិនទទួលជឿ គឺនឹងទៅកន្លែងដែលនៅអស់កល្បជានិច្ច កន្លែងធ្វើបាបសតិសម្បជញ្ញៈ ដែលគេហៅថា «ស្ថាននរក»។ កណ្ឌគម្ពីរវិវរណៈបានរៀបរាប់វាថាជា «បឹងភ្លើង និង

9Marks Online PDF

ស្ពាន់ធ័រ» ហើយព្រះយេស៊ូវបានមានបន្ទូលថាវាជាកន្លែងដែលមាន «ភ្លើងដែលពន្លត់មិនបាន» (វិវរណៈ ២០:១០; ម៉ាកុស ៩:៤៣)។

យោងតាមរបៀបដែលព្រះគម្ពីរបានលើកឡើងអំពីស្ថាននរក និងណែនាំយើងដែលគួរឲ្យប្រយ័ត្ននឹងវា ខ្ញុំមិនយល់អំពីការជំរុញរំញោចរបស់គ្រីស្ទបរិស័ទមួយចំនួនដែលហាក់បីដូចជាបានពន្យល់រំលងវាដែលពេលស្ដាប់ទៅហាក់បីដូចជាថាវាជាកន្លែងដែលអាចអត់ទ្រាំបាន។ នៅពេលដែលកណ្ឌគម្ពីរវិវរណៈលើកឡើងអំពីការដែលព្រះយេស៊ូវជាន់ក្នុងធុងឃ្នាបនៃស្រាទំពាំងបាយជូរ ជាសេចក្ដីឃោរឃៅរបស់សេចក្ដីខ្ញាល់នៃព្រះដ៏មានព្រះចេស្ដាបំផុត ហើយនៅពេលដែលព្រះយេស៊ូវផ្ទាល់បានណែនាំអំពី «ភ្លើងដែលពន្លត់មិនបាន...ជាកន្លែងដែលមានដង្កូវមិនដែលស្លាប់ ហើយភ្លើងមិនដែលរលត់ឡើយ» (ម៉ាកុស ៩:៤៣, ៤៨) នោះសំណួរដែលខ្ញុំពុំអាចជឿបានគឺៈ *ហេតុអ្វី*បានជាគ្រីស្ទបរិស័ទមានចំណាប់អារម្មណ៍ក្នុងការធ្វើឲ្យពេលយើងស្ដាប់ទៅហាក់បីដូចជាថា វាមិនសូវឃោរឃៅអញ្ចឹង? *ហេតុអ្វី*បានជាយើងកំសាន្តចិត្តមនុស្សមានបាប ដោយបំផុសនូវគំនិតដែលថា ទំនងស្ថាននរកមិនមែនជាកន្លែងដ៏អាក្រក់ខ្លាំងប៉ុន្មាននោះទេ?

**យើងមិនបានទើបតែច្នៃប្រឌិតចំណុចនេះឡើងនោះទេ**

ទិដ្ឋភាពនៃការដែលព្រះគម្ពីរបានប្រើប្រាស់ក្នុងការរៀបរាប់អំពីការជំនុំជម្រះរបស់ព្រះជាម្ចាស់ទាស់ប្រឆាំងនឹងអំពើបាបគឺពិតជាគួរឲ្យភ័យខ្លាចខ្លាំងមែនទែន។ វាពិតជាមិនមែនជារឿងដ៏គួរឲ្យភ្ញាក់ផ្អើលនោះទេ

ដែលលោកីយ៍នេះអានការពណ៌នារបស់ព្រះគម្ពីរអំពីស្ថាននរក ហើយគេហៅគ្រីស្ទបរិស័ទថា «អាក្រក់» ដោយសារជឿថា វាមានពិតមែន។

ប៉ុន្តែ នោះគឺជាការមើលរំលងចំណុចនេះហើយ។ វាមិនមែនហាក់បីដូចជាថា យើងទើបតែច្នៃប្រឌិតគំនិតទាំងអស់នោះឡើងដោយខ្លួនឯងទេ។ យើងដែលជាគ្រីស្ទបរិស័ទមិនអាន ទទួលជឿ និងនិយាយអំពីស្ថាននរក ដោយសារយើងសប្បាយជាមួយនឹងគំនិតរបស់ស្ថាននរកនោះទេ។ សូមឲ្យព្រះជាម្ចាស់ហាមប្រាម។ ទេ! ជាចុងក្រោយ យើងនិយាយអំពីស្ថាននរក ដោយសារយើងជឿលើព្រះគម្ពីរ។ យើងជឿលើព្រះគម្ពីរ នៅពេលដែលព្រះគម្ពីរលើកឡើងថាស្ថាននរកពិត ហើយយើងក៏ជឿដែរ ថាមានពេញទៅដោយទឹកភ្នែក នៅពេលដែលព្រះគម្ពីរលើកឡើងថា អ្នកដែលយើងស្រឡាញ់កំពុងតែស្ថិតនៅក្នុងគ្រោះថ្នាក់នៃការចំណាយពេលអស់កល្បជានិច្ចនៅកន្លែងនោះផងដែរ។

នេះគឺជាសេចក្តីវិនិច្ឆ័យយ៉ាងម៉ឺងម៉ាត់របស់ព្រះជាម្ចាស់មកលើយើង។ មិនមានអ្នកណាម្នាក់ក្នុងចំណោមយើងសុចរិតនោះទេ សូម្បីតែមួយក៏គ្មានផង។ ហើយដោយសារការនោះ នឹងមានថ្ងៃមួយដែលគ្រប់បបូរមាត់នឹងនៅស្ងៀម រាល់អណ្តាតដែលញុះញង់នឹងត្រូវស្ងាត់ ហើយលោកីយ៍ទាំងមូលនឹងត្រូវកាត់ទោសនៅចំពោះព្រះជាម្ចាស់។

ប៉ុន្តែ...

ជំពូកទី៤

# ព្រះយេស៊ូវដ៏ជាព្រះអង្គសង្គ្រោះ

**ជាដាច់ខាត** ខ្ញុំគិតថាពាក្យ "ប៉ុន្តែ" គឺជាពាក្យដ៏ខ្លាំងជាងគេបំផុតដែលមនុស្សយើងអាចនិយាយបាន។ វាតូច ប៉ុន្តែវាមានអំណាចក្នុងការដោះចេញនូវអ្វីៗដែលមានពីមុនមក។ នៅពេលដែលមានពាក្យ "ប៉ុន្តែ" បន្ទាប់ពីយើងទើបតែបានឮអំពីដំណឹងអាក្រក់ដូចខាងលើនេះ វាមានអំណាចក្នុងការលើកទឹកចិត្ត និងស្តារឡើងវិញនូវសេចក្តីសង្ឃឹម។ លើសជាងពាក្យនានាផ្សេងទៀតដែលអណ្តាតរបស់មនុស្សយើងអាចនិយាយបាន ពាក្យនេះមានសមត្ថភាពក្នុងការផ្លាស់ប្តូរគ្រប់អ្វីៗទាំងអស់។

- យន្តហោះបានធ្លាក់។ *ប៉ុន្តែ* មិនមានអ្នកណាម្នាក់ត្រូវរបួសឡើយ។
- លោកអ្នកមានជំងឺមហារីក។ *ប៉ុន្តែ* យើងអាចព្យាបាលវាបានយ៉ាងងាយស្រួល។
- កូនប្រុសរបស់លោកអ្នកមានគ្រោះថ្នាក់ចរាចរណ៍។ *ប៉ុន្តែ*

9Marks Online PDF

គាត់មិនអីទេ។

ជាការដែលគួរឲ្យសោកស្តាយណាស់ ពេលខ្លះមិនមានពាក្យ *"ប៉ុន្តែ"* នោះទេ។ ពេលខ្លះប្រយោគក៏បានចប់ ហើយអ្វីដែលយើងទទួលបានគឺគ្រាន់តែជាដំណឹងអាក្រក់ប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ក៏ឱកាសដូចនោះវាគ្រាន់តែពង្រីកសម្រាប់យើងនៅពេលវេលាដែលមានពាក្យ *"ប៉ុន្តែ"*។ ហើយវាពិតជាអស្ចារ្យមែន។

ខ្ញុំអរព្រះគុណព្រះជាម្ចាស់ត្រង់ថា ដំណឹងអាក្រក់នៃអំពើបាបរបស់មនុស្សលោក និងការជំនុំជម្រះរបស់ព្រះជាម្ចាស់មិនមែនជាទីបញ្ចប់នៃដំណើររឿងនោះទេ។ ប្រសិនបើព្រះគម្ពីរបានបញ្ចប់ត្រឹមការប្រកាសរបស់សាវ័ក ប៉ុល នោះផែនដីទាំងមូលនឹងឈរដោយមានភាពស្ងៀមស្ងាត់ នៅចំពោះបល្ល័ង្ករបស់ព្រះជាម្ចាស់នៃការថ្កោលទោស ហើយយើងក៏មិនមានសេចក្តីសង្ឃឹមទាល់សោះ។ គឺមានតែការអស់សង្ឃឹម។ ប៉ុន្តែ (លែងឃើញពាក្យនោះទៀតហើយ!) អរព្រះគុណព្រះជាម្ចាស់ព្រោះនៅមានទៀត!

លោកអ្នកគឺជាមនុស្សមានបាប ដែលបានកំណត់ទុកសម្រាប់ការជំនុំជម្រះ។ *ប៉ុន្តែ* ព្រះជាម្ចាស់បានប្រតិបត្តិការក្នុងការសង្គ្រោះមនុស្សបាបដូចជាលោកអ្នក!

### ពាក្យនៃសេចក្តីសង្ឃឹម

លោក ម៉ាកុស បានចាប់ផ្តើមការនិពន្ធរបស់គាត់អំពីព្រះជន្មរបស់ព្រះយេស៊ូវដោយប្រើពាក្យពេចន៍ដូចតទៅ "នេះជាដើមដំណឹងល្អពីព្រះ

9Marks Online PDF

យេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ» (ម៉ាកុស ១:១)។ ចាប់តាំងពីដើមមកលោក ម៉ាកុស និងគ្រីស្ទបរិស័ទសម័យដំបូងដឹងថា ការយាងមករបស់ព្រះយេស៊ូវគ្រីស្ទគឺជាដំណឹងល្អរបស់ព្រះជាម្ចាស់មកកាន់លោកីយ៍ដែលត្រូវវិនាស និងស្លាប់ក្រោមជើងនៃអំពើបាប។ ខណៈពេលដែលអំពើបាបមានភាពសកម្មក្នុងភាពងងឹតនៃការបំផ្លាញ នោះការយាងមករបស់ព្រះយេស៊ូវគឺជាការចាក់ទម្លុះ និងជាការប្រកាសយ៉ាងឮៗថា ឥឡូវរាល់គ្រប់អ្វីៗទាំងអស់ត្រូវបានផ្លាស់ប្តូរ!

សូម្បីតែនៅក្នុងសួនច្បារ អេដែន ព្រះជាម្ចាស់ក៏បានប្រទានឲ្យលោក អ័ដាម និងនាង អេវ៉ា នូវពាក្យពេចន៍នៃសេចក្តីសង្ឃឹមដែរ—ដំណឹងដ៏ល្អខ្លះៗខណៈពេលដែលពួកគាត់កំពុងតែស្ថិតក្នុងភាពអស់សង្ឃឹម។ វាមិនសូវជាប៉ុន្មានទេ គឺគ្រាន់តែជាតម្រុយ គឺឃ្លាចុងក្រោយមួយភ្ជាប់ជាមួយនឹងប្រយោគរបស់ព្រះជាម្ចាស់ ប្រឆាំងនឹងសត្វពស់។

> «ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ» (លោកុប្បត្តិ ៣:១៥)។

ប៉ុន្តែ វាក៏ជាអ្វីមួយដែរ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យលោក អ័ដាម និងនាង អេវ៉ា ដឹងថាដំណើររឿងមិនទាន់ចប់នៅឡើយទេ ទោះបើពួកគាត់ជាអ្នកបះបោរក៏ដោយ។ នៅត្រង់នេះ យើងឃើញមានចំណុចដំណឹងល្អខ្លះ គឺដំណឹងល្អក្នុងពេលដែលមានគ្រោះមហន្តរាយ។

កណ្ឌគម្ពីរបន្ទាប់ប្រាប់អំពីរបៀបដែលដំណើររឿងនៃគ្រាប់ពូជដ៏តូចនៃដំណឹងល្អនេះបានដុះពន្លក លូតលាស់ និងរីកធំឡើង។ អស់ប្រមាណជាពាន់ឆ្នាំ ព្រះជាម្ចាស់បានរៀបចំផែនដីនេះតាមរយៈក្រឹត្យវិន័យ និងទំនាយសម្រាប់*ការបំផ្លាញ*សត្វពស់*ចោល*ទាំងស្រុងក្នុងព្រះជន្ម ការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ។ នៅពេលដល់ទីបញ្ចប់ ពិរុទ្ធភាពដែលលោក អ័ដាម បានដាក់លើកូនចៅទាំងអស់របស់គាត់នឹងបរាជ័យ សេចក្ដីស្លាប់ដែលព្រះជាម្ចាស់បានដាក់លើរបស់សព្វសារពើដែលទ្រង់បានបង្កើតមកនឹងត្រូវដកចេញ ហើយស្ថាននរកក៏នឹងត្រូវលុតជង្គង់ដែរ។ ព្រះគម្ពីរគឺជាដំណើររឿងរបស់ព្រះជាម្ចាស់ ក្នុងការដែលព្រះអង្គវាយបកទាស់ប្រឆាំងនឹងអំពើបាបវិញ។ វាគឺជាការរៀបរាប់ដ៏រុងរឿងបំផុតនៃរបៀបដែលព្រះជាម្ចាស់ធ្វើឲ្យគ្រប់អ្វីៗទាំងអស់ត្រូវវិញ អំពីរបៀបដែលទ្រង់កំពុងតែធ្វើឲ្យវាត្រូវ ហើយអំពីរបៀបដែលថ្ងៃ និងអំពីរបៀបដែលទ្រង់ធ្វើឲ្យគ្រប់អ្វីៗទាំងអស់ត្រូវជាចុងក្រោយ និងអស់កល្បជានិច្ច។

## ព្រះ ១០០% និងមនុស្ស ១០០%

អ្នកនិពន្ធកណ្ឌដំណឹងល្អទាំងអស់សុទ្ធតែចាប់ផ្ដើមការនិពន្ធរបស់ខ្លួនអំពីព្រះជន្មរបស់ព្រះយេស៊ូវ ដោយបង្ហាញថាព្រះអង្គមិនមែនជាមនុស្សធម្មតានោះទេ។ សាវ័ក ម៉ាថាយ និងលោក លូកា បានប្រាប់អំពីរឿងទេវតាដែលបានទៅឯនាងក្រមុំព្រហ្មចារីយក្មេងម្នាក់ដែលមានឈ្មោះថានាង ម៉ារា ហើយបានប្រាប់នាងថា នាងនឹងមានគភ៌។ ដោយ

9Marks Online PDF

ពុំជឿដំណឹងនេះ នាង ម៉ារា បានសួរថា “ខ្ញុំមិនស្គាល់ប្រុសណាផង ដូច្នេះ តើធ្វើដូចម្ដេចនឹងឲ្យការនេះសម្រេចបាន?”។ ទេវតាក៏ពន្យល់ថា “ព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកសណ្ឋិតលើនាងហើយព្រះចេស្ដានៃព្រះដ៏ខ្ពស់បំផុតនឹងមកគ្របបាំងនាងដោយស្រមោល ហេតុដូច្នេះបុត្របរិសុទ្ធដែលនឹងប្រសូតមកនោះ ត្រូវហៅថាជាព្រះរាជបុត្រានៃព្រះ” (លូកា ១:៣៤-៣៥)។ សាវ័ក យ៉ូហាន បានចាប់ផ្ដើមដំណើររឿងរបស់គាត់ដោយប្រយោគដ៏គួរឲ្យភ្ញាក់ផ្អើលជាងនោះទៅទៀត៖ “កាលដើមដំបូងឡើយ” (ពាក្យពេចន៍ដែលចង្អុលយ៉ាងខ្លាំងត្រឡប់ទៅកាន់កណ្ឌគម្ពីរ លោកុប្បត្តិ ១:១) “មានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ។ ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា” (យ៉ូហាន ១:១, ១៤)។

ទាំងអស់នេះ—កំណើតរបស់ព្រះយេស៊ូវតាមរយៈស្ត្រីក្រមុំព្រហ្មចារី “ព្រះរាជបុត្រានៃព្រះ” ការដែលសាវ័ក យ៉ូហាន បានអះអាងថា “ព្រះបន្ទូលនោះឯងជាព្រះ” រួមគ្នាជាមួយនឹងការប្រកាសរបស់គាត់ដែលថា “ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម”—គឺជាចម្លើយដល់យើងថា តើព្រះយេស៊ូវជាអ្នកណា។

បើនិយាយឲ្យសាមញ្ញទៅ ព្រះគម្ពីរបានប្រាប់យើងថា ព្រះយេស៊ូវគឺជាមនុស្ស ១០០% និងជាព្រះ ១០០% ផងដែរ។ នេះគឺជាចំណុចដ៏សំខាន់ណាស់ក្នុងការយល់អំពីព្រះអង្គ ដ្បិតមានតែមនុស្ស ១០០%

និងព្រះ ១០០% ដែលជាព្រះរាជបុត្រានៃព្រះប៉ុណ្ណោះ ដែលអាចសង្គ្រោះយើងបាន។ ប្រសិនបើព្រះយេស៊ូវគ្រាន់តែជាមនុស្សដូចមនុស្សណាម្នាក់ផ្សេងទៀត—ដូចយើងក្នុងគ្រប់ចំណុច ដែលមានរួមទាំងការធ្លាក់ក្នុងអំពើបាប និងការប្រព្រឹត្តអំពើបាប—នោះព្រះអង្គនឹងមិនមានសមត្ថភាពក្នុងការសង្គ្រោះយើង ដូចដែលមនុស្សស្លាប់ម្នាក់ទៀតអាចសង្គ្រោះអ្នកផ្សេងបានដែរ។ ប៉ុន្តែ ដោយសារព្រះអង្គគឺជាព្រះរាជបុត្រានៃព្រះ ដែលគ្មានអំពើបាប ហើយមានលក្ខណៈស្មើគ្នាក្នុងរាល់ចំណុចនៃភាពជាព្រះល្អឥតខ្ចោះជាមួយនឹងព្រះវរបិតា ដូច្នេះវាក៏ជាចំណុចដ៏សំខាន់ផងដែរថា ព្រះយេស៊ូវក៏ត្រូវមានលក្ខណៈដ៏ពិតដូចយើង—ត្រង់ថាជាមនុស្ស ១០០%—ដើម្បីឲ្យព្រះអង្គអាចធ្វើជាតំណាងដ៏ពេញសិទ្ធិជំនួសយើងនៅចំពោះព្រះវរបិតាទ្រង់បាន។ ដូចដែលកណ្ឌគម្ពីរ ហេព្រើរ ៤:១៥ ពន្យល់ ព្រះយេស៊ូវមានសមត្ថភាពក្នុងការ «អាណិតអាសូរ ដល់សេចក្តីកម្សោយរបស់យើងរាល់គ្នា» ដោយសារព្រះអង្គ «បានត្រូវសេចក្តីល្បួងគ្រប់យ៉ាង ដូចជាយើងរាល់គ្នាដែរ តែឥតធ្វើបាបឡើយ»។

### ព្រះមេស្ស៊ីដ៏ជាស្តេចបានយាងមកដល់ហើយ!

នៅពេលដែលព្រះយេស៊ូវបានចាប់ផ្តើមព័ន្ធកិច្ចរបស់ទ្រង់ ព្រះអង្គបានប្រកាសសារដ៏អស្ចារ្យ៖ «ពេលវេលាបានសម្រេចហើយ នគរព្រះជិតមកដល់ ដូច្នេះ ចូរប្រែចិត្ត ហើយជឿដំណឹងល្អចុះ!»

ពាក្យពេចន៍របស់បុរសនេះ ដែលអធិប្បាយថា នគររបស់ព្រះបាន

9Marks Online PDF

មកដល់ក៏បានសាយភាយយ៉ាងឆាប់រហ័សពាសពេញប្រទេស ហើយមនុស្សម្នាដែលមានចិត្តរំភើបក៏ចាប់ផ្តើមមកជុំវិញព្រះយេស៊ូវ ដើម្បីស្តាប់ «ដំណឹងល្អ» នេះ ដែលទ្រង់កំពុងតែប្រកាស។ ប៉ុន្តែ តើអ្វីទៅធ្វើឲ្យការប្រកាសនោះរំភើបឡើង?

ជាច្រើនសតវត្សរ៍ តាមរយៈក្រឹត្យវិន័យ និងពួកហោរារបស់ទ្រង់ ព្រះជាម្ចាស់បានប្រាប់ជាមុនអំពីពេលដែលទ្រង់នឹងបញ្ឈប់អំពើអាក្រក់នៃផែនដីនេះម្តងជាសម្រេច ហើយការសង្គ្រោះរបស់ទ្រង់ចេញពីអំពើបាបរបស់ខ្លួន។ ព្រះអង្គនឹងបំផ្លាញចោលនូវរាល់ការទាស់ប្រឆាំង ហើយតាំងការសោយរាជ្យរបស់ទ្រង់ ដែលជា «នគរ» របស់ទ្រង់ លើផែនដីទាំងមូល។ លើសពីនោះទៅទៀត ព្រះជាម្ចាស់បានសន្យាថាទ្រង់នឹងតាំងនគររបស់ទ្រង់តាមរយៈបុគ្គលម្នាក់ដែលជាព្រះមេស្ស៊ីដ៏ជាស្តេច ជាបុគ្គលម្នាក់ក្នុងខ្សែស្រឡាយនៃស្តេច ដាវីឌ ដ៏អស្ចារ្យ។ នៅក្នុងកណ្ឌគម្ពីរ ២សាំយ៉ូអែល ៧:១១ ព្រះជាម្ចាស់បានសន្យាទៅកាន់ស្តេច ដាវីឌ ថា បុត្រម្នាក់ក្នុងចំណោមបុត្រនានារបស់ទ្រង់នឹងសោយរាជ្យលើរាជបល្ល័ង្ករបស់ទ្រង់អស់កល្បជានិច្ច។ ហើយហោរា អេសាយ ក៏បានលើកឡើងអំពីបុត្រាដ៏ជាស្តេចនេះថា៖

> «ហើយគេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ ព្រះដ៏មានព្រះចេស្តា ព្រះវរបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព ឯសេចក្តីចម្រើននៃរដ្ឋបាលទ្រង់ និងសេចក្តីសុខសាន្តរបស់ទ្រង់ នោះនឹងមិនចេះផុតពីបល្ល័ង្ករបស់ដាវីឌ និង

9Marks Online PDF

> នគរនៃទ្រង់ឡើយ ដើម្បីនឹងតាំងឡើង ហើយទប់ទល់ដោយសេចក្តីយុត្តិធម៌ និងសេចក្តីសុចរិត ចាប់តាំងពីឥឡូវនេះ ជារៀងរាបដរាបទៅ» (អេសាយ ៩:៦ ៧)។

ដូច្នេះ លោកអ្នកអាចស្រមៃឃើញអំពីការរំភើប ដែលគេបានស្វាគមន៍ព្រះយេស៊ូវ នៅពេលដែលព្រះអង្គបានចាប់ផ្តើមប្រកាសថា នគរនៃស្ថានសួគ៌បានយាងមកដល់ហើយ។ នេះមានន័យថា ព្រះមេស្ស៊ីតាមរយៈខ្សែស្រឡាយស្តេច ដាវីឌ ពិតជាបានមកដល់មែនហើយ!

អ្នកនិពន្ធកណ្ឌដំណឹងល្អបានទទូចថា ស្តេចក្នុងខ្សែស្រឡាយដាវីឌ នេះគឺគ្មានអ្នកណាក្រៅពីព្រះយេស៊ូវផ្ទាល់ទេ។ លោក លូកា បានសរសេរនូវពាក្យពេចន៍របស់ទេវតាដែលប្រកាសពីព្រះរាជកំណើតរបស់ព្រះយេស៊ូវទៅកាន់នាង ម៉ារា ដូចតទៅ៖

> បុត្រនោះនឹងបានជាធំឧត្តម ហើយគេនឹងហៅទ្រង់ ជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងប្រទានរាជ្យនៃហ្លួងដាវីឌ ជាឰយុកោទ្រង់ថ្វាយទ្រង់សោយ ទ្រង់នឹងសោយរាជ្យលើពួកវង្សរបស់យ៉ាកុប នៅអស់កល្បរៀងទៅ ហើយរាជ្យទ្រង់នឹងមិនផុតឡើយ (លូកា ១:៣២ ៣៣)។

សាវ័ក ម៉ាថាយ បានចាប់ផ្តើមសៀវភៅរបស់គាត់ដោយលើកឡើងនូវបញ្ជីពង្សាវតារ ដែលតាមដានរកប្រភពនៃពូជពង្សរបស់ព្រះយេស៊ូវ

9Marks Online PDF

ផ្ទាល់ទៅកាន់ស្តេច ដាវីឌ ហើយបន្ទាប់មកទៅកាន់លោក អ័ប្រាហាំផ្ទាល់។ ដោយគួរឲ្យចាប់អារម្មណ៍យ៉ាងខ្លាំង សាវ័ក ម៉ាថាយ បានរចនាបថពង្សាវតារក្សត្ររបស់គាត់ ដោយបែងចែកជាបីជំនាន់នៃដប់បួនតំណ។ ហើយតួលេខដប់បួន ដូចដែលសាសន៍យូដាដ៏ល្អម្នាក់នឹងដឹងថា គឺជាតួលេខទទួលបានតាមរយៈការបូកចំនួននៃតួអក្សរភាសាហេព្រើរ D-V-D "ដាវីឌ"។ ដូចគ្រីស្ទបរិស័ទនានា សាវ័ក ម៉ាថាយ គឺកំពុងតែប្រកាសផ្ទាល់ៗ ខណៈពេលដែលគាត់ចាប់ផ្តើមដំណើររឿងរបស់គាត់អំពីព្រះយេស៊ូវថា "ស្តេច! ស្តេច! ស្តេច!"។

**ដំណឹងល្អដែលមិនបានរំពឹងទុក—ប្រសិនបើលោកអ្នកអាចចូលទៅយកបាន**

បន្ទាប់មក ព្រះគម្ពីរសញ្ញាថ្មីក៏បានប្រាប់អំពីដំណើររឿងនៃរបៀបដែលព្រះយេស៊ូវដ៏ជាស្តេចបានចាប់ផ្តើមតាំងការសោយរាជ្យរបស់ព្រះជាម្ចាស់នៅលើផែនដី និងចាប់ផ្តើមដកនូវបណ្តាសានៃអំពើបាបចេញ។ ទោះជាយ៉ាងណាក៏ដោយ ក៏នគរដែលព្រះយេស៊ូវបានចាប់ផ្តើមតាំងមិនមានលក្ខណៈដូចអ្វីដែលសាសន៍យូដាបានរំពឹងទុក ឬក៏ចង់បានដែរ។ ពួកគេចង់បានព្រះមេស្ស៊ីដែលតាំងរាជ្យលើផែនដី ចង់បានរាជាណាចក្រផ្នែកនយោបាយ ដែលនឹងផ្តួលរំលំ ហើយយកកន្លែងជំនួសចក្រភពរ៉ូម ដែលជាអ្នកកាន់អំណាចនៅសម័យនោះ។ ទោះជាយ៉ាងណាក៏ដោយ ក៏ព្រះយេស៊ូវមិនបានស្វែងរកមកុដលើផែនដីដែរ ប៉ុន្តែអធិប្បាយ បង្រៀន ព្យាបាលអ្នកឈឺ អត់ទោសអំពើបាប ប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ និងប្រាប់អភិបាលរដ្ឋ

រ៉ូមក្នុងលក្ខខណ្ឌដែលគ្មានការប្រែប្រួលថា «នគរខ្ញុំមិនមែនត្រូវខាងលោកីយ៍នេះទេ» (យ៉ូហាន ១៨:៣៦)។

នេះមិនមែនមានន័យថា នគររបស់ទ្រង់មិនពាក់ព័ន្ធនឹងលោកីយ៍នេះនៅពេលអនាគតនោះទេ។ ទើបតែថ្មីៗនោះ ព្រះយេស៊ូវបានមានបន្ទូលទៅកាន់សម្ដេចសង្ឃថា «អ្នករាល់គ្នានឹងឃើញកូនមនុស្សអង្គុយនៅខាងស្ដាំនៃព្រះចេស្ដា ហើយទាំងមកក្នុងពពកនៅលើមេឃផង» (ម៉ាកុស ១៤:៦២) ហើយនៅក្នុងកណ្ឌគម្ពីរ វិវរណៈជំពូក២១ យើងអានអំពីការដែលទ្រង់សោយរាជ្យលើផ្ទៃមេឃថ្មី នឹងផែនដីថ្មី ដែលទទួលបានការបំផ្លាស់បំប្រែយ៉ាងខ្លាំង តាមរយៈព្រះចេស្ដារបស់ទ្រង់ ហើយក៏ទទួលបានការរំដោះចេញពីភាពជាទាសករក្រោមអំពើបាបផងដែរ។

ពិតណាស់ ទាំងអស់នេះគឺជាដំណឹងល្អដែលមិនអាចបដិសេធបាន—ប្រសិនបើលោកអ្នកអាចចូលទៅយកវាបាន។ ប៉ុន្តែ ឥឡូវនេះយើងបានត្រឡប់ទៅឯបញ្ហានៃអំពើបាបរបស់យើង ពិតមែនទេ? លុះត្រាតែមានអ្វីមួយកើតឡើង ដើម្បីដកចេញនូវពិរុទ្ធភាពនៃការមិនស្ដាប់បង្គាប់ និងការបះបោរទាស់ប្រឆាំងរបស់យើងទៅកាន់ព្រះជាម្ចាស់ យើងនៅមានការបែកបាក់គ្នាពីទ្រង់ ហើយក៏នឹងគ្មានអនាគតចូលទៅកាន់អំណរនៃផ្ទៃមេឃ និងផែនដីថ្មីផងដែរ ប៉ុន្តែគឺសម្រាប់ជាការដាក់ទណ្ឌកម្មដល់អស់កល្បជានិច្ចក្នុងស្ថាននរកវិញ។

ប៉ុន្តែ ត្រង់នេះគឺជាកន្លែងដែលដំណឹងល្អរបស់ជំនឿគ្រីស្ទបរិស័ទ

9Marks Online PDF

ឈានដល់ចំណុចដែលកាន់តែល្អយ៉ាងខ្លាំងមែនទែន។ សូមបងប្អូនមើល ព្រះយេស៊ូវដ៏ជាស្តេចមិនគ្រាន់តែបានយាងមក ដើម្បីចាប់ផ្តើមតាំងនគររបស់ព្រះជាម្ចាស់ប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីនាំមនុស្សមានបាបចូលមកកាន់នគរនោះ តាមរយៈការសុគតជំនួសពួកគេ និងសម្រាប់ជាការលោះបាបរបស់ពួកគេ ដោយទទួលយកទារុណកម្មរបស់ពួកគេលើទ្រង់ផ្ទាល់ ហើយធានានូវការអត់ទោសសម្រាប់ពួកគេ ដោយធ្វើឲ្យពួកគេសុចរិតក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់ ហើយនាំឲ្យពួកគេមានគុណសម្បត្តិក្នុងការមានចំណែកក្នុងកេរ្តិ៍មរតកនៃនគរ (កូឡុស ១:១២)។

**ស្តេចដែលរងទុក្ខ?**

«នុ៎ះន៏ កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក»! នេះជាអ្វីដែលលោក យ៉ូហាន-បាទីស្ទ បានមានប្រសាសន៍ (មានសម្លៀកបំពាក់ធ្វើពីរោមអូដ្ឋ ហោរាដែលបរិភោគកណ្តូប) នៅពេលដែលឃើញព្រះយេស៊ូវយាងសំដៅមកកាន់គាត់ (យ៉ូហាន ១:២៩)។ តើគាត់មានន័យយ៉ាងដូចម្តេច? កូនចៀមនៃព្រះ? ដែលដោះបាបមនុស្សលោក?

សាសន៍យូដានៅសតវត្សរ៍ទីមួយគ្រប់ៗរូបនឹងដឹងភ្លាមអំពីអ្វីដែលលោក យ៉ូហាន កំពុងមានន័យ ក្នុងប្រយោគ «កូនចៀមនៃព្រះ ដែលដោះបាបមនុស្សលោក»។ ប្រយោគនេះគឺជាការសំដៅទៅលើថ្ងៃបុណ្យរំលងរបស់សាសន៍យូដា ជាការរម្លឹកអំពីការអស្ចារ្យរបស់ព្រះជាម្ចាស់ក្នុងការរំដោះសាសន៍អ៊ីស្រាអែលចេញពីភាពទាសករនៅឯប្រទេសអេស៊ីព្ទប្រមាណជា១៥០០ឆ្នាំមុន។

ព្រះជាម្ចាស់បានចាក់គ្រោះកាច១០យ៉ាងលើពួកគេសម្រាប់ជាការជំនុំជម្រះទាស់ប្រឆាំងសាសន៍អេស៊ីព្ទ ហើយនៅរាល់ពេលដែលស្តេចស្រុកអេស៊ីព្ទមានចិត្តរឹងរូស និងបដិសេធមិនឲ្យពួករាស្ត្រចេញទៅ។ គ្រោះកាចចុងក្រោយគឺជាគ្រោះកាចដ៏សាហាវបំផុតក្នុងចំណោមគ្រោះកាចទាំងអស់។ ព្រះជាម្ចាស់បានប្រាប់ពួកសាសន៍អ៊ីស្រាអែលថា នៅយប់ដែលបានជ្រើសទុក នោះនឹងមានទេវតានៃសេចក្តីស្លាប់នឹងធ្វើដំណើរកាត់ទឹកដីប្រទេសអេស៊ីព្ទ ដោយសម្លាប់កូនច្បងទាំងមនុស្ស និងសត្វក្នុងប្រទេសនោះ។ ការជំនុំជម្រះដ៏សាហាវនោះក៏នឹងមានរួមទាំងសាសន៍អ៊ីស្រាអែលដែរ—លុះត្រាតែពួកគាត់ស្តាប់ការណែនាំរបស់ព្រះជាម្ចាស់ដោយយកចិត្តទុកដាក់។ ព្រះជាម្ចាស់បានប្រាប់គ្រួសារនីមួយៗឲ្យយកសត្វចៀមដែលគ្មានវិកលវិការ ឬក៏ឥតខ្ចោះ ហើយសម្លាប់វា។ ហើយបន្ទាប់មកឲ្យយកមែកហ៊ីស៊ុបមួយ ដើម្បីលាបឈាមនៅលើក្របទ្វារទាំងសងខាងផ្ទះរបស់ពួកគាត់។ បន្ទាប់មក ព្រះជាម្ចាស់សន្យាថា នៅពេលដែលទេវតានៃសេចក្តីស្លាប់ឃើញឈាមនោះគាត់នឹងរំលងផ្ទះនោះ ហើយនឹងមិនចាក់ការជំនុំជម្រះនៃសេចក្តីស្លាប់លើផ្ទះនោះឡើយ។

បុណ្យរំលង—ហើយជាពិសេសនោះគឺចៀមរំលង—បានក្លាយជាសញ្ញាសម្គាល់ដ៏សំខាន់មួយនៃគំនិតដែលថាឈ្នួលនៃសេចក្តីស្លាប់សម្រាប់អំពើបាបរបស់បុគ្គលណាម្នាក់អាចទទួលបានការបង់ថ្លៃលោះតាមរយៈការស្លាប់របស់នរណាម្នាក់ផ្សេងទៀត។ តាមពិតទៅ គំនិតនៃ

9Marks Online PDF

«ការបង់ថ្លៃលោះទទួលទោសជំនួស» (“penal substitution”) គឺជាមូលដ្ឋាននៃប្រព័ន្ធទាំងមូលនៃការថ្វាយយញ្ញបូជាក្នុងព្រះគម្ពីរសញ្ញាចាស់។ នៅថ្ងៃឲ្យបានធួននឹងបាបជាប្រចាំឆ្នាំ សម្ដេចសង្ឃបានចូលទៅក្នុងបន្ទប់កណ្ដាលនៃព្រះវិហារ ដែលគេហៅថាជាទីបរិសុទ្ធបំផុត ហើយគាត់ក៏សម្លាប់សត្វដែលល្អឥតខ្ចោះបំផុត ដើម្បីជាការបង់ថ្លៃលោះសម្រាប់អំពើបាបរបស់ប្រជាជន។ ពីមួយឆ្នាំទៅមួយឆ្នាំ ការនេះក៏បានកើតឡើង ហើយពីមួយឆ្នាំទៅមួយឆ្នាំទៀត អំពើបាបរបស់ប្រជាជនក៏ត្រូវបានទម្លាក់ជាថ្មីម្ដងទៀតទៅលើឈាមនៃកូនចៀម។

ត្រូវមានការចំណាយពេលវេលា ប៉ុន្តែមិនយូរ អ្នកដើរតាមព្រះយេស៊ូវក៏ចាប់ផ្ដើមយល់ថា បេសកម្មរបស់ទ្រង់គឺមិនមែនគ្រាន់តែចាប់ផ្ដើមតាំងនគររបស់ព្រះជាម្ចាស់ប៉ុណ្ណោះទេ ប៉ុន្តែគឺសម្រេចឡើងតាមរយៈការសុគតក្នុងនាមជាយញ្ញបូជាជំនួសរាស្ត្ររបស់ទ្រង់។ ពួកគាត់ក៏ចាប់ផ្ដើមយល់ឃើញថា ព្រះយេស៊ូវមិនមែនគ្រាន់តែជាស្ដេចប៉ុណ្ណោះនោះឡើយ។ ព្រះអង្គក៏ជាស្ដេចដែលត្រូវរងទុក្ខផងដែរ។

ព្រះយេស៊ូវផ្ទាល់បានជ្រាបតាំងពីដើមមកម្ល៉េះថា បេសកកម្មរបស់ទ្រង់គឺសុគតជំនួសមនុស្សមានបាប ដែលជារាស្ត្ររបស់ទ្រង់។ នៅពេលដែលព្រះអង្គប្រសូត ទេវតាបានប្រកាសថា «បុត្រនោះនឹងជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបាប» (ម៉ាថាយ ១:២១) ហើយលោកលូកា ក៏បានប្រាប់យើងថា «កាលជិតដល់កំណត់ ដែលទ្រង់ត្រូវឡើងទៅស្ថានសួគ៌ នោះទ្រង់ដំរង់ព្រះភក្ត្រ យាងឆ្ពោះត្រង់ទៅឯក្រុង

យេរូសាឡឹមតែម្តង» (លូកា ៩:៥១)។ ព្រះយេស៊ូវក៏បានប្រាប់ជាមុនអំពីការសុគតរបស់ទ្រង់ជាច្រើនដងនៅក្នុងកណ្ឌដំណឹងល្អផងដែរ ហើយនៅពេលដែលសាវ័ក ពេត្រុស បានព្យាយាមឃាត់ទ្រង់ដោយភាពល្ងីល្ងើក្នុងផ្លូវរបស់ទ្រង់ នោះ ព្រះយេស៊ូវក៏បានបន្ទោសគាត់ថា៖ «សាតាំងអើយ ចូរថយទៅក្រោយអញទៅ ឯងជាសេចក្តីបង្អាក់ដល់ចិត្តអញ» (ម៉ាថាយ ១៦:២៣)។ ព្រះភក្ត្ររបស់ព្រះយេស៊ូវមានការតាំងដូចជាថ្មសំដៅទៅកាន់ក្រុងយេរូសាឡឹម—ហើយជាលទ្ធផលសំដៅទៅកាន់ការសុគតរបស់ទ្រង់។

ព្រះយេស៊ូវក៏យល់អំពីចំណុចសំខាន់ និងគោលបំណងនៃការសុគតរបស់ទ្រង់ផងដែរ។ នៅក្នុងកណ្ឌគម្ពីរ ម៉ាកុស ១០:៤៥ ទ្រង់បានលើកឡើងថា «ដ្បិតកូនមនុស្សក៏បានមកមិនមែនឲ្យគេបម្រើដែរ គឺ ដើម្បីនឹងបម្រើគេវិញហើយនឹងឲ្យជីវិតខ្លួនទុកជាថ្លៃលោះមនុស្សជាច្រើនផង»។ ហើយនៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ២៦:២៨ ខណៈពេលដែលព្រះអង្គរួមចំណែកក្នុងពិធីជប់លៀងចុងក្រោយជាមួយនឹងពួកសិស្សរបស់ទ្រង់ ព្រះអង្គបានយកពែងស្រាមួយ ហើយប្រកាសថា «ចូរបរិភោគពីពែងនេះទាំងអស់គ្នាចុះ ដ្បិតនេះជាឈាមខ្ញុំគឺជាឈាមនៃសញ្ញាថ្មីដែលបានច្រួចចេញសម្រាប់មនុស្សជាច្រើនប្រយោជន៍នឹងផ្តាច់បាប» (ម៉ាថាយ ២៦:២៧-២៨)។ «ខ្ញុំស៊ូប្តូរជីវិតខ្ញុំនឹងចៀម» ព្រះអង្គបានមានបន្ទូលនៅកន្លែងមួយផ្សេងទៀត។ «គ្មានអ្នកណាដកយកជីវិតពីខ្ញុំបានទេ គឺខ្ញុំដាក់ជីវិតចុះដោយខ្លួនខ្ញុំ» (យ៉ូហាន ១០:១៥,

9Marks Online PDF

១៨)។ ព្រះយេស៊ូវបានជ្រាបអំពីមូលហេតុដែលទ្រង់ត្រូវសុគត។ ដោយកើតចេញពីសេចក្តីស្រឡាញ់សម្រាប់រាស្ត្ររបស់ទ្រង់ ព្រះអង្គក៏បានស្ម័គ្រព្រះទ័យប្រគល់ព្រះជន្មរបស់ទ្រង់ កូនចៀមនៃព្រះត្រូវបានគេសម្លាប់ ដើម្បីឲ្យរាស្ត្រទ្រង់អាចទទួលបានការអត់ទោស។

ដោយទទួលបានការបង្រៀនពីព្រះវិញ្ញាណបរិសុទ្ធ នោះគ្រីស្ទបរិស័ទសម័យដំបូងក៏យល់អំពីអ្វីដែលព្រះយេស៊ូវបានសម្រេចនៅលើឈើឆ្កាងផងដែរ។ សាវ័ក ប៉ុល បានពណ៌នាដូចនេះ «ព្រះគ្រីស្ទទ្រង់បានលោះយើងរាល់គ្នា ឲ្យរួចពីសេចក្តីបណ្តាសារបស់ក្រិត្យវិន័យ ដោយទ្រង់ត្រូវបណ្តាសាជំនួសយើងរាល់គ្នា» (កាឡាទី ៣:១៣-១៤)។ ហើយនៅក្នុងកន្លែងមួយផ្សេងទៀតគាត់ក៏បានពន្យល់ថា «ដ្បិតឯព្រះអង្គ ដែលមិនបានស្គាល់បាបសោះ នោះព្រះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះ» (២កូរិនថូស ៥:២១)។ សាវ័កពេត្រុស បានសរសេរដូចតទៅ «ព្រះគ្រីស្ទទ្រង់បានរងទុក្ខម្តងដោយព្រោះបាបដែរគឺជាព្រះដ៏សុចរិតទ្រង់រងទុក្ខជំនួសមនុស្សទុច្ចរិត ដើម្បីនឹងនាំយើងរាល់គ្នាទៅដល់ព្រះ» (ពេត្រុស ៣:១៨)។ ហើយ «ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់ជាប់លើឈើឆ្កាង ដើម្បីឲ្យយើងបានរស់ខាងឯសេចក្តីសុចរិតដោយបានស្លាប់ខាងឯអំពើបាបហើយ គឺដោយស្នាមជាំរបស់ទ្រង់ ដែលអ្នករាល់គ្នាបានជា» (១ពេត្រុស ២:២៤)។

តើលោកអ្នកឃើញអំពីអ្វីដែលគ្រីស្ទបរិស័ទទាំងអស់នេះកំពុងតែលើកឡើងអំពីចំណុចសំខាន់នៃការសុគតរបស់ព្រះយេស៊ូវដែរឬទេ? ពួកគាត់កំពុងតែលើកឡើងថា នៅពេលដែលព្រះយេស៊ូវបានសុគត គឺមិនមែនជាទារុណកម្មសម្រាប់អំពើបាបរបស់ទ្រង់ផ្ទាល់ដែលទ្រង់បានឆ្លងកាត់នោះទេ។ (ព្រះអង្គមិនមានអំពើបាបទេ!) គឺទារុណកម្មសម្រាប់អំពើបាបរបស់រាស្ត្រទ្រង់វិញទេតើ! ខណៈពេលដែលព្រះអង្គជាប់ឆ្កាងនៅឯភ្នំកាល់វ៉ារី ព្រះយេស៊ូវបានផ្ទុកនូវរាល់ទម្ងន់នៃអំពើបាបដ៏សាហាវនៃរាស្ត្ររបស់ព្រះជាម្ចាស់។ ការទាស់ប្រឆាំងទាំងអស់ ការមិនស្តាប់បង្គាប់ទាំងអស់ និងអំពើបាបទាំងអស់របស់ពួកគាត់បានធ្លាក់លើព្រះអង្គ១របស់ទ្រង់។ ហើយបណ្តាសាដែលព្រះជាម្ចាស់បានដាក់នៅឯសួនច្បារអេដែន—ការកាត់ទោសឲ្យស្លាប់—ក៏ត្រូវបានបំផ្លាញចោល។

នេះឯងជាមូលហេតុដែលព្រះយេស៊ូវបានព្រះកន្សែងដោយមានការឈឺចាប់ «ព្រះអង្គៗនៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់ចោលទូលបង្គំ» (ម៉ាថាយ ២៧:៤៦)។ ព្រះវរបិតារបស់ទ្រង់ (ដែលជាព្រះបរិសុទ្ធ និងសុចរិត ហើយព្រះនេត្ររបស់ទ្រង់បរិសុទ្ធដល់ថ្នាក់ថា មិនអាចមើលអំពើអាក្រក់បាន) បានទតមើលព្រះរាជបុត្រារបស់ទ្រង់ ហើយក៏ទតឃើញអំពើបាបនៃរាស្ត្ររបស់ព្រះរាជបុត្រារបស់ទ្រង់នៅលើព្រះអង្គារបស់ទ្រង់ ដូច្នេះព្រះអង្គក៏បានបែរចេញដោយមានការស្អប់ខ្ពើម ហើយក៏បានចាក់សេចក្តីក្រោធរបស់ទ្រង់នៅលើព្រះរាជបុត្រារបស់

9Marks Online PDF

ទ្រង់។ សាវ័ក ម៉ាថាយ បានសរសេរថា ភាពងងឹតបានគ្រប់ដណ្តប់លើផែនដីអស់រយៈពេលបីម៉ោង ខណៈពេលដែលព្រះយេស៊ូវកំពុងតែជាប់នៅលើឈើឆ្កាង។ នោះគឺជាភាពងងឹតនៃការជំនុំជម្រះ ជាទម្ងន់នៃសេចក្តីក្រោធរបស់ព្រះវរបិតាដែលធ្លាក់លើព្រះយេស៊ូវ ខណៈពេលដែលទ្រង់ផ្ទុកអំពើបាបនៃរាស្រ្តរបស់ទ្រង់ ហើយសុគតជំនួសពួកគេ។

ហោរា អេសាយ បានទាយអំពីរឿងនេះអស់ប្រមាណជាប្រាំពីរសតវត្សរ៍មុនវាបានកើតឡើង៖

> «ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្តីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្តីទុក្ខព្រួយរបស់យើងជាពិត ប៉ុន្តែយើងរាល់គ្នាបានរាប់ទ្រង់ទុកជាអ្នកមានទោសវិញ គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែលរងវេទនា តែទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើងក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់» (អេសាយ ៥៣:៤ ៥)។

តើលោកអ្នកឃើញចំណុចសំខាន់អំពីរឿងនេះដែរឬទេ? នៅចុងបញ្ចប់ នេះមានន័យថាខ្ញុំ គួរជាបុគ្គលដែលត្រូវស្លាប់ មិនមែនព្រះយេស៊ូវនោះទេ។ ខ្ញុំគួរជាបុគ្គលដែលទទួលទារុណកម្ម មិនមែនព្រះអង្គនោះទេ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយក៏ព្រះអង្គបានយកកន្លែង

9Marks Online PDF

ជំនួសខ្ញុំដែរ។ ព្រះអង្គបានសុគតសម្រាប់ខ្ញុំ។

វាជាអំពើរំលងរបស់ខ្ញុំ ប៉ុន្តែជារបួសរបស់ទ្រង់។ អំពើទុច្ចរិតរបស់ខ្ញុំ ប៉ុន្តែការវាយផ្ចាលរបស់ទ្រង់។ អំពើបាបរបស់ខ្ញុំ សេចក្តីទុក្ខព្រួយរបស់ទ្រង់។ ហើយការវាយផ្ចាលរបស់ទ្រង់បាននាំជាមេត្រីដល់ខ្ញុំ។ ស្នាមរំពាត់របស់ទ្រង់បាននាំមកនូវការព្យាបាលដល់ខ្ញុំ។ សេចក្តីឈឺចាប់របស់ទ្រង់សម្រាប់អំណាររបស់ខ្ញុំ។

ការសុគតរបស់ទ្រង់សម្រាប់ជីវិតរបស់ខ្ញុំ។

## ចំណុចស្នូលនៃដំណឹងល្អ

វាពិតជាគួរឲ្យសោកស្តាយណាស់ ដែលការបង្រៀននៃការជំនួសនេះទំនងជាផ្នែកមួយនៃដំណឹងល្អរបស់គ្រីស្ទបរិស័ទដែលលោកីយ៍នេះស្អប់ខ្លាំងជាងគេបំផុត។ ជាទូទៅ មនុស្សយើងស្អប់ខ្ពើមលើគំនិតដែលថា ព្រះយេស៊ូវបានទទួលការរងទុក្ខជំនួសអំពើបាបរបស់បុគ្គលណាផ្សេង។ មានអ្នកនិពន្ធមួយចំនួនបានហៅការនេះថាជា “ការដែលព្រះរំលោភបំពានបុត្រារបស់ទ្រង់”។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ការបដិសេធដង្វាយនៃការធួននឹងបាបជំនួស គឺជាការកាត់ចោលនូវចំណុចស្នូលនៃដំណឹងល្អ។ ដើម្បីឲ្យកាន់តែប្រាកដ មានរូបភាពជាច្រើនក្នុងព្រះបន្ទូលទាក់ទងនឹងអ្វីដែលព្រះគ្រីស្ទបានសម្រេចតាមរយៈការសុគតរបស់ទ្រង់៖ គំរូ ការផ្សះផ្សា និងជ័យជំនះ បើគ្រាន់តែលើកឡើងបីចំណុច។ ប៉ុន្តែ នៅខាងក្រោមចំណុចទាំងអស់នោះគឺមានធាតុពិតនៃការចង្អុលទៅលើរូបភាពទាំងអស់ផ្សេងទៀត—ការ

9Marks Online PDF

បង់ថ្លៃលោះទទួលទោសជំនួស។ យើងមិនអាចគ្រាន់តែដកវាចេញបានឡើយ ឬក៏បន្ទាបបន្ថោកវាដោយសារពេញចិត្តលើរូបភាពផ្សេងៗទៀត បើមិនដូច្នោះទេនោះលោកអ្នកនឹងពង្រាយទ្រង់ទ្រាយនៃព្រះគម្ពីរនូវសំណួរដែលមិនមានចម្លើយ។ ហេតុអ្វីចាំបាច់មានយញ្ញបូជា? តើការបង្ហូរឈាមនោះបានសម្រេចអ្វី? តើព្រះជាម្ចាស់អាចមានសេចក្ដីមេត្តាករុណាលើមនុស្សមានបាប ដោយមិនបំផ្លាញភាពយុត្តិធម៌បានដោយរបៀបណា? តើវាអាចមានន័យថាដូចម្ដេចដែលថាព្រះជាម្ចាស់អាចអត់ទោសអំពើទុច្ចរិត អំពើរំលង និងអំពើបាប ហើយស្របពេលនោះមិនបានអត់ឱនអ្នកមានពិរុទ្ធភាព (និក្ខមនំ ៣៤:៧)? តើព្រះដែលសុចរិត និងបរិសុទ្ធអាចបង្ហាញភាពយុត្តិធម៌ដល់មនុស្សដែលមិនកោតខ្លាចទ្រង់បានដោយរបៀបណា (រ៉ូម ៤:៥)?

យើងអាចរកឃើញនូវចម្លើយលើសំណួរទាំងអស់នោះនៅឯឈើឆ្កាងលើភ្នំកាល់វ៉ារី ក្នុងការសុគតរបស់ព្រះយេស៊ូវជំនួសរាស្ត្ររបស់ទ្រង់។ ព្រះដ៏សុចរិត និងបរិសុទ្ធអាចរាប់មនុស្សអាក្រក់ដោយយុត្តិធម៌បាន ដោយសារការសុគតរបស់ព្រះយេស៊ូវ សេចក្ដីមេត្តាករុណា និងភាពយុត្តិធម៌បានផ្សះផ្សាគ្នាយ៉ាងល្អឥតខ្ចោះ។ បណ្ដាសាក៏ត្រូវបានដកចេញដោយយុត្តិធម៌ ហើយយើងក៏ទទួលបានសេចក្ដីសង្គ្រោះដែលពេញទៅដោយមេត្តាករុណាដែរ។

## ព្រះអង្គបានមានព្រះជន្មរស់ឡើងវិញ

ពិតណាស់! ទាំងអស់នេះគឺជាការពិត—ហើយដំណឹងល្អ—គឺជា

9Marks Online PDF

ដោយសារព្រះយេស៊ូវដ៏ជាស្ដេច ដែលគេបានឆ្កាងមិននៅសុគតទៀតឡើយ។ ព្រះអង្គបានមានព្រះជន្មរស់ពីផ្នូរឡើងវិញ។ មន្ទិលសង្ស័យទាំងអស់ដែលពួកសិស្សមានខណៈពេលដែលព្រះយេស៊ូវបានសុគតក៏ត្រូវបានដកចេញ ក្នុងរំពេចដែលពួកទេវតាបានមានប្រសាសន៍ទៅកាន់ពួកស្ត្រីថា «ហេតុអ្វីបានជាមករកព្រះអង្គដែលមានព្រះជន្មរស់នៅក្នុងទីខ្មោចស្លាប់ដូច្នេះ? ទ្រង់មានព្រះជន្មរស់ឡើងវិញហើយ» (លូកា ២៤:៥-៦)។

ប្រសិនបើព្រះគ្រីស្ទនៅបន្តសុគតដូចជា «អ្នកសង្គ្រោះផ្សេងទៀត» ឬក៏ «គ្រូផ្សេងទៀត» ឬក៏ «ពួកហោរាផ្សេងទៀត» នោះការសុគតរបស់ទ្រង់មិនមានអត្ថន័យលើសជាងការស្លាប់របស់លោកអ្នក និងខ្ញុំនោះទេ។ រលកនៃសេចក្ដីស្លាប់នឹងត្រូវបានបក់បោកគ្របលើទ្រង់ ដូចដែលវាធ្វើលើមនុស្សផ្សេងទៀត នោះការអះអាងទាំងអស់ដែលទ្រង់បានលើកឡើងនឹងត្រឡប់ទុកជាអសារបង់ ហើយមនុស្សលោកនឹងនៅបន្តគ្មានសង្ឃឹមក្នុងការទទួលបានការសង្គ្រោះចេញពីអំពើបាប។ ប៉ុន្តែនៅពេលដែលខ្យល់ដង្ហើមបានចូលទៅក្នុងសួតដែលមានព្រះជន្មរស់នៅវិញរបស់ទ្រង់ជាថ្មីម្ដងទៀត នៅពេលដែលព្រះជន្មនៃការរស់ឡើងវិញបានបញ្ឆេះព្រះកាយដែលពេញដោយសិរីល្អរបស់ទ្រង់ នោះរាល់គ្រប់អ្វីៗដែលព្រះយេស៊ូវបានអះអាងក៏ ត្រូវទទួលបានការបង្ហាញថាត្រឹមត្រូវយ៉ាងពេញទី នៅចុងបញ្ចប់ ដោយមិនអាចសួរដេញដោល ឬក៏លុបចោលបាន។

9Marks Online PDF

សាវ័ក ប៉ុល បានបង្ហាញក្ដីរីករាយនៅក្នុងកណ្ឌគម្ពីររ៉ូមជំពូក៨លើការមានព្រះជន្មរស់នៅវិញរបស់ព្រះយេស៊ូវ និងអំពីអត្ថន័យនៃការនោះសម្រាប់អ្នកជឿ៖

> “តើអ្នកណានឹងចោទប្ដឹងពីពួករើសតាំងរបស់ព្រះបាន ដ្បិតគឺជាព្រះហើយ ដែលទ្រង់រាប់គេជាសុចរិត តើអ្នកណានឹងកាត់ទោសគេបាន ដ្បិតព្រះគ្រីស្ទទ្រង់បានសុគតជំនួសគេហើយ តែដែលថា ទ្រង់រស់ឡើងវិញ នោះមានទំនងជាង ទ្រង់ក៏គង់នៅខាងស្ដាំនៃព្រះ ហើយជាអ្នកអង្វរជំនួសយើងរាល់គ្នាដែរ” (រ៉ូម ៨:៣៣ ៣៤)។

នេះជាគំនិតដ៏អស្ចារ្យមែន—ដែលថា ឥឡូវនេះព្រះយេស៊ូវដែលជាមនុស្សកំពុងគង់នៅក្នុងសិរីរុងរឿងនៅឯខាងស្ដាំព្រះហស្តរបស់ព្រះវរបិតាទ្រង់នៅឯស្ថានសួគ៌ ដោយកំពុងសោយរាជ្យក្នុងនាមជាស្ដេចនៃចក្រវាល! ហើយលើសពីនោះទៅទៀត ឥឡូវនេះក៏ព្រះអង្គកំពុងតែអង្វរជំនួសរាស្ត្ររបស់ទ្រង់ សូម្បីតែខណៈពេលដែលយើងកំពុងរង់ចាំការយាងត្រឡប់មកវិញជាចុងក្រោយរបស់ទ្រង់ ដែលពេញដោយសិរីល្អ។

ប៉ុន្តែ ចំណុចទាំងអស់នេះបំផុសឡើងនូវសំណួរមួយទៀត៖ តើអ្នកណាជា “រាស្ត្ររបស់ទ្រង់”?

9Marks Online PDF

ជំពូកទី៥

# ការឆ្លើយតប—ជំនឿ និងការកែប្រែចិត្ត

ខ្ញុំបានចាប់ផ្ដើមបង្រៀនកូនប្រុសខ្ញុំឲ្យចេះហែលទឹកតាំងពីគាត់នៅក្មេង។ វាជាការងារដែលនឿយហត់ណាស់។ កាលនោះ គាត់ទើបតែមានអាយុមួយឆ្នាំជាង គាត់មិនចូលចិត្តទាំងឲ្យទឹកប៉ះមុខគាត់ក្នុងចានក្លាំផង ហើយក៏កាន់តែមិនចូលចិត្តអាងហែលទឹកធំ ប្រៀបដូចជាសមុទ្រដែលគាត់កំពុងតែមើលឥឡូវនេះដែរ។ ជាដំបូង «ការបង្រៀនឲ្យគាត់ចេះហែលទឹក» មានន័យថាខ្ញុំព្យាយាមឲ្យគាត់បាចទឹកលេងបន្តិចបន្តួចនៅលើកាំជណ្ដើរ ឬក៏ទំនងជាឲ្យគាត់ដាក់មាត់ផ្លុំទឹកលេងប្រសិនបើគាត់ពិតជាមានអារម្មណ៍ក្លាហានមែន។

មិនយូរមិនឆាប់ ខ្ញុំក៏បានបបួលគាត់ឲ្យហ៊ានដើរជុំវិញជាមួយខ្ញុំនៅឯកន្លែងរាក់ៗ ដោយគាត់បានតោងកខ្ញុំយ៉ាងជាប់។ បន្ទាប់ពីយើងបានក្លាយជាអ្នកជំនាញនៅកន្លែងនោះ   យើងក៏បានឡើងកម្រិតដោយឈានទៅលោតពីគែមអាង។ ដោយបំពេញតួនាទី ក្នុងនាមជាឪពុក ដែលព្រះជាម្ចាស់បានប្រទានមកខ្ញុំ ខ្ញុំក៏បានលើកគាត់ចេញពីអាងហែលទឹក ដាក់គាត់នៅលើគែមអាង ហើយនិយាយទៅគាត់ថា

9Marks Online PDF

“លោតមកៗ!”។

ខ្ញុំគិតថា នៅពេលនោះ កូនប្រុសខ្ញុំដែលទើបតែមានអាយុមួយឆ្នាំជាងបានគិតថាខ្ញុំជាមនុស្សឆ្កួតហើយ។ ក្នុងរយៈពេលតែពីរវិនាទី ទឹកមុខរបស់គាត់ឆ្លងចេញពីការយល់ច្រឡំទៅការងាយស្រួលយល់ ឆ្លងចេញពីការរីករាយទៅការបដិសេធ រហូតដល់ការមិនគោរពទាំងស្រុងតែម្តង។ គាត់បានចងចិញ្ចើម ហើយនិយាយថា “ទេ! ខ្ញុំទៅម៉ាក់”។ ជាថ្មីម្តងទៀត ដោយប្រព្រឹត្តឡើងដោយស្មោះត្រង់ ក្នុងនាមជាអ្នកដែលមានទំនួលខុសត្រូវយ៉ាងម៉ឺងម៉ាត់ជាឪពុក ខ្ញុំក៏មិនព្រមចុះចាញ់ ដេញចាប់គាត់ ហើយមិនយូរមិនឆាប់ក៏ធ្វើឲ្យគាត់មានចិត្តក្លាហាន (ដោយមានការសូកប៉ាន់គាត់ជាច្រើន) ដោយត្រឡប់មកអាងហែលទឹកវិញ។ ហើយយើងក៏ឈានដល់ពេលសំខាន់ដែលបានល្បងលោគាត់ ដែលនឹងចាស់ឥទ្ធិពលលើអនាគតគាត់។

ខ្ញុំក៏បានលោតចូលទឹកជាថ្មីម្តងទៀត ឈរនៅពីមុខគាត់ដោយមានការឈោងដៃ ហើយមើលគាត់មុជងើបៗក្នុងខោហែលទឹកគាត់ដែលក្មេងអាយុមួយឆ្នាំធ្វើនៅពេលដែលគាត់មានអារម្មណ៍ថាចង់លោតបន្តិច និងមិនចង់លោតបន្តិច។ ខ្ញុំបាននិយាយទៅកាន់គាត់ថា “លោតមកកូន។ ប៉ានៅទីនេះ។ ប៉ានឹងចាប់កូន។ ប៉ាសន្យា!”។ គាត់បានមើលខ្ញុំដោយមានការសង្ស័យខ្លះៗ ហើយក៏ព្យាយាមធ្វើសេចក្តីសន្និដ្ឋានជាថ្មីម្តងទៀត ដោយបន្ទន់ជង្គង់ ហើយបន្ទាប់មកក៏បានធ្លាក់ចូលអាងហែលទឹក ដែលជាក់ស្តែងធ្លាក់ប្រូង ជាជាងលោត

9Marks Online PDF

ចូល។

ហើយខ្ញុំក៏បានចាប់គាត់។

បន្ទាប់ពីពេលនោះ ការលោតនោះក៏ដំណើរការទៅមុខ។ «ម្ដងទៀត ប៉ាៗ! ធ្វើទៀត!»។ ហើយយើងក៏ធ្វើការនោះរយៈពេលកន្លះម៉ោង៖ លោត ចាប់ លើក ម្ដងទៀត លោត ចាប់ លើក ម្ដងទៀត។

ពេលយើងឈប់ ប្រពន្ធខ្ញុំ និងខ្ញុំក៏ចាប់ផ្ដើមបារម្ភថា ទំនងកូនប្រុសរបស់យើងមានការសាំពេកហើយជាមួយនឹងទឹក។ ចុះបើសិនជាគាត់លួចទៅកន្លែងហែលទឹកដោយគ្មានអ្នកណានៅជាមួយនឹងគាត់? តើគាត់នឹងចាំអំពីរាល់ពេលដែលគាត់បានលោតចូលក្នុងទឹកដោយមានសុវត្ថិភាព ហើយសម្រេចចិត្តថាគាត់ចេះគ្រប់គ្រងការលេងទឹក? តើគាត់នឹងលោតចូលម្ដងទៀត?

ប្រមាណថ្ងៃបន្ទាប់ យើងក៏មើលគាត់នៅក្បែរអាងហែលទឹក ហើយអ្វីដែលយើងឃើញក៏កំសាន្តចិត្តខ្ញុំក្នុងនាមជាឪពុក និងប៉ះពាល់ចិត្តខ្ញុំយ៉ាងខ្លាំង។ សូម្បីតែម្ដង ក៏យើងមិនដែលឃើញកូនប្រុសរបស់យើងគិតអំពីការលោតចូលក្នុងទឹកផងដែរ—យ៉ាងហោចណាស់ លុះត្រាតែខ្ញុំឈរនៅពីក្រោមគាត់ដោយឈោងដៃឡើងលើ ដោយសន្យាថានឹងចាប់គាត់។ គឺនៅពេលនោះឯងដែលគាត់នឹងលោត។

សូមគិតជាមួយខ្ញុំ ទោះបើកូនខ្ញុំបានជោគជ័យយ៉ាងជាក់ស្ដែង កូនប្រុសខ្ញុំក៏មិនបានទុកចិត្តសមត្ថភាពរបស់គាត់ផ្ទាល់ក្នុងការលេងទឹកនោះទេ។ គឺគាត់ទុកចិត្តឪពុកគាត់ និងក្នុងសេចក្ដីសន្យារបស់ឪពុក

9Marks Online PDF

គាត់ថា “លោតមកកូន! ប៉ានៅទីនេះ! ប៉ានឹងចាប់កូន! ប៉ាសន្យា!”។

## ការណែនាំអំពីជំនឿ និងការកែប្រែចិត្ត

លោក ម៉ាកុស បានប្រាប់យើងថា ព្រះយេស៊ូវបានចាប់ផ្ដើមព្រះរាជកិច្ចរបស់ទ្រង់ដោយអធិប្បាយថា “ពេលវេលាបានសម្រេចហើយ នគរព្រះជិតមកដល់ ដូច្នេះ ចូរប្រែចិត្ត ហើយជឿដំណឹងល្អចុះ” (ម៉ាកុស ១:១៥)។ ការបង្គាប់នោះ—ចូរប្រែចិត្ត ហើយជឿ—គឺជាអ្វីដែលព្រះជាម្ចាស់ទាមទារពីយើង ក្នុងការឆ្លើយតបចំពោះដំណឹងល្អរបស់ព្រះយេស៊ូវ។

ពាសពេញព្រះគម្ពីរសញ្ញាថ្មី នេះគឺជាអ្វីដែលយើងឃើញពួកសាវ័កបានត្រាស់ហៅឲ្យមនុស្សម្នាធ្វើ។ ព្រះយេស៊ូវបានបង្គាប់អ្នកស្ដាប់ទ្រង់ឲ្យកែប្រែចិត្ត និងទទួលជឿដំណឹងល្អ។ នៅចុងបញ្ចប់នៃសេចក្ដីអធិប្បាយរបស់សាវ័ក ពេត្រុស នៅថ្ងៃបុណ្យទី៥០ គាត់បានប្រាប់អ្នកស្ដាប់ថា “ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ” (កិច្ចការ ២:៣៨)។[១] សាវ័ក ប៉ុល បានពន្យល់នៅក្នុងព័ន្ធកិច្ចរបស់គាត់ក្នុងកណ្ឌគម្ពីរ កិច្ចការ ២០:២១ ថា៖ “ក៏ធ្វើបន្ទាល់អស់ពីចិត្ត ដល់ទាំងពួកសាសន៍យូដា នឹងពួកសាសន៍ក្រិកផង គឺពីការប្រែចិត្តទៅឯព្រះ ហើយពីសេចក្ដីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើងរាល់

១. ការទទួលពធជ្រមជទឹកក្នុងព្រះនាមព្រះយេស៊ូវគឺជាការបង្ហាញថា មានជំនឿលេទ្រង់។

9Marks Online PDF

គ្នា»។ ហើយនៅក្នុងកណ្ឌគម្ពីរ កិច្ចការ ២៦:១៨ គាត់បានរៀបរាប់អំពីរបៀបដែលព្រះយេស៊ូវផ្ទាល់បានចាត់ឲ្យគាត់ទៅៈ

> «ប្រយោជន៍នឹងបំភ្លឺភ្នែកគេ ឲ្យបានបែរចេញពីសេចក្តីងងឹតមកឯពន្លឺ ហើយពីអំណាចអារក្សសាតាំង មកឯព្រះវិញ [មានន័យថា កែប្រែចិត្ត] ដើម្បីឲ្យគេបានរួចពីបាប ហើយបានទទួលមរតក ជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយសារសេចក្តីជំនឿជឿដល់ខ្ញុំ»។

ជំនឿ និងការកែប្រែចិត្ត។ នេះគឺជាចំណុចសម្គាល់ថា អ្នកណាជារាស្ត្ររបស់ព្រះគ្រីស្ទ ឬក៏ជា «គ្រីស្ទបរិស័ទ»។ និយាយម្យ៉ាងវិញទៀតទៅ គ្រីស្ទបរិស័ទម្នាក់គឺជាបុគ្គលដែលបានបែរចេញពីអំពើបាបរបស់ខ្លួន ហើយបានទុកចិត្តលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ—មិនលើអ្វីផ្សេងទៀតឡើយ—ដើម្បីសង្គ្រោះឲ្យរួចពីអំពើបាប និងការជំនុំជម្រះដែលនឹងកើតឡើង។

## ជំនឿគឺជាការទុកចិត្ត

ពាក្យ *«ជំនឿ»* គឺជាពាក្យមួយដែលគេបានប្រើប្រាស់មិនត្រឹមត្រូវអស់រយៈពេលជាយូរឆ្នាំ ហើយមនុស្សជាច្រើនក៏មិនយល់ថា វាពិតជាមានន័យយ៉ាងដូចម្តេចផងដែរ។ ប្រសិនបើលោកអ្នកសួរបុគ្គលណាម្នាក់នៅតាមដងផ្លូវឲ្យពណ៌នាពាក្យ «ជំនឿ» ហើយទោះបើលោកអ្នកនឹងទទួលបានពាក្យពេចន៍ជាការពណ៌នាដែលស្តាប់ទៅវិញដោយមាន

9Marks Online PDF

ការគោរពខ្លះៗក៏ដោយ នោះក៏ចំណុចស្នូលនៃចម្លើយនឹងទំនងជាមានការលើកឡើងថា ជំនឿគឺជាការជឿដែលប្រឆាំងនឹងភស្តុតាងដែលគួរឲ្យអស់សំណើចណាស់។

នៅប្រទេសអាមេរិក ដែលជាស្រុកកំណើតខ្ញុំ មានឆ្នាំមួយខ្ញុំបានមើលក្បួនដង្ហែសម្រាប់ថ្ងៃដឹងគុណរបស់ក្រុមមេស៊ី (Macy's Thanksgiving Day Parade. មេស៊ីជាហាងលក់ទំនិញធំមួយនៅសហរដ្ឋអាមេរិក) ជាមួយនឹងកូនច្បងរបស់ខ្ញុំតាមទូរទស្សន៍។ "ជឿ!" គឺជាប្រធានបទនៃកម្មវិធីនោះ ហើយចំណុចកណ្តាល ដែលគេបានដាក់នៅលើកន្លែងឈរ ដើម្បីពិនិត្យ គឺយុទ្ធនាការដែលគេហៅថា "រង្វាស់ការជឿ"។ រាល់ពេលដែលការបណ្តែតថ្មីបានឆ្លងកាត់ ឬក៏ក្រុមតន្ត្រីបានផ្គុំ ឬក៏អ្នករាំបានរាំក្នុងសំលៀកបំពាក់ទេវតា នោះទ្រនិចនៃរង្វាស់ការជឿក៏លោតរៀងខ្ពស់បន្តិច។ ពិតណាស់! ផ្នែកសំខាន់នៃក្បួនដង្ហែនោះ គឺនៅពេលដែលលោក សាន់តា ក្លស់ ផ្ទាល់បានជិះចូល—ដែលគេបានរចនាគាវទឹកកករបស់គាត់ក្នុងរបៀបដែលប្លែក ដោយយករូបរាងតាមសត្វក្ងានដែលប្រកបដោយការទាក់ទាញអារម្មណ៍—ហើយរង្វាស់ការជឿក៏បានលោតយ៉ាងខ្ពស់! ភ្លេងតន្ត្រីក៏ឮលើសដើម មានការលោតរាំកញ្ឆេងយ៉ាងខ្លាំង មានការបាញ់ក្រដាសពណ៌ជាច្រើន និងការស្រែកយ៉ាងឮៗពីក្មេងៗ—មានរួមទាំងការស្រែកពីមនុស្សចាស់ៗដែរ—នៅពេលនោះ ប្រសិនបើមានអ្នកមកលេងពីភពផ្សេងឃើញ នោះគេនឹងប្រាកដជាសន្មតថា អ្នកនៅរដ្ឋវើចិននា (Virginia) ពិតជាជឿ

9Marks Online PDF

លើការនេះមែន។

កូនខ្ញុំដែលទើបតែមានអាយុ៦ឆ្នាំបានគិតថា កម្មវិធីអ៊ូអរនេះគួរឲ្យអស់សំណើចមែន។ សូមព្រះប្រទានពរគាត់។

ប៉ុន្តែ ឥឡូវនេះគឺជាអ្វីដែលលោកីយ៍គិតអំពីជំនឿ។ វាជាការសម្តែងល្បែងដែលសប្បាយ និងកំសាន្តចិត្តដែលមនុស្សមានសេរីភាពក្នុងការចូលរួមប្រសិនបើពួកគេចង់ ប៉ុន្តែមិនមានការតភ្ជាប់ទៅនឹងពិភពលោកនេះឡើយ។ ក្មេងៗជឿលើលោក សាន់តា ក្លស់ និងសត្វទន្សាយដែលយកកាដូឲ្យពួកគេ។ អ្នកមានជំនឿលើអធិធម្មជាតិជឿលើរឿងវេទមន្ត។ ចុះគ្រីស្ទបរិស័ទវិញ? ពួកគេជឿលើព្រះយេស៊ូវ។

ទោះយ៉ាងណាក៏ដោយ សូមអានព្រះគម្ពីរ នោះលោកអ្នកនឹងឃើញថា ជំនឿមិនមានអ្វីដូចទៅនឹងការបំផ្លើសនោះទេ។ ជំនឿមិនមែនជាការជឿលើអ្វីដែលលោកអ្នកមិនអាចផ្តល់ភ័ស្តុតាងឲ្យបាន ដូចដែលមនុស្សជាច្រើនបានផ្តល់អត្ថន័យលើឡើយ។ យោងតាមព្រះគម្ពីរ ជំនឿគឺជាការទុកចិត្ត។ ជំនឿគឺជាថ្មដ៏រឹងមាំ មានមូលដ្ឋាននៅលើសេចក្តីពិត ផ្តើមឡើងដោយមានសេចក្តីសន្យានៃការមានទំនុកចិត្តលើព្រះយេស៊ូវដែលបានមានព្រះជន្មរស់ឡើងវិញ ដើម្បីសង្គ្រោះលោកអ្នកឲ្យរួចពីអំពើបាប។

ក្នុងការវែកញែករបស់សាវ័ក ប៉ុល អំពីលោក អ័ប្រាហាំ នៅក្នុងកណ្ឌគម្ពីររ៉ូមជំពូក៤ គាត់បានប្រាប់យើងអំពីលក្ខណៈនៃជំនឿ។ ខាងក្រោមនេះគឺជារបៀបដែលគាត់បានពណ៌នាអំពីជំនឿរបស់លោក

9Marks Online PDF

អ័ប្រាហាំ៖

> “ដ្បិតកាលលោកអស់ទីសង្ឃឹមហើយ នោះក៏ចេះតែជឿដោយសង្ឃឹមវិញ ដើម្បីឲ្យបានត្រឡប់ជាឪពុកដល់សាសន៍ជាច្រើន ដូចសេចក្តីដែលមានបន្ទូលទុកមកថា “ពូជឯងនឹងបានដូច្នោះ” ហើយដោយព្រោះលោកមិនខ្សោយខាងសេចក្តីជំនឿ បានជាលោកមិនគិតពីរូបកាយលោក ដែលរាប់ដូចជាស្លាប់ ដោយមានអាយុប្រហែលជា១០០ឆ្នាំហើយ ឬពីផ្ទៃសារ៉ា ដែលរាប់ដូចជាស្លាប់ដែរនោះទេ លោកក៏មិនបានសង្ស័យចំពោះសេចក្តីសន្យារបស់ព្រះ ដោយចិត្តមិនជឿឡើយ គឺរឹតតែមានសេចក្តីជំនឿខ្លាំងឡើង ទាំងសរសើរដំកើងដល់ព្រះវិញ ហើយក៏ជឿជាក់អស់ពីចិត្តថា សេចក្តីអ្វីដែលទ្រង់សន្យា នោះអាចនឹងធ្វើឲ្យសម្រេចបាន” (រ៉ូម ៤:១៨ ២១)។

មិនថាមានការទាស់ប្រឆាំងជាច្រើននឹងការសន្យារបស់ព្រះជាម្ចាស់—ដូចជាអាយុរបស់លោក អ័ប្រាហាំ អាយុប្រពន្ធគាត់ និងភាពជាស្ត្រីអា—ក៏លោក អ័ប្រាហាំ នៅជឿលើអ្វីដែលព្រះជាម្ចាស់បានមានបន្ទូលដែរ។ គាត់ទុកចិត្តលើព្រះជាម្ចាស់ដោយមិនមានការរារែ ហើយពឹងលើព្រះអង្គឲ្យសម្រេចនូវសេចក្តីសន្យារបស់ទ្រង់។ ពិតណាស់ ជំនឿរបស់លោក អ័ប្រាហាំ មិនមែនជាជំនឿដែលល្អឥតខ្ចោះនោះទេ។ កំណើតរបស់លោក អ៊ីសម៉ាអែល ជាមួយនឹងនាង ហាការ បានបង្ហាញថា៖ ជាដំបូងលោក អ័ប្រាហាំ បានព្យាយាមពឹងលើ

9Marks Online PDF

គម្រោងការរបស់គាត់ក្នុងការបំពេញសេចក្តីសន្យារបស់ព្រះជាម្ចាស់វិញ។ ប៉ុន្តែ បន្ទាប់ពីគាត់បានកែប្រែចិត្តចេញពីអំពើបាបនោះ នៅចុងបញ្ចប់លោក អ័ប្រាហាំ បានដាក់ជំនឿរបស់គាត់លើព្រះជាម្ចាស់។ គាត់បានទុកចិត្តលើព្រះជាម្ចាស់ ដូចដែលសាវ័ក ប៉ុល បានលើកឡើង "ហើយក៏ជឿជាក់អស់ពីចិត្តថា សេចក្តីអ្វីដែលទ្រង់សន្យា នោះអាចនឹងធ្វើឲ្យសម្រេចបាន"។

ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទត្រាស់ហៅឲ្យយើងធ្វើដូចនោះដែរ—គឺឲ្យយើងដាក់ជំនឿរបស់យើងលើព្រះយេស៊ូវ រំពឹងលើទ្រង់ និងទុកចិត្តលើទ្រង់ក្នុងការធ្វើនូវអ្វីដែលទ្រង់បានសន្យាថានឹងធ្វើ។

## ជំនឿសម្រាប់ការសម្រេចចិត្តដ៏សុចរិត

ប៉ុន្តែ តើយើងកំពុងរំពឹងលើព្រះយេស៊ូវសម្រាប់អ្វីពិតទៅ? បើនិយាយឲ្យសាមញ្ញទៅ យើងកំពុងតែទុកចិត្តលើព្រះអង្គក្នុងការធានាឲ្យយើងនូវការសម្រេចចិត្តពីព្រះជាម្ចាស់ដែលជាចៅក្រម ថាយើងសុចរិតជំនួសទទួលបានការសម្រេចចិត្តថាយើងមានពិរុទ្ធភាព។

សូមអនុញ្ញាតឲ្យខ្ញុំពន្យល់។ ព្រះគម្ពីរបានបង្រៀនថា តម្រូវការដ៏ធំបំផុតរបស់មនុស្សគ្រប់រូបគឺឲ្យព្រះជាម្ចាស់រកឃើញយើងថាសុចរិតនៅចំពោះព្រះនេត្ររបស់ទ្រង់ជាជាងអាក្រក់។ នៅពេលដែលការជំនុំជម្រះមកដល់ យើងពិតជាត្រូវការព្រះអង្គសម្រេចចិត្តថាយើងជា "សុចរិត" ព្រះអង្គនឹងរាប់យើងជា "សុចរិត" ជាជាង "មានទោស"។ នោះគឺជាអ្វីដែលព្រះគម្ពីរហៅថាជា "ការរាប់ជាសុចរិត"—វាគឺជាការប្រកាស

9Marks Online PDF

របស់ព្រះជាម្ចាស់ថា យើងសុចរិតនៅក្នុងព្រះនេត្ររបស់ទ្រង់ ជាជាងមានពិរុទ្ធភាព។

ចុះតើយើងអាចធានាថា យើងនឹងទទួលបានការសម្រេចចិត្តដ៏សុចរិតនេះពីព្រះជាម្ចាស់បានដោយរបៀបណា? ព្រះគម្ពីរបានប្រាប់យើងយ៉ាងច្បាស់ថា វាមិនទាក់ទិននឹងការទូលសូមឲ្យព្រះជាម្ចាស់ទតមើលជីវិតរបស់យើងនោះទេ។ ទេ! ការធ្វើបែបនេះគឺជាសកម្មភាពល្ងីល្ងើ។ ប្រសិនបើព្រះជាម្ចាស់នឹងរាប់យើងជាសុចរិត នោះព្រះអង្គនឹងត្រូវធ្វើវាឡើងលើមូលដ្ឋានផ្សេងពីកំណត់ត្រាបញ្ជីនៃអំពើបាបរបស់យើង។ ព្រះអង្គត្រូវធ្វើការនោះឡើងលើមូលដ្ឋាននៃកំណត់ត្រាបញ្ជីរបស់បុគ្គលម្នាក់ផ្សេងទៀត បុគ្គលដែលជាអ្នកជំនួសយើង។ នេះហើយគឺជាមូលហេតុដែលយើងជឿលើព្រះយេស៊ូវ។ នៅពេលយើងដាក់ជំនឿរបស់យើងលើព្រះយេស៊ូវ នោះមានន័យថា យើងកំពុងរំពឹងលើទ្រង់ជាអ្នកឈរជំនួសយើងនៅចំពោះព្រះជាម្ចាស់ ដោយអាងលើព្រះជន្មដ៏ល្អឥតខ្ចោះរបស់ទ្រង់ និងការសុគតបង់ថ្លៃលោះរបស់ទ្រង់សម្រាប់យើងនៅលើឈើឆ្កាង។ របៀបនិយាយម្យ៉ាងទៀតគឺថា យើងកំពុងតែទុកចិត្តថាព្រះជាម្ចាស់នឹងជំនួសកំណត់ត្រាបញ្ជីរបស់ព្រះយេស៊ូវជំនួសយើង ហើយជាលទ្ធផលព្រះជាម្ចាស់នឹងប្រកាសថាយើងសុចរិត (រ៉ូម ៣:២២)។

លោកអ្នកអាចគិតអំពីការនោះដូចនេះ៖ នៅពេលដែលយើងជឿទុកចិត្តលើព្រះយេស៊ូវឲ្យសង្គ្រោះយើង យើងក៏មានការរួបរួមជាមួយ

9Marks Online PDF

ទ្រង់ ហើយការប្ដូរគ្នាដ៏អស្ចារ្យក៏បានកើតឡើង។ អំពើបាបទាំងអស់របស់យើង ការបះបោរ និងអំពើអាក្រក់ត្រូវបានដាក់ (ឬក៏បង់) ទៅលើព្រះយេស៊ូវ ហើយព្រះអង្គក៏បានសុគត ដោយសារការនោះផងដែរ (១ពេត្រុស ៣:១៨)។ ស្របពេលនោះដែរ ព្រះជន្មដ៏ល្អឥតខ្ចោះដែលព្រះគ្រីស្ទបានរស់នៅក៏ត្រូវបានដាក់មកលើយើង ហើយព្រះអង្គក៏បានរាប់យើងថាជាសុចរិត។ នៅពេលដែលព្រះជាម្ចាស់ទតមើលយើង ជំនួសឃើញអំពើបាបរបស់យើង ព្រះអង្គឃើញសេចក្ដីសុចរិតរបស់ព្រះយេស៊ូវវិញ។

នេះគឺជាអ្វីដែលសាវ័ក ប៉ុល បានមានន័យ នៅពេលដែលគាត់សរសេរនៅក្នុងកណ្ឌគម្ពីររ៉ូមជំពូក៤ថា ព្រះជាម្ចាស់ "ប្រោសឲ្យ [យើង] សុចរិត" មិនមែនដោយសារការប្រព្រឹត្តរបស់យើង ហើយថាព្រះអង្គ "បានគ្របបាំង" អំពើបាបរបស់យើង (ខ៥, ៧)។ សំខាន់លើនោះ គឺទាក់ទងទៅនឹងអ្វីដែលសាវ័ក ប៉ុល បានមានន័យ នៅពេលដែលគាត់មានប្រសាសន៍ថា "ជឿព្រះអង្គដែលបានរាប់មនុស្សមិនគោរពកោតខ្លាចព្រះជាម្ចាស់ជាសុចរិត" (រ៉ូម ៤:៥ ខគខ)! ព្រះជាម្ចាស់មិនរាប់យើងថា សុចរិតដោយសារយើងផ្ទាល់សុចរិតស្រាប់នោះទេ។ ហើយយើងក៏គួរតែអរព្រះគុណព្រះអង្គដែរ ដោយសារការនោះគឺជាការពិត ព្រោះគ្មានអ្នកណាក្នុងចំណោមយើងអាចឈានទៅដល់ស្ដង់ដារនោះបានឡើយ! ទេ ផ្ទុយទៅវិញ! ព្រះជាម្ចាស់រាប់យើងសុចរិតដោយសារតាមរយៈជំនឿ យើងទទួលបានការបំពាក់

9Marks Online PDF

សេចក្ដីសុចរិតនៃព្រះជន្មរបស់ព្រះគ្រីស្ទ។ ព្រះជាម្ចាស់សង្គ្រោះយើង តាមរយៈព្រះគុណទាំងស្រុង មិនមែនដោយសារអ្វីដែលយើងបាន ប្រព្រឹត្តនោះទេ ប៉ុន្តែគឺដោយសារអ្វីដែលព្រះយេស៊ូវបានធ្វើសម្រាប់ យើងទាំងស្រុង។

ហោរា សាការី បានលើកឡើងអំពីចំណុចនេះ ដោយប្រើប្រាស់ ឧទាហរណ៍បានយ៉ាងល្អអំពីលោក យេសួរ ដែលជាសម្ដេចសង្ឃ នៅពេលដែលគាត់ទទួលបានសំលៀកបំពាក់ថ្មី។ ខាងក្រោមនេះគឺ ជាអ្វីដែលហោរា សាការី បានសរសេរចុះ៖

> "រួចមកទេវតានោះ ក៏បង្ហាញឲ្យខ្ញុំឃើញយេសួរ ជាសម្ដេចសង្ឃ ឈរនៅចំពោះទេវតានៃព្រះយេហូវ៉ា មានអារក្សសាតាំងឈរ នៅខាងស្ដាំលោក ដើម្បីតវ៉ានឹងលោក នោះព្រះយេហូវ៉ាទ្រង់ មានបន្ទូលនឹងសាតាំងថា "ម្នាលសាតាំង ព្រះយេហូវ៉ាទ្រង់ បន្ទោសឯង អើ ព្រះយេហូវ៉ាដែលបានរើសក្រុងយេរូសាឡឹម ទ្រង់ស្ដីបន្ទោសដល់ឯងនេះ តើមិនមែនជាកន្ទុយឧស ដែល បានកញ្ឆក់យកចេញពីភ្លើងទេឬ?" រីឯយេសួរ លោកកំពុង ឈរនៅចំពោះទេវតាទាំងស្លៀកពាក់កខ្វក់ ទ្រង់ក៏បង្គាប់ដល់ ពួកដែលឈរនៅចំពោះទ្រង់ថា "ចូរដោះសំលៀកបំពាក់កខ្វក់ ពីលោកចេញ។" រួចទ្រង់មានបន្ទូលដល់លោកថា "មើល អញ បានលើកចោលអំពើទុច្ចរិតពីឯងចេញហើយ អញនឹងប្រដាប់ ខ្លួនឯង ដោយសំលៀកបំពាក់ដ៏រុងរឿងវិញ" នោះខ្ញុំក៏ទូលថា

“សូមឲ្យគេបំពាក់ក្បាំងស្អាត នៅលើក្បាលលោកផង” ដូច្នេះ គេក៏បំពាក់ក្បាំងស្អាត នៅលើក្បាលលោក ព្រមទាំងប្រដាប់កាយឲ្យផង មានទាំងទេវតានៃព្រះយេហូវ៉ាឈរនៅទីនោះដែរ» (សាការី ៣:១ ៥)។

ខោអាវថ្មី ស្អាត និងមានតម្លៃនោះមិនមែនជាកម្មសិទ្ធិរបស់លោក យេសួរ ទេ។ មានរួមទាំងក្បាំងដ៏ស្អាតនោះផងដែរ។ អ្វីដែលជាកម្មសិទ្ធិផ្ទាល់របស់លោក យេសួរ គឺសំលៀកបំពាក់កខ្វក់ដែលគាត់កំពុងតែឈរនៅជាមួយ គឺជាអ្វីដែលអារក្សសាតាំងហៀបនឹងចង្អុលចំអក និងចោទ។ ទេ! សេចក្តីសុចរិតដែលលោក យេសួរ កំពុងតែមានអំណរជាមួយនៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់គឺមិនមែនជារបស់គាត់ផ្ទាល់នោះទេ។ គឺគាត់ទទួលបានពីអ្នកផ្សេងទេតើ។

ការនោះក៏ជាការពិតសម្រាប់យើងដែលជាគ្រីស្ទបរិស័ទផងដែរ។ សេចក្តីសុចរិតរបស់យើងនៅចំពោះព្រះជាម្ចាស់គឺមិនមែនជារបស់យើងនោះទេ។ គឺយើងទទួលបានពីព្រះយេស៊ូវទេតើ។ ព្រះជាម្ចាស់មើលព្រះរាជបុត្រារបស់ទ្រង់ ហើយក៏ឃើញអំពើបាបរបស់យើង ហើយនៅពេលដែលព្រះអង្គទតមើលយើង នោះទ្រង់ក៏ឃើញសេចក្តីសុចរិតរបស់ព្រះយេស៊ូវវិញ។ ដូចដែលបទចម្រៀងបានលើកឡើង៖

9Marks Online PDF

ព្រះដ៏សុចរិតក៏មានការស្កប់ព្រះទ័យក្នុងការទតមើលទ្រង់ ហើយ
អត់ទោសខ្ញុំ។[២]

## តាមរយៈតែជំនឿ

នៅពេលដែលលោកអ្នកយល់ឃើញថា ខ្លួនពឹងលើព្រះយេស៊ូវខ្លាំងប៉ុណ្ណាសម្រាប់សេចក្ដីសង្គ្រោះរបស់ខ្លួន—ការសុគតរបស់ទ្រង់សម្រាប់អំពើបាបរបស់លោកអ្នក ព្រះជន្មរបស់ទ្រង់សម្រាប់សេចក្ដីសុចរិតរបស់លោកអ្នក—នោះលោកអ្នកនឹងយល់អំពីមូលហេតុដែលព្រះគម្ពីរបាននិយាយសង្កត់ធ្ងន់យ៉ាងខ្លាំងថា សេចក្ដីសង្គ្រោះកើតឡើងតាមរយៈតែជំនឿលើទ្រង់ប៉ុណ្ណោះ។ មិនមានផ្លូវណាផ្សេងឡើយ មិនមានព្រះសង្គ្រោះឯណាទៀតទេ មិនមានអ្វី ឬក៏បុគ្គលម្នាក់ផ្សេងទៀតនៅក្នុងលោកីយ៍នេះ ដែលយើងអាចរំពឹងលើបានសម្រាប់សេចក្ដីសង្គ្រោះរបស់យើង ដែលមានរួមទាំងការខិតខំប្រឹងប្រែងរបស់យើងដែរ។

គ្រប់សាសនាផ្សេងទៀតក្នុងប្រវត្តិសាស្ត្រមនុស្សលោកបានបដិសេធនូវគំនិតដែលថាយើងទទួលបានការរាប់ជាសុចរិតដោយសារតែជំនឿតែមួយមុខ។ ផ្ទុយទៅវិញ សាសនាផ្សេងៗទៀតបានបង្រៀនថា យើងអាចទទួលបានសេចក្ដីសង្គ្រោះតាមរយៈការខិតខំប្រឹងប្រែងផ្នែកសីលធម៌ ការមានទង្វើល្អ និងតាមរបៀបនៃការថ្លឹងថ្លែងទង្វើរបស់ខ្លួនក្នុងរបៀបណាមួយដែលធ្វើឲ្យទង្វើល្អកើនជាងទង្វើអាក្រក់។ តាម

២. ដកស្រង់ចេញពី៖ “Before the Throne of God Above,” នពន្ធដោយ៖ Charitie L. Bancroft, ឆ្នាំ១៨៦៣។

9Marks Online PDF

ពិតទៅ នេះមិនមែនជាការរកឃើញដែលគួរឲ្យភ្ញាក់ផ្អើលនោះទេ។ វាគឺជារបៀបដែលមនុស្សយើងគិត—ហើយថែមទាំង*ទទូចចង់*បានដែរ—ត្រង់ថាយើងអាចផ្តល់វិភាគទានចំពោះសេចក្តីសង្គ្រោះរបស់ខ្លួនផ្ទាល់បាន។

យើងជាមនុស្សដែលចង់សម្រេចកិច្ចការដោយខ្លួនឯង ពិតអត់? យើងជឿជាក់ថា មានខ្លួនឯងគឺគ្រប់គ្រាន់ហើយ ហើយយើងក៏ខឹងនឹងការបញ្ឆិតបញ្ឆៀងថា យើងជាអ្នកណាឥឡូវនេះ ដោយសារមានបុគ្គលណាម្នាក់ផ្សេងទៀតបានថ្លែងអន្តរាគមន៍។ សូមគិតអំពីអារម្មណ៍ដែលលោកអ្នកមាន ប្រសិនបើបុគ្គលម្នាក់ផ្សេងទៀតបានលើកឡើងអំពីការងាររបស់លោកអ្នក ឬក៏អំពីនរណាម្នាក់ដែលលោកអ្នកឲ្យតម្លៃលើ “ពិតណាស់ ឯងមិនទទួលបានដោយសារសមត្ថភាពរបស់ឯងទេ។ ឯងមានវាដោយសារមានបុគ្គលផ្សេងទៀតបានឲ្យឯង”។ ហើយទោះជាយ៉ាងណាក៏ដោយក៏នោះគឺពិតជាអ្វីដែលបានកើតឡើងទាក់ទងទៅនឹងសេចក្តីសង្គ្រោះរបស់យើងនៅចំពោះព្រះជាម្ចាស់។ យើងទទួលបានក្នុងនាមជាអំណោយទាននៃព្រះគុណ ហើយយើងក៏មិនបានផ្តល់វិភាគទានទាល់តែសោះ—មិនមែនដោយសារសេចក្តីសុចរិតរបស់យើងផ្ទាល់ ហើយក៏មិនមែនការបង់ថ្លៃរបស់យើងផ្ទាល់សម្រាប់អំពើបាបរបស់យើង ហើយពិតណាស់ក៏មិនមានទង្វើល្អណាមួយ ដែលស៊ីសងគ្នានឹងការប្រព្រឹត្តិរបស់យើងផងដែរ (កាឡាទី ២:១៦)។

ការមានជំនឿលើព្រះគ្រីស្ទមានន័យថា លោកអ្នកបដិសេធសេចក្តី

សង្ឃឹមផ្សេងទៀតទាំងអស់នៃការទទួលបានការរាប់ជាសុចរិតនៅចំពោះព្រះជាម្ចាស់។ តើលោកអ្នកឃើញថា ខ្លួនទុកចិត្តលើទង្វើល្អរបស់ខ្លួនដែរឬទេ? ជំនឿមានន័យថា លោកអ្នកទទួលស្គាល់ថាទាំងអស់នោះវេទនា ហើយក៏មិនគ្រប់គ្រាន់ទេ ហើយថាលោកអ្នកទុកចិត្តតែលើព្រះគ្រីស្ទមួយអង្គប៉ុណ្ណោះ។ តើលោកអ្នកឃើញថា ខ្លួនទុកចិត្តលើអ្វីដែលលោកអ្នកយល់ថា ជាការមានចិត្តល្អដែរឬទេ? ជំនឿមានន័យថា លោកអ្នកទទួលស្គាល់ថា ចិត្តរបស់លោកអ្នកមិនល្អទាល់តែសោះ ហើយថាលោកអ្នកទុកចិត្តតែលើព្រះគ្រីស្ទតែមួយអង្គប៉ុណ្ណោះ។ បើនិយាយម្យ៉ាងវិញទៀតទៅ គឺវាមានន័យថាជាការលោតចេញពីគែមនៃអាងហែលទឹក ហើយនិយាយថា «ព្រះយេស៊ូវ ប្រសិនបើព្រះអង្គមិនចាប់ទូលបង្គំ នោះទូលបង្គំនឹងស្លាប់។ ទូលបង្គំមិនមានសេចក្តីសង្ឃឹម ឬព្រះសង្គ្រោះណាផ្សេងទៀតឡើយ។ ឱព្រះយេស៊ូវអើយ សូមសង្គ្រោះទូលបង្គំ បើមិនដូច្នោះទេ នោះទូលបង្គំនឹងស្លាប់ជាមិនខាន»។

នោះឯងគឺជាជំនឿ។

## ការកែប្រែចិត្តជាផ្នែកម្ខាងទៀត

សាររបស់ព្រះយេស៊ូវទៅកាន់អ្នកស្តាប់ទ្រង់គឺ «ចូរប្រែចិត្ត ហើយជឿដំណឹងល្អចុះ» (ម៉ាកុស ១:១៥)។ ប្រសិនបើជំនឿគឺការបែរទៅរកព្រះយេស៊ូវ ហើយរំពឹងលើទ្រង់ ដើម្បីទទួលបានសេចក្តីសង្គ្រោះ នោះការកែប្រែចិត្តគឺ ជាផ្នែកម្ខាងទៀត៖ វាគឺជាការបែរចេញពីអំពើបាប ការស្អប់អំពើបាប និងការតាំងចិត្តថានឹងបោះបង់វាចោល ដោយរំពឹងលើ

9Marks Online PDF

កម្លាំងរបស់ព្រះជាម្ចាស់ ខណៈពេលដែលយើងកំពុងតែបែរទៅរកទ្រង់ក្នុងជំនឿក៏ដោយ។ ដូច្នេះសាវ័ក ពេត្រុស បានប្រាប់ហ្វូងមនុស្សដែលកំពុងតែសម្លឹងមកគាត់ថា «ចូរប្រែចិត្ត ហើយវិលមកចុះ ដើម្បីឲ្យបាបរបស់អ្នករាល់គ្នាបានលុបចេញ» (កិច្ចការ ៣:១៩)។ ហើយសាវ័កប៉ុល បានប្រាប់មនុស្សគ្រប់គ្នាឲ្យ «ប្រែចិត្ត ហើយងាកបែរមកឯព្រះវិញ» (កិច្ចការ ២៦:២០)។

ការកែប្រែចិត្តគឺមិនមែនគ្រាន់តែជាជម្រើសនៃការដាក់ចូលបន្ថែមក្នុងជីវិតគ្រីស្ទបរិស័ទនោះទេ។ គឺវាសំខាន់ខ្លាំងណាស់ វាជាចំណុចសម្គាល់ថា បុគ្គលម្នាក់បានទទួលសេចក្ដីសង្គ្រោះពីព្រះជាម្ចាស់ ឬបុគ្គលនោះមិនទាន់បាន។

ខ្ញុំបានស្គាល់មនុស្សជាច្រើននាក់ដែលនឹងលើកឡើងដូចតទៅ៖ «ពិតណាស់! ខ្ញុំបានទទួលយកព្រះយេស៊ូវជាព្រះសង្គ្រោះហើយ ដូច្នេះខ្ញុំជាគ្រីស្ទបរិស័ទ។ ប៉ុន្តែ ខ្ញុំមិនទាន់បានត្រៀមចិត្តនៅឡើយ ក្នុងការទទួលយកទ្រង់ជាព្រះអម្ចាស់។ ខ្ញុំមានចំណុចខ្លះៗដែលខ្ញុំត្រូវដោះស្រាយជាមុនសិន»។ មួយវិញសោត ពួកគេអះអាងថាខ្លួនអាចមានជំនឿលើព្រះគ្រីស្ទបានហើយអាចទទួលបានសេចក្ដីសង្គ្រោះ ប៉ុន្តែមិនទាន់បានកែប្រែចិត្តចេញពីអំពើបាបឡើយ។

ប្រសិនបើយើងយល់អំពីការកែប្រែចិត្តបានយ៉ាងត្រឹមត្រូវ នោះយើងឃើញថាគំនិតដែលថាលោកអ្នកអាចទទួលព្រះយេស៊ូវធ្វើជាព្រះអង្គសង្គ្រោះ ប៉ុន្តែមិនមែនជាព្រះអម្ចាស់គឺជារឿងដ៏ល្ងីល្ងើណាស់។

9Marks Online PDF

សម្រាប់ចំណុចមួយ វាមិនយុត្តិធម៌ទៅនឹងអ្វីដែលព្រះបន្ទូលបានលើកឡើងអំពីការកែប្រែចិត្ត និងភាពភ្ជាប់គ្នាជាមួយនឹងសេចក្តីសង្គ្រោះឡើយ។ ឧទាហរណ៍៖ ព្រះយេស៊ូវបានព្រមានថា «បើអ្នករាល់គ្នាមិនប្រែចិត្តទេ នោះនឹងត្រូវវិនាសទាំងអស់គ្នាដូច្នោះដែរ» (លូកា ១៣:៣)។ នៅពេលដែលពួកសាវ័កបានឮសាច់រឿងរបស់សាវ័ក ពេត្រុស អំពីការដែលលោក កូនេលាស បានក្លាយជាគ្រីស្ទបរិស័ទ នោះពួកគាត់ក៏បានសរសើរតម្កើងព្រះជាម្ចាស់ ក្នុងការប្រទានឲ្យពួកសាសន៍ដទៃ «ប្រែចិត្ត...ឲ្យគេមានជីវិតដែរ» (កិច្ចការ ១១:១៨) ហើយសាវ័ក ប៉ុល ក៏បានមានប្រសាសន៍អំពីការ «ប្រែចិត្តឡើង ប្រយោជន៍ឲ្យបានសង្គ្រោះ» នៅក្នុងកណ្ឌគម្ពីរ ២កូរិនថូស ៧:១០។

លើសពីនេះទៀត ក្នុងចំណុចស្នូល ការមានជំនឿលើព្រះយេស៊ូវគឺជាការទទួលជឿថាព្រះអង្គគឺជាអង្គដែលទ្រង់បានមានបន្ទូលអំពីព្រះអង្គទ្រង់—ជាស្តេចដែលបានជាប់ឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញដែលបានយកឈ្នះលើសេចក្តីស្លាប់ និងអំពើបាប ហើយក៏ជាអង្គដែលមានអំណាចក្នុងការសង្គ្រោះ។ តើឲ្យបុគ្គលណាម្នាក់ដែលជឿលើទាំងអស់នោះ មានទំនុកចិត្តលើវា រំពឹងលើវា ហើយស្របពេលនោះអាចនិយាយថា «ប៉ុន្តែ ខ្ញុំមិនទទួលស្គាល់ថា ព្រះអង្គជាស្តេចនៃជីវិតរបស់ខ្ញុំឡើយ» បានដោយរបៀបណា? វាមិនសមហេតុផលសោះ។ ជំនឿលើព្រះគ្រីស្ទមានបង្កប់ទៅដោយការបដិសេធនូវអំណាចប្រឆាំងដែលថា ព្រះយេស៊ូវដ៏ជាស្តេចបានយកឈ្នះលើ—អំពើបាប។ ហើយទីណា

9Marks Online PDF

ដែលមិនមានការបដិសេធមិនធ្វើបាប ទីនោះក៏មិនមានជំនឿដ៏ពិតលើអង្គដែលយកឈ្នះលើវាផងដែរ។

ដូចដែលព្រះយេស៊ូវបានមានបន្ទូលនៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ៦:២៤៖ «គ្មានអ្នកណាអាចនឹងបម្រើចៅហ្វាយ២នាក់បានទេ ដ្បិតអ្នកនោះនឹងស្អប់១ ហើយស្រឡាញ់១ ឬស្មោះត្រង់នឹង១ ហើយមើលងាយ១»។ ការមានជំនឿលើព្រះយេស៊ូវដ៏ជាស្តេចគឺជាការបដិសេធខ្មាំងសត្រូវរបស់ទ្រង់។

## ការកែប្រែចិត្ត មិនមែនការល្អឥតខ្ចោះ ប៉ុន្តែគឺជាការជ្រើសរើសថានៅខាងណាទេតើ

ទាំងនោះមិនមែនមានន័យថា គ្រីស្ទបរិស័ទនឹងលែងប្រព្រឹត្តអំពើបាបទៀតឡើយ។ ការកែប្រែចិត្តចេញពីអំពើបាបមិនមែនដាច់ខាតត្រូវមានន័យថា លោកអ្នកនឹងឈប់ប្រព្រឹត្តអំពើបាបទេ—មិនដូច្នោះទាំងស្រុងឡើយ ហើយជាទូទៅក៏មិនមែនក្នុងផ្នែកជាក់លាក់ណាមួយដែរ។ គ្រីស្ទបរិស័ទក៏នៅតែជាមនុស្សមានបាប ដែលបានធ្លាក់ក្នុងអំពើបាប សូម្បីតែបន្ទាប់ពីពេលដែលព្រះជាម្ចាស់បានប្រទានជីវិតថ្មីខាងឯព្រលឹងវិញ្ញាណដល់យើងក៏ដោយ ហើយយើងក៏នឹងនៅបន្តតយុទ្ធជាមួយនឹងអំពើបាប រហូតទាល់តែយើងទទួលបានសិរីល្អជាមួយនឹងព្រះយេស៊ូវដែរ (ឧទាហរណ៍៖ សូមមើលនៅក្នុងកណ្ឌគម្ពីរកាឡាទី ៥:១៧; ១យ៉ូហាន ២:១)។ ប៉ុន្តែ ទោះបើការកែប្រែចិត្តមិនមែនមានន័យថា ភ្លាមៗនោះយើងនឹងឈប់ប្រព្រឹត្តិអំពើបាបក៏ដោយ

9Marks Online PDF

ក៏វានៅមានន័យថា យើងនឹងមិនអាចបន្តរស់នៅដោយមានសន្តិភាពជាមួយនឹងអំពើបាបរបស់យើងបានទៀតឡើយ។ យើងនឹងប្រកាសសង្គ្រាមស៊ីសាច់ហុតឈាមទាស់ប្រឆាំងនឹងវា ហើយប្ដេជ្ញាចិត្តតយុទ្ធនឹងវា ដោយពឹងលើអំណាចរបស់ព្រះជាម្ចាស់ ក្នុងគ្រប់ជ្រុងជ្រោយនៃជីវិតរបស់យើង។

មានគ្រីស្ទបរិស័ទច្រើនតយុទ្ធយ៉ាងខ្លាំងជាមួយនឹងគំនិតនៃការកែប្រែចិត្តនេះ ពីព្រោះគាត់បានរំពឹងថា ប្រសិនបើខ្លួនពិតជាកែប្រែចិត្តបាន នោះអំពើបាបនឹងបាត់អស់ទៅ ហើយការល្បួងក៏នឹងឈប់។ នៅពេលដែលការនោះមិនបានកើតឡើង ពួកគាត់ក៏អស់សង្ឃឹម ហើយចាប់ផ្ដើមសួរខ្លួនឯងថា តើជំនឿរបស់ខ្លួនលើព្រះយេស៊ូវពិត ឬក៏អត់។ វាគឺជាការពិតនៅពេលដែលព្រះជាម្ចាស់បង្កើតយើងជាថ្មី នោះព្រះអង្គប្រទាននូវអំណាចមកកាន់យើង ដើម្បីតយុទ្ធប្រឆាំង នឹងយកឈ្នះលើអំពើបាប (១កូរិនថូស ១០:១៣)។ ប៉ុន្តែ ដោយសារយើងនឹងនៅបន្តតយុទ្ធជាមួយនឹងអំពើបាបរហូតទាល់តែយើងទទួលសិរីល្អ យើងត្រូវតែចងចាំថា ការកែប្រែចិត្តដ៏ពិតមានមូលដ្ឋានច្រើនជាងទាក់ទងនឹងអាកប្បកិរិយានៃដួងចិត្តរបស់យើងទៅកាន់អំពើបាប ជាងការមានការបំផ្លាស់បំប្រែខាងឯឥរិយាបថ។ តើយើងស្អប់អំពើបាប ហើយប្រឆាំងទាស់នឹងវា ឬក៏យើងឱបក្រសោបវា ហើយការពារវា?

មានអ្នកនិពន្ធបានសរសេរអំពីសេចក្តីពិតនេះយ៉ាងពីរោះ៖

9Marks Online PDF

> ចំណុចខុសគ្នារវាងបុគ្គលដែលមិនបានក្លាយជាគ្រីស្ទបរិស័ទ និងបុគ្គលម្នាក់ទៀតដែលបានក្លាយជាគ្រីស្ទបរិស័ទគឺមិនមែនថា បុគ្គលម្នាក់មានអំពើបាប ហើយបុគ្គលម្នាក់ទៀតមិនមានអំពើបាបនោះទេ ប៉ុន្តែគឺថាបុគ្គលម្នាក់មានចំណែកជាមួយនឹងអំពើបាបរបស់គាត់ដោយមានការឱបក្រសោបវាប្រឆាំងនឹងព្រះជាម្ចាស់ដែលគួរឲ្យខ្លាច ហើយបុគ្គលម្នាក់ទៀតមានចំណែកជាមួយវាដោយមានការផ្សះផ្សាជាមួយនឹងព្រះជាម្ចាស់ ហើយទាស់ប្រឆាំងនឹងអំពើបាបដែលគាត់ស្អប់។[៣]

តើលោកអ្នកជ្រើសរើសយកខាងណា—ខាងអំពើបាបរបស់ខ្លួន ឬក៏ខាងព្រះជាម្ចាស់?

## ការផ្លាស់ប្តូរដ៏ពិត និងផលផ្លែដ៏ពិត

នៅពេលដែលបុគ្គលណាម្នាក់ពិតជាកែប្រែចិត្តមែន ហើយទទួលជឿលើព្រះគ្រីស្ទ ព្រះគម្ពីរបានមានបន្ទូលថា គាត់ក៏ទទួលបានជីវិតថ្មីខាងឯវិញ្ញាណដែរ។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា «ពីដើម អ្នករាល់គ្នាក៏ស្លាប់ក្នុងការរំលង ហើយក្នុងអំពើបាបដែរ»។ «ប៉ុន្តែព្រះដែលទ្រង់មានសេចក្ដីមេត្តាករុណាដ៏លើសលប់ ដោយព្រោះសេចក្ដីស្រឡាញ់ជាខ្លាំង ដែលទ្រង់មានដល់យើងរាល់គ្នា ក្នុងកាលដែលយើងនៅស្លាប់ក្នុងការរំលងនៅឡើយ នោះទ្រង់បានប្រោសឲ្យយើងរាល់គ្នាបានរស់

៣. ដកស្រង់ចេញពី៖ លោកគ្រូ William Arnot, សៀវភៅ ‘‘Laws from Heaven for Life on Earth’’ (ទីក្រុងឡុង៖ T. Nelson and Sons, ឆ្នាំ១៨៨៤), ទំព័រទី៣១១។

9Marks Online PDF

ជាមួយនឹងព្រះគ្រីស្ទ គឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ» (អេភេសូរ ២:១, ៤-៥)។ នៅពេលដែលការនោះកើតឡើង ជីវិតរបស់យើងក៏ទទួលបានការផ្លាស់ប្តូរ—មិនមែនភ្លាមៗ មិនឆាប់រហ័ស ហើយក៏ថាទាំងមិនមានន័យនៅយ៉ាងនឹងថ្កល់នោះដែរ។ ប៉ុន្តែ វាមានការផ្លាស់ប្តូរ ។ យើងចាប់ផ្តើមបង្កើតផលផ្លែ។

ព្រះគម្ពីរបានមានបន្ទូលថា គ្រីស្ទបរិស័ទក៏ត្រូវមានការសម្គាល់ដូចនឹងប្រភេទនៃសេចក្តីស្រឡាញ់ ចិត្តមេត្តាករុណា និង សេចក្តីសប្បុរសដូចដែលព្រះយេស៊ូវផ្ទាល់មានដែរ។ សាវ័ក ប៉ុល បានមានប្រសាសន៍ថា គ្រីស្ទបរិស័ទដ៏ពិតនឹង «ប្រព្រឹត្តបែបសំណុំនឹងការប្រែចិត្តផង» (កិច្ចការ ២៦:២០)។ «គេស្គាល់ដើមឈើនីមួយៗ ដោយសារតែផ្លែទេ» ព្រះយេស៊ូវបានមានបន្ទូលថា «គេមិនដែលបេះផ្លែល្វាពីគុម្ពបន្លា ឬផ្លែទំពាំងបាយជូរពីអញ្ចាញទ្បើយ» (លូកា ៦:៤៤)។ បើនិយាយម្យ៉ាងវិញទៀតទៅ នៅពេលដែលបុគ្គលណាម្នាក់ទទួលបានជីវិតថ្មីខាងឯវិញ្ញាណ នោះពួកគាត់នឹងចាប់ផ្តើមធ្វើនូវអ្វីដែលព្រះយេស៊ូវបានប្រព្រឹត្ត។ ពួកគាត់ចាប់ផ្តើមរស់នៅដូចការដែលព្រះយេស៊ូវបានមានព្រះជន្ម ហើយក៏នឹងចាប់ផ្តើមបង្កើតផលផ្លែល្អផងដែរ។

ដាច់ខាត ចំណុចមួយដែលយើងត្រូវតែការពារគ្រប់ពេល គឺការមានគំនិតថា ផលផ្លែទាំងនោះគឺជាបុព្វហេតុនៃសេចក្តីសង្គ្រោះរបស់យើង។ វាតែងតែមានគ្រោះថ្នាក់នៅពេលដែលយើងចាប់ផ្តើមឃើញមានផលផ្លែនៅក្នុងជីវិតរបស់យើង ដោយមានការស្រពេចស្រពិល នោះយើង

នឹងចាប់ផ្ដើមពឹងលើផលផ្លែនោះ ដើម្បីឲ្យទទួលបានសេចក្ដីសង្គ្រោះរបស់យើង ជាជាងពឹងព្រះគ្រីស្ទ។ ឱគ្រីស្ទបរិស័ទអើយ សូមការពារដោយទាស់ប្រឆាំងនឹងការនោះ។ សូមទទួលស្គាល់ថាផលផ្លែដែលលោកអ្នកបង្កើតគឺគ្រាន់តែថា—ជាផលផ្លែនៃដើមដែលព្រះជាម្ចាស់បានបង្កើតរួចហើយ  តាមរយៈព្រះគុណរបស់ទ្រង់ក្នុងព្រះគ្រីស្ទតែប៉ុណ្ណោះ។ ការពឹងលើផលផ្លែផ្ទាល់ខ្លួនរបស់គ្រីស្ទបរិស័ទក្នុងការធានាថានឹងទទួលបានការសព្វព្រះហឫទ័យពីព្រះជាម្ចាស់ នៅទីបំផុតគឺជាការប្ដូរជំនឿរបស់លោកអ្នកចេញពីព្រះយេស៊ូវ មកលើខ្លួនឯងវិញ។ ហើយនោះគឺមិនមែនជាសេចក្ដីសង្គ្រោះទេ។

**តើលោកអ្នកនឹងចង្អុលទៅឯណា?**

នៅពេលដែលលោកអ្នកឈរនៅចំពោះព្រះភក្ត្ររបស់ព្រះជាម្ចាស់នៅថ្ងៃជំនុំជម្រះ ខ្ញុំងឿងឆ្ងល់ ថាតើលោកអ្នកមានគម្រោងធ្វើអ្វី ឬក៏និយាយយ៉ាងដូចម្ដេច ដើម្បីឲ្យព្រះអង្គរាប់លោកអ្នកថាសុចរិត ហើយប្រទានដល់លោកអ្នកនូវរាល់ព្រះពរនៃនគររបស់ទ្រង់? តើលោកអ្នកនឹងយកទង្វើល្អ ឬក៏អាកប្បកិរិយាដែលកោតខ្លាចព្រះអង្គមួយណាចេញពីហោប៉ៅរបស់ខ្លួន ដើម្បីធ្វើឲ្យទ្រង់ចាប់អារម្មណ៍? តើលោកអ្នកនិងប្រើប្រាស់ចំនួននៃការមានវត្តមាននៅព្រះវិហារ? ជីវិតគ្រួសាររបស់លោកអ្នក? ជីវិតនៃការគិតដែលគ្មានសៅហ្មង? ចំណុចដែលថា លោកអ្នកមិនដែលប្រព្រឹត្តអ្វីដែលពិតជាអាក្រក់មែន ក្នុងភ្នែករបស់ខ្លួន? ខ្ញុំងឿងឆ្ងល់ថា តើលោកអ្នកនឹងលើកអ្វីនៅចំពោះព្រះភក្ត្រទ្រង់

ខណៈពេលដែលនិយាយថា «ឱព្រះជាម្ចាស់អើយ ដោយពឹងលើកំណាត់ត្រានេះ សូមរាប់ទូលបង្គំជាសុចរិត!»។

ខ្ញុំនឹងប្រាប់លោកអ្នកនូវអ្វីដែលគ្រីស្ទបរិស័ទគ្រប់រូប ដែលមានជំនឿលើព្រះគ្រីស្ទតែមួយគត់នឹងធ្វើ៖ តាមរយៈព្រះគុណរបស់ព្រះជាម្ចាស់។ ពួកគាត់នឹងគ្រាន់តែធ្វើយ៉ាងសាមញ្ញ និងស្ងៀមស្ងាត់ដោយចង្អុលទៅកាន់ព្រះយេស៊ូវ។ ហើយនេះគឺជាការទទូចអង្វររបស់ពួកគាត់៖ «ឱព្រះជាម្ចាស់អើយ សូមកុំស្វែងរកសេចក្ដីសុចរិតណាមួយនៅក្នុងជីវិតរបស់ទូលបង្គំឡើយ។ សូមទតមើលព្រះរាជបុត្រាទ្រង់។ សូមកុំរាប់ទូលបង្គំថា សុចរិតដោយសារអ្វីដែលទូលបង្គំបានប្រព្រឹត្ត ឬក៏លក្ខណសម្បត្តិរបស់ទូលបង្គំឡើយ ប៉ុន្តែសូមរាប់ព្រះរាជបុត្រារបស់ទ្រង់វិញ។ ព្រះអង្គបានរស់នៅដោយព្រះជន្ម ដែលទូលបង្គំគួរតែបានរស់នៅ។ ព្រះអង្គបានសុគតដោយសេចក្ដីស្លាប់ ដែលទូលបង្គំស័ក្ដិសមនឹងទទួល។ ទូលបង្គំបានបដិសេធនូវការទុកចិត្តលើអ្វីផ្សេងទៀត ហើយការអង្វរកររបស់ទូលបង្គំគឺរំពឹងលើព្រះរាជបុត្រារបស់ទ្រង់តែមួយគត់។ ឱព្រះជាម្ចាស់អើយ! សូមរាប់ទូលបង្គំជាសុចរិតដោយសារព្រះយេស៊ូវ”។

9Marks Online PDF

ជំពូក៦

# នគរព្រះ

**នៅច្រកផ្លូវចូល**កន្លែងចតឡាននៅព្រះវិហារខ្ញុំ មានស្លាកសំរឹទ្ធនៃសម្រង់សម្ដីអមតៈរបស់លោកគ្រូ ជីម អិលីអៀត (Jim Elliot) ដែលជាបេសកជនម្នាក់៖ «បុគ្គលម្នាក់ដែលបានលះបង់នូវអ្វីដែលគាត់មិនអាចរក្សាទុកបាន ដើម្បីឈោងចាប់យកនូវអ្វីដែលគាត់មិនអាចបាត់បង់បាន បុគ្គលនោះមិនមែនជាមនុស្សល្ងីល្ងើទេ»។ ខ្ញុំស្រឡាញ់សម្រង់សម្ដីនេះណាស់ ពីព្រោះវាក្ដោបបានយ៉ាងល្អទាំងតម្លៃនៃការលះបង់ និងរង្វាន់នៃជីវិតជាគ្រីស្ទបរិស័ទ។

មិនមានមន្ទិលសង្ស័យទេត្រង់ថា ការក្លាយជាគ្រីស្ទបរិស័ទ គឺមានការលះបង់ខ្លាំងណាស់ (លូកា ១៤:២៨)។ ប៉ុន្តែ វាក៏ជាការពិតផងដែរថា រង្វាន់នៃការក្លាយជាគ្រីស្ទបរិស័ទក៏ពិតជាអស្ចារ្យដល់ថ្នាក់ថាមិនអាចពណ៌នាបានផង។ ការទទួលបានការអត់ទោសចេញពីអំពើបាប ការក្លាយជាកូនចិញ្ចឹមរបស់ព្រះជាម្ចាស់ ការមានទំនាក់ទំនងជាមួយនឹងព្រះយេស៊ូវ ការទទួលបានអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ការទទួលបានសេរីភាពចេញពីអំណាចនៃអំពើបាប ការប្រកបគ្នាក្នុងក្រុមជំនុំ ការរស់ឡើងវិញជាចុងក្រោយ និងការទទួលបានសិរីរុងរឿងខាងឯរូបកាយ ការរាប់បញ្ចូលក្នុងនគររបស់ព្រះជាម្ចាស់ ផ្ទៃមេឃនិង

9Marks Online PDF

ផែនដីថ្មី ការនៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់អស់កល្បជានិច្ច ការឃើញព្រះភក្ត្រទ្រង់—ទាំងនេះគឺជាសេចក្តីសន្យាដែលព្រះជាម្ចាស់បានធ្វើឡើងមកកាន់យើងក្នុងព្រះគ្រីស្ទ។ ហេតុដូច្នេះហើយបានជាសាវ័កប៉ុល បានលើកសម្រង់សម្តីរបស់ហោរា អេសាយៈ

> ដូចមានសេចក្តីចែងទុកមកថា «សេចក្តីដែលភ្នែកមិនដែលឃើញត្រចៀកមិនដែលឮ ហើយចិត្តនឹកមិនដែលដល់ គឺសេចក្តីនោះឯងដែលព្រះបានរៀបចំទុក សម្រាប់ពួកអ្នកដែលស្រឡាញ់ទ្រង់» (១កូរិនថូស ២:៩)។

ជីវិតរបស់គ្រីស្ទបរិស័ទមិនមែនគ្រាន់តែជាផ្លូវគេចផុតពីសេចក្តីក្រោធរបស់ព្រះជាម្ចាស់នោះទេ។ មិនដូច្នោះទេ! វាគឺជាការមានទំនាក់ទំនងយ៉ាង*ត្រឹមត្រូវ*ជាមួយនឹងព្រះជាម្ចាស់ ហើយនៅចុងបំផុតនោះគឺមានអំណរជាមួយនឹងទ្រង់អស់កល្បជានិច្ច។ ទាំងនេះគឺចង់លើកឡើងអំពីការទទួលបាននូវអ្វីដែលយើងមិនអាចបាត់បង់—ការក្លាយជារាស្ត្រនៃនគរដ៏អស់កល្បជានិច្ចរបស់ទ្រង់។

ចាប់តាំងពីពេលដែលបុគ្គលណាម្នាក់បានក្លាយជាអ្នកជឿលើព្រះយេស៊ូវគ្រីស្ទ នោះគ្រប់អ្វីៗទាំងអស់ក្នុងជីវិតរបស់គាត់ក៏ទទួលបានការផ្លាស់ប្តូរជានិរន្តរ៍ផងដែរ។ ខ្ញុំដឹងៗ—ពេលខ្លះ វាមិនមានអារម្មណ៍ដូច្នោះទេ។ មិនមានក្រដាសពណ៌ធ្លាក់ពីលើមេឃ មិនមានការផ្លុំត្រែហើយក៏មិនមានការច្រៀងពីពួកទេវតាផងដែរ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយក៏វានៅតែជាការពិតដែរ។ *គ្រប់អ្វីៗទាំងអស់*ក៏បានផ្លាស់ប្តូរ។

9Marks Online PDF

សាវ័ក ប៉ុល បានមានប្រសាសន៍ថា ព្រះជាម្ចាស់ “បានប្រោសឲ្យយើងរួចពីអំណាចនៃសេចក្ដីងងឹត ហើយផ្លាស់យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់” (កូឡុស ១:១៣)។

## តើអ្វីទៅជានគររបស់ព្រះជាម្ចាស់?

នគររបស់ព្រះជាម្ចាស់គឺជាប្រធានបទដ៏សំខាន់មួយនៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ ព្រះយេស៊ូវផ្ទាល់ក៏បានអធិប្បាយអំពីវាឥតឈប់ឈរដោយមានបន្ទូលថា “ចូរឲ្យប្រែចិត្តចុះ ដ្បិតនគរស្ថានសួគ៌ជិតដល់ហើយ”។ កណ្ឌគម្ពីរ កិច្ចការ ២៨:៣១ បានសង្ខេបអំពីព័ន្ធកិច្ចរបស់សាវ័ក ប៉ុល ដូចតទៅ៖ “ទាំងប្រកាសប្រាប់ពីនគរព្រះ ហើយបង្រៀនគ្រប់ទាំងសេចក្ដី ពីព្រះអម្ចាស់យេស៊ូវគ្រីស្ទតាមចិត្ត ឥតមានអ្នកណាឃាត់ឃាំងឡើយ”។ អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានបង្ហាញសេចក្ដីរីករាយនៅក្នុងចំណុចដែលថាអ្នកជឿព្រះគ្រីស្ទកំពុង “ទទួលនគរ១ដ៏កក្រើករញ្ជួយពុំបាន” (ហេព្រើរ ១២:២៨) ហើយសាវ័ក ពេត្រុសបានលើកទឹកចិត្តអ្នកស្ដាប់ ដោយនាំមកនូវគំនិតនៃការទទួលបានការស្វាគមន៍យ៉ាងកក់ក្ដៅចូលទៅក្នុង “នគរដ៏នៅអស់កល្បជានិច្ចរបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់ ហើយជាព្រះអង្គសង្គ្រោះនៃយើងរាល់គ្នា” (២ពេត្រុស ១:១១)។ បន្ទាប់មក នៅក្នុងកណ្ឌគម្ពីរវិវរណៈពួកពលបរិវារនៅស្ថានសួគ៌ក៏បានបន្លឺឡើងនៅក្នុងការសរសើរថា៖ “ឥឡូវនេះ សេចក្ដីសង្គ្រោះ ព្រះចេស្ដា នឹងរាជ្យរបស់ព្រះនៃយើងរាល់គ្នា ហើយអំណាចរបស់ព្រះគ្រីស្ទនៃទ្រង់ បានមកដល់ហើយ” (វិវរណៈ

9Marks Online PDF

១២:១០)។

ប៉ុន្តែ តាមពិតទៅ តើអ្វីទៅជានគរនេះ? តើវាជារាជាណាចក្រ ជាកន្លែងមួយដែលព្រះជាម្ចាស់មានអំណាចពិសេសលើវាមែនឬ? តើវាជាក្រុមជំនុំ? តើវាមានឥឡូវនេះ ឬក៏វាជាអ្វីដែលយើងកំពុងតែទន្ទឹងរង់ចាំ ជាអ្វីដែលនឹងមាននៅឯអនាគត? ទាក់ទងនឹងចំណុចនោះ តើមានអ្នកណាខ្លះនៅក្នុងនគររបស់ព្រះជាម្ចាស់? តើការសោយរាជ្យរបស់ព្រះជាម្ចាស់មិនគ្របដណ្តប់លើមនុស្សគ្រប់រូប មិនថាគាត់ជឿ ឬក៏មិនជឿលើព្រះយេស៊ូវមែនឬ? តើយើងទាំងអស់គ្នាមិននៅក្នុងនគរ ឬក៏ថាយើងទាំងអស់មិនអាច—មិនថាយើងជាគ្រីស្ទបរិស័ទ ឬក៏អត់—រួបរួមគ្នាក្នុងការបង្កើតនគរ?

តោះ! ចូលយើងព្យាយាមឆ្លើយសំណួរទាំងនេះខ្លះៗ ដោយកត់សម្គាល់លើចំណុចមួយចំនួនដែលព្រះបន្ទូលបានបង្រៀនយើងអំពីនគររបស់ព្រះជាម្ចាស់។

## ការសោយរាជ្យនៃការប្រោសលោះរបស់ព្រះជាម្ចាស់

ជាដំបូង នគររបស់ព្រះជាម្ចាស់គឺជាការសោយរាជ្យនៃការប្រោសលោះរបស់ទ្រង់លើរាស្ត្ររបស់ព្រះអង្គ។ ពាក្យថា *«នគរ»* គឺជាពាក្យមួយក្នុងចំណោមពាក្យជាច្រើន ដែលនាំមកនូវគំនិតបន្ថែមទៅលើអត្ថន័យដ៏សំខាន់នេះ ហើយក្នុងករណីនេះគំនិតបន្ថែមទាំងនោះក៏អាចនាំឲ្យមានការច្រឡំគ្នាផងដែរ។ ជាទូទៅ នៅពេលដែលយើងគិតអំពីនគរណាមួយ យើងគិតអំពីដីនៅកន្លែងណាមួយ ដែលមាន

9Marks Online PDF

ព្រំដែនជាក់លាក់។ ចំពោះយើងជាច្រើននាក់ ពាក្យថា *“នគរ”* គឺជាពាក្យភូមិសាស្ត្រ។ ទោះជាយ៉ាងណាក៏ដោយក៏នេះមិនមែនជាករណីនៅក្នុងព្រះគម្ពីរដែរ។ បើយោងតាមព្រះគម្ពីរ ការយល់ដឹងដ៏ល្អប្រសើរអំពីនគររបស់ព្រះជាម្ចាស់គឺថា វាពាក់ព័ន្ធទៅនឹងភាពជា*ស្តេច* ជាជាង*នគរ*ដូចដែលយើងប្រើប្រាស់ពាក្យនោះជាទូទៅ។ ដូច្នេះ នគររបស់ព្រះជាម្ចាស់គឺជាការគ្រងរាជ្យ ការសោយរាជ្យ និងអំណាចរបស់ទ្រង់ (ទំនុកតម្កើង ១៤៥:១១, ១៣)។

ទោះជាយ៉ាងណាក៏ដោយក៏នៅមានពាក្យដ៏សំខាន់មួយទៀត ដែលយើងត្រូវបន្ថែមចូលអត្ថន័យរបស់យើង។ ខណៈពេលដែលព្រះគម្ពីរលើកឡើងអំពីពាក្យនោះ នគររបស់ព្រះជាម្ចាស់មិនមែនគ្រាន់តែជាការគ្រងរាជ្យ និងការសោយរាជ្យ របស់ទ្រង់ប៉ុណ្ណោះទេ។ វាគឺជាការគ្រងរាជ្យ ការសោយរាជ្យនៃ*ការប្រោសលោះ*របស់ទ្រង់ វាគឺជាអធិបតេយ្យភាពដែលពេញទៅដោយសេចក្តីស្រឡាញ់ដែលទ្រង់បង្ហូរ*លើរាស្ត្រទ្រង់*។

ប្រាកដណាស់ វាគឺជាការពិតដែលថា គ្មានចន្លោះណាក្នុងចក្រវាលគ្មានបុគ្គលណាម្នាក់ មានឯករាជ្យ ដោយមិនស្ថិតក្រោមការគ្រប់គ្រងរបស់ទ្រង់ ឬក៏ថាគាត់មិនស្ថិតក្រោមអំណាចរបស់ទ្រង់ក្នុងរបៀបណាមួយឡើយ។ ព្រះអង្គបានបង្កើតរាល់គ្រប់អ្វីទាំងអស់ ព្រះអង្គគ្រងរាជ្យលើអ្វីៗទាំងអស់ ហើយព្រះអង្គនឹងជំនុំជម្រះទាំងអស់ដែរ។ ប៉ុន្តែ នៅពេលដែលព្រះគម្ពីរប្រើឃ្លា “នគរព្រះ” ជាទូទៅគឺប្រើប្រាស់ ដើម្បីសំដៅ

យ៉ាងជាក់លាក់ទៅលើការគ្រងរាជ្យរបស់ព្រះជាម្ចាស់លើរាស្ត្ររបស់ទ្រង់ លើអស់អ្នកដែលបានទទួលសេចក្តីសង្គ្រោះតាមរយៈព្រះគ្រីស្ទ។ ហេតុដូច្នេះហើយបានជាសាវ័ក ប៉ុល លើកឡើងអំពីការដែលគ្រីស្ទបរិស័ទផ្លាស់ទីលំនៅចេញពីអំណាចនៃសេចក្តីងងឹតមកក្នុងនគររបស់ព្រះគ្រីស្ទ (កូរិនថូស ១:១២-១៣) ហើយគាត់ក៏មានការប្រុងប្រយ័ត្នយ៉ាងខ្លាំងក្នុងការចង្អុលបង្ហាញថា ពួកមនុស្សអាក្រក់នឹងមិនទទួលចំណែកកេរ្តិ៍អាករក្នុងនគររបស់ព្រះផងដែរ (១កូរិនថូស ៦:៩)។

ដូច្នេះ យើងអាចផ្តល់អត្ថន័យលើឃ្លា "នគរព្រះ" ថាជាការគ្រងរាជ្យការសោយរាជ្យ និងអំណាចរបស់ទ្រង់លើអស់អ្នកដែលព្រះយេស៊ូវបានរំដោះ។

**នគរបានមកដល់**

ទី២ នគររបស់ព្រះជាម្ចាស់បានមកដល់។ នៅពេលដែលព្រះយេស៊ូវបានចាប់ផ្តើមព័ន្ធកិច្ចរបស់ព្រះអង្គនៅលើផែនដី ព្រះអង្គបានប្រកាសនូវសារដ៏គួរឲ្យភ្ញាក់ផ្អើលមួយ៖ "ចូរឲ្យប្រែចិត្តចុះ ដ្បិតនគរស្ថានសួគ៌ជិតដល់ហើយ" (ម៉ាថាយ ៣:២)។ តាមពិតទៅ លោកអ្នកក៏អាចបកប្រែឃ្លាត្រង់ថា "ចូរឲ្យប្រែចិត្ត ដ្បិតនគរស្ថានសួគ៌បានមកដល់ហើយ!»។"

យើងបានឃើញរួចហើយអំពីការប្រកាសដ៏គួរឲ្យភ្ញាក់ផ្អើលនេះដែលព្រះយេស៊ូវបានលើកឡើងជាមួយនឹងពាក្យពេចន៍ទាំងនេះ។ សាសន៍យូដាបានរង់ចាំ មានសង្ឃឹម និងអធិស្ឋានអស់ជាច្រើន

9Marks Online PDF

សតវត្សរ៍សម្រាប់ការលេចមកនូវនគរនេះ សម្រាប់ថ្ងៃដែលការគ្រងរាជ្យរបស់ព្រះជាម្ចាស់នឹងត្រូវបានតាំងឡើងលើផែនដី នឹងនៅចុងក្រោយនៅពេលដែលរាស្ត្ររបស់ទ្រង់ទទួលការបង្ហាញថាគ្មានទោស។ ហើយឥឡូវនេះ ព្រះយេស៊ូវ—ជាអ្នកភូមិណាសារ៉ែត ដែលបានក្លាយជាគ្រូ—កំពុងតែប្រាប់ពួកគាត់ថា ថ្ងៃដែលពួកគាត់បានទន្ទឹងរង់ចាំបានមកដល់ហើយ។

ប៉ុន្តែ មិនគ្រាន់តែប៉ុណ្ណោះ ព្រះអង្គក៏កំពុងតែប្រកាសថា នគររបស់ព្រះជាម្ចាស់ត្រូវបានតាំងឡើងក្នុងទ្រង់! ដូច្នេះ ក្នុងកណ្ឌគម្ពីរ ម៉ាថាយ ១២:២៨ នៅពេលដែលពួកផារិស៊ីចោទប្រកាន់ព្រះយេស៊ូវ ទាក់ទងនឹងការដេញអារក្សដោយនូវឈ្មោះសាតាំង នោះព្រះយេស៊ូវបានស្ដីបន្ទោសពួកគេ ហើយធ្វើការអះអាងយ៉ាងភ្ញាក់ផ្អើល «បើសិនជាខ្ញុំដេញអារក្ស ដោយសារព្រះវិញ្ញាណនៃព្រះវិញ នោះឈ្មោះថា នគរព្រះបានមកដល់អ្នករាល់គ្នាហើយ»។ តើលោកអ្នកឃើញនូវអ្វីដែលទ្រង់កំពុងតែមានបន្ទូលដែរឬទេ? ច្បាស់ណាស់ ព្រះយេស៊ូវ*បាន*ដេញអារក្ស ហើយព្រះអង្គបានធ្វើការនោះតាមរយៈព្រះវិញ្ញាណរបស់ព្រះជាម្ចាស់។ នៅចុងបញ្ចប់ អ្វីដែលព្រះអង្គកំពុងតែអះអាងគឺថា សេចក្ដីសន្យារបស់ព្រះជាម្ចាស់ក្នុងការរំដោះរាស្ត្រទ្រង់បានចាប់ផ្ដើមហើយ។ នគរព្រះបានមកដល់។

នោះជាគំនិតដ៏អស្ចារ្យមែន! ការដែលព្រះយេស៊ូវបានយាងមកយកកំណើត គឺធំលើសច្រើនជាងការដែលព្រះអាទិកររបស់យើង

បានមកលេង។ វាគឺជាការចាប់ផ្ដើមនៃដំណើរការយ៉ាងពេញទីរបស់ព្រះជាម្ចាស់ និងការប្រយុទ្ធប្រឆាំងនឹងអំពើបាប សេចក្ដីស្លាប់ និងការបំផ្លាញអ្វីៗទាំងអស់ជាចុងក្រោយដែលបានចូលមកកាន់ផែនដីនៅពេលដែលលោក អ័ដាម ធ្លាក់ក្នុងអំពើបាប។

លោកអ្នកអាចឃើញសង្គ្រាមដែលបានកើតឡើងពាសពេញដំណើររឿងនៃព្រះជន្មរបស់ព្រះយេស៊ូវក្នុងព្រះគម្ពីរសញ្ញាថ្មី។ ព្រះយេស៊ូវដ៏ជាស្ដេចបានចូលទៅក្នុងទីរហោស្ថានតែម្នាក់ឯង ដើម្បីប្រឈមមុខនឹងសាតាំង—វាបានល្បួងលោក អ័ដាម ហើយបោះលោកីយ៍ចូលក្នុងភាពពុករលួយអស់ជាច្រើនឆ្នាំតាំងពីដើមរៀងមក—ហើយព្រះអង្គក៏បានយកឈ្នះលើវាជាស្រេចផងដែរ! ព្រះអង្គបានពាល់ភ្នែកមនុស្សប្រុសម្នាក់ដែលបានកើតមកខ្វាក់ពីកំណើត ហើយពន្លឺក៏បានចូលទៅកាន់គាត់ជាលើកដំបូងបង្អស់។ ព្រះអង្គបានទតមើលផ្នូរដ៏ងងឹតដែលពេញដោយការខកចិត្ត ហើយបន្លឺសំឡេងថា «ឡាសារអើយ ចូរចេញមក!» ហើយកណ្ដាប់ដៃនៃសេចក្ដីស្លាប់លើមនុស្សជាតិក៏ចាប់ផ្ដើមមានភាពទន់ខ្សោយ ខណៈពេលដែលមនុស្សស្លាប់នោះដើរចេញមកក្រៅ។

ហើយប្រាកដណាស់ លើសពីការទាំងអស់នោះ បន្ទាប់មកព្រះយេស៊ូវបានយកឈ្នះលើអំពើបាបផ្ទាល់នៅពេលដែលព្រះអង្គបានបន្លឺសំឡេងនៅលើឈើឆ្កាងថា «ការស្រេចហើយ!»។ ហើយនៅចុងបញ្ចប់ កណ្ដាប់ដៃនៃសេចក្ដីស្លាប់ក៏បានបរាជ័យទាំងស្រុងនៅពេលដែលពួកទេវតាលើកឡើងថា—ដោយមានស្នាមញញឹម ខ្ញុំប្រាកដ

ណាស់— «ហេតុអ្វីបានជាមករកព្រះអង្គ ដែលមានព្រះជន្មរស់ នៅក្នុងទីខ្មោចស្លាប់ដូច្នេះ ទ្រង់មានព្រះជន្មរស់ឡើងវិញហើយ» (លូកា ២៤:៥-៦)។ ពីមួយជំហានទៅមួយជំហានទៀត និងការវាយហើយវាយទៀត ព្រះយេស៊ូវកំពុងតែស្តារឡើងវិញជាស្រេចនូវលទ្ធផលនៃការធ្លាក់ក្នុងអំពើបាប។ ស្តេចដ៏ត្រឹមត្រូវនៃផែនដីនេះបានយាងមកហើយគ្រប់អ្វីៗដែលកំពុងតែរារាំងការតាំងនគររបស់ទ្រង់—អំពើបាប សេចក្តីស្លាប់ ស្ថាននរក សាតាំង—ក៏កំពុងតែចាញ់ទាំងស្រុងដែរ។

អ្វីដែលចំណាចនេះចង់មានន័យគឺថា ផ្នែកជាច្រើននៃព្រះពរខាងឯនគរក៏បានក្លាយជារបស់យើងផងដែរ។ ដូច្នេះ ព្រះយេស៊ូវបានប្រាប់ពួកសិស្សរបស់ទ្រង់ថាព្រះអង្គនឹងចាត់ «ជំនួយ១អង្គទៀត» គឺព្រះវិញ្ញាណបរិសុទ្ធ ដែលនឹងដឹកនាំពួកគាត់ ធ្វើឲ្យពួកគាត់ដឹងជាក់ក្នុងចិត្តអំពីអំពើបាបរបស់ខ្លួន ហើយនឹងបន្សុទ្ធពួកគាត់។ ដូចគ្នាផងដែរ សូម្បីតែឥឡូវនេះក៏គ្រីស្ទបរិស័ទដឹងអំពីអត្ថន័យនៃការក្លាយជាកូនចិញ្ចឹមក្នុងគ្រួសាររបស់ព្រះជាម្ចាស់ និងការទទួលបានការផ្សះផ្សាជាមួយទ្រង់ដែរ។ សាវ័ក ប៉ុល ក៏បានលើកឡើងថា ក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់ ព្រះអង្គបានលើកយើងឡើងរួចហើយ ហើយយើងក៏កំពុងតែអង្គុយជាមួយនឹងព្រះគ្រីស្ទផងដែរ (អេភេសូរ ២:៦)។

នេះគឺជាសេចក្តីពិតដែលលើកទឹកចិត្តយើងយ៉ាងខ្លាំងមែនទែន។ ប៉ុន្តែ នៅមានអ្វីផ្សេងទៀត ជាចំណុចដែលសំខាន់ស្មើគ្នា ដែលដាច់ខាតយើងក៏ត្រូវតែយល់។

**នគរដែលមិនទាន់ពេញទីនៅឡើយ**

ទី៣ នគររបស់ព្រះជាម្ចាស់មិនទាន់ពេញទីនៅឡើយទេ ហើយនគរនេះក៏នឹងនៅមិនទាន់ពេញទីរហូតទាល់តែព្រះយេស៊ូវដ៏ជាស្តេចយាងត្រឡប់មកវិញផងដែរ។ ទោះបើគ្រប់អ្វីៗដែលព្រះយេស៊ូវបានធ្វើ ដើម្បីផ្តួលអំណាចអាក្រក់ ក៏ព្រះអង្គមិនទាន់បានតាំងការគ្រងរាជ្យរបស់ព្រះជាម្ចាស់នៅលើផែនដីនេះយ៉ាងពេញទី និងជាចុងបញ្ចប់នៅឡើយដែរ—យ៉ាងហោចណាស់មិនទាន់។ មនុស្សខ្លាំងពូកែត្រូវបានគេចងប៉ុន្តែមិនបានបំផ្លាញចោល។ អំពើអាក្រក់ក៏បានចាញ់ ប៉ុន្តែមិនទាន់បានរំលាយចោល ហើយនគររបស់ព្រះជាម្ចាស់ក៏ត្រូវបានតាំងឡើង ប៉ុន្តែមិនទាន់បានឈានដល់ការពេញទីទាំងស្រុង និងជាចុងក្រោយនៅឡើយទេ។

ព្រះយេស៊ូវបានមានបន្ទូលអំពីថ្ងៃអនាគត នៅពេលដែលនគរនឹងទទួលបានការបំពេញយ៉ាងពេញទី។ នៅថ្ងៃនោះ ព្រះអង្គបានមានបន្ទូលថា ពួកទេវតានឹង «ទៅប្រមូលយកអស់ទាំងក្បួន ដែលនាំឲ្យមនុស្សរវាតចិត្ត នឹងពួកអ្នកដែលប្រព្រឹត្តទទឹងច្បាប់ ពីនគរចេញ…ពួកសុចរិតនឹងភ្លឺដូចជាថ្ងៃ នៅក្នុងនគររបស់ព្រះវរបិតានៃគេ» (ម៉ាថាយ ១៣:៤១-៤៣)»។ នៅពិធីជប់លៀងចុងក្រោយ ព្រះអង្គក៏បានទន្ទឹងរង់ចាំថ្ងៃដែលព្រះអង្គនឹងផឹកពីផលផ្លែទំពាំងបាយជូរម្តងទៀតជាមួយនឹងពួកសិស្សរបស់ទ្រង់ «តែខ្ញុំប្រាប់អ្នករាល់គ្នាថា ពីនេះតទៅមុខ ខ្ញុំមិនផឹកពីផលផ្លែទំពាំងបាយជូរទៀតទេ ដរាបដល់ថ្ងៃណាដែលខ្ញុំនឹង

9Marks Online PDF

ផឹកជាថ្មី ជាមួយនឹងអ្នករាល់គ្នានៅក្នុងនគរព្រះវរបិតានៃខ្ញុំ» (ម៉ាថាយ ២៦:២៩)។

សាវ័ក ប៉ុល ក៏បានទន្ទឹងរង់ចាំថ្ងៃដែលអ្នកស្លាប់នឹងរស់ឡើងវិញនៅអស់កល្បជានិច្ចផងដែរ (១កូរិនថូស ១៥) ហើយគាត់ក៏បានប្រាប់ពួកជំនុំអេភេសូរថា ព្រះវិញ្ញាណបរិសុទ្ធបានដៅចំណាំពួកគាត់រួចហើយដែរ «ព្រះវិញ្ញាណនោះទ្រង់ជាទីបញ្ចាំចិត្ត ពីដំណើរកេរ្តិ៍អាកររបស់យើងរាល់គ្នា *ទាល់តែបានលោះរបស់កំណាន់*» (អេភេសូរ ១:១៤)។ បន្ទាប់មកទៀត គាត់បានលើកឡើងថា ព្រះជាម្ចាស់បានសង្គ្រោះយើង «ដើម្បីឲ្យទ្រង់បានសម្តែង *ឲ្យអស់ទាំងកល្បខាងមុខ* បានឃើញព្រះគុណដ៏ធ្ងន់លើសលប់របស់ទ្រង់ ដោយសេចក្តីសប្បុរសដែលទ្រង់ផ្តល់មកយើង ក្នុងព្រះគ្រីស្ទយេស៊ូវ» (អេភេសូរ ២:៧)។ សាវ័ក ពេត្រុស ក៏បានមានប្រសាសន៍អំពី «សេចក្តីសង្គ្រោះ ដែលប្រុងប្រៀបនឹងសម្តែងមកនៅជាន់ក្រោយបង្អស់នោះ» (១ពេត្រុស ១:៥) ហើយអ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរក៏បានប្រាប់មិត្តអ្នកអានរបស់គាត់ថា ពួកគាត់ «ជាអ្នកដទៃ ដែលគ្រាន់តែសំណាក់នៅផែនដីប៉ុណ្ណោះ» (ហេព្រើរ ១១:១៣) ហើយថា ពួកគាត់គួររង់ចាំ «ក្រុង១ ដែលមានឫសជញ្ជាំង ដែលព្រះទ្រង់ជាអ្នកគូរ ហើយជាជាងសង់» (ខ១០)។

សេចក្តីសង្ឃឹមដ៏អស្ចារ្យរបស់គ្រីស្ទបរិស័ទ (អ្វីដែលយើងទទឹងរង់ចាំ និងសម្លឹងមើលដើម្បីទទួលបានកម្លាំង និងការលើកទឹកចិត្ត) គឺថ្ងៃដែលស្តេចរបស់យើងនឹងហែកមេឃ ហើយយាងចុះត្រឡប់មកវិញ

9Marks Online PDF

ដើម្បីតាំងនគរដ៏រុងរឿងរបស់ទ្រង់ ជាសម្រេចនិងអស់កល្បជានិច្ច។ ក្នុងខណៈដ៏រុងរឿងនោះ គឺជាពេលដែលរាល់គ្រប់អ្វីៗនៅលើផែនដីនេះនឹងទទួលការរៀបរៀងឡើងវិញយ៉ាងត្រឹមត្រូវ ជាពេលដែលភាពយុត្តិធម៌និងកើតឡើងជាសម្រេច ជាពេលដែលអំពើអាក្រក់នឹងបំផ្លាញចោលអស់កល្បជានិច្ច ហើយសេចក្តីសុចរិតនឹងត្រូវបានតាំងឡើងម្តងជាស្រេច។ ព្រះជាម្ចាស់បានសន្យាថា៖

> «ដ្បិតមើល អញនឹងបង្កើតផ្ទៃមេឃថ្មី ហើយនឹងផែនដីថ្មី ឯរបស់ពីមុនៗ នោះនឹងគ្មានអ្នកណានឹកចាំទៀត ក៏មិនដែលចូលក្នុងគំនិតឡើយ....នោះអញនឹងមានសេចក្តីរីករាយចំពោះក្រុងយេរូសាឡិម និងសេចក្តីអំណរចំពោះរាស្ត្រអញ រួចនៅក្នុងទីក្រុងនោះ នឹងលែងឮសំឡេងយំ និងសម្រែកឮយំទៀតឡើយ» (អេសាយ ៦៥:១៧ ១៩)។

ហើយនៅគ្រានោះ ហោរា អេសាយ បានប្រាប់យើងថា៖

> «វារាល់គ្នានឹងមិនធ្វើទុក្ខ ឬបំផ្លាញគ្នា នៅគ្រប់លើភ្នំបរិសុទ្ធរបស់អញ ដ្បិតគ្រប់ទាំងអស់នឹងស្គាល់ព្រះយេហូវ៉ានៅពេញពាសលើផែនដី ដូចជាទឹកនៅពេញពាសក្នុងសមុទ្រដែរ» (អេសាយ ១១:៩)។

កាលខ្ញុំនៅក្មេង ខ្ញុំធ្លាប់គិតថាវាសនារបស់គ្រីស្ទបរិស័ទគឺត្រូវ

ចំណាយពេលវេលាក្នុងកម្មវិធីក្រុមជំនុំដែលមិនចេះចប់ ហើយដាច់ដោយឡែកពីខ្លួន។ នោះគឺជាគំនិតដែលគួរឲ្យខ្លាចណាស់! ប៉ុន្តែ វាគឺជាគំនិតដែលខុសទាំងស្រុង។ ព្រះជាម្ចាស់សព្វព្រះហឫទ័យក្នុងការបង្កើតផែនដីថ្មីសម្រាប់រាស្ត្ររបស់ទ្រង់ ដែលមិនមានអំពើបាប សេចក្តីស្លាប់ និងជំងឺ។ នឹងលែងមានសង្គ្រាមទៀត ការសង្កត់សង្កិននឹងត្រូវបញ្ឈប់ ហើយព្រះជាម្ចាស់នឹងគង់នៅជាមួយនឹងរាស្ត្ររបស់ទ្រង់អស់កល្បជានិច្ច។ រាស្ត្ររបស់ព្រះជាម្ចាស់នឹងលែងរងទុក្ខដោយស្លាប់ទៀតហើយ ហើយយើងក៏នឹងមិនដែលស្រក់ទឹកភ្នែកនៅឯផ្នូរទៀត។ ហើយក៏នឹងលែងមានពេលដែលទារករស់នៅតែប៉ុន្មានថ្ងៃ ហើយបន្ទាប់មកស្លាប់ផងដែរ។ ហើយយើងក៏នឹងលែងកាន់ទុក្ខ មានភាពឈឺចាប់ ឬក៏យំសោកទៀតផង។ ហើយយើងក៏នឹងលែងចង់បានផ្ទះនៅលើផែនដីនេះទៀតហើយ។ ដ្បិតដូចកណ្ឌគម្ពីរវិវរណៈបានប្រាប់យើងថា ព្រះជាម្ចាស់ផ្ទាល់នឹងជូតទឹកភ្នែកចេញពីភ្នែកយើងរាល់គ្នា ហើយនៅចុងបញ្ចប់យើងនឹងឃើញព្រះភក្ត្រទ្រង់!

អស្ចារ្យណាស់ តើលោកអ្នកនឹងឆ្លើយតបយ៉ាងដូចម្តេចចំពោះចំណុចទាំងអស់នេះ? ខ្ញុំគិតថា មានចំណុចមួយ៖ ឱព្រះអម្ចាស់ព្រះយេស៊ូវអើយ សូមព្រះអង្គឆាប់យាងមកវិញ!

ខ្ញុំតែងតែមានការភ្ញាក់ផ្អើលបន្តិច នៅពេលដែលខ្ញុំឮគេនិយាយអំពីសេចក្តីសន្យាទាំងនេះ—ផ្ទៃមេឃនិងផែនដីថ្មី ទីក្រុងស្ថានសួគ៌ដែលមិនមានអំពើអាក្រក់អាចចូលបាន ពិភពលោកដែលគ្មានសេចក្តីស្លាប់

សង្គ្រាម និងការសង្កត់សង្កិន រាស្ត្ររបស់ព្រះជាម្ចាស់ដែលបានរស់ឡើងវិញ ហើយរស់នៅចំពោះព្រះភក្ត្រទ្រង់ ពេញទៅដោយអំណរអស់កល្បជានិច្ច—ហើយបន្ទាប់មកពួកគាត់ក៏បែរចេញពីសេចក្ដីសន្យានេះ ហើយនិយាយថា “តោះ! ចូរយើងនាំគ្នាទៅធ្វើឲ្យការនោះកើតឡើង!”។

ចំណុចពិតគឺថា យើងដែលជាមនុស្សមិនមានសមត្ថភាពក្នុងការនាំឲ្យការតាំងនគរ និងការធ្វើឲ្យនគររបស់ព្រះជាម្ចាស់បានសម្រេចឡើងឡើយ។ មិនថាយើងខំឲ្យបានល្អខ្លាំងប៉ុណ្ណាក៏ដោយ—ហើយធ្វើអស់ពីចិត្តយ៉ាងស្មោះ—ក្នុងការធ្វើឲ្យផែនដីនេះក្លាយជាកន្លែងដ៏ល្អប្រសើរ ក៏នគរដែលបានសន្យានៅក្នុងព្រះគម្ពីរនឹងកើតឡើងនៅពេលតែព្រះយេស៊ូវដ៏ជាស្ដេចផ្ទាល់យាងត្រឡប់មកធ្វើឲ្យវាកើតឡើង។

នោះគឺជាចំណុចដ៏សំខាន់ក្នុងការចងចាំ ដោយមានហេតុផលពីរបីយ៉ាង។ ទី១ វាការពារយើងពីការមានសុទិដ្ឋិនិយមមិនត្រឹមត្រូវ នៅចុងបញ្ចប់ជាការបោកប្រាស់ អំពីអ្វីដែលយើងគិតថាយើងមានសមត្ថភាពក្នុងការសម្រេចឡើងនៅលើផែនដីដែលបានធ្លាក់ក្នុងអំពើបាបនេះ។ ប្រាកដណាស់ គ្រីស្ទបរិស័ទនឹងមានសមត្ថភាពក្នុងការនាំមកនូវការផ្លាស់ប្រែមួយចំនួនក្នុងសង្គមនេះ។ ការនោះបានកើតឡើងពីមុនហើយនៅក្នុងប្រវត្តិសាស្ត្រ ហើយខ្ញុំក៏មិនមានមូលហេតុក្នុងការសង្ស័យថាវាក៏កំពុងតែកើតឡើងក្នុងកន្លែងមួយចំនួនសូម្បីតែឥឡូវនេះផងដែរ ហើយថាវាក៏អាចកើតឡើងជាថ្មីម្ដងទៀតនៅអនាគត។ គ្រីស្ទបរិស័ទធ្លាប់ ហើយក៏អាចធ្វើអ្វីដែលល្អប្រសើរយ៉ាងខ្លាំងលើផែនដីនេះ—អំពើ

9Marks Online PDF

ល្អដែលធ្វើឲ្យគេសរសើរព្រះជាម្ចាស់ និងព្រះយេស៊ូវគ្រីស្ទនៅលើផែនដីនេះ។

ប៉ុន្តែ ខ្ញុំគិតថា ដំណើររឿងព្រះគម្ពីរបង្ខំឲ្យយើងទទួលស្គាល់ថា លុះត្រាតែព្រះគ្រីស្ទយាងត្រឡប់មកវិញ នោះជ័យជម្នះរបស់យើងក្នុងសង្គម និងប្រពៃណីនឹងបន្តនៅមិនរឹងប៉ឹង ឬក៏អចិន្ត្រៃយ៍ឡើយ។ គ្រីស្ទបរិស័ទនឹងមិនអាចនាំឲ្យនគររបស់ព្រះជាម្ចាស់កើតឡើងបានឡើយ។ មានតែព្រះជាម្ចាស់ផ្ទាល់ទេដែលអាចធ្វើឲ្យការនោះកើតឡើងបាន។ ទីក្រុងយេរូសាឡឹមដ៏រុងរឿង*នឹងចុះពីស្ថានសួគ៌* មិនមែនសង់ពីក្រោមឡើងលើនោះទេ។

ហើយកាន់តែសំខាន់ជាងនោះទៅទៀត ការចងចាំថា នគរនឹងត្រូវតាំងឡើងនៅពេលដែលព្រះយេស៊ូវយាងត្រឡប់មកវិញក៏ផ្ដោតយ៉ាងត្រឹមត្រូវនូវសេចក្ដីសង្ឃឹម ការស្រឡាញ់ និងការដែលយើងចង់បានព្រះយេស៊ូវផ្ទាល់។ ជាជាងស្វែងរកកម្លាំង ទង្វើ អំណាចរបស់មនុស្សផ្សេងទៀត ឬក៏សូម្បីតែការខិតខំប្រឹងប្រែងរបស់យើងផ្ទាល់ ដើម្បីធ្វើឲ្យគ្រប់អ្វីៗមានភាពត្រឹមត្រូវឡើង គឺយើងសម្លឹងមើលទៅឯស្ថានសួគ៌ ហើយស្រែកជាមួយនឹងសាវ័ក យ៉ូហាន “អាម៉ែន ព្រះអម្ចាស់យេស៊ូវអើយ សូមយាងមក!”។ យើងនឹងកាន់តែចង់ឲ្យព្រះអង្គយាងត្រឡប់មកវិញ ការអធិស្ឋានរបស់យើងនឹងកាន់តែឆេះឆួលជាងមុន ហើយយើងក៏កាន់តែស្រឡាញ់ព្រះអង្គជាងមុនផងដែរ។ និយាយឲ្យខ្លីទៅ សេចក្ដីប្រាថ្នា និងសេចក្ដីសង្ឃឹមរបស់យើងមានមូលដ្ឋានកណ្ដាល

យ៉ាងរឹងមាំ—ហើយត្រឹមត្រូវ—មិនមែនផ្ដោតយ៉ាងខ្លាំងលើនគរ ដូចជានគររបស់ស្ដេចនោះទេ។

## ការឆ្លើយតបទៅកាន់ស្ដេច

ទី៤ ការរាប់បញ្ចូលក្នុងនគររបស់ព្រះជាម្ចាស់អាស្រ័យទាំងស្រុងលើការឆ្លើយតបរបស់បុគ្គលណាម្នាក់ចំពោះស្ដេចនៃនគរនោះ។ ព្រះយេស៊ូវមិនអាចមិនមានបន្ទូលយ៉ាងច្បាស់លាស់អំពីចំណុចនេះបានទៀតទេ។ ម្ដងហើយម្ដងទៀត ព្រះអង្គបានយកការឆ្លើយតបរបស់បុគ្គលណាម្នាក់ចំពោះទ្រង់ និងសាររបស់ទ្រង់ជាចំណាចសម្រេចត្រង់ថា តើបុគ្គលនោះនឹងត្រូវបានរាប់បញ្ចូលក្នុងនគររបស់ទ្រង់ ឬក៏អត់? សូមគិតអំពីសាច់រឿងនៃអ្នកមានម្នាក់។ គាត់បានសួរថា “តើត្រូវឲ្យខ្ញុំធ្វើដូចម្ដេច ប្រយោជន៍ឲ្យបានគ្រងជីវិតរស់អស់កល្បជានិច្ច?”។ ហើយជាចុងក្រោយ ព្រះយេស៊ូវបានមានបន្ទូលតបថា “មកតាមខ្ញុំចុះ” ដែលចំពោះបុរសនោះ នេះមានន័យថា គាត់ត្រូវបែរចេញពីទំនុកចិត្តរបស់គាត់នៅលើទ្រព្យសម្បត្តិគាត់ផ្ទាល់ ហើយទទួលជឿលើព្រះយេស៊ូវ (ម៉ាកុស ១០:១៧, ២១)។

ម្ដងហើយម្ដងទៀត ព្រះយេស៊ូវបានមានបន្ទូលថា ព្រះជាម្ចាស់នឹងគូសបន្ទាត់យ៉ាងច្បាស់ចំពាក់កណ្ដាលមនុស្សលោក ឲ្យអ្នកដែលទទួលបានសេចក្ដីសង្គ្រោះ និងអ្នកដែលមិនទទួលបានសេចក្ដីសង្គ្រោះនៅដាច់ដោយឡែកពីគ្នា។ ហើយមានចំណុចមួយដែលជាចំណាចខុសគ្នារវាងក្រុមទាំងពីរ គឺទាក់ទងទៅនឹងរបៀបដែលពួកគាត់

9Marks Online PDF

បានឆ្លើយតបទៅកាន់ព្រះយេស៊ូវដ៏ជាស្តេច។ នេះគឺជាចំណុចស្នូលនៃសាច់រឿងសត្វចៀម និងសត្វពពែនៅក្នុងកណ្ឌគម្ពីរម៉ាថាយជំពូក ២៥។ នៅចុងបញ្ចប់ ចំណាចខុសគ្នារវាង “ចូរមក” និង “ចូរថយចេញពីអញទៅ” គឺទាក់ទងនឹងរបៀបដែលបុគ្គលនីមួយៗបានឆ្លើយតបទៅកាន់ព្រះយេស៊ូវ តាមដែល “ពួកបងប្អូន” ទ្រង់ដែលជារាស្ត្ររបស់ទ្រង់បានប្រកាស។

ហើយពិតណាស់ អ្វីដែលធ្វើឲ្យយើងមានសមត្ថភាពក្នុងការក្លាយជារាស្ត្ររបស់ព្រះយេស៊ូវជាដំបូងនោះ គឺថាព្រះអង្គបានសុគតនៅលើឈើឆ្កាងជំនួសយើង។ នោះគឺជាចំណុចដែលគួរឲ្យភ្ញាក់ផ្អើលខ្លាំងណាស់អំពីព្រះយេស៊ូវ មិនមែនគ្រាន់តែថាព្រះអង្គជាស្តេច ឬក៏ថាព្រះអង្គបានចាប់ផ្តើមតាំងនគរនៃសេចក្តីស្រឡាញ់ និងសេចក្តីអាណិតអាសូរប៉ុណ្ណោះទេ។ តាមពិតទៅ នេះមិនសូវជាគួរឲ្យភ្ញាក់ផ្អើលប៉ុន្មានឡើយ ពួកសាសន៍យូដាគ្រប់រូបបានដឹងហើយថា ការនោះនឹងកើតឡើងនៅថ្ងៃណាមួយជាមិនខាន។ ទេ! អ្វីដែលពិតជាគួរឲ្យភ្ញាក់ផ្អើលអំពីដំណឹងល្អនៃព្រះយេស៊ូវ គឺថាស្តេចមួយអង្គនេះបាន*សុគត* ដើម្បីសង្គ្រោះរាស្ត្ររបស់ទ្រង់ ត្រង់ថាព្រះមេស្ស៊ីជាព្រះមេស្ស៊ីដែលគេ*បានឆ្កាង*។

ពួកសាសន៍យូដាបានសង្ឃឹមជាច្រើនសតវត្សរ៍ថា ស្តេចដែលជាព្រះមេស្ស៊ីនឹងយាងមកហើយរំដោះពួកគាត់។ ពួកគេក៏សង្ឃឹមថានឹងមានអ្នកបម្រើរបស់ព្រះអម្ចាស់ដែលនឹងរងទុក្ខលំបាកផងដែរ (ហោរា

9Marks Online PDF

អេសាយ បានទាយទុក) ហើយពួកគាត់ក៏ថែមទាំងមានការរំពឹងទុកមិនច្បាស់លាស់អំពី «កូនមនុស្ស» ដែលជាព្រះ ដែលនឹងលេចមកនៅគ្រាចុងក្រោយ (ហោរា ដានីយ៉ែល)។ ទោះជាយ៉ាងណាក៏ដោយក៏អ្វីដែលពួកគាត់មិនបាននឹកស្មានដល់គឺថា រូបអង្គទាំងបីនេះគឺជាបុរសតែមួយ! ហើយក៏នឹងមិនមានអ្នកណាផ្សេងទៀតដែលនឹងព្យាយាមបំពេញតួនាទីទាំងបីនោះម្ដងទៀត—យ៉ាងហោចណាស់មិនមានរហូតដល់ព្រះយេស៊ូវយាងមក។

ទោះជាយ៉ាងណាក៏ដោយ ក៏ព្រះយេស៊ូវមិនគ្រាន់តែបានអះអាងថា ទ្រង់គឺជាការបំពេញសេចក្ដីសង្ឃឹមនៃព្រះមេស្ស៊ីរបស់សាសន៍អ៊ីស្រាអែល (ដែលគឺជាស្ដេច) ប៉ុន្តែថែមទាំងសំដៅមកកាន់រូបអង្គទ្រង់ម្ដងហើយម្ដងទៀតថាជា «កូនមនុស្ស» ដែលជាព្រះពីកណ្ឌគម្ពីរដានីយ៉ែលជំពូក៧។ លើសពីនោះទៅទៀត ព្រះយេស៊ូវបានមានបន្ទូលថា កូនមនុស្សបានមក «ឲ្យជីវិតខ្លួនទុកជាថ្លៃលោះមនុស្សជាច្រើនផង» (ម៉ាកុស ១០:៤៥) ដែលនោះក៏បានចង្អុលយ៉ាងប្រាកដប្រជាទៅកាន់អ្នកបម្រើរបស់ព្រះអម្ចាស់ដែលរងទុក្ខនៅក្នុងកណ្ឌគម្ពីរអេសាយ ៥៣:១០។

តើលោកអ្នកឃើញអ្វីដែលព្រះយេស៊ូវកំពុងតែអះអាងដែរឬទេ? ព្រះអង្គកំពុងតែមានបន្ទូលថាទ្រង់ផ្ទាល់បានបំពេញ—ទាំងអស់ក្នុងពេលតែមួយ—នូវតួនាទីនៃព្រះមេស្ស៊ីពីខ្សែស្រឡាយស្ដេច ដាវីឌ អ្នកបម្រើដែលរងទុក្ខនៅក្នុងកណ្ឌគម្ពីរអេសាយ និងកូនមនុស្សនៅ

ក្នុងកណ្ឌគម្ពីរដានីយ៉ែល! ព្រះយេស៊ូវបានយកសណ្ឋានជាព្រះនៃកូនមនុស្ស ភ្ជាប់វាទៅក្នុងអ្នកបម្រើដែលរងទុក្ខជំនួស ហើយនៅចុងបញ្ចប់ក៏បានច្របាច់ចូលគ្នានូវរាល់តួនាទីជាព្រះមេស្ស៊ីរបស់ទ្រង់។ ទំរាំតែដល់ពេលព្រះយេស៊ូវចប់ការប្រមូលផ្តុំគ្នានូវការគំរាមកំហែងពីសេចក្តីសង្ឃឹមរបស់ពួកសាសន៍យូដា ប្រាកដណាស់ស្តេចមួយអង្គនេះមានលក្ខណៈលើសជាងអ្នកបដិវត្តន៍ដែលសាសន៍យូដាសង្ឃឹមចង់បានទៅទៀត។ ព្រះអង្គគឺជាព្រះដែលជាស្តេច និងជាអ្នកបម្រើដែលនឹងត្រូវរងទុក្ខ ហើយសុគតសម្រាប់រាស្ត្រទ្រង់ ដើម្បីទទួលបានសេចក្តីសង្គ្រោះសម្រាប់ពួកគេ ធ្វើឲ្យពួកគេសុចរិតនៅក្នុងព្រះនេត្រព្រះវរបិតាទ្រង់ និងនាំពួកគេចូលនគរយ៉ាងរុងរឿងរបស់ទ្រង់។

អាស្រ័យលើចំណុចទាំងអស់នោះ វាមិនមែនជារឿងភ្ញាក់ផ្អើលនោះទេដែលព្រះយេស៊ូវបានតម្រូវឲ្យការចូលក្នុងនគររបស់ទ្រង់ពឹងផ្អែកទាំងស្រុងលើចំណុចដែលថា បុគ្គលណាម្នាក់កែប្រែចិត្តចេញពីបាប និងទុកចិត្តលើទ្រង់ និងព័ន្ធកិច្ចនៃការធួននឹងបាបរបស់ទ្រង់នៅលើឈើឆ្កាង។ នៅពេលដែលព្រះយេស៊ូវមានបន្ទូលអំពី “ដំណឹងល្អពីនគរ” គោលបំណងរបស់ព្រះអង្គគឺមិនមែនគ្រាន់តែថានគរបានមកដល់នោះទេ។ គោលបំណងគឺថា នគរបានមកដល់ហើយ *ហើយ* លោកអ្នកក៏អាចទទួលបានការរាប់បញ្ចូលទៅក្នុងវាបានដែរ ប្រសិនបើលោកអ្នកមានការរួបរួមជាមួយនឹងខ្ញុំ ដែលជាស្តេច តាមរយៈជំនឿដែលថាមានតែខ្ញុំមួយប៉ុណ្ណោះដែលអាចសង្គ្រោះលោកអ្នកចេញពីអំពើ

បាបរបស់ខ្លួនបាន។

ដូច្នេះ ការក្លាយជារាស្ត្រនៃនគររបស់ព្រះគ្រីស្ទគឺមិនមែនគ្រាន់តែជា «ការរស់នៅក្រោមក្រឹត្យក្រមនគរ» ឬក៏ «ការត្រាប់តាមគំរូរបស់ព្រះយេស៊ូវ» ឬក៏ «រស់នៅដូចព្រះយេស៊ូវបានមានព្រះជន្ម» នោះទេ។ ចំណុចពិតគឺថា បុគ្គលណាម្នាក់អាចអះអាងថាខ្លួនជា «អ្នកដើរតាមព្រះយេស៊ូវ» ឬក៏ «ការរស់នៅក្រោមក្រឹត្យក្រមនគរ» ហើយគាត់ក៏អាចនៅក្រៅនគរនៅឡើយដែរ។ លោកអ្នកអាចរស់នៅដូចដែលព្រះយេស៊ូវបានមានព្រះជន្មដូចដែលលោកអ្នកចង់ធ្វើបាន លុះត្រាតែលោកអ្នកចូលទៅកាន់ស្តេចដែលគេបានឆ្កាង ដោយកែប្រែចិត្ត និងមានជំនឿ ហើយរំពឹងលើទ្រង់តែមួយអង្គគត់ថាជាយញ្ញបូជាដ៏ល្អឥតខ្ចោះសម្រាប់អំពើបាបរបស់លោកអ្នក ហើយថាជាសេចក្តីសង្ឃឹមតែមួយគត់របស់លោកអ្នកសម្រាប់សេចក្តីសង្គ្រោះ នោះលោកអ្នកមិនមែនជាគ្រីស្ទបរិស័ទ ឬក៏ជារាស្ត្រនៃនគររបស់ទ្រង់នោះទេ។

របៀបនៃការទទួលបានការរាប់បញ្ចូលក្នុងនគររបស់ព្រះគ្រីស្ទគឺការចូលទៅកាន់ស្តេច មិនមែនគ្រាន់តែក្នុងរបៀបដែលប្រកាសថាព្រះអង្គជាគំរូដ៏ល្អដែលបង្ហាញយើងអំពីរបៀបល្អប្រសើរក្នុងការរស់នៅប៉ុណ្ណោះទេ ប៉ុន្តែគឺការទុកចិត្តដោយមានការបន្ទាបខ្លួនលើទ្រង់ថាជាព្រះអម្ចាស់ដែលត្រូវបានគេឆ្កាង ហើយក៏បានមានព្រះជន្មរស់ឡើងវិញ ដែលអាចរំដោះយើងចេញពីការកាត់ទោសឲ្យស្លាប់។ នៅចុងបញ្ចប់ មានរបៀបតែមួយគត់ក្នុងការចូលក្នុងនគរគឺតាមរយៈព្រះលោហិតរបស់ស្តេច។

9Marks Online PDF

## ការត្រាស់ហៅឲ្យរស់នៅសម្រាប់ស្ដេច

ទី៥ ការក្លាយជារាស្ត្រនៃនគរគឺជាការត្រាស់ហៅឲ្យរស់នៅសម្រាប់នគរ។ ក្នុងកណ្ឌគម្ពីររ៉ូមជំពូក៦ សាវ័ក ប៉ុល បានប្រាប់ឲ្យគ្រីស្ទបរិស័ទទទួលស្គាល់ថា ព្រះអង្គបានសង្គ្រោះពួកគេចេញពីអំណាចនៃអំពើបាប ហើយក៏បាននាំពួកគេចូលនគរព្រះផងដែរ។

> «ដូច្នេះ យើងបានត្រូវកប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជក្នុងសេចក្ដីស្លាប់ ដើម្បីឲ្យយើងបានដើរក្នុងជីវិតបែបថ្មី ដូចជាព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញ ដោយសារសិរីល្អនៃព្រះវរបិតាដែរ ដ្បិតបើយើងបានជាប់ជាមួយនឹងទ្រង់ ក្នុងការដែលជាគំរូពីសេចក្ដីសុគតរបស់ទ្រង់ នោះក៏នឹងបានជាប់ក្នុងសេចក្ដីរស់ឡើងវិញរបស់ទ្រង់ដែរ ដោយដឹងសេចក្ដីនេះថា មនុស្សចាស់របស់យើង បានត្រូវឆ្កាងជាមួយនឹងទ្រង់ហើយ ដើម្បីឲ្យតួអំពើបាបបានត្រូវសូន្យទៅ ប្រយោជន៍កុំឲ្យយើងនៅបម្រើអំពើបាបទៀតឡើយ ដ្បិតអ្នកណាដែលស្លាប់ នោះក៏បានរាប់ជាសុចរិតរួចពីបាបហើយ បើសិនជាយើងស្លាប់ជាមួយនឹងព្រះគ្រីស្ទ នោះយើងជឿថា យើងនឹងរស់ជាមួយនឹងទ្រង់ដែរ ដោយដឹងថា ដែលព្រះគ្រីស្ទមានព្រះជន្មរស់ពីស្លាប់ឡើងវិញ នោះទ្រង់មិនចេះសុគតទៀតឡើយ ព្រោះសេចក្ដីស្លាប់គ្មានអំណាចលើទ្រង់ទៀត ដ្បិតដែលទ្រង់សុគត នោះគឺបានសុគតខាងឯបាប ១ដងជាសម្រេច ហើយដែលទ្រង់មានព្រះជន្មរស់ នោះទ្រង់រស់

ខាងឯព្រះវិញ ដូច្នេះ ចូរអ្នករាល់គ្នារាប់ខ្លួនទុកជាស្លាប់ខាងឯបាបដែរ តែរស់ខាងឯព្រះវិញចុះ ដោយនូវព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា» (រ៉ូម ៦:៤ ១១)។

នៅពេលដែលព្រះអង្គនាំយើងចូលនគររបស់ទ្រង់តាមរយៈជំនឿ ព្រះវិញ្ញាណបរិសុទ្ធប្រទានជីវិតថ្មីដល់យើង។ យើងក្លាយជារាស្ត្រនៃនគរថ្មី ជាអ្នកនៅក្រោមស្ដេចថ្មី។ ដោយសារការនោះ យើងក៏មានកាតព្វកិច្ចថ្មីក្នុងការស្ដាប់បង្គាប់ស្ដេចនោះ ក្នុងការរស់នៅក្នុងរបៀបដែលថ្វាយព្រះកិត្តិយសដល់ទ្រង់។ នេះហើយជាមូលហេតុដែលសាវ័កប៉ុល បានមានប្រសាសន៍ថា៖

«ហេតុនេះ កុំឲ្យបាបសោយរាជ្យក្នុងរូបកាយរបស់អ្នករាល់គ្នាដែលតែងតែស្លាប់ ដើម្បីនឹងស្ដាប់តាមសេចក្ដីប៉ងប្រាថ្នារបស់បាបនោះឡើយ ក៏កុំឲ្យប្រគល់អវយវៈទាំងប៉ុន្មាន របស់អ្នករាល់គ្នាទៅក្នុងអំពើបាប ទុកដូចជាប្រដាប់ប្រដាទុច្ចរិតនោះឡើយ គឺត្រូវប្រគល់ខ្លួនទៅព្រះ ដូចជាបានរស់ពីស្លាប់នោះឡើងវិញ» (រ៉ូម ៦:១២ ១៣)។

រហូតដល់ពេលព្រះគ្រីស្ទយាងត្រឡប់មកវិញ យើងដែលជារាស្ត្ររបស់ទ្រង់បន្តរស់នៅក្នុងយុគសម័យដែលពោរពេញទៅដោយអំពើបាប ហើយស្ដេចរបស់យើងបានត្រាស់ហៅឲ្យយើងរស់នៅក្នុងរបៀបដែលស័ក្តិសមសម្រាប់នគរដែលទ្រង់បានត្រាស់ឲ្យយើងចូល

9Marks Online PDF

(១ថែស្សាឡូនិច ២:១២) ឲ្យ “អ្នករាល់គ្នាភ្លឺនៅកណ្តាល” នៅជំណាន់មនុស្សវៀច ហើយខិលខូច (ភីលីព ២:១៥)។ នេះមិនមែនមានន័យថា ការរស់នៅជីវិតក្រោមក្រឹត្យក្រមនគរនឹងនាំឲ្យយើងចូលនគរទេ។ តែមានន័យថា នៅពេលដែលព្រះអង្គនាំយើងចូលទៅក្នុងនគររបស់ទ្រង់តាមរយៈជំនឿលើស្តេច គឺយើងមានចៅហ្វាយថ្មី ច្បាប់ថ្មី ក្រឹត្យក្រមថ្មី ជីវិតថ្មី—ដែលដូច្នោះ នោះយើងនឹងចាប់ផ្តើម*ចង់*រស់នៅជីវិតបែបនគរ។

ព្រះគម្ពីរបានប្រាប់យើងថានៅក្នុងយុគសម័យនេះ ជីវិតបែបនគរ គឺត្រូវបង្ហាញឡើងជាចម្បងនៅក្នុងក្រុមជំនុំ។ តើលោកអ្នកធ្លាប់គិតអំពីការនេះដែរឬទេ? ក្រុមជំនុំ*គឺជា*កន្លែងដែលព្រះអង្គធ្វើឲ្យគេ*ឃើញ*នគរទ្រង់ក្នុងយុគសម័យនេះ។ សូមមើលនៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៣:១០-១១៖

> “ដើម្បីឲ្យពួកគ្រប់គ្រង នឹងពួកមានអំណាចនៅស្ថានដ៏ខ្ពស់ បានស្គាល់ពីប្រាជ្ញានៃព្រះដ៏មានជាច្រើនយ៉ាងណាស់ ដោយសារពួកជំនុំ តាមគំនិតសម្រេចតាំងពីអស់កល្បរៀងមក ដែលទ្រង់បានគិតស្រេចក្នុងព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើង”។

ខ្ពស់លើសទាំងអស់ ក្រុមជំនុំគឺជាកន្លែងដែលព្រះជាម្ចាស់បានជ្រើសរើស ដើម្បីបង្ហាញប្រាជ្ញា របស់ទ្រង់ និងសិរីរុងរឿងនៃដំណឹងល្អ។ ដូចដែលមនុស្សជាច្រើននាក់បានលើកឡើងពីមុន ក្រុមជំនុំគឺ

ជាបន្ទាយនៃនគររបស់ព្រះជាម្ចាស់លើលោកនេះ។ វាមិនត្រឹមត្រូវទេក្នុងការលើកឡើងថា ក្រុមជំនុំ*គឺជា*នគររបស់ព្រះជាម្ចាស់។ ដូចដែលយើងបានឃើញ មានចំណុចលើសច្រើនជាងនោះទៅទៀតអំពីនគរ។ ប៉ុន្តែ វា*គឺជា*ការត្រឹមត្រូវក្នុងការលើកឡើងថា ក្រុមជំនុំគឺជាកន្លែងដែលយើង*ឃើញ*ការបង្ហាញនូវនគររបស់ព្រះជាម្ចាស់ក្នុងយុគសម័យនេះ។

តើអ្នកចង់ឃើញថានគររបស់ព្រះមានលក្ខណៈយ៉ាងដូចម្ដេចដែរឬទេ យ៉ាងហោចណាស់មុនពេលដែលព្រះអង្គធ្វើឲ្យវាល្អឥតខ្ចោះ? តើលោកអ្នកចង់ឃើញការរស់នៅជីវិតបែបនគរក្នុងយុគសម័យនេះដែរឬទេ? សូមមើលក្រុមជំនុំ។ នោះគឺជាកន្លែងដែលព្រះអង្គបង្ហាញប្រាជ្ញារបស់ទ្រង់ ហើយជាកន្លែងដែលព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះកំពុងតែស្ដាបនាឡើងវិញ និងសង់ឡើងវិញនូវជីវិតមនុស្ស។ វាជាកន្លែងដែលរាស្ត្ររបស់ព្រះជាម្ចាស់រៀនស្រឡាញ់គ្នាទៅវិញទៅមក យកអាសាគ្នា និងមានទុក្ខព្រួយ ជាកន្លែងយំជាមួយគ្នានិងជាកន្លែងដែលមានអំណរជាមួយគ្នា និងជាកន្លែងមើលខុសត្រូវគ្នាទៅវិញទៅមក។ ពិតណាស់ វាមិនល្អឥតខ្ចោះនោះទេ ប៉ុន្តែក្រុមជំនុំគឺជាកន្លែងដែលមានការរស់នៅបែបនគរ ដែលជាកន្លែងបង្ហាញលោកីយ៍ដែលពិតជាត្រូវការសេចក្ដីសង្គ្រោះណាស់។

## ការរត់តម្រង់កាត់ភាពងងឹត

ប្រាកដណាស់ ការដែលពិភពលោកនេះពិតជាត្រូវការការសង្គ្រោះគឺជាអ្វីដែលធ្វើឲ្យវាពិបាកណាស់ក្នុងការរស់នៅបែបជារាស្ត្រនៃ

9Marks Online PDF

នគររបស់ព្រះគ្រីស្ទក្នុងសម័យនេះ។ ចំពោះលោកីយ៍ គ្រីស្ទបរិស័ទគឺជាអ្នកគំរាមកំហែង ហើយវាតែងតែមានលក្ខណៈបែបនេះតាំងពីយូរយារណាស់មកហើយ។ ក្នុងគ្រានៃពួកជំនុំដំបូង គេរាប់ការប្រកាសថា «ព្រះយេស៊ូវជាព្រះអម្ចាស់!» ជាការបះបោរ និងការប្រមាថដែលមានការបដិសេធអំណាចមហារាជ ហើយគេក៏បានសម្លាប់គ្រីស្ទបរិស័ទដែលបានប្រកាសដូច្នោះដែរ។ សព្វថ្ងៃនេះ គេរាប់ការប្រកាសថា «ព្រះយេស៊ូវជាព្រះអម្ចាស់!» ជាការមិនចេះអត់អោន និងការមានគំនិតចង្អៀតចង្អល់ដែលបដិសេធពហុជំនឿ ហើយលោកីយ៍នេះក៏ស្អប់យើងដោយសារការនេះដែរ។

ព្រះបន្ទូលមិនដែលបានលើកឡើងថាការរស់នៅបែបនគរ—ការតយុទ្ធក្នុងការរស់នៅឲ្យស្មោះត្រង់សម្រាប់ស្ដេច—គឺជាការងាយស្រួលនោះទេ។ ព្រះយេស៊ូវបានសន្យាថា អ្នកដើរតាមទ្រង់នឹងប្រឈមមុខនឹងការបៀតបៀន ហើយថាលោកីយ៍នេះស្អប់ពួកគាត់ ហើយគេនឹងមើលងាយពួកគាត់ ហើយក៏ថែមទាំងសម្លាប់ពួកគាត់ដែរ។ ប៉ុន្តែ សូម្បីតែក្នុងចំណោមការទាំងអស់នោះ ក៏យើងដែលជាគ្រីស្ទបរិស័ទបន្តរត់តម្រង់ទៅមុខ ដោយសារយើងដឹងថា ក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ ព្រះអង្គបានទុកមរដកសម្រាប់យើង លើសជាងអ្វីៗដែលយើងអាចនឹកស្មានទៅដល់បានទៅទៀត។

ក្នុងសៀវភៅចុងក្រោយ *“The Lord of the Rings”* និពន្ធដោយលោក ចេ. អ. អ. ថូគិន (J. R. R. Tolkien) គាត់បានបង្ហាញយ៉ាង

9Marks Online PDF

ល្អថា វីរបុរសនិងវីរនារីនៃដំណើររឿងបានឈានដល់ផ្នែកងងឹតបំផុត នៃដំណើររឿងរបស់ពួកគេ។ ពួកគេបានធ្វើដំណើររាប់ពាន់គីឡូម៉ែត្រ ហើយចុងក្រោយក៏បានមកដល់ទឹកដីអាក្រក់ ដែលជាគោលដៅរបស់ពួកគេ ប៉ុន្តែដោយសារមានមូលហេតុខុសៗគ្នាមួយចំនួន ពេលនោះ អ្វីទាំងអស់ហាក់បីដូចជាបាត់បង់។ ទោះជាយ៉ាងណាក៏ដោយក៏ក្នុង គ្រាដ៏ងងឹតនោះ វីរបុរសម្នាក់ដែលមានឈ្មោះថា សែម (Sam) ក៏ បានមើលទៅលើមេឃខ្មៅងងឹត។ នេះគឺជាអ្វីដែលលោក ថូគិន បាន សរសេរៈ

> នៅលើភ្នំដ៏ឆ្ងាយនៅឯទិសខាងលិច មេឃពេលយប់នៅងងឹត និងស្លេកស្លាំង។ នៅទីនោះ ក្នុងចំណោមពពកបែកៗលើភាព ងងឹត ខ្ពស់នៅលើភ្នំ លោក សែម បានឃើញផ្កាយពណ៌ស មានពន្លឺភ្លឺមួយភ្លែត។ ភាពស្រស់ស្អាតរបស់វាក៏បានឆក់ដួង ចិត្តរបស់គាត់ ខណៈពេលដែលគាត់សម្លឹងមើលចេញពីតំបន់ ដែលគេបានបោះបង់ចោល ហើយគាត់ក៏ចាប់ផ្តើមមានសង្ឃឹម វិញ។ ដូចជាលំពែង ច្បាស់និងមិនមានភាពកក់ក្តៅ គំនិតនោះ ក៏បានចាក់ចូលគាត់ថា នៅចុងបញ្ចប់ ស្រមោលវាតូចណាស់ ហើយក៏កំពុងតែរំលងបាត់ទៅដែរៈ មានពន្លឺ និងភាពស្រស់ ស្អាតខ្ពស់អស់កល្បជានិច្ចលើសពីការអាចឈោងទៅដល់ បានទៅទៀត។

នោះគឺជាពេលមួយដែលខ្ញុំចូលចិត្តខ្លាំងជាងគេក្នុងចំណោមពេល

ផ្សេងៗក្នុងដំណើររឿងនោះ ពីព្រោះគឺនៅត្រង់នោះឯងដែលលោក ថូគិន ជាអ្នកអះអាងថាជាអ្នកជឿទៅព្រះគ្រីស្ទ ចង្អុលបង្ហាញយើងទៅកាន់កន្លែងដែលយើងរកបានភាពក្លាហានក្នុងការរត់តម្រង់កាត់ភាពងងឹត។ វាកើតចេញពីសេចក្តីសង្ឃឹម។ វាកើតចេញពីការដឹងថា ការរងទុក្ខរបស់យើងបច្ចុប្បន្ននេះគឺពិតជាតូច ហើយក៏កំពុងតែរំលងបាត់ទៅ ហើយថាដូចដែលសាវ័ក ប៉ុល មានប្រសាសន៍ថា៖ វាពិតជាមិនមានតម្លៃក្នុងការប្រៀបធៀបទៅនឹងសិរីល្អ ដែលព្រះអង្គបើកសម្តែងដល់យើង នៅពេលដែលស្តេចយើងយាងត្រឡប់មកវិញនោះទេ។

ជំពូក៧

# ការដាក់ឈើឆ្កាងជាចំណុចកណ្ដាល

**នៅក្នុងសៀវភៅ** *"ផ្លូវស្ថានសួគ៌"* (*"Pilgrim's Progress"*) និពន្ធដោយលោកគ្រូ ចន ប៊ុនយ៉ាន (John Bunyan) មានពេលមួយអ្នក គ្រីស្ទាន (Christian) ដែលជាវីរបុរសនៃដំណើររឿងបានសន្ទនាជាមួយបុរសមិនប្រាកដប្រជាពីរនាក់ឈ្មោះ ទម្លាប់ (Formalist) និង កំពុត (Hypocrisy)។ ដូចអ្នក គ្រីស្ទាន ពួកគេក៏ទទូចថា ខ្លួនកំពុងតែធ្វើដំណើរទៅកាន់ទីក្រុងស្ថានសួគ៌ (Celestial City) ហើយពួកគេក៏ប្រាកដផងដែរថាពួកគេនឹងទៅដល់ ពីព្រោះមានមនុស្សជាច្រើនពីប្រទេសរបស់ពួកគេបានធ្វើដំណើរតាមផ្លូវនេះពីមុន។

ប្រាកដណាស់ ឈ្មោះពួកគេបានប្រាប់ឲ្យយើងដឹងពីលទ្ធផលហើយ។ លោក ទម្លាប់ និងលោក កំពុត និងមិនទៅដល់ទីក្រុងនោះទេ។

លើកដំបូងដែលអ្នក គ្រីស្ទាន បានឃើញបុរសទាំងពីរនាក់នោះ គឺពេលដែលពួកគេកំពុងតែលោតរំលងពីកំផែង តាមផ្លូវដ៏តូចស្របគ្នាជាមួយនឹងផ្លូវដែលអ្នក គ្រីស្ទាន កំពុងតែធ្វើដំណើរ។ គាត់ក៏ឃើញ

9Marks Online PDF

ភ្លាមថា នេះជាបញ្ហា ដោយសារគាត់ដឹងថា មានរបៀបតែមួយដែលត្រឹមត្រូវ ក្នុងការចូលតាមផ្លូវតូច គឺតាមទ្វារកំពែង (Wicket Gate) ដែលក្នុងដំណើររឿងនេះតំណាងឲ្យការកែប្រែចិត្ត និងជំនឿលើព្រះគ្រីស្ទដែលគេបានឆ្កាង។

អ្នក គ្រីស្ទាន មិនដែលមានការភ័យខ្លាចក្នុងការនិយាយចំៗ ដូច្នេះគាត់ក៏បានសួរបុរសទាំងពីរនាក់ហ្នឹងអំពីស្ថានការណ៍៖ «ហេតុអ្វីបានអ្នកទាំងពីរមិនបានចូលតាមទ្វារ?»។ ពួកគេក៏ពន្យល់យ៉ាងរហ័សថា អ្នកស្រុកពួកគេគិតថាទ្វារនោះនៅឆ្ងាយពេក ដូច្នេះពួកគេក៏បានសម្រេចចិត្តតាំងពីយូរយារណាស់មកហើយថា «នឹងដើរតាមផ្លូវកាត់»។ លើសពីនេះទៅទៀត ពួកគាត់ក៏បានវែកញែកថា៖

> ប្រសិនបើយើងចូលដល់ផ្លូវ តើវាសំខាន់ទេថាយើងចូលតាមផ្លូវណា? ប្រសិនបើយើងបានចូលហើយ នោះមានន័យថាយើងបានចូលហើយ។ លោកបានចូលដល់ផ្លូវ ហើយលោកក៏បានចូលតាមខ្លោងទ្វារ ហើយយើងក៏បានចូលដល់ផ្លូវ តាមរយៈការផ្លោះតាមកំផែង។ ដូច្នេះ តើលោកល្អប្រសើរជាងយើងដោយរបៀបណា?

អ្នក គ្រីស្ទាន បានព្រមានបុរសទាំងពីរនាក់នោះថា ព្រះអម្ចាស់នៃទីក្រុងនោះបានចេញព្រះរាជបញ្ជាថា ដាច់ខាតអស់អ្នកដែលចូលទីក្រុងស្ថានសួគ៌ត្រូវតែចូលតាមផ្លូវតូចតាមរយៈទ្វារ ហើយគាត់ក៏បាន

បង្ហាញពួកគេនូវក្រាំងដែលគាត់ទទួលបានពីទីនោះ ដែលគាត់ត្រូវតែបង្ហាញនៅទ្វារនៃទីក្រុង ដើម្បីឲ្យអាចចូលបាន។ «ខ្ញុំគិតថា» អ្នកគ្រីស្ទាន បានលើកឡើង «លោកមិនមានសំបុត្រនេះទេ ពីព្រោះលោកមិនបានចូលតាមខ្លោងទ្វារ»។

អ្វីដែលលោក ប៊ុនយ៉ាន ចង់បង្ហាញគឺថា តាមទ្វារកំពែងគឺជាផ្លូវតែមួយគត់ទៅកាន់សេចក្តីសង្គ្រោះ—ដែលនេះមានន័យថា តាមរយៈការកែប្រែចិត្ត និងជំនឿ។ វាមិនល្មមគ្រប់គ្រាន់ទេក្នុងការវាស់ស្ទង់ទិសផ្លូវនៃជីវិតគ្រីស្ទបរិស័ទ។ ប្រសិនបើបុគ្គលណាម្នាក់មិនចូលតាមទ្វារនោះទេ នោះមានន័យថា គាត់មិនមែនជាគ្រីស្ទបរិស័ទពិតទេ។

**ដំណឹងល្អដែលធំ និងកាន់តែទាក់ទាញ?**

នោះគឺជារឿងចាស់ ប៉ុន្តែវាក៏កាន់តែជាចំណុចដែលចាស់ជាងនោះទៅទៀតដែលលោក ប៊ុនយ៉ាន កំពុងតែលើកឡើង។ ចាប់តាំងពីដើមកំណើតពេលវេលា មនុស្សបានព្យាយាមសង្គ្រោះខ្លួនឯងក្នុងរបៀបដែល*ពួកគេ*យល់ ជាជាងស្តាប់ និងចុះចូលចំពោះព្រះជាម្ចាស់។ ពួកគេបានព្យាយាមរកគន្លឹះក្នុងការឲ្យសេចក្តីសង្គ្រោះដំណើរការបាន—របៀបឲ្យ*ដំណឹងល្អ*ដំណើរការ—ដោយឡែកពីតាមរយៈទ្វារកំពែង ដែលនេះមានន័យថា ដោយឡែកពីឈើឆ្កាងរបស់ព្រះយេស៊ូវគ្រីស្ទ។

ការនោះក៏នៅតែជាការពិតដែរសព្វថ្ងៃនេះ។ ពិតណាស់ គ្រោះថ្នាក់ដ៏ធំបំផុតមួយដែលអវយវៈរបស់ព្រះគ្រីស្ទប្រឈមមុខសព្វថ្ងៃនេះគឺការធ្លាក់ក្នុងសេចក្តីល្បួងដោយការគិតជាថ្មី និងការបរិយាយជាថ្មីអំពី

9Marks Online PDF

ដំណឹងល្អក្នុងរបៀបដែលផ្តោតលើអ្វីមួយផ្សេងទៀតជាចំណុចស្នូលជាជាងលើការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាងជំនួសមនុស្សមានបាប។

សម្ពាធនៃការធ្វើបែបនេះគឺធំធេងណាស់ ហើយវាហាក់បីដូចជាកើតឡើងចេញពីទិសដៅពីរបីកន្លែង។ ប្រភពចម្បងមួយនៃសម្ពាធនោះគឺការកាន់តែមានគំនិតរួមគ្នាថា ដំណឹងល្អនៃការអត់ទោសបាបតាមរយៈការសុគតរបស់ព្រះយេស៊ូវ គឺមិន «ធំ» ល្មមក្នុងរបៀបណាមួយ—ត្រង់ថាវាមិនលើកឡើងអំពីបញ្ហាដូចជាសង្គ្រាម ការសង្កត់សង្កិន ភាពក្រីក្រ និងភាពអយុត្តិធម៌ ហើយវាក៏ «មិនសូវជាសំខាន់ប៉ុន្មាន» ដូចដែលអ្នកនិពន្ធម្នាក់បានលើកឡើង ទាក់ទងទៅនឹងបញ្ហាពិតនៃពិភពលោកនេះដែរ។

តាមពិតទៅ ខ្ញុំគិតថា សេចក្តីណែនាំនោះគឺខុសឆ្គងទាំងស្រុង។ លទ្ធផលនៃអំពើបាបរបស់មនុស្សគឺជាឫសគល់នៃបញ្ហាទាំងអស់នោះ ហើយវាគឺជារឿងល្ងីល្ងើណាស់ក្នុងការគិតថា បើគ្រាន់តែកាន់តែមានសកម្មភាពនិយមបន្ថែមទៀត ការយកចិត្តទុកដាក់បន្ថែមទៀត និងការកាន់តែ «រស់នៅជីវិតដូចដែលព្រះយេស៊ូវបានរស់នៅ» នោះយើងនឹងអាចដោះស្រាយបញ្ហាទាំងអស់នោះបាន។ ទេ! គឺមានតែតាមរយៈឈើឆ្កាងប៉ុណ្ណោះ ដែលពិតជាអាចដោះស្រាយតែម្តងជាស្រេចនូវអំពើបាបបាន ហើយគឺឈើឆ្កាងនោះឯងដែលធ្វើឲ្យមនុស្សយើងអាចមានសមត្ថភាពក្នុងការរាប់បញ្ចូលក្នុងនគរដ៏ល្អឥតខ្ចោះរបស់

9Marks Online PDF

ព្រះជាម្ចាស់បាន។

ទោះជាយ៉ាងណាក៏ដោយ ក៏សម្ពាធនៃការស្វែងរកដំណើងល្អដែល “ធំជាង” និងកាន់តែ “ទាក់ទាញ” ហាក់បីដូចជាបានចាប់យកមនុស្សជាច្រើននាក់។ ម្តងហើយម្តងទៀត ពីសៀវភៅមួយក្បាលទៅសៀវភៅមួយក្បាលទៀត យើងឃើញការពណ៌នាដំណើងល្អមានការប្តូរទីតាំងឈើឆ្កាងទៅជាចំណុចសំខាន់ទី២។ នៅក្នុងកន្លែងរបស់វាមានការប្រកាសថាចំណុចស្នូលនៃដំណើងល្អគឺថា ព្រះជាម្ចាស់កំពុងតែស្តាបនាផែនដីនេះឡើងវិញ ឬក៏ថាព្រះអង្គបានសន្យាថា នឹងមាននគរដែលគ្រប់អ្វីៗនឹងត្រូវបានតាំងឡើងយ៉ាងត្រឹមត្រូវ ឬថាព្រះអង្គកំពុងតែត្រាស់ហៅឲ្យយើងមានចំណែកជាមួយនឹងទ្រង់ក្នុងការបំផ្លាស់បំប្រែប្រពៃណីយើង។ មិនថាមានចំណាចជាក់លាក់ណាក៏ដោយ លទ្ធផលម្តងហើយម្តងទៀតគឺថា គេបានសន្មត ដោយមិនចាត់ទុកថា ឬក៏ថាពេលខ្លះមិនអើពើលើការសុគតរបស់ព្រះយេស៊ូវជំនួសមនុស្សមានបាបដោយចេតនាទៀតផង។

## ចំណុចជំនួសដំណើងល្អ៣យ៉ាង

ការមិនយកឈើឆ្កាងជាចំណាចកណ្តាលកំពុងតែកើតឡើងបន្តិចម្តងៗក្នុងចំណោមគ្រីស្ទបរិស័ទដំណើងល្អ ចំពោះខ្ញុំវាហាក់បីដូចជាកំពុងតែកើតឡើងក្នុងរបៀបខុសៗគ្នាមួយចំនួន។ ថ្មីៗនេះ មានដំណើងល្អ “ធំ និងល្អប្រសើរ” មួយចំនួនដែលគេកំពុងតែគាំទ្រ ហើយដំណើងល្អនីមួយៗនោះក៏ហាក់បីដូចជាកំពុងតែទទួលបានការគាំទ្រជាច្រើន

ផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ដល់កម្រិតដែលដំណឹងល្អ "ធំជាង" ទាំងនោះបានយកអ្វីផ្សេងទៀតមកធ្វើជាចំណុចស្នូលជាជាងឈើឆ្កាង ក៏ខ្ញុំនៅតែប្រកែកថា តាមពិតទៅវាកាន់តែតិចជាងដំណឹងល្អ ឬក៏មិនមែនជាដំណឹងល្អទាល់តែសោះផង។ សូមអនុញ្ញាតឲ្យខ្ញុំផ្តល់ជូនលោកអ្នកនូវឧទាហរណ៍៣យ៉ាងអំពីការនេះ។

**ឃ្លាថា «ព្រះយេស៊ូវជាព្រះអម្ចាស់» មិនមែនជាដំណឹងល្អទេ**

ដំណឹងល្អដែលមានប្រជាប្រិយភាពដ៏ខ្លាំងមួយក្នុងចំណោមដំណឹងល្អ "ធំជាង" នេះគឺការអះអាងថា ដំណឹងល្អគឺគ្រាន់តែជាការប្រកាសថា "ព្រះយេស៊ូវជាព្រះអម្ចាស់" តែប៉ុណ្ណោះ។ វាស្រដៀងគ្នាទៅនឹងអ្នកនាំពាក្យ ដែលចូលទីក្រុងណាមួយ ហើយប្រកាសថា "សេសារជាព្រះអម្ចាស់" ដូច្នេះគ្រីស្ទបរិស័ទដែលជាអ្នកនាំពាក្យដំណឹងល្អត្រូវលើកឡើងថា ព្រះយេស៊ូវគឺជាអ្នកត្រួតត្រា ហើយថាព្រះអង្គកំពុងតែស្ថិតក្នុងដំណើរការនៃការផ្សះផ្សាផែនដីទាំងមូលមកកាន់ទ្រង់ ហើយក៏កំពុងតែនាំវាមកស្ថិតក្រោមការសោយរាជ្យរបស់ទ្រង់ផងដែរ។

ប្រាកដណាស់ ការប្រកាសថា "ព្រះយេស៊ូវជាព្រះអម្ចាស់" គឺជាការពិត និងត្រឹមត្រូវទាំងស្រុង! ហើយការប្រកាសអំពីភាពជាព្រះអម្ចាស់របស់ព្រះយេស៊ូវគឺជាចំណុចសំខាន់នៃសារដំណឹងល្អ។ ដូច្នេះ សាវ័កប៉ុល បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១០:៩ ថា៖ បុគ្គលដែលទទួលថ្លែងប្រាប់ថា "ព្រះយេស៊ូវជាព្រះអម្ចាស់" នឹងទទួលបានសេចក្តីសង្គ្រោះ ហើយនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១២:៣ គាត់ក៏បានមាន

9Marks Online PDF

ប្រសាសន៍ថា គឺមានតែតាមរយៈព្រះវិញ្ញាណនៃព្រះតែមួយអង្គគត់ ដែលបុគ្គលណាម្នាក់អាចបញ្ជាក់អះអាងសេចក្តីពិតនោះបាន។

ប៉ុន្តែ ប្រាកដណាស់ វាមិនមែនជាការត្រឹមត្រូវទេក្នុងការប្រកាសថា "ព្រះយេស៊ូវជាព្រះអម្ចាស់" គឺជាចំណុចសង្ខេប និងអត្ថន័យសំខាន់នៃដំណឹងល្អរបស់គ្រីស្ទបរិស័ទទាំងមូលនោះទេ។ យើងបានឃើញរួចហើយ អំពីរបៀបដែលគ្រីស្ទបរិស័ទសម័យដំបូងបានលើកឡើងច្រើនជាងនោះ នៅពេលដែលពួកគាត់ប្រកាសដំណឹងល្អ។ ប្រាកដណាស់ នៅក្នុងកណ្ឌគម្ពីរកិច្ចការជំពូក២ សាវ័ក ពេត្រុស បានអធិប្បាយថា "ដូច្នេះ ចូរឲ្យពួកវង្សអ៊ីស្រាអែលទាំងអស់ដឹងជាប្រាកដថា ព្រះទ្រង់បានលើកព្រះយេស៊ូវនេះ ដែលអ្នករាល់គ្នាបានឆ្កាង ឲ្យទ្រង់ធ្វើជាព្រះអម្ចាស់ ហើយជាព្រះគ្រីស្ទផង" (ខ៣៦)។ ប៉ុន្តែ មានការពន្យល់យ៉ាងពេញលេញអំពី*អត្ថន័យ*នៃភាពជាអម្ចាស់របស់ព្រះយេស៊ូវនៅពីមុន និងក្រោយប្រយោគនោះ។ វាមានន័យថា ព្រះអម្ចាស់នេះត្រូវបានគេឆ្កាង បញ្ចុះក្នុងផ្នូរ និងមានព្រះជន្មរស់ឡើងវិញ ហើយវាក៏មានន័យផងដែរថា ការសុគត និងការមានព្រះជន្មរស់នៅរបស់ទ្រង់ក៏បានសម្រេចលើសទាំងអស់នូវ "ការអត់ទោសនៃអំពើបាប" សម្រាប់អស់អ្នកដែលនឹងកែប្រែចិត្ត ហើយទទួលជឿលើទ្រង់។ សាវ័ក ពេត្រុស មិនគ្រាន់តែបានប្រកាសថា ព្រះយេស៊ូវជាព្រះអម្ចាស់ប៉ុណ្ណោះទេ។ គាត់ថែមទាំងបានប្រកាសថា ព្រះអម្ចាស់នេះបានអនុម័តជំនួសរាស្ត្ររបស់ទ្រង់ ដើម្បីសង្គ្រោះពួកគេចេញពីសេចក្តីក្រោធរបស់ព្រះជាម្ចាស់ទាស់

9Marks Online PDF

ប្រឆាំងនឹងអំពើបាបរបស់ពួកគេ។

មកដល់ពេលនេះ វាគួរឲ្យច្បាស់លាស់ហើយ ក្នុងការគ្រាន់តែថា "ព្រះយេស៊ូវជាព្រះអម្ចាស់" គឺតាមពិតទៅមិនមែនជាដំណឹងល្អទាល់តែសោះ ប្រសិនបើយើងមិនពន្យល់ថាព្រះយេស៊ូវមិនមែនគ្រាន់តែជាព្រះអម្ចាស់ប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គក៏ជាព្រះសង្គ្រោះផងដែរ។ ភាពជាអម្ចាស់មានបង្កប់នូវសិទ្ធិក្នុងការជំនុំជម្រះ ហើយយើងក៏បានឃើញហើយថាព្រះជាម្ចាស់សព្វព្រះហឫទ័យក្នុងការជំនុំជម្រះអំពើអាក្រក់។ ដូច្នេះ ចំពោះមនុស្សមានបាបដែលកំពុងតែបះបោរប្រឆាំងនឹងព្រះជាម្ចាស់ និងព្រះមេស្ស៊ីរបស់ទ្រង់ នោះការប្រកាសថាព្រះយេស៊ូវបានក្លាយជាព្រះអម្ចាស់គឺជាដំណឹងដ៏អាក្រក់ណាស់។ វាមានន័យថា ខ្មាំងសត្រូវរបស់លោកអ្នកបានឈ្នះលើបល្ល័ង្ក ហើយឥឡូវនេះហៀបនឹងជំនុំជម្រះលោកអ្នកសម្រាប់ការបះបោរប្រឆាំងនឹងទ្រង់។

ដើម្បីឲ្យដំណឹងនោះជាដំណឹងដ៏ល្អ ហើយមិនមែនគ្រាន់តែជាដំណឹងអាក្រក់ វាត្រូវតែមានរួមបញ្ចូលនូវមធ្យោបាយសម្រាប់ឲ្យការបះបោរទាស់ប្រឆាំងរបស់លោកអ្នកទទួលបានការអត់ទោស មធ្យោបាយសម្រាប់ឲ្យលោកអ្នកអាចទទួលបានការផ្សះផ្សាជាមួយនឹងអង្គដែលបានក្លាយជាព្រះអម្ចាស់។ ការនេះផ្ទាល់គឺជាអ្វីដែលយើងឃើញនៅក្នុងព្រះគម្ពីរសញ្ញាថ្មី—មិនមែនគ្រាន់តែជាការប្រកាសថាព្រះយេស៊ូវជាព្រះអម្ចាស់ប៉ុណ្ណោះទេ ប៉ុន្តែថាព្រះអម្ចាស់យេស៊ូវនេះត្រូវបានគេឆ្កាង ដើម្បីឲ្យមនុស្សមានបាបទទួលបានការអត់ទោស ហើយនាំ

9Marks Online PDF

ចូលទៅ ក្នុងអំណាចនៃនគររបស់ទ្រង់ដែលនឹងមកដល់។ ដោយឡែកពីនោះ ការប្រកាសថា "ព្រះយេស៊ូវជាព្រះអម្ចាស់" មិនជាការអ្វីលើសជាងពីការកាត់ក្ដីឲ្យស្លាប់នោះទេ។

**ការបង្កើត-ការធ្លាក់ក្នុងអំពើបាប-ការប្រោសលោះ-ការសម្រេចមិនមែនជាដំណឹងល្អទេ**

មានគ្រីស្ទបរិស័ទជាច្រើននាក់បានសង្ខេបដំណើររឿងព្រះគម្ពីរដោយប្រើពាក្យទាំងបួននេះ៖ *ការបង្កើត-ការធ្លាក់ក្នុងអំពើបាប-ការប្រោសលោះ-ការសម្រេច*។

តាមពិតទៅ ការសង្ខេបនេះគឺពិតជារបៀបនៃការសង្ខេបដំណើររឿងចម្បងៗនៃព្រះគម្ពីរបានល្អមែន។ ព្រះជាម្ចាស់បានបង្កើតផែនដី មនុស្សលោកបានប្រព្រឹត្តអំពើបាប តាមរយៈព្រះយេស៊ូវដែលជាព្រះមេស្ស៊ី ព្រះជាម្ចាស់បានប្រតិបត្តិការក្នុងការប្រោសលោះរាស្ត្រមួយសម្រាប់ទ្រង់ ហើយប្រវត្តិសាស្ត្រនឹងឈានដល់ទីបញ្ចប់នៅពេលដែលនគរដ៏រុងរឿងរបស់ទ្រង់ឈានដល់ការសម្រេច។ ចាប់ពីកណ្ឌគម្ពីរលោកុប្បត្តិរហូតដល់វិវរណៈ នោះគឺជារបៀបដ៏ល្អមួយក្នុងការចងចាំសាច់រឿងត្រួសៗនៃព្រះគម្ពីរ។ តាមពិតទៅ នៅពេលដែលលោកអ្នកយល់ និងលើកឡើងយ៉ាងត្រឹមត្រូវ នោះការសង្ខេបអំពីការបង្កើត-ការធ្លាក់ក្នុងអំពើបាប-ការប្រោសលោះ-ការសម្រេចនឹងផ្ដល់ជូននូវកម្រងដ៏ល្អមួយសម្រាប់ការបង្ហាញយ៉ាងស្មោះត្រង់អំពីដំណឹងល្អយោងតាមព្រះគម្ពីរ។

9Marks Online PDF

ប៉ុន្តែ បញ្ហាគឺថា អ្នកខ្លះបានប្រើប្រាស់ការសង្ខេបអំពីការបង្កើត-ការធ្លាក់ក្នុងអំពើបាប-ការប្រោសលោះ-ការសម្រេចក្នុងរបៀបមិនត្រឹមត្រូវ ដោយយកលេសផ្តោតលើដំណឹងល្អនៃសេចក្តីសន្យារបស់ព្រះជាម្ចាស់ក្នុងការស្តាបនាផែនដីជាថ្មី ជាជាងលើឈើឆ្កាង។ ដូច្នេះជារឿយៗគេបង្ហាញ «ដំណឹងល្អ» ថាជាការបង្កើត-ការធ្លាក់ក្នុងអំពើបាប-ការប្រោសលោះ-ការសម្រេចដូចតទៅ៖

> ដំណឹងល្អគឺជាដំណឹងដែលថា កាលដើមដំបូងឡើយព្រះបានបង្កើតផែនដី និងរាល់គ្រប់អ្វីៗក្នុងវា។ កាលដើមដំបូង វាពិតជាល្អមែន ប៉ុន្តែមនុស្សលោកបានបះបោរទាស់ប្រឆាំងនឹងការគ្រងរាជ្យរបស់ព្រះជាម្ចាស់ ហើយក៏បាននាំឲ្យពិភពលោកនេះមានភាពច្របូកច្របល់។ ទំនាក់ទំនងរវាងមនុស្សនឹងព្រះក៏មានការបាក់បែកគ្នា ក៏ដូចជាទំនាក់ទំនងរវាងមនុស្សនឹងមនុស្ស ជាមួយខ្លួនផ្ទាល់នឹងជាមួយពិភពលោក។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីការធ្លាក់ក្នុងអំពើបាប ក៏ព្រះជាម្ចាស់បានសន្យាថា នឹងចាត់ឲ្យមានស្តេចមួយអង្គមក ដើម្បីប្រោសលោះរាស្ត្រមួយសម្រាប់ទ្រង់ផ្ទាល់ និងផ្សះផ្សារបស់សព្វសារពើឲ្យជានឹងទ្រង់ជាថ្មីម្តងទៀត។ សេចក្តីសន្យានោះបានចាប់ផ្តើមទទួលការបំពេញ តាមរយៈការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ ប៉ុន្តែវានឹងឈានដល់ចំណុចបំពេញ ឬក៏សម្រេចនៅពេលដែលព្រះយេស៊ូវដ៏ជាស្តេចយាងត្រឡប់មកវិញ។

9Marks Online PDF

តាមពិតទៅ អ្វីៗទាំងអស់នៅក្នុងកថាខណ្ឌនោះគឺជាការពិត។ ប៉ុន្តែ អ្វីដែលខ្ញុំបានសរសេរនៅទីនេះមិនមែនជាដំណឹងល្អទេ។ ដូចគ្នានឹងការប្រកាសថា “ព្រះយេស៊ូវជាព្រះអម្ចាស់” មិនមែនជាដំណឹងល្អ លុះត្រាតែមានមធ្យោបាយក្នុងការឲ្យលោកអ្នកទទួលបានការអត់ទោសចេញពីការបះបោរទាស់ប្រឆាំងនឹងទ្រង់។ ដូច្នេះ ត្រង់ចំណុចដែលថា ព្រះជាម្ចាស់កំពុងតែស្ថាបនាផែនដីនេះឡើងជាថ្មីវិញ គឺមិនមែនជាដំណឹងល្អទេ លុះត្រាតែលោកអ្នកអាចទទួលបានការរាប់បញ្ចូលក្នុងវា។

ប្រាកដណាស់ វាមិនមែនជាបញ្ហាទេក្នុងការប្រើប្រាស់ការសង្ខេបពីការបង្កើត-ការធ្លាក់ក្នុងអំពើបាប-ការប្រោសលោះ-ការសម្រេច ជារបៀបមួយនៃការពន្យល់ដំណឹងល្អរបស់គ្រីស្ទបរិស័ទ។ ពិតណាស់ ការរៀបរៀង “ការបង្កើត” និង “ការធ្លាក់ក្នុងអំពើបាប” ស្ទើរតែមានភាពស៊ីគ្នាទាំងស្រុងជាមួយនឹងការរៀបរៀងអំពី “ព្រះជាម្ចាស់” និង “មនុស្ស”។ ទោះជាយ៉ាងណាក៏ដោយ ក៏ចំណាចដ៏សំខាន់នៅមានក្នុងការរៀបរៀងអំពី “ការប្រោសលោះ” ដែរ។ ដើម្បីឲ្យយើងពិតជាប្រកាសដំណឹងល្អមែន នោះគឺជាកន្លែងដែលយើងត្រូវតែពន្យល់ដោយយកចិត្តទុកដាក់ថា ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ និងការឆ្លើយតបដែលព្រះជាម្ចាស់តម្រូវឲ្យមានពីមនុស្សមានបាប។ ប្រសិនបើយើងគ្រាន់តែថា ព្រះជាម្ចាស់កំពុងតែប្រោសលោះរាស្ត្រមួយ ហើយនឹងកំពុងតែស្ថាបនាផែនដីឡើងវិញ ប៉ុន្តែមិនបាន

លើកឡើង*អំពីរបៀបដែលព្រះអង្គកំពុងតែធ្វើ* (តាមរយៈការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ) និង*អំពីរបៀបដែលបុគ្គលណាម្នាក់អាចទទួលបានការរាប់បញ្ចូលក្នុងការប្រោសលោះនោះបាន* (តាមរយៈការកែប្រែចិត្តចេញពីអំពើបាប និងការមានជំនឿលើព្រះយេស៊ូវ) នោះមានន័យថា យើងមិនទាន់បានប្រកាសដំណឹងល្អនៅឡើយទេ។ យើងគ្រាន់តែបានរៀបរាប់ដំណើររឿងនៃព្រះគម្ពីរដោយសង្ខេបទូទៅ ហើយបានទុកឲ្យមនុស្សមានបាបពិតមុខនឹងកញ្ចក់មើលតែប៉ុណ្ណោះ។

## ការបំផ្លាស់បំប្រែវប្បធម៌ក៏មិនមែនជាដំណឹងល្អដែរ

ថ្មីៗនេះ គំនិតនៃការឃើញការផ្លាស់ប្រែក្នុងវប្បធម៌តាមរយៈព័ន្ធកិច្ចគ្រីស្ទបរិស័ទហាក់បីដូចជាបានចាប់យកគំនិតគ្រីស្ទបរិស័ទដំណឹងល្អជាច្រើននាក់។ ខ្ញុំគិតថា នោះគឺជាគោលដៅល្អ ហើយខ្ញុំក៏គិតផងដែរថាការខិតខំប្រឹងប្រែងតយុទ្ធនឹងអំពើអាក្រក់ក្នុងសង្គម មិនថាជាក្រុម ឬជាបុគ្គលផ្ទាល់ គឺជាការខិតខំដែលមានភាពស៊ីគ្នាជាមួយនឹងព្រះគម្ពីរ។ សាវ័ក ប៉ុល បានប្រាប់យើងថា “ត្រូវធ្វើល្អដល់មនុស្សទាំងអស់ ហើយគឺដល់ពួកអ្នកជឿជាដើម” (កាឡាទី ៦:១០)។ ព្រះយេស៊ូវបានមានបន្ទូលប្រាប់យើងថា ឲ្យយើងមើលថែអ្នកជិតខាងរបស់យើង ដែលមានរួមបញ្ចូលទាំងអស់អ្នកដែលនៅក្រៅ (លូកា ១០:២៥-៣៧)។ ហើយព្រះអង្គក៏បានមានបន្ទូលប្រាប់ផងដែរថា “ចូរឲ្យពន្លឺរបស់អ្នករាល់គ្នា បានភ្លឺនៅមុខមនុស្សលោកយ៉ាងនោះដែរ ដើម្បី

9Marks Online PDF

ឲ្យគេឃើញការល្អ ដែលអ្នករាល់គ្នាប្រព្រឹត្ត រួចសរសើរតម្កើង ដល់ព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌» (ម៉ាថាយ ៥:១៦)។

ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកបំផ្លាស់បំប្រែជាច្រើនធ្វើលើសហ្នឹងទៅទៀត ដោយទាញយកបទបញ្ជាឲ្យ «ប្រោសលោះវប្បធម៌» ក្នុងដំណើរសាច់រឿងព្រះគម្ពីរផ្ទាល់។ ពួកគាត់វែកញែកថា ប្រសិនបើព្រះជាម្ចាស់កំពុងតែស្ដាបនាផែនដីនេះឡើងវិញ នោះមានន័យថាវាជាទំនួលខុសត្រូវរបស់យើងក្នុងការរួមចំណែកជាមួយនឹងទ្រង់ក្នុងព័ន្ធកិច្ចនេះ៖ ក្នុងការប្រមូលផ្ដុំសម្ភារៈសម្រាប់កសាងនគរ ជាពិសេសក្នុងការឈានទៅមុខ ដើម្បីតាំងការគ្រងរាជ្យរបស់ព្រះជាម្ចាស់នៅក្នុងសង្គម ទីក្រុង ប្រទេសជាតិ និងផែនដីយើង។ ពួកគេលើកឡើងថា «ដាច់ខាត! យើងត្រូវតែធ្វើនូវអ្វីដែលយើងឃើញព្រះជាម្ចាស់កំពុងតែធ្វើ»។

សូមអនុញ្ញាតឲ្យខ្ញុំបញ្ចេញមតិយោបល់របស់ខ្ញុំទាំងអស់។ ចំពោះលំនាំនៃការបំផ្លាស់បំប្រែវប្បធម៌ ខ្ញុំមានមន្ទិលសង្ស័យមួយចំនួនដែលកើតចេញពីព្រះគម្ពីរ និងទេវវិទ្យា។ ខ្ញុំមិនជឿជាក់ថា ព្រះបន្ទូលបានព្យាយាមដាក់ការបំផ្លាស់បំប្រែវប្បធម៌នៅឋានៈខ្ពស់ដូចអ្នកបំផ្លាស់បំប្រែជាច្រើននាក់ថាឲ្យដាក់នោះទេ។ ហើយខ្ញុំមានមូលហេតុមួយចំនួន។ សម្រាប់ទីមួយ ខ្ញុំគិតថាព្រះជាម្ចាស់មិនបានប្រទានបទបញ្ជាវប្បធម៌នៅក្នុងគម្ពីរលោកុប្បត្តិទៅកាន់រាស្ត្ររបស់ទ្រង់ដូចនេះទេ។ ខ្ញុំគិតថាព្រះអង្គបានប្រទានបទបញ្ជានោះទៅកាន់មនុស្សលោកទាំង

9Marks Online PDF

អស់គ្នា។ ហើយខ្ញុំក៏គិតផងដែរថា ទិសដៅទូទៅនៃវប្បធម៌មនុស្ស មិនថាក្នុងព្រះបន្ទូល ឬក៏ក្នុងប្រវត្តិសាស្ត្រ ក៏មិនមែនឆ្ពោះទៅកាន់ព្រះជាម្ចាស់ដែរ។ ផ្ទុយទៅវិញ ខ្ញុំគិតថាទិសដៅនៃវប្បធម៌មនុស្សទាំងអស់គ្នា មិនថាក្នុងរបៀបជាក់លាក់ណាមួយនោះទេ គឺឆ្ពោះទៅកាន់ការជំនុំជម្រះ (សូមមើលនៅក្នុងកណ្ឌគម្ពីរវិវរណៈជំពូក១៧-១៩)។ ដូច្នេះ ខ្ញុំគិតថា សុទិដ្ឋិនិយមរបស់អ្នកបំផ្លាស់បំប្រែជាច្រើននាក់ ទាក់ទងទៅនឹងលទ្ធភាពនៃ «ការផ្លាស់ប្តូរពិភពលោកនេះ» គឺមានការយល់ខុសហើយ ហើយវាក៏នឹងនាំឲ្យមានការខកចិត្តផងដែរ។

ទោះជាយ៉ាងណាក៏ដោយក៏ទាំងអស់នោះគឺជាការជជែកវែកញែកយ៉ាងធំ ទាក់ទងទៅនឹងទេវវិទ្យាព្រះគម្ពីរ ហើយវាមិនមែនជាអ្វីដែលខ្ញុំចង់ផ្តោតលើនៅទីនេះទេ។ តាមពិតទៅ ខ្ញុំគិតថា វាអាចទៅរួចបានក្នុងការមានការប្តេជ្ញាចិត្តធ្វើជាអ្នកបំផ្លាស់បំប្រែ ហើយស្របពេលនោះដែរក៏អាចមានការប្តេជ្ញាចិត្តក្នុងការរក្សាទុកឈើឆ្កាងរបស់ព្រះគ្រីស្ទ ក្នុងចំណុចស្នូលនៃដំណើររឿងព្រះគម្ពីរ និងដំណឹងល្អ។ មិនថាទោះជាយ៉ាងណាក៏ដោយក៏*ការទទួលបានការអត់ទោស* និង*ការសង្គ្រោះ*ឆាស្ត្រ របស់ព្រះជាម្ចាស់ គឺជាអ្នកដែលព្រះអង្គនឹងប្រើប្រាស់ ដើម្បីសម្រេចការបំផ្លាស់បំប្រែ ហើយការទទួលបានការអត់ទោស និងការសង្គ្រោះកើតឡើងតាមតែរយៈឈើឆ្កាងប៉ុណ្ណោះ។

ផ្ទុយទៅវិញ អ្វីដែលខ្ញុំចង់ផ្តោតលើគឺជាអ្វីដែលខ្ញុំសង្ឃឹមថា អ្នកបំផ្លាស់បំប្រែដែលជាអ្នកផ្សាយដំណឹងល្អ ដែលជាមិត្តភក្តិរបស់ខ្ញុំ ក៏

នឹងឯកភាពអស់ពីចិត្តជាមួយផងដែរ។ គឺវាគ្រាន់តែថា ជារឿយៗ ក្នុងចំណោមអ្នកបំផ្លាស់បំប្រែមួយចំនួន ការសង្គ្រោះវប្បធម៌ក៏ចាប់ផ្ដើមមានការស្រពេចស្រពិល ដោយក្លាយជាសេចក្ដីសន្យាយ៉ាងធំ និងចំណុចនៃដំណឹងល្អ—ដែលជាក់ស្ដែង នេះមានន័យថា គេបានរុញឈើឆ្កាង (បើថាដោយចេតនា ឬក៏អចេតនា) ចេញពីកន្លែងនោះ។ ពីសៀវភៅមួយទៅសៀវភៅមួយទៀត លោកអ្នកអាចឃើញការនេះកំពុងកើតឡើង ដោយត្រាស់ហៅឲ្យមានការផ្ដោតធ្ងន់ជាងនោះទៅទៀតលើការបំផ្លាស់បំប្រែវប្បធម៌។ គេបញ្ចេះចំណុចរំភើបចិត្ត និងអំណរដ៏ខ្ពស់បំផុតដោយប្រើប្រាស់នូវសេចក្ដីសន្យានៃការផ្លាស់ប្ដូរវប្បធម៌ ជាជាងកិច្ចការរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាង។ ការបបួលអ្នកផ្សេងឲ្យមានចំណែកក្នុងព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ក្នុងការផ្លាស់ប្ដូរពិភពលោកគឺជាទូទៅដែលគេប្រើប្រាស់ខ្លាំងជាងគេ ជាជាងការប្រែចិត្ត ហើយទទួលជឿលើព្រះយេស៊ូវ។ គេថាចំណុចស្នូលនៃដំណើររឿងព្រះគម្ពីរគឺផ្ដោតលើការស្ដាបនាផែនដីជាថ្មី ជាជាងលើការសុគតជំនួសរបស់ព្រះយេស៊ូវ។

នៅក្នុងដំណើរការនោះ ជំនឿគ្រីស្ទបរិស័ទក៏កាន់តែលែងផ្ដោតលើព្រះគុណ និងជំនឿ ហើយបែរជាផ្ដោតលើសាសនាដែលគ្មានខ្លឹមសារនៃ «ការរស់ក្នុងរបៀបនេះ ហើយយើងនឹងផ្លាស់ប្ដូរពិភពលោក»។ នេះមិនមែនជាជំនឿគ្រីស្ទបរិស័ទទេ តែជាសីលធម៌និយមវិញ។

## ហេតុជំពប់ដួល និងភាពល្ងីល្ងើ

នៅចុងបញ្ចប់ ខ្ញុំគិតថា ការចង់រុញឈើឆ្កាងចេញពីចំណុចស្នូលនៃដំណឹងល្អទំនងកើតឡើងចេញពីការដែលពិភពលោកនេះមិនចូលចិត្តឈើឆ្កាង។ តាមដែលគេអាចគិតខ្ពស់បំផុតបាន វាជារឿងព្រេងដែលគួរឲ្យអស់សំណើច ហើយតាមដែលគេអាចគិតទាបបំផុតបាន វាគឺជាការកុហកដ៏អាក្រក់។ តាមពិតទៅ នេះមិនគួរធ្វើឲ្យយើងមានការភ្ញាក់ផ្អើលទេ។ សាវ័ក ប៉ុល បានប្រាប់យើងថា វានឹងត្រូវជាដូច្នោះ។ គាត់បានមានប្រសាសន៍ថា ចំពោះអ្នកខ្លះសារនៃឈើឆ្កាងគឺជាហេតុដែលនាំឲ្យជំពប់ដួល ហើយចំពោះអ្នកផ្សេងទៀតគឺជាភាពល្ងីល្ងើ!

បន្ថែមលើនោះគឺចំណុចដែលថា យើងពិតជាចង់ឲ្យលោកីយ៍នេះមានចំណាប់អារម្មណ៍លើដំណឹងល្អ នោះលោកអ្នកនិងបង្កើតសម្ពាធយ៉ាងធ្ងន់លើគ្រីស្ទបរិស័ទ ក្នុងការស្វែងរករបៀបមិននិយាយអំពី «សាសនាដែលមានឈើឆ្កាងប្រឡាក់ដោយឈាម» ច្រើនពេក។ ខ្ញុំមានន័យថា យើងចង់ឲ្យលោកីយ៍នេះទទួលយកដំណឹងល្អ ជាងសើចចំអក ត្រូវអត់?

ប៉ុន្តែ ប្រាកដណាស់ យើងគួរតែប្រឈមមុខនឹងការនោះផ្ទាល់តែម្តងទៅ។ ចំពោះអស់អ្នកដែលនៅជុំវិញយើង សារនៃឈើឆ្កាងគឺមិនសមហេតុផលនោះទេ។ វានឹងធ្វើឲ្យយើងដែលជាគ្រីស្ទបរិស័ទមានលក្ខណៈដូចជាល្ងីល្ងើ ហើយវាក៏នឹងប្រាកដជាធ្វើឲ្យការខិតខំរបស់យើងអន្តរាយ ក្នុងការព្យាយាម «មានទំនាក់ទំនង» ជាមួយនឹងអ្នក

9Marks Online PDF

ដែលមិនមែនជាគ្រីស្ទបរិស័ទ ហើយបង្ហាញពួកគាត់ថា យើងក៏ទ្បួយនឹងមិនមានគ្រោះថ្នាក់ដូចជាអ្នកបន្ទាប់ដែរ។ គ្រីស្ទបរិស័ទអាចតែងតែព្យាយាមឲ្យលោកីយ៍គិតថាខ្លួនទ្បួយ—រហូតដល់ពេលដែលពួកគាត់ចាប់ផ្ដើមនិយាយអំពីការទទួលបានសេចក្ដីសង្គ្រោះតាមរយៈបុគ្គលដែលគេឆ្កាង។ ហើយនេះគឺជាពេលដែលភាពទ្បួយនឹងរលាយបាត់ទៅ មិនថាលោកអ្នកបានព្យាយាមថែរក្សាវាខ្លាំងប៉ុណ្ណាក៏ដោយ។

ទោះជាយ៉ាងណាក៏ដោយក៏ព្រះបន្ទូលបានលើកឡើងយ៉ាងច្បាស់ហើយថា ដាច់ខាតឈើឆ្កាង*ត្រូវតែ*នៅជាចំណុចស្នូលនៃដំណឹងល្អ។ យើងមិនអាចលើកវាដាក់ទៅម្ខាងបានឡើយ ហើយយើងក៏មិនអាចប្ដូរវាចេញជាមួយនឹងសេចក្ដីពិតណាផ្សេងទៀតថាជាចំណុចស្នូល ទីកណ្ដាល ហើយជាមូលដ្ឋានគ្រឹះនៃដំណឹងល្អបានដែរ។ ប្រសិនបើធ្វើបាននោះ នោះមានន័យថា យើងបង្ហាញទៅកាន់លោកីយ៍នូវអ្វីដែលមិនមែនជាការសង្គ្រោះ ដែលនោះជាលទ្ធផល គឺមិនមែនជាដំណឹងល្អទាល់តែសោះ។

តាមពិតទៅ ព្រះគម្ពីរបានផ្ដល់ដល់យើងនូវការណែនាំយ៉ាងច្បាស់អំពីរបៀបដែលយើងគួរឆ្លើយតបចំពោះសម្ពាធនៃការដកឈើឆ្កាងចេញពីចំណុចស្នូលនៃដំណឹងល្អ។ យើងត្រូវតែប្រឆាំងនឹងការនោះ។ សូមមើលអំពីអ្វីដែលសាវ័ក ប៉ុល បានលើកឡើងអំពីការនេះនៅក្នុងកណ្ឌគម្ពីរកូរិនថូសខ្សែទី១។ គាត់ដឹងហើយថា ចំពោះអស់អ្នកដែលនៅជុំវិញគាត់ សារនៃឈើឆ្កាងគឺជារឿងភ្លីភ្លើ។ គាត់បានដឹងហើយថា

ពួកគេនឹងបដិសេធដំណឹងល្អដោយសារឈើឆ្កាង ថាវាជាក្លិនស្អុយក្នុងច្រមុះរបស់ពួកគេ។ ប៉ុន្តែ សូម្បីតែក្នុងការប្រឈមមុខនឹងការបដិសេធដូចនោះ ក៏គាត់នៅតែលើកឡើងថា «តែយើងខ្ញុំប្រកាសប្រាប់ពីព្រះគ្រីស្ទ ដែលទ្រង់ត្រូវឆ្កាងវិញ» (១កូរិនថូស ១:២៣)។ តាមពិតទៅគាត់បានប្ដេជ្ញាចិត្តថា «មិនព្រមស្គាល់*រឿងអ្វីទៀត* ក្រៅពីព្រះយេស៊ូវគ្រីស្ទទេ ហើយគឺដែលទ្រង់ត្រូវឆ្កាងផង» (១កូរិនថូស ២:២)។ ដូចដែលគាត់បានលើកឡើងនៅចុងកណ្ឌគម្ពីរ នោះគឺដោយសារ «ព្រះគ្រីស្ទបានសុគត ដោយព្រោះបាបរបស់យើងរាល់គ្នា តាមបទគម្ពីរ» នោះមិនមែនគ្រាន់តែសំខាន់ ហើយក៏ថែមទាំងថា វាមិនមែនគ្រាន់តែសំខាន់*បំផុត*ប៉ុណ្ណឹងទេ ប៉ុន្តែគឺសំខាន់ «*មុនដំបូង*» បង្អស់ទៅទៀត (១កូរិនថូស ១៥:៣)

ហើយចុះបើការនោះនាំឲ្យមានការចំអកពីលោកីយ៍? ចុះបើមនុស្សយើងឆ្លើយតបបានល្អប្រសើរជាងចំពោះដំណឹងល្អ ដែលទំនោរទៅរកការស្ដាបនាពិភពលោកនេះជាថ្មីឡើងវិញ ជាជាងទៅរកការសុគតរបស់ព្រះគ្រីស្ទជំនួសមនុស្សមានបាបទៅវិញ? ចុះប្រសិនបើមនុស្សយើងសើចចំអកឲ្យដំណឹងល្អ ដោយសារដំណឹងលើកឡើងអំពីបុរសម្នាក់ដែលបានស្លាប់នៅលើឈើឆ្កាង? សាវ័ក ប៉ុល បានមានប្រសាសន៍ថា បើដូច្នោះ ឲ្យវាដូច្នោះទៅ។ ខ្ញុំកំពុងតែអធិប្បាយអំពីឈើឆ្កាង។ ពួកគាត់អាចគិតថា វាជារឿងដែលគួរឲ្យអស់សំណើច ហើយអាចគិតថាវាក៏ជារឿងល្ងីល្ងើ។ ប៉ុន្តែ ខ្ញុំដឹងថា «សេចក្ដីល្ងង់ល្ងើ

9Marks Online PDF

របស់ព្រះ នោះមានប្រាជ្ញាលើសជាងមនុស្ស» ទៅទៀត (១កូរិនថូស ១:២៥)។

សាវ័ក ប៉ុល បានប្រាកដយ៉ាងច្បាស់ថា ឈើឆ្កាងគឺជាចំណុចស្នូលនៃដំណឹងល្អដែលគាត់ប្រកាស តើយើងគួរធ្វើដូចម្តេចដែរ។ ប្រសិនបើយើងអនុញ្ញាតឲ្យមានអ្វីផ្សេងទៀតក្លាយជាចំណុចស្នូល នោះយើងទំនងគួរនិយាយដូចនេះតែម្តងទៅ៖ «ណេះ! សូមអនុញ្ញាតឲ្យខ្ញុំជួយលោកអ្នកលោតរំលងកំផែងនោះ។ សូមទុកចិត្តខ្ញុំ! លោកអ្នកនឹងមិនអីទេ»។

ជំពូក៨

# អំណាចនៃដំណើងល្អ

ពេលដែលខ្ញុំហៀបនឹងទទួលសញ្ញាប័ត្រពីមហាវិទ្យាល័យ មិត្តភក្តិស្និទ្ធស្នាលពីរនាក់របស់ខ្ញុំ ហើយនិងខ្ញុំក៏បានសម្រេចចិត្តទៅដើរលេងអត់គ្រោងទុក ពីស្រុកកំណើតរបស់យើងនៅរដ្ឋតិចសាស់ភាគខាងកើត (East Taxes) នៅឧទ្យានជាតិ យេឡូស្ទោន (Yellowstone National Park)។ វាជាដំណើរដើរលេងដ៏សប្បាយ ហាក់បីដូចជាឯកសិទ្ធិមួយសម្រាប់បុរសបីនាក់ ដែលជិតនឹងពេញវ័យ។

ដូចដែលលោកអ្នកអាចទំនងជាស្រមៃដល់ ដំណើរកម្សាន្តនោះមានពេញទៅដោយទេសភាពដ៏ស្រស់ស្អាតនៃភ្នំ ទឹកជ្រោះ ទឹកផុសពុះស្តាន់ធ័រក្តៅ និងក្តាន់ធំៗជាច្រើន។ ព្រឹកមួយ យើងបានសម្រេចចិត្តថានឹងចំណាយពេលដើរកម្សាន្តហាត់ប្រាណ ហើយដើម្បីឲ្យកាន់តែរំភើប យើងទាំងអស់គ្នាក៏បានឯកភាពគ្នាថា នឹងមិនយកផែនទីទៅជាមួយយើងនោះទេ។ យើងចង់ឃើញថា តើផ្លូវលំនោះនឹងនាំយើងទៅដល់ណា។ ដូច្នេះ យើងក៏យកអាហារពេលថ្ងៃ និងទូរស័ព្ទដៃយើងដាក់ចូលក្នុងកាបូប ហើយចេញដំណើរទៅ។

វាជាដំណើរកំសាន្តហាត់ប្រាណយ៉ាងយូរ ហើយមិនយូរប៉ុន្មានយើងក៏ចាប់ផ្តើមលេងសើចជាមួយនឹងគ្នាថាយើងបានមកដល់ឧទ្យានជាតិ

9Marks Online PDF

យេឡូស្តោន ហើយវាក៏មិនសូវខុសគ្នាពីព្រៃឈើនៅរដ្ឋតិចសាស់ភាគខាងកើត ដែលជាស្រុកកំណើតរបស់យើងប៉ុន្មានដែរ។ មានដើមស្រល់ធំៗនៅជុំវិញយើងគ្រប់ទិសទី ហើយម្តងកាល យើងក៏ត្រូវលោតរំលងព្រែកតូចៗ ដែលហូរកាត់ផ្លូវដើរ។ ប៉ុន្តែ វាមិនសូវជាមានអ្វីមើលប៉ុន្មានទេ ហើយតាមពិតទៅយើងក៏ចាប់ផ្តើមមួម៉ៅបន្តិចដែរ។

ប៉ុន្តែ បន្ទាប់មក ភ្លាមៗនោះ មុនអ្នកណាម្នាក់ក្នុងចំណោមយើងពិតជាចាប់ផ្តើមមានពេលវេលាក្នុងការកត់សម្គាល់ថា ចាប់ផ្តើមមានអ្វីផ្លាស់ប្តូរ ក៏លែងមានដើមឈើទៀត ហើយយើងក៏ឃើញថាខ្លួនឯងកំពុងតែឈរនៅគែមជ្រលងភ្នំ ហ្ក្រេន ខេនញាណនៃឧទ្យានជាតិ យេឡូស្តោន (the Grand Canyon of the Yellowstone)។ នៅពីមុខយើង មានជ្រលងភ្នំដ៏ស្រស់ស្អាតជាច្រើនគីឡូម៉ែត្រ។ មានទន្លេហូរកាត់នៅពីក្រោម បញ្ចេញពន្លឺផ្លេកៗខណៈពេលដែលព្រះអាទិត្យជះពន្លឺព្រឹមៗ។ មានបក្សាបក្សីហោះហើរនៅខាងក្រោមយើង ហើយពពកដែលនៅរៀងទាបក៏បានហោះពីលើយើង ខ្ញុំគិតថាហាក់បីដូចជាវាជាប់ក្នុងចរន្តខ្យល់ឆានែលនៃជ្រលងភ្នំ។

នៅពេលនោះ ខ្ញុំមានអារម្មណ៍ថាខ្លួនខ្ញុំតូចណាស់ ដោយសារកំពុងតែសម្លឹងមើលទីកន្លែងដ៏ធំធេងនៅពីក្រោមខ្ញុំ និងដោយកំពុងតែសម្លឹងមើលផ្ទៃមេឃ។ អស់ប្រហែលជាមួយរយៈ យើងទាំងបីនាក់—ជាលើកដំបូងនៅថ្ងៃនោះ—និយាយមិនចេញសោះ។ ហើយបន្ទាប់មក មិត្តភក្តិម្នាក់របស់ខ្ញុំក៏ចាប់ផ្តើមច្រៀង៖

9Marks Online PDF

> «ឱព្រះអម្ចាស់ ការខ្ញុំនឹកស្ញើចខ្លាំងអស្ចារ្យ ពីសកលលោក
> ដែលទ្រង់សាងដោយព្រះហស្ត...»។[៤]

សូមព្រះជាម្ចាស់ប្រទានពរគាត់ ទោះបើគាត់មិនមែនជាអ្នកចេះច្រៀងប៉ុន្មានក៏ដោយ ក៏ប៉ុន្តែដួងចិត្តរបស់គាត់ក៏ពិតជាបាននៅកន្លែងដ៏ត្រឹមត្រូវមែន! អស់ប៉ុន្មានជាប្អូនដប់នាទីទៀត យើងក៏ឈរនៅគែមជ្រលងភ្នំ ហ្វ្រេន្ត ខេនញាណនៃឧទ្យានជាតិ យេទ្យូស្មោន ហើយច្រៀងសរសើរតម្កើងព្រះអង្គដែលបានបង្កើតស្នាដៃឯកដែលគួរឲ្យកោតសរសើរនេះ។

## ហេតុអ្វីបានជាយើងមើលរំលងដំណឹងល្អ?

តាមពិតទៅ ដំណឹងល្អក៏គួរមានការជះឥទ្ធិពលលើអារម្មណ៍រំភើបដូចនោះលើយើង ប្រសិនបើយើងញែកពេលវេលាដើម្បីឈប់ ហើយពិតជាគិតអំពីដំណឹងល្អនោះមែន។ តើពេលវេលាបានកន្លងផុតយូរប៉ុណ្ណាហើយក្នុងការដែលលោកអ្នកងើបដោយងាកចេញពីការមើលភាពលម្អិតនៃជីវិត ហើយបានប្រឈមមុខជាមួយនឹងជ្រលងភ្នំហ្វ្រេន្ត ខេនញាណនៃអ្វីដែលព្រះជាម្ចាស់បានធ្វើសម្រាប់យើងក្នុងដំណឹងល្អ—ជម្រៅនៃព្រះគុណរបស់ទ្រង់ដែលយើងមិនអាចយល់ដល់បាន ក្នុងការអត់ទោសអស់អ្នកដែលបានបះបោរទាស់ប្រឆាំងនឹងទ្រង់ ផែនការ

៤. ដកស្រង់ចេញពី «ទ្រង់ធំណាស់ណា» និពន្ធដោយលោក Stuart K. Hine, ឆ្នាំ១៩៤៩; អែកលេកំណាព្យ “O Store Gud,” និពន្ធដោយលោក Carl G. Boberg, ឆ្នាំ១៨៨៦។

9Marks Online PDF

របស់ទ្រង់ដែលរំភើបយ៉ាងខ្លាំងនៃការចាត់ឲ្យព្រះរាជបុត្រារបស់ទ្រង់យាងមក ដើម្បីរងទុក្ខ និងសុគតជំនួសគេ ដើម្បីតាំងនគររបស់ព្រះយេស៊ូវដែលបានមានព្រះជន្មរស់ឡើងវិញលើនគរនៃសេចក្តីសុចរិតដ៏ល្អឥតខ្ចោះ និងដើម្បីនាំឲ្យអ្នកដែលទទួលបានសេចក្តីសង្គ្រោះ និងប្រោសលោះតាមរយៈព្រះហស្តរបស់ទ្រង់ចូលក្នុងផ្ទៃមេឃនិងផែនដីថ្មីដែលទ្រង់បានយកឈ្នះលើអំពើបាប និងអំពើអាក្រក់អស់កល្បជានិច្ច!

ហេតុអ្វីបានជាខ្ញុំអនុញ្ញាតឲ្យភាពស្រស់ស្អាត អំណាច និងភាពធំធេងនៃដំណឹងល្អមានការឃ្លាតចេញពីចិត្តគំនិតរបស់ខ្ញុំជាញឹកញាប់ហើយយូរម្លេះ? ជារឿយៗ ហេតុអ្វីបានជាគំនិត និងអារម្មណ៍របស់ខ្ញុំផ្តោតទៅលើអ្វីដែលភ្លឹភ្លើដូចជាថា ឡានខ្ញុំស្អាតឬអត់ ឬក៏ថាកំពុងមានអ្វីកើតឡើងនៅក្នុងបណ្តាញព័ត៌មានឥឡូវនេះ ឬក៏ថាថ្ងៃនេះខ្ញុំញ៉ាំបាយថ្ងៃត្រង់ឆ្ងាញ់ឬក៏អត់ ជាជាងផ្តោតលើសេចក្តីពិតដ៏រុងរឿងទាំងនោះវិញ? ជារឿយៗ ហេតុអ្វីបានជាខ្ញុំរៀបចំ និងគិតអំពីជីវិតរបស់ខ្ញុំហាក់បីដូចជាថាខ្ញុំកំពុងតែពាក់ឃ្លុំភ្នែក ជាជាងផ្អែកលើភាពអស់កល្បជានិច្ច? ហេតុអ្វីបានជាដំណឹងល្អនេះមិនតែងតែជ្រាបចូលរហូតដល់ទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងប្រពន្ធកូន អ្នករួមការងារ មិត្តភក្តិ និងសមាជិកនៅឯក្រុមជំនុំ?

ខ្ញុំដឹងពីមូលហេតុយ៉ាងច្បាស់។ គឺដោយសារខ្ញុំជាមនុស្សមានបាប ហើយទំនោរនៃការចង់ត្រាប់តាមលោកីយ៍នឹងបន្តមាននៅក្នុងចិត្តរបស់ខ្ញុំ ហើយបន្តធ្វើសង្គ្រាមទាស់ប្រឆាំងនឹងខ្ញុំរហូតដល់ថ្ងៃ

9Marks Online PDF

ដែលព្រះយេស៊ូវយាងត្រឡប់មកវិញ។ ប៉ុន្តែ រហូតដល់ពេលនោះ ខ្ញុំចង់បន្តប្រឆាំងនឹងវា។ ខ្ញុំចង់បន្តប្រឆាំងនឹងភាពខ្ជិលខាងវិញ្ញាណ—ប្រឆាំងនឹងភាពធីងធោងដែលជាលទ្ធផលនៃគ្រឿងញៀន ដែលលោកីយ៍នេះបន្តសម្លុតដាក់លើខ្ញុំ—ហើយខ្ញុំចង់ឱបក្រសោបដំណឹងល្អនេះឲ្យជាប់ ហើយឲ្យវាជះឥទ្ធិពលលើគ្រប់អ្វីៗទាំងអស់—ទង្វើ ភាពចូលចិត្ត អារម្មណ៍ សេចក្តីប្រាថ្នា គំនិត និងឆន្ទៈ។

ហើយខ្ញុំក៏សង្ឃឹមថា លោកអ្នកក៏ចង់បានដូច្នោះដែរ។ ខ្ញុំសង្ឃឹមថាសៀវភៅមួយក្បាលនេះក៏បានជួយផ្នែកខ្លះៗ ដើម្បីឲ្យលោកអ្នកអាចឃើញភាពអស្ចារ្យនៃអ្វីដែលព្រះជាម្ចាស់បានធ្វើសម្រាប់យើងនៅក្នុងព្រះយេស៊ូវ។ ប៉ុន្តែ ចុះយ៉ាងដូចម្តេចទៅតទៀតនេះ? សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងពីរទៅបីចំណុច—មានរាប់លានចំណុចដែលខ្ញុំនឹងមិនលើកឡើង—ទាក់ទងនឹងរបៀបដែលដំណឹងល្អរបស់ព្រះយេស៊ូវគួរជះឥទ្ធិពលលើជីវិតយើង។

## ចូរប្រែចិត្ត ហើយទទួលជឿ

ទី១ ប្រសិនបើលោកអ្នកមិនមែនជាគ្រីស្ទបរិស័ទ ខ្ញុំសូមអរគុណលោកអ្នកដែលបានអានសៀវភៅនេះរហូតមកដល់ពេលនេះ។ ខ្ញុំសង្ឃឹមថា លោកអ្នកបានចំណាយពេលខ្លះៗ ដើម្បីគិតលើដំណឹងល្អអំពីព្រះយេស៊ូវ ហើយខ្ញុំក៏អធិស្ឋានថាវាក៏បានជ្រាបចូលក្នុងចិត្តគំនិតរបស់លោកអ្នកបានយ៉ាងជ្រាលជ្រៅផងដែរ។ សម្រាប់លោកអ្នក ខ្ញុំគិតថាសំណួរ “ចុះយ៉ាងដូចម្តេចទៅតទៀតនេះ?” គឺតាមពិតទៅជាសំណួរដ៏

ងាយស្រួលណាស់។ លោកអ្នកមិនមានចំណុចរាប់លានក្នុងការធ្វើនោះទេ។ មានតែការមួយទេ៖ ចូរប្រែចិត្តចេញពីអំពើបាប ហើយទទួលជឿលើព្រះយេស៊ូវចុះ។ នេះមានន័យថា លោកអ្នកទទួលស្គាល់ថាខ្លួនក្ស័យធនខាងឯវិញ្ញាណ និងទទួលស្គាល់ថាលោកអ្នកមិនមានសមត្ថភាពទាល់តែសោះក្នុងការសង្គ្រោះខ្លួនឯង ហើយចូលមកឯព្រះយេស៊ូវ ដែលព្រះអង្គគឺជាសេចក្ដីសង្ឃឹមតែមួយគត់ក្នុងការអត់ទោសបាប ហើយឲ្យយើងឈរបានយ៉ាងត្រឹមត្រូវនៅមុខព្រះភក្ត្រព្រះជាម្ចាស់បាន។

ការក្លាយជាគ្រីស្ទបរិស័ទមិនមែនជាដំណើរការវែងឆ្ងាយនោះទេ។ គ្មានអ្វីដែលយើងអាចទទួលបានកំរៃឡើយ។ ព្រះយេស៊ូវបានរកកំរៃគ្រប់គ្រាន់សម្រាប់អ្វីៗទាំងអស់ដែលលោកអ្នកត្រូវការហើយ។ អ្វីដែលដំណឹងល្អត្រាស់ហៅលោកអ្នកឲ្យធ្វើគឺការប្រែចិត្តចេញពីអំពើបាប ហើយបែរទៅឯព្រះយេស៊ូវដោយជំនឿ—ដែលនោះគឺជាការទុកចិត្ត និងការពឹងផ្អែកលើ។ ដំណឹងល្អហៅលោកអ្នកឲ្យចូលមកឯព្រះអង្គ ហើយសារភាពថា “ឱព្រះយេស៊ូវអើយ! ទូលបង្គំដឹងថា ទូលបង្គំមិនអាចសង្គ្រោះខ្លួនឯងបានទេ ដូច្នេះទូលបង្គំទុកចិត្តព្រះអង្គក្នុងការធ្វើវាសម្រាប់ទូលបង្គំ”។

បន្ទាប់មក ផែនដីទាំងមូលនឹងបើកចំហនៅចំពោះលោកអ្នក។ ប៉ុន្តែទាំងអស់ចាប់ផ្ដើមដោយការប្រែចិត្តចេញពីអំពើបាប ហើយការជឿថាព្រះយេស៊ូវបានសង្គ្រោះលោកអ្នកសិន។

9Marks Online PDF

## ចូរសម្រាក ហើយមានអំណរ

ប្រសិនបើលោកអ្នកជាគ្រីស្ទបរិស័ទ នោះជាដំបូងគេបង្អស់ ដំណឹងល្អហៅលោកអ្នកឲ្យសម្រាកក្នុងព្រះយេស៊ូវគ្រីស្ទ ហើយឲ្យលោកអ្នកមានអំណរនៅក្នុងសេចក្តីសង្គ្រោះដែលមិនអាចរង្កើបានដែលព្រះអង្គបានយកជ័យជម្នះសម្រាប់លោកអ្នករួចហើយ។ ដោយសារព្រះយេស៊ូវ ហើយដោយសារខ្ញុំដឹងថាខ្ញុំបានរួបរួមជាមួយព្រះអង្គតាមរយៈជំនឿ នោះខ្ញុំអាចតយុទ្ធនឹងការល្បួង ដែលនាំឲ្យគិតថា សេចក្តីសង្គ្រោះរបស់យើងខ្ញុំងាយបាក់បែក ឬរំលងផុតទៅ។ មិនថាខ្ញុំអាចមានអារម្មណ៍ដូចនោះពេលណាក៏ដោយ ក៏ខ្ញុំដឹងថា—នៅក្រោមទីជម្រៅនៃសំណួរដែលកំពុងតែផុសឡើង—ខ្ញុំជាកម្មសិទ្ធិរបស់ព្រះយេស៊ូវ ហើយថាគ្មានអ្នកណាអាចឆក់ខ្ញុំចេញពីព្រះហស្តរបស់ទ្រង់បានឡើយ។ នេះគឺដោយសារដំណឹងល្អប្រាប់ខ្ញុំថា សេចក្តីសុចរិតរបស់ខ្ញុំនៅចំពោះព្រះជាម្ចាស់មិនមានមូលដ្ឋានលើការគ្រីសបញ្ជីត្រួតពិនិត្យណាមួយខាងឯវិញ្ញាណនោះទេ។ មានផលផ្លែល្អម? គ្រីស។ បានចំណាយពេលជាមួយព្រះ? គ្រីស។ បានមានការសន្ទនាខាងឯវិញ្ញាណ? គ្រីស។ គ្រីស។ គ្រីស។ អស្ចារ្យមែន! ខ្ញុំមានអារម្មណ៍ថា ថ្ងៃនេះខ្ញុំ*ពិតជា*ទទួលបានសេចក្តីសង្គ្រោះមែន!

នេះពិតជាគួរឲ្យអស់សំណើចមែន ប្រសិនបើប្រៀបធៀបទៅនឹងអ្វីដែលដំណឹងល្អបានលើកឡើងអំពីព្រះយេស៊ូវ! អរព្រះគុណដល់ព្រះជាម្ចាស់ ត្រង់ថាទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងព្រះអង្គមិនពឹងផ្អែក

9Marks Online PDF

លើបំណងប្រាថ្នាដែលមិនស្មោះត្រង់ ឬសមត្ថភាពក្នុងការរស់នៅឲ្យសុចរិតនោះទេ។ អត់ទេ! ព្រះជាម្ចាស់បានសម្រេចសេចក្តីវិនិច្ឆ័យលើខ្ញុំហើយ ហើយថា “ខ្ញុំបានទទួលការអត់ទោស”។ លើសពីនោះទៅទៀត ការសម្រេចសេចក្តីវិនិច្ឆ័យក៏នឹងមិនដែលមានការផ្លាស់ប្រែ ពីព្រោះវាមានមូលដ្ឋានលើព្រះយេស៊ូវតែមួយអង្គគត់ និងអស់កល្បជានិច្ច—ការសុគតនៅលើឈើឆ្កាងរបស់ទ្រង់ជំនួសខ្ញុំ ហើយនិងការអង្វររកររបស់ទ្រង់សម្រាប់ខ្ញុំ សូម្បីតែឥឡូវនេះនៅមុខបល្ល័ង្ករបស់ព្រះជាម្ចាស់។

ប្រសិនបើលោកអ្នកជាគ្រីស្ទបរិស័ទ នោះឈើឆ្កាងរបស់ព្រះយេស៊ូវនឹងឈរដូចជាភ្នំថ្មក្រានីតនៅក្នុងជីវិតរបស់លោកអ្នក មិនអាចរើចេញបាន ដោយធ្វើជាទីបន្ទាល់អំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់លោកអ្នក និងការប្តេជ្ញាព្រះទ័យរបស់ទ្រង់ក្នុងការនាំលោកអ្នកឲ្យបានចូលក្នុងព្រះវត្តមានរបស់ទ្រង់ដែលមានសុវត្ថិភាព។ ដូចដែលសាវ័ក ប៉ុល បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ រ៉ូម៖ “បើសិនជាព្រះកាន់ខាងយើង តើអ្នកណាអាចទាស់នឹងយើងបាន ឯព្រះអង្គ ដែលមិនបានសំចៃទុកនូវព្រះរាជបុត្រាទ្រង់បង្កើត គឺបានបញ្ជូនទ្រង់ទៅជំនួសយើងរាល់គ្នា នោះតើមានទំនងអ្វី ឲ្យទ្រង់មិនប្រទានគ្រប់ទាំងអស់មកយើង” (រ៉ូម ៨:៣១-៣២)។

## ចូរស្រឡាញ់រាស្ត្ររបស់ព្រះគ្រីស្ទ

មួយវិញទៀត ឱគ្រីស្ទបរិស័ទអើយ ដំណឹងល្អក៏គួរតែធ្វើឲ្យលោកអ្នកកាន់តែស្រឡាញ់រាស្ត្ររបស់ព្រះជាម្ចាស់ គឺក្រុមជំនុំ។ មិនមានគ្រីស្ទ

9Marks Online PDF

បរិស័ទណាម្នាក់ក្នុងចំណោមយើងបានធ្វើអ្វីមួយ ដើម្បីឲ្យខ្លួនអាចទទួលបានមរតកដែលព្រះជាម្ចាស់បានគ្រោងទុកសម្រាប់យើងទេ។ យើងមិនមែនជារាស្ត្រនគរដែល “បានតាំងខ្លួនឯងឡើង” នោះទេ។ យើងទទួលបានការរាប់បញ្ចូលក្នុងសេចក្ដីសន្យារបស់ព្រះជាម្ចាស់ គឺដោយសារតែយើងរំពឹងលើព្រះយេស៊ូវគ្រីស្ទក្នុងការសង្គ្រោះយើង ហើយយើងមានការរួបរួមគ្នាជាមួយនឹងព្រះអង្គតាមរយៈជំនឿ។

ប៉ុន្តែ នេះជាចំណុចដែលយើងមិនបានរំពឹងទុក។ តើលោកអ្នកដឹងទេថា នេះក៏ជាចំណុចពិតដូចគ្នានឹងបងប្អូនរបស់លោកអ្នកនៅក្នុងក្រុមជំនុំដែលរំខានលោកអ្នកដែរឬទេ? គាត់ក៏ជឿ និងស្រឡាញ់ព្រះអម្ចាស់យេស៊ូវដូចលោកអ្នកដែរ ហើយលើសពីនោះទៅទៀតគាត់ក៏ស្គាល់ ហើយទទួលបានសេចក្ដីសង្គ្រោះ និងការអត់ទោសពីព្រះអម្ចាស់ដូចគ្នា ដែលបានសង្គ្រោះ និងអត់ទោសលោកអ្នកផងដែរ។ សូមគិតអំពីបងប្អូនដែលលោកអ្នកមិនបានចំណាយពេលស្គាល់ ពីព្រោះលោកអ្នកគិតថានឹងមិនត្រូវគ្នា។ សូមគិតអំពីបងប្អូនដែលលោកអ្នកមានទំនាក់ទំនងបាក់បែក ដែលលោកអ្នកមិនព្រមផ្សះផ្សាគ្នា។ បន្ទាប់មក សូមគិតអំពីការដែលគាត់ក៏ស្រឡាញ់ និងទុកចិត្តលើព្រះអម្ចាស់ដូចលោកអ្នកផងដែរ។ សូមគិតអំពីចំណុចដែលថា ព្រះអម្ចាស់ដែលបានសុគតជំនួសលោកអ្នកក៏បានសុគតសម្រាប់គាត់ផងដែរ។

ខ្ញុំនៅឆ្ងល់ថា តើការយល់ដឹងរបស់លោកអ្នកអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ—ដំណឹងល្អដែលថា ព្រះយេស៊ូវបានសង្គ្រោះលោកអ្នក

9Marks Online PDF

ទោះបីជាលោកអ្នកមិនស័ក្តិសមទទួលបានក៏ដោយ—មានជម្រៅជ្រៅល្មមក្នុងការទទួលយកការរិះគន់បន្តិចបន្តួចដែលទទួលបានពីបងប្អូន។ ខ្ញុំនៅឆ្ងល់ថា តើវាជ្រៅល្មមក្នុងការពន្លិចចោលនូវការអន់ចិត្តដែលពួកគាត់ប្រព្រឹត្តទាស់នឹងលោកអ្នក សូម្បីតែការវាយប្រហារយ៉ាងខ្លាំង ហើយនាំឲ្យលោកអ្នកអត់ទោសពួកគាត់ និងស្រឡាញ់ពួកគាត់ដូចដែលព្រះយេស៊ូវផ្ទាល់បានធ្វើសម្រាប់អ្នកទាំងពីរនាក់។

ខ្ញុំនៅឆ្ងល់ថា តើសេចក្តីស្រឡាញ់ដ៏ធំធេងរបស់ព្រះជាម្ចាស់សម្រាប់លោកអ្នកបានធ្វើឲ្យសេចក្តីស្រឡាញ់របស់លោកអ្នកសម្រាប់អ្នកដទៃបានកើនឡើងដែរឬទេ។

## ចូរផ្សាយដំណឹងល្អទៅកាន់លោកីយ៍

មិនត្រឹមតែប៉ុណ្ណោះនោះទេ ប៉ុន្តែខ្ញុំនៅមានចម្ងល់ថា តើព្រះគុណរបស់ព្រះជាម្ចាស់មកកាន់លោកអ្នកបានធ្វើឲ្យលោកអ្នកស្រឡាញ់លោកីយ៍ដែលនៅជុំវិញលោកអ្នក និងចង់ឃើញមនុស្សស្គាល់ និងទទួលជឿលើព្រះយេស៊ូវដែរឬទេ? ប្រសិនបើយើងពិតជាយល់អំពីព្រះគុណរបស់ព្រះជាម្ចាស់ដែលទ្រង់បានបង្ហាញមកកាន់យើងមែន នោះដួងចិត្តរបស់យើងនឹងមានការឆេះឆួលចង់ឃើញព្រះគុណនោះបង្ហាញទៅកាន់អ្នកដទៃផងដែរ។

បន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ ព្រះយេស៊ូវបានលេចមកឯពួកសិស្សរបស់ព្រះអង្គ ហើយបានមានបន្ទូលប្រាប់ពួកគេពីការនេះថា “គឺសេចក្តីនេះហើយ ដែលបានចែងទុកមក គឺថា ព្រះ

គ្រីស្ទត្រូវរងទុក្ខលំបាក ហើយនៅថ្ងៃទី៣ទ្រង់នឹងរស់ពីស្លាប់ឡើងវិញ ហើយត្រូវឲ្យការប្រែចិត្ត នឹងសេចក្ដីប្រោសឲ្យរួច បានប្រកាសប្រាប់ដល់អស់ទាំងសាសន៍ ដោយនូវព្រះនាមទ្រង់ ចាប់តាំងពីក្រុងយេរូសាឡឹមទៅ»។ នៅក្នុងខគម្ពីរនេះ ព្រះអង្គបានលើកឡើងយ៉ាងច្បាស់លាស់សម្រាប់ពួកសិស្ស—អំពីផែនការរបស់ទ្រង់ ដើម្បីសង្គ្រោះរាស្ត្ររបស់ទ្រង់សម្រាប់ទ្រង់។ ហើយបន្ទាប់មក ព្រះយេស៊ូវក៏បានបន្ថែមយ៉ាងភ្ញាក់ផ្អើលថា «អ្នករាល់គ្នាជាស្មរបន្ទាល់ពីការទាំងនេះ» (លូកា ២៤:៤៦-៤៨)។ ខ្ញុំតែងតែគិតថា មុខពួកសិស្សប្រហែលជាស្លេកស្លាំង នៅពេលដែលពួកគាត់ឮពាក្យពេចន៍ទាំងនោះ! គោលបំណងរបស់ព្រះជាម្ចាស់មិនមានអ្វីលើសជាងការប្រោសលោះលោកីយ៍ ហើយនៅត្រង់នេះព្រះយេស៊ូវកំពុងតែប្រាប់ពួកគាត់ថា *ពួកគាត់*នឹងសម្រេចគោលបំណងនោះ!

ខ្ញុំមិនដឹងអំពីលោកអ្នកទេ ប៉ុន្តែគំនិតនោះធ្វើឲ្យខ្ញុំមានអារម្មណ៍ថាខ្ញុំពុំអាចទុកចិត្តខ្លួនឯងបានទាល់តែសោះ។ ព្រះជាម្ចាស់មានផែនការក្នុងការសម្រេចគោលបំណងរបស់ទ្រង់លើលោកនេះតាមរយៈ*យើង?* ពិតជាអស្ចារ្យមែន! ប៉ុន្តែ ប្រសិនបើលោកអ្នកមានអារម្មណ៍ថាមិនស័ក្តិសម និងគ្រប់គ្រាន់ សូមអនុញ្ញាតឲ្យខ្ញុំផ្តល់ជូននូវការលើកទឹកចិត្តមួយចំនួន។ លោកអ្នកមិនស័ក្តិសមទេ ហើយប្រាកដណាស់លោកអ្នកក៏មិនគ្រប់គ្រាន់ផងដែរ! តើនេះជាការលើកទឹកចិត្តដោយរបៀបណា? សូមមើលយើង—ជាមនុស្សទន់ខ្សោយ ដែលនៅតយុទ្ធទាស់ប្រឆាំង

9Marks Online PDF

នឹងអំពើបាបជារៀងរាល់ថ្ងៃ រហូតដល់ថ្ងៃយើងស្លាប់។ ទោះជាយ៉ាងណាក៏ដោយក៏ព្រះយេស៊ូវមានបន្ទូលមកកាន់យើងថា អ្នករាល់គ្នាជាស្មរបន្ទាល់ពីការទាំងនេះ»។ គឺតាមរយៈការប្រកាសដំណឹងល្អរបស់យើង—មិនថាតាមរយៈការអធិប្បាយ ការបង្រៀន ឬក៏ការសន្ទនាជាមួយនឹងមិត្តភក្តិ បងប្អូន និងអ្នករួមការងារនៅពេលបរិភោគអាហារ—ដែលថា ព្រះជាម្ចាស់បានប្តេជ្ញាព្រះទ័យក្នុងការសង្គ្រោះមនុស្សមានបាប។

តើលោកអ្នកធ្លាប់ងឿងឆ្ងល់ទេថា ហេតុអ្វីបានជាទេវតាដែលបាននិយាយជាមួយនឹងលោក កូនេលាស នៅក្នុងកណ្ឌគម្ពីរកិច្ចការជំពូក ១០ មិនបានប្រាប់ដំណឹងល្អដល់គាត់? ហេតុអ្វីបានជាចាំបាច់ឆ្លងកាត់ឧបសគ្គក្នុងការឲ្យលោក កូនេលាស ទៅរកសាវ័ក ពេត្រុស ដែលកាលនោះគាត់នៅទីក្រុងខុសគ្នាតែម្តង។ ប្រាកដណាស់ ប្រសិនបើទេវតាអាចប្រាប់លោក កូនេលាស អំពីចំណុចទាំងអស់នោះ នោះក៏ទេវតាពិតជាអាចប្រាប់ដំណឹងល្អទៅដល់ លោក កូនេលាស បានដែរ! ប៉ុន្តែ មិនដូច្នោះទេ ព្រះជាម្ចាស់សម្រេចថាដំណឹងល្អនឹងទៅមុខតាមរយៈពាក្យពេចន៍នៃរាស្ត្ររបស់ទ្រង់—ដែលនោះ គឺតាមរយៈមាត់របស់អស់អ្នកដែលពួកគាត់ផ្ទាល់ក៏បានឱបក្រសោបដំណឹងល្អអំពីព្រះយេស៊ូវ ហើយក៏បានស្គាល់នូវការអស់ទោសដែលកើតចេញពីព្រះអង្គដែរ។

ប្រសិនបើលោកអ្នកជាគ្រីស្ទបរិស័ទ សូមទទួលស្គាល់ថា លោក

9Marks Online PDF

អ្នកកាន់នៅក្នុងដៃរបស់ខ្លួននូវសារដ៏ពិតតែមួយនៃសេចក្ដីសង្គ្រោះដែលលោកីយ៍នេះត្រូវឮ។ នឹងមិនមានដំណឹងល្អណាផ្សេងទៀតទេ ហើយក៏គ្មានមធ្យោបាយណាផ្សេងទៀតក្នុងការឲ្យមនុស្សទទួលបានសេចក្ដីសង្គ្រោះចេញពីអំពើបាបរបស់ខ្លួនដែរ។ ប្រសិនបើចង់ឲ្យមិត្តភក្ដិ គ្រួសារ និងអ្នករួមការងាររបស់លោកអ្នកទទួលបានការសង្គ្រោះចេញពីអំពើបាបរបស់ពួកគាត់ នោះដាច់ខាតត្រូវតែមាននរណាម្នាក់និយាយអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទទៅកាន់ពួកគាត់។ នេះហើយជាមួយហេតុដែលព្រះយេស៊ូវបានចាត់ឲ្យយើងចេញទៅក្នុងលោកីយ៍ ប្រកាស និងបង្រៀនដំណឹងល្អនេះទៅកាន់ជាតិសាសន៍។ វាក៏ដូចគ្នានឹងអ្វីដែលសាវ័ក ប៉ុល មានន័យនៅក្នុងកណ្ឌគម្ពីរ រ៉ូមជំពូក ១០ នៅពេលដែលគាត់សួរថា «ដូច្នេះ បើគេមិនជឿ ធ្វើដូចម្ដេចឲ្យគេអំពាវនាវដល់ព្រះបាន ហើយបើគេមិនបានឮនិយាយ នោះធ្វើដូចម្ដេចឲ្យគេជឿដល់ព្រះបាន ហើយធ្វើដូចម្ដេចឲ្យគេឮនិយាយបាន បើគ្មានអ្នកណាប្រាប់សោះ» (ខ១៤)។ មានចំណុចល្អៗជាច្រើនដែលយើងអាចធ្វើក្នុងនាមជាគ្រីស្ទបរិស័ទ ប៉ុន្តែចំណាចជាក់ស្ដែងគឺថា អ្នកដែលមិនមែនជាគ្រីស្ទបរិស័ទក៏នឹងធ្វើការនោះយ៉ាងសប្បាយចិត្តផងដែរ។ ប៉ុន្តែ ប្រសិនបើយើងជាគ្រីស្ទបរិស័ទបរាជ័យក្នុងការប្រកាសដំណឹងល្អរបស់ព្រះយេស៊ូវ តើអ្នកណានឹងធ្វើការនោះ? គ្មានទេ។

ដូច្នេះ សូមឲ្យសេចក្ដីពិតនៃដំណឹងល្អជ្រាបចូលក្នុងដួងចិត្តរបស់លោកអ្នក ហើយឲ្យបំបែកដួងចិត្តអស់អ្នកដែលមិនទាន់ស្គាល់ព្រះ

យេស៊ូវគ្រីស្ទនៅឡើយដែរចុះ។ សូមគិតអំពីអ្វីដែលនឹងកើតឡើងចំពោះមិត្តភក្តិ គ្រួសារ និងអ្នករួមការងាររបស់លោកអ្នក នៅពេលដែលពួកគាត់ឈរនៅចំពោះព្រះ ដែលជាអ្នកជំនុំជម្រះដ៏យុត្តិធម៌ ប្រសិនបើពួកគាត់មិនមានព្រះយេស៊ូវគ្រីស្ទ។ សូមចងចាំអំពីអ្វីដែលព្រះគុណរបស់ព្រះជាម្ចាស់បានធ្វើក្នុងជីវិតរបស់លោកអ្នក និងសាកស្រមៃពីអ្វីដែលព្រះអង្គអាចធ្វើនៅក្នុងជីវិតរបស់ពួកគេផងដែរ។ បន្ទាប់មក ចូរដកដង្ហើមវែងមួយៗ អធិស្ឋានសូមឲ្យព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ធ្វើការនោះ និងបើកមាត់លោកអ្នក ហើយនិយាយ!

## ចូរប្រាថ្នាចង់បានព្រះអង្គ

ជាចុងក្រោយ ដំណឹងល្អគួរធ្វើឲ្យយើងចង់បានថ្ងៃដែលព្រះយេស៊ូវដ៏ជាស្ដេចរបស់យើងនឹងត្រឡប់មកវិញ ដើម្បីតាំងនគររបស់ទ្រង់យ៉ាងពេញទី និងជាចុងក្រោយ ហើយអស់កល្បជានិច្ច។ នេះមិនមែនគ្រាន់តែជាការប្រាថ្នាដែល*កើតចេញ*ជាលទ្ធផលនៃការនៅក្នុងនគរប៉ុណ្ណោះទេ។ យើងមិនគួរប្រាថ្នាចង់ឲ្យព្រះយេស៊ូវយាងត្រឡប់មកវិញ គ្រាន់តែដោយសារយើងចង់រស់នៅក្នុងពិភពលោកដែលបានយកឈ្នះលើអំពើអាក្រក់ ហើយគ្រប់គ្រងដោយភាពយុត្តិធម៌នោះទេ។

ទាំងនោះគឺជាសេចក្ដីសន្យាយ៉ាងអស្ចារ្យ ប៉ុន្តែវាក៏មិនធំល្មមគ្រប់គ្រាន់ផងដែរ។ ទេ! ប្រសិនបើយើងបានយល់ដំណឹងល្អយ៉ាងត្រឹមត្រូវ នោះយើងនឹងមិនគ្រាន់តែចង់បាននគរប៉ុណ្ណោះនោះទេ ប៉ុន្តែគឺចង់បានស្ដេចផ្ទាល់តែម្ដង។ ដំណឹងល្អបាននាំឲ្យយើងស្គាល់ និងស្រឡាញ់

9Marks Online PDF

ព្រះអង្គ ដែលជាលទ្ធផលនាំឲ្យយើងចង់នៅជាមួយនឹងទ្រង់។ “ឯពួកអ្នកដែលទ្រង់ប្រទានមកទូលបង្គំ នោះទូលបង្គំចង់ឲ្យគេ...[ទៅ] ក្នុងកន្លែងដែលទូលបង្គំនៅដែរ” (យ៉ូហាន ១៧:២៤)។ ហើយយើងក៏ប្រាថ្នាចង់នៅជាមួយនឹងព្រះអង្គ ដោយរួមជាមួយនឹងមនុស្សរាប់លាននាក់ ដើម្បីថ្វាយបង្គំទ្រង់។

កណ្ឌគម្ពីរវិវរណៈមាននូវការបើកសម្ដែងការអស្ចារ្យនៃអ្វីដែលព្រះជាម្ចាស់បានរៀបចំសម្រាប់យើងដែលស្រឡាញ់ទ្រង់។ វាគ្រាន់តែជាតម្រុយ តែលោកអ្នកក៏នៅអាចមានអារម្មណ៍រំភើបយ៉ាងខ្លាំងអំពីជ័យជម្នះ អំណរ ការសម្រាក និងទិដ្ឋភាពចុងក្រោយនៃអស់អ្នកដែលទទួលបានការប្រោសលោះថ្វាយបង្គំព្រះយេស៊ូវគ្រីស្ទ។

> “ក្រោយនោះមក ខ្ញុំក្រឡេកទៅឃើញមនុស្ស១ហ្វូងយ៉ាងធំដែលគ្មានអ្នកណាអាចនឹងរាប់បានឡើយ គេមកពីគ្រប់ទាំងសាសន៍ គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ ហើយគ្រប់ទាំងភាសា ក៏ឈរនៅមុខបល្ល័ង្ក នឹងកូនចៀម ទាំងពាក់អាវសវែង ហើយកាន់ធាងចាកនៅដៃគេបន្លឺសំឡេងថា “សេចក្ដីសង្គ្រោះស្រេចនូវព្រះនៃយើងរាល់គ្នា ដែលគង់លើបល្ល័ង្ក ហើយស្រេចនឹងកូនចៀមផង” (វិវរណៈ ៧:៩ ១០)។

នោះគឺជាថ្ងៃដែលដំណឹងល្អបញ្ឆេះឲ្យយើងប្រាថ្នាចង់បាន។ ខណៈពេលដែលយើងប្រណាំងប្រជែងឆ្លងកាត់ទុក្ខលំបាក ការបៀតបៀន

9Marks Online PDF

ការក្តៅក្រហាយ សេចក្តីល្បួង ការមិនអាចផ្ទង់ស្មារតីបាន ការមិនចាប់អារម្មណ៍ និងភាពនឿយហត់ក្នុងលោកីយ៍នេះ នោះដំណឹងល្អចង្អុលបង្ហាញយើងទៅកាន់ស្ថានសួគ៌ជាកន្លែងដែលព្រះយេស៊ូវដ៏ជាស្តេចរបស់យើង—កូនចៀមនៃព្រះដែលគេបានឆ្កាងជំនួសយើង ហើយក៏បានមានព្រះជន្មរស់ឡើងវិញយ៉ាងរុងរឿងពីការសុគត—កំពុងតែគង់នៅ អង្វរករជំនួសយើង។ មិនត្រឹមតែប៉ុណ្ណោះ ដំណឹងល្អក៏ហៅយើងឲ្យឆ្ពោះទៅថ្ងៃចុងក្រោយ ដែលពេលនោះស្ថានសួគ៌នឹងមានពេញទៅដោយការបន្លឺសូរសំឡេងយ៉ាងអឺងកងពីមនុស្សរាប់រយលាននាក់ដែលទទួលបានការអត់ទោស ច្រៀងសរសើរតម្កើងទ្រង់ ជាព្រះអង្គសង្គ្រោះដែលគេបានឆ្កាង ហើយក៏ជាស្តេចដែលបានមានព្រះជន្មរស់ឡើងវិញផងដែរ។

# សេចក្ដីថ្លែងអំណរគុណដ៏ពិសេស

ដូចជាការរៀបរៀងសៀវភៅផ្សេងៗទៀត សៀវភៅមួយក្បាលនេះក៏មានមនុស្សជាច្រើននាក់ ដែលខ្ញុំជំពាក់ការថ្លែងអំណរគុណដល់។ មិនមានបុគ្គលណារៀន ឬក៏គិតតែឯងនោះទេ ហើយខ្ញុំក៏អាចចំណាយពេលពេញមួយថ្ងៃបានដែរ  ក្នុងការរាយឈ្មោះបងប្អូនដែលខ្ញុំបាននិយាយជាមួយ និងគិតអំពីដំណឹងល្អ អស់រយៈពេលច្រើនជាង១០ឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយក៏មានមនុស្សមួយចំនួនដែលខ្ញុំចង់ថ្លែង «អំណរគុណ» ពិសេសទៅដល់។ ជាដំបូង ទៅកាន់ក្រុមដ៏ល្អនៅឯ Crossway ខ្ញុំសូមថ្លែងអំណរគុណ ដែលបានហ៊ានសាកល្បងជាមួយនឹងអ្នកនិពន្ធដែលគេមិនស្គាល់។ ប្រសិនបើព្រះជាម្ចាស់សព្វព្រះហឫទ័យក្នុងការប្រើប្រាស់សៀវភៅនេះ ដើម្បីស្ដារក្រុមជំនុំរបស់ទ្រង់ នោះគឺដោយសារតាមរយៈលោកអ្នកហើយ។

សូមថ្លែងអំណរគុណទៅកាន់ក្រុម 9Marks ដែលបានលើកទឹកចិត្តខ្ញុំឲ្យនិពន្ធសៀវភៅនេះ និងការខិតខំប្រឹងប្រែងរបស់ពួកគេ ដើម្បីឲ្យការនេះកើតឡើង។ និមិត្ត និងការឆេះឆួលរបស់លោក Matt Schmucker សម្រាប់សុខភាពក្រុមជំនុំនៅជុំវិញពិភពលោកក៏ពិតជាបានលើកទឹក

9Marks Online PDF

ចិត្តខ្ញុំមែន ហើយខ្ញុំក៏មានកិត្តិយសក្នុងការស្គាល់គាត់ និងធ្វើការជាមួយគាត់ផងដែរ។ លោក Jonathan Leeman បានជួយខ្ញុំយ៉ាងខ្លាំងក្នុងការនិពន្ធសៀវភៅនេះ។ តាមរយៈការសន្ទនា ការផ្ញើអ៊ីម៉ែល និងការកែសម្រួល គាត់បានធ្វើឲ្យសៀវភៅនេះកាន់តែល្អប្រសើរ។ ខ្ញុំសូមថ្លែងអំណរគុណដល់លោក Bobby Jamieson ដែលបានអង្គុយហូបកាហ្វេអស់ជាច្រើនកែវ ដែលយើងរាប់ភ្លេច ដើម្បីនិយាយគ្នាជាមួយនឹងខ្ញុំអំពីនគរ។ ខ្ញុំមានអំណរយ៉ាងខ្លាំងដែលខ្ញុំនៅក្នុងក្រុមនេះ!

ចំពោះលោក Mark Dever ដែលជាបងប្អូនស្ងួនភ្ងារបស់ខ្ញុំ ប្អូនសូមថ្លែងអំណរគុណដែលបានជំរុញឲ្យប្អូននិពន្ធសៀវភៅដំបូងនេះ។ ប្អូនជំពាក់គុណបងក្នុងរបៀបដែលប្អូនគិតថាប្អូនមិនអាចពណ៌នាបានផង។ ប្អូនមានមោទនភាពណាស់ក្នុងការហៅបងថាជាអ្នកណែនាំ ហើយប្អូនក៏សប្បាយចិត្តយ៉ាងខ្លាំងដែលព្រះអម្ចាស់របស់យើងបាននាំយើងទាំងពីរនាក់ដោយមានការភ្ញាក់ផ្អើល ក្នុងការនាំប្អូនឲ្យត្រឡប់មករដ្ឋវ៉ាស៊ីនតោន ឌី.ស៊ី. សម្រាប់មួយរយៈ។ ព្រះអង្គពិតជាសប្បុរសមែន ក្នុងការប្រទានពេលវេលាមកកាន់យើងជាមួយគ្នា។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណទៅកាន់លោកស្រី Moriah ដែលជាប្រពន្ធដ៏ខ្លាំងពូកែ និងស្រស់ស្អាតរបស់ខ្ញុំ។ គាត់ស្រឡាញ់ និងយកចិត្តទុកដាក់ដល់ខ្ញុំយ៉ាងខ្លាំង។ ហើយក៏បានចំណាយពេលលើសពីចំណែករបស់គាត់ នៅពេលដែលខ្ញុំលេចបាត់ចូលទៅក្នុងគំនិត ដោយព្យាយាមគិតរកដំណោះស្រាយលើបញ្ហាទេវវិទ្យាដែល

9Marks Online PDF

ពិបាកៗ។ អូនអើយ បងស្រឡាញ់អូនណាស់!

# លិបិក្រមតាមព្រះគម្ពីរ


## ព្រះគម្ពីរសញ្ញាចាស់

លោកុប្បត្តិ
១:១ ១០៣
១:២៦ ៧០, ៧១
១:២៨ ៨២
២:១៦ ៧១
២:១៧ ៨៣
៣:១៥ ១០១
៣:១៧ ៨២

និក្ខមនំ
៣៤:៦ ៧៣, ៧៤
៣៤:៧ ១១៧

ទំនុកតម្កើង
១១:៧ ៧៥
១៨:៣០ ៤២
១៩:១ ៦៩
៣៣:៥ ៧៥
៨៩:១៤ ៧៥
១៤៥:១១ ១៤៩

អេសាយ
៩:៦ ១០៦
១១:៩ ១៥៦
៥៣:៤ ១១៥
៥៣:១០ ១៦២
៥៩:២ ៩៥
៦៥:១៧ ១៥៦

យ៉ូអែល
៧:១១ ១០៥

ហាបាគុក
១:១៣ ៧៧

សាការី
៣:១ ១៣៣

## ព្រះគម្ពីរសញ្ញាថ្មី

ម៉ាថាយ
១:២១ ១១១
៣:២ ១៥០
៥:១៦ ១៨៥
៦:២៤ ១៣៩
១២:២៨ ១៥១
១៣:៤១ ១៥៤
១៥:១៩ ៩៣
១៦:២៣ ១១២
២៦:២៧ ១១២
២៦:២៨ ១១២
២៦:២៩ ១៥៥
២៧:៤៦ ១១៤

ម៉ាកុស
១:១ ១០១
១:១៥ ១២៤, ១៣៦
៩:៤៣ ៩៧, ៩៧
១០:១៧ ១៦០
១០:៤៥ ១១២, ១៦២
១៤:៦២ ១០៨


9Marks Online PDF

លូកា
១:៣២ ១០៦
១:៣៤ ១០៣
៦:៤៤ ១៤២
៩:៥១ ១១២
១០:២៥ ១៨៤
១៣:៣ ១៣៨
១៤:២៨ ១៤៥
២៤:៥ ១១៨, ១៥៣
២៤:៤៦ ២០៣

យ៉ូហាន
១:១ ១០៣
១:២៩ ១០៩
២:១ ១៣៩
១០:១៥ ១១៣
១៧:២៤ ២០៧
១៨:៣៦ ១០៨

កិច្ចការ
២:៣៨ ៥៥, ១២៤
៣:១៨ ៥៦
៣:១៩ ១៣៧
១០:៣៩ ៥៧
១១:១៨ ១៣៨
២០:២១ ១២៤
២៦:១៨ ១២៥
២៦:២០ ១៣៧, ១៤២
២៨:៣១ ១៤៧

រ៉ូម
១:១ ៤៥
១:១៦ ៤៥
១:២០ ៦៩
៣:១០ ៨៦
៣:១៩ ៩៤
៣:២២ ១៣០
៣:២៣ ៨៥
៣:២៤ ៥០, ៥០
៤:៥ ១១៧, ១៣១
៤:១៨ ១២៨
៦:៤ ១៦៦
៦:១២ ១៦៦
៦:២៣ ៩៥
៨:៧ ៩៣
៨:៣១ ២០០
៨:៣៣ ១១៩
១០:៩ ១៧៨
១១:៣៣ ៣២

១កូរិនថូស
១:២៣ ១៩០
១:២៥ ១៩១
២:២ ១៩០
២:៩ ១៤៦
៦:៩ ១៥០
១០:១៣ ១៤០
១២:៣ ១៧៨
១៥:៣ ១៩០

២កូរិនថូស
៥:២១ ១១៣
៧:១០ ១៣៨

កាឡាទី
២:១៦ ១៣៥
៣:១៣ ១១៣
៥:១៧ ១៣៩
៦:១០ ១៨៤

អេភេសូរ
១:១៤ ១៥៥
២:១ ៩៤, ១៤២
២:៣ ៩៣
២:៦ ១៥៣
២:៧ ១៥៥
៣:៧ ៣៣
៣:១០ ១៦៧

9Marks Online PDF

ភីលីព
២:១៥ ១៦៧

កូឡុស
១:១២ ១០៩
១:១៣ ១៤៧

២ធីម៉ូថេ
៣:១៦ ៤២

ហេព្រើរ
៤:១៥ ១០៤
១១:១៣ ១៥៥
១២:២៨ ១៤៧

១ពេត្រុស
១:៥ ១៥៥
២:២៤ ១១៤
៣:១៨ ១៣១

២ពេត្រុស
១:១១ ១៤៧

១យ៉ូហាន
២:១ ១៣៩

យូដាស
១:៣ ១៨

វិវរណៈ
៦:១៦ ៩៦
៧:៩ ២០៧
១២:១០ ១៤៧
១៤:៦ ៤៣
១៦:១ ៩៦
១៩:១៥ ៩៦
២០:១០ ៩៧

9Marks Online PDF

ផ្លូវពិត
plovpit.com

**គេហទំព័រដែលមានព្រះគ្រីស្ទ
ជាគោលដើម្បីលើកទឹកចិត្តអ្នកជឿ
ទាំងអស់។**

- វីដេអូ
- សៀវភៅ
- សៀវភៅជាសំឡេង
- កំណត់ហេតុបណ្ដាញ







ចូលរួមក្រុម
# Telegram
ដើម្បីទទួលមេរៀនព្រះបន្ទូល
រៀងរាល់ថ្ងៃ

**t.me/plovpit**

9Marks Online PDF

ផ្លូវពិត plovpit.com

សេចក្តីបង្រៀនដ៏គួរឲ្យទុកចិត្តបានអំពីព្រះយេស៊ូវ
មាននៅ www.plovpit.com ក្នុងទម្រង់ជាកំណត់
ហេតុបណ្តាញ វីដេអូ សំឡេង និងសៀវភៅ



អានបន្ថែមនៅ៖

ផ្លូវពិត
plovpit.com

ហើយទាញយកសៀវភៅជា

ច្រើនទៀតដោយឥតគិតថ្លៃនៅ៖

CambodianChristianResources.com

IX 9Marks

Building Healthy Churches

ការកសាងក្រុមជំនុំដែលមានសុខភាពល្អ

ព័ន្ធកិច្ច ៩Marks គឺដើម្បីជួយអ្នកដឹកនាំក្រុមជំនុំឲ្យមានចក្ខុវិស័យព្រះគម្ពីរ និងធនធានជាក់ស្ដែងសម្រាបបង្ហាញសិរីល្អរបស់ព្រះដលប្រជាជាតិនានា តាមរយៈក្រុមជំនុំដែលមានសុខភាពល្អ។

ដើម្បីបំពេញការនោះ យើងចងឃើញក្រុមជំនុំដែលមានសុខភាពល្អដោយមានលក្ខណៈ ៩ យ៉ាងខាងក្រោមនេះ៖

១. សេចក្ដីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ

២. គោលលទ្ធិដែលផ្ដោតលើដំណឹងល្អ

៣. ការយលដឹងដែលបានផ្លាស់ប្រែចិត្តយ៉ាងពិតប្រាកដ និងប្រកាសដំណឹងល្អតាមព្រះគម្ពីរ

៤. ការយលដឹងដ៏ត្រឹមត្រូវពីសមាជិកភាពនៃពួកជំនុំតាមព្រះគម្ពីរ

៥. ការយលដឹងពីការដាក់វិន័យពួកជំនុំតាមព្រះគម្ពីរ

៦. ការយលដឹងពីការបង្កើតសិស្ស និងការលូតលាសតាមព្រះគម្ពីរ

៧. ការយលដឹងពីការដឹកនាំពួកជំនុំតាមព្រះគម្ពីរ

៨. ការយលដឹងពីការអធិស្ឋានតាមព្រះគម្ពីរ

៩. ការយលដឹងពីការធ្វើបេសកកម្ម

នៅ ៩Marks យើងបានសរសេរអត្ថបទផ្សេងៗ សៀវភៅជាច្រើន ការពិនិត្យសៀវភៅឡើងវិញ និងទស្សនាវដ្ដីតាមប្រព័ន្ធអ៊ីនធឺណិត។ ពួកយើងក៏បានរៀបចំសន្និសីទ បានថតទុកការសម្ភាសន៍ និងផលិតធនធានផ្សេងៗទៀត ដើម្បីជួយទ្រទ្រង់ក្រុមជំនុំ និងបង្ហាញពីសិរីល្អរបស់ព្រះ។

សូមចូលទៅកានគេហទំព័ររបស់យើង ដើម្បីស្វែងរកមាតិកាជាង ៤0+ ភាសា ហើយចុះឈ្មោះ ដើម្បីទទួលបានទស្សនាវដ្ដីតាមប្រព័ន្ធអ៊ីនធឺណិតរបស់យើង ដោយឥតគិតថ្លៃ។ សូមមើលបញ្ជីឈ្មោះពេញលេញនៃគេហទំព័រជាភាសាផ្សេងៗទៀតរបស់យើង នៅតំណខាងក្រោមនេះ៖

9marks.org/international

9Marks Online PDF

ដំណឹងល្អនៃព្រះយេស៊ូវគឺជាអ្វីដែលព្រះទាមទារ និងបានប្រទានមក មិនមែនជាអ្វីដែលមនុស្សចង់បាននោះទេ។ ជាការសោកស្ដាយណាស់ ដែលបណ្ដាព្រះវិហារ និងអង្គការគ្រីស្ទបរិស័ទមួយចំនួនចាប់ផ្ដើមចាកឆ្ងាយចេញពីចំណុចស្នូលនៃដំណឹងល្អដ៏ពិត។ ពួកគេបានធ្វើព័ន្ធកិច្ចហើយបានអះអាងថា យកដំណឹងល្អជាចំណុចស្នូលនៅក្នុងអាទិភាព ប៉ុន្តែជាក់ស្ដែងពួកគេគ្រាន់តែណែនាំមនុស្សហើយផ្ដល់ជូនពួកគេនៅសារមិនត្រឹមត្រូវទៅជាដំណឹងល្អដែលផ្ដល់ជូនដល់កុមារៗនៅក្ដីសង្ឃឹមបែបអប់រំលោកីយ៍ ផ្ដោតទៅលើអនាគតល្អ មុខរបររកស៊ី នឹងផ្ដល់ជូនបុរសៗនូវក្ដីសង្ឃឹមនៃការមានការងារធ្វើ និងស្ត្រីៗដែលក្រីក្រឲ្យរស់នៅមានជីវភាពសមរម្យលើផែនដីនេះប៉ុណ្ណោះ។ល។ ពួកគេហាក់បីជាព្យាយាមជួសជុលផែននេះដែលបានធ្លាក់ក្នុងអំពើបាប ដោយគ្រាន់តែសន្មតថា បញ្ហារបស់មនុស្សគឺថាមិនមែនជាការល្មើស និងការមិនស្ដាប់បង្គាប់ព្រះនោះទេ គឺថាបញ្ហារបស់មនុស្សជាតិមកពីការមើលមកខ្លួនឯងបែបអវិជ្ជមាន ហើយនិងការកង្វះខាតផ្នែកអប់រំ និងចំណេះដឹងប៉ុណ្ណោះ។ ដំណឹងល្អនៃព្រះយេស៊ូវមិនមែនសម្រាប់ការរស់នៅលើផែនដីដោយពេញដោយអំពើបាបនោះទេ តែជាការត្រៀមខ្លួនប្រឈមមុខនឹងស្ថាននរក និងស្ថានសួគ៌ដែលមានដំណោះស្រាយតែមួយគត់គឺនៅក្នុងអង្គព្រះយេស៊ូវ។

មានដំណឹងល្អដែលច្បាស់លាស់ និងត្រឹមត្រូវនៅក្នុងព្រះគម្ពីរទាំងមូល។ យើងមិនត្រូវការបន្ថែម ឬបន្ថយដំណឹងល្អនោះតាមតែចិត្ត តម្រូវចិត្តមនុស្ស និងយុគសម័យកាលនីមួយៗនោះទេ។ ដំណឹងល្អនេះ មិនត្រូវការនរណាម្នាក់ជួសជុលបន្ថែម ឬដកចេញខ្លះ ដើម្បីងាយស្រួលទទួលយកនោះដែរ។

យើងគួរតែមានការភ្ញាក់រឭកនៅពេលដែលយើងបានយល់ពីចំណុចស្នូលនៃដំណឹងល្អដ៏ពិតចេញពីព្រះគម្ពីរ និងការបកស្រាយនៅក្នុងសៀវភៅមួយនេះ ហើយយើងក៏ត្រូវតែប្រកាន់ខ្ជាប់ ហើយប្រកាសផងដែរ។

IX 9Marks
www.9marks.org

ផ្លូវពិត
plovpit.com